ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



◆ សៀវភៅសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

◆ ប្រភេទនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ ៨២ ខែតុលា ឆ្នាំ២០០៦

ស្វែងរកការពិត

ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៨២ ខែតុលា ឆ្នាំ២០០៦

## មាតិកា


- សំបុត្រ ៖ សៀវភៅសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ............១

**ផ្នែកឯកសារ**

- ស្រី ញ៉ែមបូរ៉ាក់ស៊ី ៖ អតីតនិស្សិតស្ថាបត្យកម្ម ..................................២
- បញ្ជីឈ្មោះជនរងគ្រោះដែលកម្មេចនៅមន្ទីរ ស-២១ ..........................៤

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- គុកខ្មែរក្រហម ......................................................................៦
- ចំណាំខក្រិដ្ឋកម្មមន្ទីរសន្តិសុខភូមិភាគនិរតី .....................................១៦
- ជីវិតសល់ពីសេចក្តីស្លាប់ ...........................................................១៩
- ប្រភេទនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា ..................................២១
- ក្រុមគ្រួសាររបស់ មឿង ជាន.....................................................២៦
- ការសងសឹកមិនមែនជាដំណោះស្រាយ ..........................................២៨
- បែកប្តីព្រោះភាពអត់ឃ្លាន .........................................................២៩
- សហគមន៍ចាមនៅភូមិព្រែកប្រធាតុ...............................................៣១
- ការចូលរួមរបស់ជនរងគ្រោះ .....................................................៣៤

**ផ្នែកច្បាប់**

- គោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបាននូវ ........៣៩

**វេទិកាពិភាក្សាសាធារណៈ**

- សេចក្តីសម្រេចអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ........៤៨

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- ខ្ញុំ និង ថ្នាំជក់......................................................................៥៧
- តើ ពូ បងប្រុសខ្ញុំ និងជនរងគ្រោះ នឹងទទួលបានយុត្តិធម៌ ..................៥៨




អ្នកស្រុកកំពុងពិនិត្យមើលឈ្មោះនិងរូបថតសាច់ញាតិនៅគុកទួលស្លែង



រកឃើញរូបថតសាច់ញាតិនៅគុកទួលស្លែង

**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម/៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារ ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

**ស្នេរលេខនេះ ៖** អៀ ម៉េងទ្រី, ដេង ពង្សរ៉ាស៊ី, ឆាយ ណារឿន, កែវ ដាស៊ីល, នង ឧត្តតារា, ប៊ុង ពីរ៉ែន, សូ ហ្វារីណា, ស៊ូហ្សាន អ៊ី យុក, ម៉េង រស្មី, គុង វ៉ា **អ្នកនិពន្ធនិងស្រាវជ្រាវ ៖** លី សុផល, ណយ សុផារី, ឌី ខាំបូលី **អ្នកបកប្រែ ៖** បាន់ ចំរើន, ប៉ាន់ ស៊ីម៉ាឡា **និពន្ធនាយកទូទៅ ៖** ឆាំង យុ **ក្រាហ្វិកកុំព្យូទ័រ ៖** គឹម សុវណ្ណដានី **គ្រប់គ្រងការចែកផ្សាយ ៖** វ័ន្ត គាវាពិដោរ Email: dccam@online.com.kh, Homepage: www.dccam.org

*សំបុត្រ ៖*

# សៀវភៅសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ

អ្នកដំណើរចិនម្នាក់ឈ្មោះ ជី តាក្វាន់ បានរៀបរាប់ឲ្យពិភពលោកបានដឹងអំពីរឿងរ៉ាវរបស់គាត់នៅប្រាសាទអង្គរវត្តកាលពី ៨០០ឆ្នាំមុន ។ តាំងពីពេលនោះមកអ្នកស្រាវជ្រាវជាច្រើនទៀត បានកំពុងតែសរសេរប្រវត្តិសាស្ត្រកម្ពុជាសម្រាប់ឲ្យយើងសិក្សា ។ មានអ្នកស្រាវជ្រាវជាន់ខ្ពស់ជាច្រើនសិក្សាស្រាវជ្រាវពីសម្បត្តិវប្បធម៌ដ៏មានតម្លៃរបស់យើងនិងប្រវត្តិសាស្ត្រថ្មីៗ ដូចជាអំពើប្រល័យពូជសាសន៍កម្ពុជា នៅចន្លោះឆ្នាំ១៩៧៥និងឆ្នាំ១៩៧៩ជាដើម ។ ក៏ប៉ុន្តែជាមួយនឹងសៀវភៅសិក្សា ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ដែលជាស្នាដៃរបស់អ្នកស្រាវជ្រាវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យឈ្មោះ ឌី ខាំបូលី នៅទីបំផុត ប្រជាជនកម្ពុជាកំពុងតែចាប់ផ្តើមការងារស្រាវជ្រាវ និងកត់ត្រារឿងរ៉ាវអតីតកាលនៃប្រទេសជាតិរបស់ខ្លួន ។ សៀវភៅសិក្សាថ្មីនេះនឹងបង្ហាញអំពីការស្រាវជ្រាវដែលមានរយៈពេលពីរឆ្នាំ និងបង្ហាញអំពីអត្ថបទប្រវត្តិសាស្ត្របែបនេះជាលើកទីមួយដែលសរសេរដោយប្រជាជនកម្ពុជាវ័យក្មេង ។



ការកត់ត្រាអំពីសម័យកាលដ៏ខ្មៅងងឹតនៃប្រវត្តិសាស្ត្រកម្ពុជាសម្រាប់ក្មេងជំនាន់ក្រោយអាចជាការប្រថុយប្រថាននឹងការធ្វើឲ្យស្នាមរបួសចាស់សើរើឡើងវិញសម្រាប់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនកម្ពុជាជាច្រើនព្យាយាមបំភ្លេចរបបខ្មៅងងឹតនេះ និងព្យាយាមផ្លាស់ប្តូរជីវិតថ្មីរបស់ខ្លួន ។ ក៏ប៉ុន្តែ ខ្ញុំជឿជាក់ថាយើងនឹងមិនអាចផ្លាស់ប្តូរជីវិតថ្មីរបស់យើងដោយការផ្សះផ្សាខ្លួនឯងនិងការផ្សះផ្សាអ្នកដទៃបានទេ ដរាបណាយើងមិនទាន់បានដោះស្រាយរឿងរ៉ាវអតីតកាល ស្វែងយល់អំពីរឿងរ៉ាវទាំងឡាយនិងមូលហេតុដែលបានកើតឡើងនៃរបបនេះ ។ ការស្វែងយល់ជាមួយប្រវត្តិសាស្ត្រនេះ យើងពិតជាអាចចាប់ផ្តើមដំណើរការផ្សះផ្សាបាន ។ ក្រៅពីគោលបំណងនៃការបម្រើឲ្យសិស្សានុសិស្សថ្នាក់វិទ្យាល័យ សៀវភៅមួយនេះក៏មានតម្លៃស្មើៗគ្នាសម្រាប់មនុស្សពេញវ័យដែរ ។ យើងទាំងអស់គ្នាអាចសិក្សាមេរៀនទាំងឡាយពីប្រវត្តិសាស្ត្ររបស់យើង ។ តាមការប្រឈមមុខនឹងសម័យកាលដ៏ខ្មៅងងឹតនៃអតីតកាលរបស់យើង យើងអាចធ្វើការសិក្សាអំពីសម័យកាលដ៏ខ្មៅងងឹតនេះនិងបន្តដំណើរឆ្ពោះទៅមុខ ដើម្បីប្រែក្លាយប្រជាជននៃប្រជាជាតិមួយឲ្យខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ការកកើតនៃអំពើប្រល័យពូជសាសន៍នៅថ្ងៃអនាគត ទាំងនៅក្នុងទឹកដីរបស់ខ្លួននិងនៅក្នុងបណ្តាប្រទេសជាច្រើនទៀត ដែលសព្វថ្ងៃកំពុងតែប្រឈមមុខនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្ស ។ ម្យ៉ាងទៀត តាមរយៈការទទួលខុសត្រូវក្នុងការបង្រៀនកុលបុត្រកុលធីតាខ្មែរតាមរយៈអត្ថបទសិក្សា ដូចជាសៀវភៅនេះជាដើម ប្រទេសកម្ពុជានឹងបន្តដំណើរឆ្ពោះទៅមុខ និងបំពាក់បំប៉នកុលបុត្រកុលធីតាជំនាន់ក្រោយដែលមានភារៈក្នុងការធានាមិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងជាថ្មីម្តងទៀតនៅក្នុងប្រទេសកម្ពុជា ។

**ឆាំង យុ**

## កំណត់ចំណាំ

រាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងវាយតម្លៃសៀវភៅសិក្សាថ្មីនេះហើយរំពឹងថានឹងអាចបញ្ចូលដោយផ្នែកឬទាំងស្រុងនៃសៀវភៅទៅក្នុងកម្មវិធីជាតិនាពេលខាងមុខនេះ ។

*(អត្ថបទសង្ខេបចេញពីចម្លើយសារភាព)*

# ស្រី ញ៉ែមបូរ៉ាក់ស៊ី : អតីតនិស្សិតស្ថាបត្យកម្ម

ស្រី ញ៉ែមបូរ៉ាក់ស៊ី កើតនៅសង្កាត់លេខ២ ក្រុងភ្នំពេញ ។ ប្រពន្ធរបស់ បូរ៉ាក់ស៊ី ឈ្មោះ អង្គា បូរី ។ អ្នកទាំងពីរមានកូនស្រីម្នាក់ ។ បូរ៉ាក់ស៊ី មានឪពុកឈ្មោះ ស្រី សិនឡៀម ជាចាងហ្វាងតុលាការសាលាដំបូង និងម្តាយឈ្មោះ គឹម គុណា ។ បូរ៉ាក់ស៊ី មានបងប្អូនបង្កើត១៨នាក់ ស្រី១១ នាក់ ។ បូរ៉ាក់ស៊ី ជាកូនទី៨ ។

អំឡុងឆ្នាំ១៩៦៩-១៩៧២ បូរ៉ាក់ស៊ី រៀនថ្នាក់ទីបីនិងរៀនថ្នាក់ត្រៀមមហាវិទ្យាល័យស្ថាបត្យកម្ម ។ បូរ៉ាក់ស៊ី ត្រូវបានជ្រើសតាំងឲ្យធ្វើជាគណៈកម្មការសាលានិងជាប្រធានកុម្ម៉ង់ដូសិស្សប្រចាំសាលា ។ ឆ្លៀតឱកាសនេះ បូរ៉ាក់ស៊ី បានឃោសនាអប់រំសិស្សនិស្សិតឲ្យគាំទ្ររបបសេរីនិងប្រឆាំងរបបកុម្មុយនិស្ត ។ ក្នុងអំឡុងពេលសិក្សា បូរ៉ាក់ស៊ី បានចូលរួមវាយសិស្សពីរនាក់ឲ្យសន្លប់ដោយសារតែសិស្សនោះបញ្ចេញជំហរប្រឆាំងនឹងរបបសេរី ។

នៅឆ្នាំ១៩៧៣ បូរ៉ាក់ស៊ី ចូលរៀនថ្នាក់ឆ្នាំទី១នៅមហាវិទ្យាល័យស្ថាបត្យកម្ម ។ ក្រៅពីសិក្សា បូរ៉ាក់ស៊ី បានចូលធ្វើជាទាហានពាក់ស័ក្តិ១ ។ បូរ៉ាក់ស៊ី បានទាក់ទង ខៃ ម៉ាត់ទូរី ជាប្រធានសាលា និង កុល ណុក ជាទាហានស័ក្តិ៣ ជាញឹកញាប់ ដើម្បីពិគ្រោះស្ថានភាពនយោបាយនៅក្នុងស្រុក ។ ក្រោយមក ខៃ ម៉ាត់ទូរី និង កុល ណុក បានអប់រំ បូរ៉ាក់ស៊ី ឲ្យចូលបម្រើ សេ.អ៊ី.អា ។

នៅខែ៨ឆ្នាំ១៩៧៣ បូរ៉ាក់ស៊ី បានចូលរៀននយោបាយ សេ.អ៊ី.អា(សិក្សាប្រៀបធៀបលទ្ធិកុម្មុយនិស្តនិងលោកសេរី) រយៈពេល២ខែនៅការិយាល័យរបស់ លុន ណុន ក្រោមការបង្រៀន របស់ អួង សារ៉ែល ពាក់ស័ក្តិ៥, ព្រីង គី ពាក់ស័ក្តិ៣, និង កុល ណុក ពាក់ស័ក្តិ៣ ។

ពីរខែក្រោយមក បូរ៉ាក់ស៊ី បានចូលជាសមាជិកសេ.អ៊ី.អាពេញលក្ខណៈ ក្រោមការណែនាំពី កុល ណុក នៅផ្ទះរបស់ឈ្មោះនេះតែម្តង និងដោយមានការទទួលស្គាល់ពី វ៉ែន សំបុក ។ បូរ៉ាក់ស៊ី មានឋានៈជាភ្នាក់ងារនិងទទួលបានប្រាក់ខែ៦០,០០០ រៀលក្នុងមួយខែ ។ ក្នុងពេលបញ្ចូលជាសមាជិកសេ.អ៊ី.អា សំបុក និង កុល ណុក បានរៀបចំពិធីដោយមានការស៊ីផឹកបន្តិចបន្តួច និងមានការណែនាំខ្លះដើម្បីបញ្ជាក់ពីភារកិច្ចនៅក្នុងអង្គការនេះ ។ បន្ទាប់មក សមាជិកម្នាក់ៗបានឡើងចាប់អារម្មណ៍ពីមូលហេតុនិងគោលបំណងក្នុងការចូលជាសមាជិកសេ.អ៊ី.អា និងប្តេជ្ញាស្មោះត្រង់និងហ៊ានប្តូរជីវិតគ្រប់ពេលវេលាដើម្បីបម្រើអង្គការនេះ ។ នៅខែសីហា ប៉ូរ៉ាក់ស៊ី បានរាយការណ៍ឲ្យ កុល ណុក ថាមាននិស្សិតម្នាក់ឈ្មោះ ឃួន សាហ៊ុន មានសកម្មភាពប្រឆាំងរដ្ឋាភិបាល លន់ នល់ រួចក៏ចាប់ខ្លួននិស្សិតនោះយកទៅឲ្យប៉ូលិស ។

នៅឆ្នាំ១៩៧៤ បូរ៉ាក់ស៊ី បានឃោសនានិងអប់រំនិស្សិតឲ្យក្រោកឈរឡើងប្រឆាំងរបបកុម្មុយនិស្តនៅតាមមហាវិទ្យាល័យពេទ្យ មហាវិទ្យាល័យអក្សរសាស្ត្រមហាវិទ្យាល័យវិទ្យាសាស្ត្រ វិទ្យាល័យ ១៨មីនា និងវិទ្យាល័យកម្ពុជបុត្រ ។ បូរ៉ាក់ស៊ី កសាងកម្លាំងសេ.អ៊ី.អាបានចំនួន៨នាក់ក្នុងអំឡុងពេលឃោសនានោះ ។ បូរ៉ាក់ស៊ី ទទួលបន្ទុកស៊ើបការណ៍ពីសកម្មភាពរបស់កម្លាំងខ្មែរក្រហមនៅតាមសាលា ហើយរាយការណ៍ឲ្យ កុល ណុក និង សំបុក ជារៀងរាល់ខែ ។

នៅឆ្នាំ១៩៧៥ បូរ៉ាក់ស៊ី ចូលជាសមាជិកសមាគមបញ្ញវន្តប្រឆាំងនឹងបក្សកុម្មុយនិស្តឥណ្ឌូចិន ដែលមាន សន ថាត ជាប្រធាន ។

ក្រោយថ្ងៃជ័យជម្នះ១៧ខែមេសាឆ្នាំ១៩៧៥ បូរ៉ាក់ស៊ី ត្រូវបានជម្លៀសទៅនៅភូមិបឹងព្រាវ ឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកំពត ។ នៅខែសីហា បូរ៉ាក់ស៊ី បានទាក់ទង ព្រុំ ប៊ុន អគ្គនាយកធនាគារពាណិជ្ជកម្មនៅក្រុងកំពង់សោម ។ ព្រុំ ប៊ុន បានអប់រំនិងណែនាំ បូរ៉ាក់ស៊ី ឲ្យចូលរួមក្នុងចលនាចោរព្រៃ ប្រឆាំងនឹងអង្គការបដិវត្តន៍ ។ មួយខែក្រោយមក

បូរ៉ាក់ស៊ី បានចូលជាសមាជិកចោរព្រៃនៅភូមិបឹងព្រាវ ក្រោមការណែនាំ និងទទួលស្គាល់ពី ព្រាំ ប៊ុន ។ នៅខែតុលា បូរ៉ាក់ស៊ី បានឃោសនានិងណែនាំយុវជននៅក្នុងភូមិបឹងព្រាវឲ្យប្រឆាំងនឹងអង្គការបដិវត្តន៍ ។ នៅចុងឆ្នាំ បូរ៉ាក់ស៊ី បានទាក់ទង អុន អ្នកបច្ចេកទេសម៉ាស៊ីនកំពង់ផែនៅក្រុងកំពង់សោមដើម្បីអនុវត្តផែនការចោរព្រៃ ។

នៅដើមឆ្នាំ១៩៧៦ បូរ៉ាក់ស៊ី បានទៅជួប អុន និង មាយ នៅផ្ទះរបស់ អុន ហើយបានទទួលភារកិច្ចចំនួន៥ ៖ ១) ប្រមូលកម្លាំងយុវជននិងទាក់ទងខ្សែបណ្ដាញដើម្បីប្រឆាំងនឹងបដិវត្តន៍ ២) ប្លន់អាវុធពីយុទ្ធជននិងអ្នកយាមហើយរត់ចូលព្រៃ ៣) ប្លន់និងលួចអង្ករនៅឃ្លាំងសហករណ៍ភូមិបឹងព្រាវ ៤) អនុវត្តសកម្មភាពចោរព្រៃដោយយកទង់សាសនាជាបង្អែកទាក់ទាញកម្លាំងប្រជាជននិងរកស្បៀង ៥) ប្រមូលកម្លាំងរត់ចូលព្រៃនៅថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៧៦ ។ អុន និង មាយ មិនបានប្រាប់ពីទិសដៅ និងខ្សែបណ្ដាញនៅក្នុងព្រៃដល់ បូរ៉ាក់ស៊ី ទេ ប៉ុន្តែសន្យាថានឹងប្រាប់នៅពេលជួបគ្នានៅក្នុងព្រៃ ។

នៅខែមីនា បូរ៉ាក់ស៊ី និង ម៉ី ទីម បានពង្រីកកម្លាំងចោរព្រៃចំនួន៦នាក់នៅភូមិបឹងព្រាវ ។ បូរ៉ាក់ស៊ី បានទាក់ទងជាមួយ មាយ ដើម្បីភ្ជាប់ខ្សែពង្រីកកម្លាំងអនុវត្តផែនការចោរព្រៃ ទទួលផែនការចាត់តាំងពង្រីកកម្លាំងផ្នែកយុវជន ត្រៀមស្បៀង និងសម្ភារទុករត់ចូលព្រៃ ។ បូរ៉ាក់ស៊ី និង មាយ បានរៀបចំផែនការសម្លាប់អ្នកយាមអង្ករនៅភូមិបឹងព្រាវដើម្បីប្លន់យកអង្ករ និងកាំភ្លើង ហើយរត់ចូលព្រៃដើម្បីវាយអង្គការបដិវត្តន៍វិញ ។ បូរ៉ាក់ស៊ី បានលួចអង្ករសហករណ៍៩ តៅនិងថ្នាំពេទ្យប្រហែលជិត ២០០គ្រាប់ត្រៀមទុកដើម្បីរត់ចូលព្រៃ ។

នៅខែមេសា បូរ៉ាក់ស៊ី បានទទួលផែនការពី មាយ និង អុន ឲ្យប្រមូលកម្លាំងរត់ចូលព្រៃនៅត្រើយខាងកើតស្រុកស្រែអំបិល និងចាប់អនុវត្តសកម្មភាពតាមផែនការដែលបានគ្រោងទុក ។ នៅថ្ងៃទី១៨ ខែមេសា បូរ៉ាក់ស៊ី ត្រូវអង្គការចាប់ខ្លួនហើយបញ្ជូនមកមន្ទីរស-២១ (គុកទួលស្លែង) ។

ចម្លើយសារភាពរបស់ បូរ៉ាក់ស៊ី ជាឯកសារសរសេរដោយដៃមាន១១ទំព័រ ដែលមានបញ្ជាក់ពីប្រវត្តិផ្ទាល់ខ្លួននិងការទាក់ទងជាមួយ សេ.អ៊ី.អា ។ នៅក្នុងចម្លើយសារភាពមិនបានបញ្ជាក់ថា បូរ៉ាក់ស៊ី ត្រូវបានកម្ទេចនៅថ្ងៃណាទេ ។

## អំពីបងប្អូនបង្កើត

ទី១) ឈ្មោះ ញ៉ែម វ៉ាន់នី ភេទស្រី ប្តីឈ្មោះ លឹម រស់ ជារដ្ឋលេខាធិការក្រសួងហិរញ្ញវត្ថុ ។ ទី២) ញ៉ែម ទេពបូរី ភេទស្រី ប្តីឈ្មោះ សូ សឿន ជាសុភាចារបុរសតុលាការនៅភ្នំពេញ ។ ទី៣) ញ៉ែម សុខុន ភេទស្រី ជាគ្រូបង្រៀន ប្តីឈ្មោះ សោម គឿន ជាទាហានម៉ារីនស័ក្តិ៥នៅក្រុងព្រះសីហនុ ។ ទី៤) ញ៉ែម សន់ថាត ភេទស្រី ប្តីឈ្មោះ អោម សាខន ជាអនុរដ្ឋលេខាធិការគយ ។ ទី៥) ស្រីញ៉ែម ស៊ីដែល ភេទប្រុស ជាទាហាន ស័ក្តិ៣ ។ ទី៦) ញ៉ែម ចាន់ធី ភេទស្រី ប្តីឈ្មោះ កែម ណារី ជារដ្ឋលេខាធិការឃ្លាំងប្រាក់ ។ ទី៧) ញ៉ែម ស៊ីសារៈ ភេទស្រី ប្តីឈ្មោះ អ៊ឹង បូរី ជាអនុរដ្ឋលេខាធិការធនាគារជាតិកម្ពុជា ។ ទី៨) ស្រីញ៉ែម បូរ៉ាក់ស៊ី ។ ទី៩) ស្រីញ៉ែម បូរ៉ាក់សិទ្ធ ភេទប្រុស ជានិស្សិតមហាវិទ្យាល័យច្បាប់ ។ ទី១០) ញ៉ែម ប្រសើរ ភេទស្រី ប្តីឈ្មោះ ចាប សំអុល ជាសាស្ត្រាចារ្យវិទ្យាល័យក្បាលថ្នល់ ។ ទី១១) ញ៉ែម កែវមុនីរ៉ា ភេទស្រី ប្តីឈ្មោះ សូ វ៉ាន់ឌី ជាទាហានស័ក្តិ២ ។ ទី១២) ញ៉ែម ដាន់ណែត ភេទស្រី ជាសិស្សថ្នាក់បញ្ចប់ ។ ទី១៣) ញ៉ែម ដាន់ណាត ភេទស្រី ជាសិស្សថ្នាក់ទី១ ។ ទី១៤) ញ៉ែម សុវ៉ាន់រ័ត្ន ភេទស្រី ជាសិស្សថ្នាក់ទី៣ ។

## ឈ្មោះអ្នកពាក់ព័ន្ធក្នុងចម្លើយសារភាព

◆ អ៊ួង សារ៉ែល ជាទាហានស័ក្តិ៥និងជារដ្ឋមន្ត្រីក្រសួងសាធារណការសាធារណរដ្ឋខ្មែរ ◆ លន់ ណុន ប្អូនប្រុសរបស់ លន់ នល់ ◆ កុល ណុក ទាហានស័ក្តិ៣នៅជាមួយ លន់ នល់ ◆ ព្រីង គី ពាក់ស័ក្តិ៣ ◆ វ៉ែន សំបុក នាយការិយាល័យអ៊ែ.ដេ.អ៊េះ ◆ អ៊ឹម យូហៃ តំណាងរាស្ត្រ ◆ ខៃ ម៉ាត់ទូរី ប្រធាននិស្សិតនៅមហាវិទ្យាល័យស្ថាបត្យកម្ម ◆ សុខ ណម អតីតនិស្សិតមហាវិទ្យាល័យស្ថាបត្យកម្ម ◆ ព្រាំ ប៊ុន អគ្គនាយកធនាគារពាណិជ្ជកម្មកំពង់សោម ◆ ម៉ី ទីម ◆ មាយ ◆ អុន អ្នកបច្ចេកទេសម៉ាស៊ីន កំពង់ផែកំពង់សោម ។

**ណាយ សុផារី**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ (គុកទួលស្លែង)

## រៀបចំនិងចងក្រងដោយ : យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | មុខងារ | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ២៩៤៩ | ខុំ ឈាង ហៅ រុន | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ១០-៣-៧៧ | ២០-៦-៧៧ |
| ២៩៥០ | គុយ គាវ (ស្រី) | យុទ្ធនារី | ដឹកជញ្ជូនជើងទឹក | ១៤-៤-៧៧ | ២០-៦-៧៧ |
| ២៩៥១ | សាវ ដា (ស្រី) | យុទ្ធនារី | ដឹកជញ្ជូនជើងទឹក | ៤-៤-៧៧ | ២០-៦-៧៧ |
| ២៩៥២ | មាស សារឿន ហៅ សេង | ជាងសំណង់ | ពាណិជ្ជកម្ម | ១-៣-៧៧ | ២០-៦-៧៧ |
| ២៩៥៣ | អ៊ុង ឡឿន ហៅ ជី | អនុប្រធានប.ក.គ | ពាណិជ្ជកម្ម | ២១-៣-៧ | ២០-៦-៧៧ |
| ២៩៥៤ | ឡាង ហ៊ | ប្រធានកងតូច | ពាណិជ្ជកម្ម | ១៥-៥-៧៧ | ២០-៦-៧៧ |
| ២៩៥៥ | តាន់ ឆ៊ាំ ហៅ ថន | សមាជិក | ពាណិជ្ជកម្ម | ២១-៣-៧៧ | ២០-៦-៧៧ |
| ២៩៥៦ | នូ សុកនី ហៅ រ៉ី | អនុក្រុម | ពាណិជ្ជកម្ម | ១៧-១០-៧៦ | ២០-៦-៧៧ |
| ២៩៥៧ | ម៉ៅ គីមស៊ាង ហៅ មាន | ប្រធានមន្ទីរ | ពាណិជ្ជកម្ម | ២១-៣-៧៧ | ២០-៦-៧៧ |
| ២៩៥៨ | សួស វុធី ហៅ ធ្វី | យុទ្ធជន | ពាណិជ្ជកម្ម | ២១-៣-៧៧ | ២០-៦-៧៧ |
| ២៩៥៩ | ពាង ស្រ៊ីម ហៅ ហ៊ាន | មេក្រុម | ពាណិជ្ជកម្ម | ២១-៣-៧៧ | ២០-៦-៧៧ |
| ២៩៦០ | ឯក វ៉ុន ហៅ បេន | លេខាកងធំ | ពាណិជ្ជកម្ម | ៧-២-៧៧ | ២០-៦-៧៧ |
| ២៩៦១ | អ៊ុក សាមឿន ហៅ ភីន | ប្រធាន សំរិត ផល | ពាណិជ្ជកម្ម | ២៧-១១-៧៦ | ២០-៦-៧៧ |
| ២៩៦២ | ណុប សុទ្ធ ហៅ នី | មេក្រុម | ពាណិជ្ជកម្ម | ២៧-៣-៧៧ | ២០-៦-៧៧ |
| ២៩៦៣ | ខៃ ហេង ហៅ ណូ | ប្រធានបញ្ជី | ពាណិជ្ជកម្ម | ២៥-៤-៧៧ | ២០-៦-៧៧ |
| ២៩៦៤ | ខែក ឃឿន ហៅ ខាយ | អនុកងតូច | ពាណិជ្ជកម្ម | ២១-៣-៧៧ | ២០-៦-៧៧ |
| ២៩៦៥ | ណៃ យ៉ុន ហៅ នឿន | អនុប្រធានមន្ទីរ | ពាណិជ្ជកម្ម | ២៥-២-៧៧ | ២០-៦-៧៧ |
| ២៩៦៦ | សូ ឆេង | ជាងឈើ | ពាណិជ្ជកម្ម | ១០-៣-៧៧ | ២០-៦-៧៧ |
| ២៩៦៧ | ម៉ៅ ជា | ជាងឈើ | ពាណិជ្ជកម្ម | ១០-៣-៧៧ | ២០-៦-៧៧ |
| ២៩៦៨ | អេង ហៅ គីម (ស្រី) | ពេទ្យ | ពាណិជ្ជកម្ម | ៤-៦-៧៧ | ២០-៦-៧៧ |
| ២៩៦៩ | ញូង អេន ហៅ រិន (ស្រី) | សមាជិកពេទ្យ | ពាណិជ្ជកម្ម | ៧-៥-៧៧ | ២០-៦-៧៧ |
| ២៩៧០ | ម៉ុក កុំហ៊ុ ហៅ ហ៊ី | ប្រធានកងវរយ | ពាណិជ្ជកម្ម | ២-៦-៧៧ | ២០-៦-៧៧ |
| ២៩៧១ | ហ៊ឹម យឿង ហៅ តាយ | មេក្រុម | ពាណិជ្ជកម្ម | ៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៧២ | ទឹម សាន ហៅ ស្រ៊ាង | យុទ្ធជន | ពាណិជ្ជកម្ម | ៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៧៣ | ភ៊ំ សាមឿន ហៅ វុធ | យុទ្ធជន | ពាណិជ្ជកម្ម | ២១-៣-៧៧ | ២០-៦-៧៧ |
| ២៩៧៤ | ចាន់ ជឿន ហៅ លឿន | អនុក្រុម | ពាណិជ្ជកម្ម | ១៤-៤-៧៧ | ២០-៦-៧៧ |
| ២៩៧៥ | ជា ឈៀក ហៅ សូត្រ | ប្រធានមន្ទីរ | ពាណិជ្ជកម្ម | ២៦-៥-៧៧ | ២០-៦-៧៧ |

| | | | | | |
|---|---|---|---|---|---|
| ២៩៧៦ | ប៊ុន ឡាយ ហៅ វ៉ន | មេក្រុម | ពាណិជ្ជកម្ម | ២៦-៥-៧៧ | ២០-៦-៧៧ |
| ២៩៧៧ | ឱិត សុន | យុទ្ធជន | ឃ្លាំងរដ្ឋ | ៤-៦-៧៧ | ២០-៦-៧៧ |
| ២៩៧៨ | ឡុង សាន | ជាងម៉ាស៊ីន | ឃ្លាំងរដ្ឋ | ៤-៦-៧៧ | ២០-៦-៧៧ |
| ២៩៧៩ | ចាន់ ណាក់ ហៅ ភ័ស (ស្រី) | មើលកុមារ | ឃ្លាំងរដ្ឋ | ៥-៦-៧៧ | ២០-៦-៧៧ |
| ២៩៨០ | ទេព សុភាន ហៅ ភាន (ស្រី) | អនុនយោបាយ | ឃ្លាំងរដ្ឋ | ៥-៦-៧៧ | ២០-៦-៧៧ |
| ២៩៨១ | ឡាំង ចេង ហៅ ស៊ាន (ស្រី) | ប្រពន្ធ យន | ឃ្លាំងរដ្ឋ | ?-៥-៧៧ | ២០-៦-៧៧ |
| ២៩៨២ | អ៊ឹម យឿន ហៅ ឆើត | យុទ្ធជន | សេនាធិការ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៨៣ | យូ វ៉ាន ហៅ ខែង | យុទ្ធជន | សេនាធិការ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៨៤ | ប៉ែន សាន់ | យុទ្ធជន | សេនាធិការ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៨៥ | សូ សាំង ហៅ និន | អនុក្រុម | សេនាធិការ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៨៦ | ជឹម វួន ហៅ វ៉ុន | យុទ្ធជន | សេនាធិការ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៨៧ | ជេត អេ | យុទ្ធជន | សេនាធិការ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៨៨ | កែ ឈុន | យោធាកងធំ | កងពល៣១០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៨៩ | អេង ជុន | យុទ្ធជន | កងពល៤៥០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩០ | ចាន់ លន | យុទ្ធជន | កងពល៤៥០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩១ | ពិន ពឿន | យុទ្ធជន | កងពល៤៥០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩២ | ដួ ហុង ហៅ ហេង | យុទ្ធជន | កងពល៤៥០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩៣ | ស សាំ ហៅ រ៉ុង | យោធាកងតូច | កងពល៣១០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩៤ | បេន គ្រឿន ហៅ រ៉ែន | យុទ្ធជន | កងពល៣១០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩៥ | នុត សាក់ | យុទ្ធជន | កងពល៣១០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩៦ | ជីង វ៉ីរ ហៅ ណាត | អនុនយោបាយ | កងពល៣១០ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩៧ | ប៊ុត ណែវ | យុទ្ធជន | វរសេនាធំ៣៧៧ | ១៨-៦-៧៧ | ២០-៦-៧៧ |
| ២៩៩៨ | ណាម សុខ | ប្រធានកងតូច | កងពល៣១០ | ១៩-៦-៧៧ | ២០-៦-៧៧ |
| ២៩៩៩ | សុក ស៊ាង | ភ័ស្តុភារ | កងពល៤៥០ | ១៩-៦-៧៧ | ២០-៦-៧៧ |
| ៣០០០ | អ៊ុម គ្រី ហៅ ភី | យុទ្ធជន | កងពល៤៥០ | ១៩-៦-៧៧ | ២០-៦-៧៧ |
| ៣០០១ | ស្រី ឌឹម | យោធាកងធំ | កងពល៤៥០ | ១៩-៦-៧៧ | ២០-៦-៧៧ |
| ៣០០២ | ហង់ ឆួយ ហៅ ស្រ៊យ | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ១៣-៥-៧៧ | ២០-៦-៧៧ |
| ៣០០៣ | អៀម ឆួន | យុទ្ធជន | ដឹកជញ្ជូនជើងទឹក | ១៣-៥-៧៧ | ២០-៦-៧៧ |
| ៣០០៤ | វ៉ាញ នៀង | យុទ្ធជន | ផែកំពង់សោម | ២៩-៣-៧៧ | ២០-៦-៧៧ |
| ៣០០៥ | សោម ហ៊ឹម ហៅ ហួត | អនុក្រុម | ដឹកជញ្ជូនជើងទឹក | ៤-៤-៧៧ | ២០-៦-៧៧ |
| ៣០០៦ | គ្រោក គ្រឿន ហៅ ផល | សមាជិកក្រុម | ផែកំពង់សោម | ២៧-៣-៧៧ | ២០-៦-៧៧ |

**(នៅមានត)**

# គុកខ្មែរក្រហម

## ខេត្តកំពង់ស្ពឺ

## ស្រុកឧត្តុង្គ

### ៦) មន្ទីរសន្តិសុខបឹងរាំ

នៅក្នុងឆ្នាំ១៩៧៥ មន្ទីរសន្តិសុខប្រចាំឃុំត្រាចទង មួយកន្លែងដែលមានឈ្មោះថា មន្ទីរសន្តិសុខបឹងរាំ ត្រូវបានបង្កើតឡើងសម្រាប់ឃុំឃាំងអ្នកទោសប្រភេទស្រាល ។ ខ្មែរក្រហមសាងសង់រោងចំនួន៤ សម្រាប់ដាក់អ្នកទោស ប៉ុន្តែរហូតមកដល់បច្ចុប្បន្នរោងទាំងនេះត្រូវប្រជាជនរុះរើគ្មានសល់ ។

ជ័យ ស៊ីម អាយុ៤៦ឆ្នាំ ជាប្រជាជនរស់នៅភូមិបឹងរាំ ឃុំត្រាចទង ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ បានសង់លំនៅឋាននៅលើដីដែលជាអតីតមន្ទីរសន្តិសុខនេះ ។ ស៊ីម បាននិយាយរឿងរ៉ាវទាក់ទងនឹងមន្ទីរសន្តិសុខបឹងរាំថា បន្ទាប់ពីខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រជាជនទាំងអស់នៅក្នុងភូមិត្រូវខ្មែរក្រហមជម្លៀសទៅនៅឃុំថ្មីមួយទៀត ដើម្បីយកភូមិនេះធ្វើជាមន្ទីរសន្តិសុខប្រចាំឃុំត្រាចទង ។

ជ័យ ស៊ីម បានរៀបរាប់ពីទោសកំហុសរបស់អ្នកទោសថា "អ្នកខ្លះគ្រាន់តែលួចដំឡូងស៊ី មានទំនាស់ជាមួយអង្គការ ទាំងសម្តីទាំងការងារ ទាំងសតិអារម្មណ៍ក៏យកគ្នាមកលត់ដំនៅមន្ទីរសន្តិសុខបឹងរាំដែរ ហើយឲ្យធ្វើការងារផ្សេងៗដូចជាកាប់ដីដឹបូកដាក់ស្រែ និងដាំដំឡូងនៅឆ្ងាយៗពីមន្ទីរឃុំឃាំងថែមទៀត ។ បើអ្នកទោសណាអាចកែប្រែអត្តចរិតបានក្នុងរយៈពេលពីរឬបីខែ នឹងត្រូវដោះលែងឲ្យទៅរស់នៅសហករណ៍វិញ ប៉ុន្តែបើកសាងខ្លួនមិនបានច្បាស់ជាត្រូវឈ្លបនាំយកទៅសម្លាប់នៅក្នុងព្រៃខាងកើតភូមិមិនខាន" ។ ជ័យ ស៊ីម សន្និដ្ឋានថា អ្នកទោសប្រហែល៥០០នាក់ជាប់ឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខបឹងរាំ ។ បច្ចុប្បន្នមន្ទីរសន្តិសុខនេះពុំមានបន្សល់ទុកនូវវត្ថុតាងអ្វីបន្តិចឡើយ ។

**ទិន្នន័យសង្ខេប**

**ទីតាំង** : មន្ទីរសន្តិសុខបឹងរាំស្ថិតនៅភូមិបឹងរាំ ឃុំត្រាចទង ស្រុកឧត្តុង្គ ខេត្តកំពង់ស្ពឺ ។

**ស្ថិតិ** : បឹងរាំ ជាមន្ទីរសន្តិសុខមួយដែលឃុំឃាំងតែ ជនរងគ្រោះប្រភេទស្រាលប៉ុណ្ណោះ ។ ជនរងគ្រោះមួយចំនួនត្រូវបានសម្លាប់ និងមួយចំនួនទៀត ត្រូវបានដោះលែងបន្ទាប់ពីបានលត់ដំអស់រយៈពេលពី ពីរ-បីខែ ។

## ស្រុកភ្នំស្រួច

### ៧) មន្ទីរសន្តិសុខកប់ឆ្កែ

មន្ទីរសន្តិសុខកប់ឆ្កែបង្កើតឡើងនៅឆ្នាំ១៩៦៨ ដោយក្រុមខ្មែររំដោះ ។ សាត់ ជាប្រធានគ្រប់គ្រងនៅទីនោះ ។ នៅពេលខ្មែរក្រហមទទួលបានជ័យជម្នះទាំងស្រុង មន្ទីរសន្តិសុខនេះត្រូវពួកខ្មែរក្រហមប្រើប្រាស់ជាកន្លែងអប់រំ"ក្រុមប្រជាជនប្រវាស់ដៃ" ។ សាយ អ៊ឹម អាយុ៦៥ឆ្នាំ រស់នៅភូមិស្រែត្រពាំង ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺបានរៀបរាប់ថា គាត់ធ្លាប់បានដើរឆ្លងកាត់តាមមន្ទីរសន្តិសុខនេះ ហើយឃើញអ្នកទោសដែលម្នាក់ៗសុទ្ធតែមានជើងជាប់ខ្នោះឈើវែងៗប្រហែល២០នាក់នៅក្នុងរោងវែងមួយ ដែលមានបណ្តោយប្រហែល១០ម៉ែត្រ និងទទឹងប្រហែល៥ម៉ែត្រ ។ ចំណែករោងផ្សេងៗទៀតក៏មានអ្នកទោសដូចគ្នាដែរ ។ ជនរងគ្រោះដែលជាប់នៅមន្ទីរសន្តិសុខកប់ឆ្កែ ជាប្រជាជនរស់នៅក្នុងភូមិព្រៃក្មេងនិងអ្នកដែលធ្លាប់ធ្វើមេឃុំកាលពីជំនាន់មុន ។ អ្នកទោសទាំងអស់មិនត្រូវបានដោះលែងទេ ដរាបណាការស្រាវជ្រាវមិនទាន់ត្រូវបានរកឃើញថា មានទោសដែរឬអត់ ។ អ៊ឹម និយាយថា អ្នកទោសប្រភេទស្រាលមួយចំនួនត្រូវបានដោះលែង ហើយអ្នកទោសប្រភេទធ្ងន់ត្រូវនាំយកទៅសម្លាប់ចោលនៅបរិវេណជើងភ្នំក្វារគង់ ដែលមានចម្ងាយប្រហែលជា៥០០ម៉ែត្រពីមន្ទីរកប់ឆ្កែប៉ែកខាងត្បូង ។

**ទិន្នន័យសង្ខេប**

**ទីតាំង** : ទួលកប់ឆ្កែស្ថិតនៅភូមិស្រែត្រពាំង ឃុំព្រៃក្មេង ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ ។

**ស្ថិតិ** : កប់ឆ្កែ ជាមន្ទីរសន្តិសុខរបស់ខ្មែររំដោះតាំងពីឆ្នាំ១៩៦៨ និងមានសកម្មភាពរហូតដល់ក្រោយថ្ងៃជ័យជម្នះទី១៧

ខែមេសា ឆ្នាំ១៩៧៥ ។ អ្នកទោសប្រមាណជាង២០នាក់ ជាប់នៅក្នុងរោងនីមួយៗនៃមន្ទីរសន្តិសុខកប់ផ្អែ ។ អ្នកទោសប្រភេទស្រាលត្រូវបានដោះលែង ហើយអ្នកទោសប្រភេទធ្ងន់ត្រូវសម្លាប់ចោលនៅជើងភ្នំក្អារគន់ដែលមានចម្ងាយប្រហែល៩០០ម៉ែត្រពីមន្ទីរសន្តិសុខ ។

## ស្រុកថ្ពង

### ៨) មន្ទីរសន្តិសុខ ម-១៣

ខ្មែរក្រហមបង្កើតមន្ទីរនេះឡើងនៅឆ្នាំ១៩៧១ ហើយឲ្យឈ្មោះថាមន្ទីរសន្តិសុខភូមិភាគពិសេស ។ កាលពីដំបូងមន្ទីរនេះមានទីតាំងនៅថ្មយោង ដែលពេលនោះមានឈ្មោះថា "មន្ទីរសម្ងាត់ថ្មយោង" ដែលស្ថិតនៅក្នុងព្រៃជ្រៅនៃទឹកដីស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ ក្រោយមកមន្ទីរនេះបានផ្លាស់មកនៅភូមិត្រពាំងច្រាប ក្នុងស្រុកថ្ពងវិញ បន្ទាប់ពីអ្នកទោសបះបោរប្រឆាំងនឹងកងការពារ ។



មន្ទីរសន្តិសុខបឹងរាំ

នៅឆ្នាំ១៩៧២ មន្ទីរភូមិភាគពិសេស ឬមន្ទីរសម្ងាត់ថ្មយោង បានប្តូរឈ្មោះទៅជា "មន្ទីរសន្តិសុខ ម-១៣" ឬ "មន្ទីរ ម-១៣" វិញ ។ ឌុច ជាអ្នកគ្រប់គ្រងមន្ទីរនេះតាំងពីដំបូងមកម្ល៉េះ រួមជាមួយកម្មាភិបាលនិងកងការពារមួយចំនួនទៀត ។ ការគ្រប់គ្រងមន្ទីរនៅពេលនោះមានការប្រយ័ត្នប្រយែងបំផុត ។ នៅជុំវិញមន្ទីរ ខ្មែរក្រហមបានសង់របងអំពីឈើក្រាក់យ៉ាងខ្ពស់ (កម្ពស់ពី៥ ទៅ៦ម៉ែត្រ) ។ នៅក្នុងបរិវេណនោះមានផ្ទះប្រាំខ្នងសម្រាប់ធ្វើជាទីស្នាក់អាស្រ័យរបស់កម្មាភិបាលដឹកនាំមន្ទីរ ជាកន្លែងសួរចម្លើយ និងជាកន្លែងស្នាក់នៅរបស់កងការពារផង ។ ខ្មែរក្រហមជីករណ្តៅជាច្រើនសម្រាប់ដាក់អ្នកទោស និងមានរណ្តៅមួយទៀតមានទំហំធំជាងគេក្នុងចំណោមរណ្តៅទាំងនោះ ដែលប្រើប្រាស់សម្រាប់ឃុំខ្លួនអ្នកទោសដែលទើបបញ្ជូនមកថ្មីៗ ។ ចាន់ ខន អាយុ ៤៧ឆ្នាំ រស់នៅភូមិទេពគិរម្យ ហៅភូមិក្បាលចិន ឃុំវាលពន់ ស្រុកថ្ពង ខេត្តកំពង់ស្ពឺ និងជាអតីតកងការពារនៅមន្ទីរម-១៣ បានឲ្យដឹងថានៅចុងឆ្នាំ១៩៧២និងដើមឆ្នាំ១៩៧៣ អ្នកទោសត្រូវកងសន្តិសុខឃុំខ្លួនដូចធម្មតា ប៉ុន្តែបន្ទាប់ពីមានយន្តហោះបេ-៥២របស់កងទ័ពអាកាសអាមេរិកាំងទម្លាក់គ្រាប់បែកមកលើបរិវេណមន្ទីរសន្តិសុខនោះមក ទើប ឌុច បញ្ជាឲ្យជីករណ្តៅធំៗសម្រាប់ឃុំឃាំងអ្នកទោសជំនួសវិញ ។ ការបញ្ជាឲ្យជីករណ្តៅទាំងនេះ គឺក្នុងបំណងបិទបាំងការឃ្លាំមើលរបស់កងទ័ពអាកាសអាមេរិកាំងដែលតែងតែហោះឈ្លបយកការណ៍ជាប្រចាំ ។ រណ្តៅនីមួយៗសុទ្ធតែមានដំបូលប្រក់ស្លឹកទម្លាក់សំយាបស្មើរប៉ះដី ។ នៅជុំវិញបរិវេណមន្ទីរសន្តិសុខម-១៣ ដែលមានទំហំធំ និងស្ថិតនៅកណ្តាលព្រៃភ្នំចម្ងាយជិតពីរគីឡូម៉ែត្រពីភូមិប្រជាជនរស់នៅ គឺមានមួយកន្លែងទៀតសម្រាប់ឃុំឃាំងអ្នកទោសទើបបញ្ជូលមកថ្មី ដែលកន្លែងនោះមានធ្មើរបងពទ្ធ័ជុំវិញ ចំណែករណ្តៅឯទៀតគ្មានធ្មើរបងពទ្ធ័ឡើយ ។ កងការពារក្មេងៗត្រូវយាមការពារនៅមាត់រណ្តៅអ្នកទោសដែលមានរបងជុំវិញ ដើម្បីការពារកុំឲ្យអ្នកទោសលួចរត់ ។

### សាខានៃមន្ទីរសន្តិសុខ ម-១៣

សាខាសំខាន់ៗចំនួនបីកន្លែងរបស់មន្ទីរសន្តិសុខភូមិភាគពិសេស ម-១៣ គឺ ៖

១) មន្ទីរសន្តិសុខនគរបាល មានទីតាំងនៅក្នុងភូមិស្តុកស្អាត ឃុំមានជ័យ ស្រុកឧត្តុង ខេត្តកំពង់ស្ពឺ ។ មន្ទីរនេះគ្រប់គ្រងដោយកម្មាភិបាលខ្មែរក្រហមឈ្មោះ ស៊ឹម ។

២) មន្ទីរសន្តិសុខភ្នំប្រសិទ្ធិត្រ័យត្រិង្សមានទីតាំងស្ថិតនៅ

ក្នុងឃុំឈ្មាំង ស្រុកពញាឮ ខេត្តកណ្ដាល ។ វុធ ជាកម្មាភិបាលគ្រប់គ្រងមន្ទីរទាំងមូល ។ មន្ទីរសន្តិសុខនេះបែងចែកជាកន្លែងឃុំឃាំងអ្នកទោសចំនួន៤ទៀតគឺ ១) នៅក្រោមដើមម៉ៃសាក់ជាប់នឹងជើងភ្នំត្រ័យត្រិង្សប៉ែកខាងលិច ។ ២) នៅចម្ការស្វាយ ។ ៣) នៅសាលាវត្តភ្នំប្រសិទ្ធិក្រោម និង៤) នៅសាលាវត្តភ្នំប្រសិទ្ធិលើ ។ អ្នកទោសដែលជាប់នៅក្នុងមន្ទីរសន្តិសុខខាងលើនេះត្រូវកងឈ្លបនាំយកទៅសម្លាប់នៅជើងភ្នំនិងលើភ្នំប្រសិទ្ធិលើ ។ ចំណែកការធ្វើទារុណកម្មគឺនៅនឹងស្រះទឹកមួយលើកំពូលភ្នំដែលមានទំហំ៨ម៉ែត្រនិងជម្រៅជាង១ម៉ែត្រ ។ នៅកន្លែងសួរចម្លើយមានបង្គោលមួយ កងឈ្លបបានយកខ្សែចងជើងអ្នកទោស រួចទាញព្យួរឡើងលើទម្លាក់ក្បាលចូលក្នុងស្រះទឹក ។ ការធ្វើទារុណកម្មផ្សេងទៀត គឺខ្មែរក្រហមបញ្ជាឲ្យអ្នកទោសវាយថ្ម និងជីកស្រះទឹក ។ ការប្រជុំបានធ្វើឡើងរៀងរាល់ពីរ-បីសប្ដាហ៍ម្ដង ហើយបន្ទាប់ពីប្រជុំម្ដងៗមានអ្នកទោសយ៉ាងហោចណាស់ពី៥០ទៅ១០០នាក់ត្រូវបានយកទៅសម្លាប់ ។

៣) មន្ទីរសន្តិសុខ ម-៩៩ មានទីតាំងស្ថិតនៅក្នុងព្រៃជ្រៅត្រង់ព្រំប្រទល់ឃុំតាសាល និងឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ។ ការគ្រប់គ្រងនៅមន្ទីរសន្តិសុខនេះមានច្រើនដំណាក់កាល និងមានការផ្លាស់ប្ដូរប្រធានមន្ទីរជាច្រើននាក់ ។ ដំបូងមន្ទីរនេះគ្រប់គ្រងដោយសមមិត្ត ឆៃ បន្ទាប់មកគ្រប់គ្រងដោយសមមិត្ត គុល និងសមមិត្ត ណម ។ មន្ទីរម-៩៩ ជាកន្លែងឃុំឃាំងនិងសម្លាប់អ្នកទោសអស់ជាច្រើន ។ នៅឆ្នាំ១៩៧៧ មន្ទីរម-៩៩ ត្រូវខ្មែរក្រហមរុះរើនិងរំលាយចោល ដោយសារមានជម្លោះគ្នារវាងមេដឹកនាំមន្ទីរគឺសមមិត្ត ណម និងសមមិត្ត គល់ ។

## អ្នកទោសនៅមន្ទីរ ម-១៣

អ្នកទោសជាច្រើនត្រូវបានឃុំឃាំងនៅក្នុងមន្ទីរសន្តិសុខ ម-១៣នេះ ។ កាលពីដំបូង អ្នកទោសនៅទីនោះគឺជាយុទ្ធជននិងប្រជាជនមូលដ្ឋានដែលមិនព្រមដើរតាមមាគ៌ាដ៏ភ្លឺស្វាងរបស់បក្ស ។ ក្រោយមកមន្ទីរសន្តិសុខ ម-១៣ បានពង្រីកខ្លួននិងទទួលអ្នកទោសរាប់សិបនាក់ទៀត ដែលសុទ្ធសឹងជាប្រជាជនថ្មីនិងអ្នកមកពីទីឆ្ងាយៗ ។ នៅក្នុងឆ្នាំ១៩៧៣ កម្មាភិបាលដែលទើបតែត្រឡប់មកពីក្រុងហាណូយ (ប្រទេសវៀតណាម) ប្រហែលជាង១០នាក់បានមកត្រួតត្រាអ្នកទោសជាមួយក្រុមរបស់ ឌុច ។ ប៉ុន្តែមិនយូរប៉ុន្មានអ្នកទាំងនេះ បានក្លាយទៅជាអ្នកទោសវិញ និងត្រូវកងការពារនាំយកទៅសម្លាប់ដោយយកលេសថា "ទៅរៀនសូត្របន្ថែម" ។

ហម អ៊ីន ជាអតីតអ្នកទោសនៅក្នុងមន្ទីរម-១៣ តាំងពីខែ


សៃ ស៊ីម បង្ហាញប្រាប់ពីទីតាំងរបស់មន្ទីរសន្តិសុខកប់ស្រៃ

មិថុនា ឆ្នាំ១៩៧៣ បាននិយាយប្រាប់ថា គាត់បានឃើញកម្មាភិបាលដែលមកពីទីក្រុងហាណូយតាំងពីទើបមកដល់មន្ទីរដំបូង និងថ្ងៃចុងក្រោយមុននឹងត្រូវនាំទៅរៀនសូត្របន្ថែម ។ ចំណែកអ្នកទោសមួយប្រភេទទៀត គឺយុទ្ធជនខ្មែរក្រហមដែលដើរសេរី និងកម្មាភិបាលដែលមានឋានៈធំៗ ដូចជាប្រធានកងពល គណៈស្រុកនិងប្រធានវរសេនាតូចជាដើម ។ គ្មានអ្នកទោសណាម្នាក់បាន ដឹងពីទោសកំហុសរបស់ខ្លួនឡើយ គឺមានតែអង្គការមួយគត់ដែលអាចមើលឃើញទោសកំហុសរបស់មនុស្សម្នាក់ៗ ។ អ៊ីន ប្រាប់ថា គាត់មិនបានដឹងពីទោសកំហុសរបស់គាត់ឡើយ ។ គាត់

គ្រាន់តែជាអ្នកកូតវីយូឡុងម្នាក់នៅក្នុងក្រុមសិល្បៈប្រចាំតំបន់ប៉ុណ្ណោះ ។ អ្នកទោសទាំងអស់ត្រូវជាប់ឃុំនៅក្នុងរណ្ដៅដែលធំជាងគេជម្រៅប្រហែលពី៤ទៅ៥ម៉ែត្រ ។ ដែលរណ្ដៅនេះគ្រាន់តែជាកន្លែងឃុំខ្លួនអ្នកទោសបណ្ដោះអាសន្នប៉ុណ្ណោះ ទម្រាំមានបទបញ្ជាឲ្យធ្វើការបែងចែងប្រភេទអ្នកទោសឡើងវិញ ។ អ្នកទោសដែល ឌុច យល់ថាជាប្រភេទធ្ងន់ត្រូវដាក់ខ្នោះជើង ហើយបញ្ជូនទៅដាក់ក្នុងរណ្ដៅមួយចំនួន ដែលក្នុងរណ្ដៅនីមួយៗអាចដាក់អ្នកទោសបាន២០នាក់ ។ រណ្ដៅទាំងនោះស្ថិតនៅក្បែរមាត់ស្ទឹងនិងក្បែររណ្ដៅដែលធំជាងគេ ។ លើសពីនេះ ឌុច បានបញ្ជាឲ្យជីករណ្ដៅជាច្រើនទៀតសម្រាប់ដាក់ទណ្ឌ-កម្ម ។ អ៊ីន បានរៀបរាប់ថា រណ្ដៅមួយប្រភេទដែលជារណ្ដៅសម្រាប់ធ្វើទារុណកម្មអ្នកទោសមានទំហំទទឹងកន្លះម៉ែត្រ បណ្ដោយប្រវែងដងខ្លួនមនុស្ស និងជម្រៅ២ម៉ែត្រ ។ រណ្ដៅមួយអាចដាក់មនុស្សបានតែម្នាក់ប៉ុណ្ណោះ ហើយរណ្ដៅមួយៗតម្រូវឲ្យជីកដង្ហែនិងជិតៗគ្នា ។ នៅបាតរណ្ដៅមានចោះប្រហោងទម្លុះដីពីរណ្ដៅមួយទៅរណ្ដៅមួយទៀតសម្រាប់ស៊កនរនុកដែកភ្ជាប់នឹងខ្នោះដែលដាក់ជាប់កជើងអ្នកទោស ។ រណ្ដៅមួយប្រភេទទៀត ទំហំកន្លះម៉ែត្របួនជ្រុងជម្រៅមួយម៉ែត្រកន្លះ ហើយគ្មានដំបូលប្រក់ពីលើ គឺរណ្ដៅឃុំឃាំងអ្នកទោសប្រភេទធ្ងន់ដែលត្រូវឈរហូតមិនអាចកម្រើកខ្លួនបានឡើយ ។



**ការសួរចម្លើយ ការធ្វើទារុណកម្ម និងមន្ទីររបស់កម្មាភិបាលជាន់ខ្ពស់នៅមន្ទីរ ម-១៣**

រាល់ពេលសួរចម្លើយ ប្រសិនបើអ្នកទោសណាម្នាក់ផ្ដល់ចម្លើយមិនត្រឹមត្រូវតាមអ្វីដែលអ្នកសួរចង់បានច្បាស់ជាត្រូវរងទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរហូតដល់សម្លាប់ចោលទៀតផង ។ ហម អ៊ីន បានប្រាប់ថា នៅពេលគាត់ត្រូវចាប់ខ្លួនបញ្ជូនទៅកាន់មន្ទីរម-១៣ ដំបូងអ្នកទោសដែលជាប់មុនគាត់បានខ្សឹបប្រាប់ថា "ត្រូវតែឆ្លើយថាធ្លាប់ធ្វើនេះធ្វើនោះ បើមិនដូច្នេះទេនឹងត្រូវស្លាប់ខ្លួនមិនខាន" ។ មិនយូរប៉ុន្មាន អ៊ីន ក៏ត្រូវនាំយកទៅសួរចម្លើយ ដោយ ឌុច ហើយ អ៊ីន បានធ្វើតាមពាក្យសម្ដីដែលអ្នកទោសដូចគ្នានិយាយប្រាប់មែន ។ អ៊ីន បានឆ្លើយសារភាពនៅចំពោះមុខ ឌុច ទាំងកុហកខ្លួនឯងថា "ធ្លាប់ធ្វើជាប៉ូលិសពាក់ដោយបីជាន់" ។ ចំណែកបងប្រុសរបស់ អ៊ីន ម្នាក់ដែលពុំបានដឹងរឿងនេះជាមុនបានសារភាពតាមអ្វីដែលខ្លួនធ្លាប់ឆ្លើយប្រាប់ ឌុច ពីមុន ប៉ុន្តែបែរជាត្រូវទទួលទណ្ឌកម្មយ៉ាងធ្ងន់ធ្ងរទៅវិញ ហើយក្រោយមកត្រូវកងការពារនាំយកទៅសម្លាប់ចោល ។ អ៊ីន បានរួចខ្លួនពីការធ្វើទារុណកម្មនិងត្រូវដោះលែងជាអ្នកទោសកម្រិតស្រាលនិងឲ្យធ្វើជាជំនួយការរោងបាយប្រចាំមន្ទីរថែមទៀត ។ អ៊ីន បាននិយាយតាមសម្ដីរបស់ ឌុច ថា "អ្នកដែលចាប់មកដាក់នៅក្នុងមន្ទីរនេះសុទ្ធតែជាអ្នកមានទោស ដូច្នេះត្រូវតែឆ្លើយសារភាពពីទោសកំហុសរបស់ខ្លួន" ។ ការសួរចម្លើយបានប្រព្រឹត្តទៅជារៀងរាល់ថ្ងៃដោយមានការចូលរួមសួរពីសំណាក់កម្មាភិបាលធំៗប្រចាំមន្ទីរដូចជា ឌុច, ចាន់, ប៉ុន, ផល និង មាស ជាដើម ។ ទារុណកម្មនិងការសួរចម្លើយបានធ្វើឡើងនៅក្នុងរណ្ដៅដែលមានទំហំ៤ម៉ែត្រការ៉េ ជម្រៅពី៥ទៅ៦ម៉ែត្រ និងមានបង្គោលក្រាក់មួយនៅចំកណ្ដាលរណ្ដៅផង ។ រណ្ដៅនេះត្រូវកងឈ្លបជីកដង្ហែគ្នានៅតាមបណ្ដោយមាត់ស្ទឹងត្រើយខាងលិច ។ កម្មាភិបាលសួរចម្លើយអ្នកទោសបានប្រើឧបករណ៍ចាំបាច់មួយចំនួនដូចជាម្ជុល ប្រវ៉ាក់ ញញួរ បន្ទាត់ និងដង្កាប់ ។ អ្នកទោសដែលត្រូវយកមកធ្វើទារុណកម្ម មុនដំបូង ត្រូវកងឈ្លបចងដៃទាំងពីរទៅក្រោយភ្ជាប់នឹងបង្គោលក្រាក់ ហើយទាញរ៉តឡើងលើឲ្យជើងហើបផុតពីដីរួចទើបចាប់ផ្ដើមធ្វើទារុណកម្ម ។ អ្នកទោសខ្លះត្រូវឆ្មាំគុកយកបន្ទាត់វាយបញ្ចូលម្ជុលទៅក្នុងក្រចកដៃបន្តិចម្ដងៗ ។ បន្ទាប់ពីអ្នកទោសផ្ដល់ចម្លើយត្រឹមត្រូវហើយម្ជុលត្រូវដកចេញមកវិញដោយដង្កាប់ ។ កម្មាភិបាលទាំងអស់គឺ ឌុច, ចាន់, ផល, ប៉ុន និង មាស សុទ្ធតែមានកន្លែងសួរចម្លើយម្នាក់មួយនៅនឹងមន្ទីរស្នាក់នៅរបស់ខ្លួន ។ ឌុច ជាអ្នកសួរចម្លើយដោយផ្ទាល់មាត់ចំពោះអ្នកទោសណាដែលត្រូវចោទប្រកាន់ថាមានឋានៈខ្ពង់ខ្ពស់ ។ មន្ទីររបស់ ឌុច ស្ថិតនៅចម្ងាយប្រហែល ៥០ម៉ែត្រពីត្រពាំងប្រាប ។ ឧបករណ៍សម្រាប់ ឌុច សួរចម្លើយមាន កាំបិត និងចន្ទុះ ។ អ៊ីន

បានប្រាប់ថា ឌុច ជាមនុស្សកាចជាងគេក្នុងការសួរចម្លើយនិងធ្វើទារុណកម្មអ្នកទោស ។ ចំណែក ចាន់ ក៏ដូច្នោះដែរលើកលែងតែ ប៉ុន និង ផល ប៉ុណ្ណោះ ដែលពុំសូវមាត់កធំៗនិងវាយដំអ្នកទោស ។ អ៊ីន បានប្រាប់ពីវិធីដែល ឌុច ធ្វើទារុណកម្មមកលើបងប្រុសរបស់គាត់គឺ ឌុច បានចងដៃទាំងពីរព្យួរឡើងលើក្តាប់នឹងបង្គោលក្រាក់ រួចយកកាំបិតចាក់លើរាងកាយសព្វកន្លែងតាំងពីដើមដៃរហូតដល់ចុងជើង ។ នៅក្រោមជើងអ្នកទោស ឌុច បានដាក់ចានដែកមួយ ដើម្បីត្រងឈាមដែលហូរចេញពីស្នាមចាក់ដោយកាំបិត ។ ទារុណកម្មមួយប្រភេទទៀតដែល ឌុច ប្រព្រឹត្តមកលើអ្នកទោស ហើយដែលខ្លួនយល់ថាអ្នកទោសផ្តល់ចម្លើយមិនត្រឹមត្រូវ គឺយកញញួរឈើវាយដើមទ្រូងនិងខ្នងរហូតដល់អ្នកទោសសន្លប់បាត់ស្មារតី ហើយជួនកាលស្លាប់ផងក៏មាន ។ វិធីសំខាន់មួយទៀតគឺ ឌុច បានបញ្ច្រកទឹកសាប៊ូអ្នកទោស ដោយប្រើទុយោស៊ីកបញ្ចូលចូលបំពង់-ក ។ វិធីទាំងប៉ុន្មាននេះជាវិធីសាហាវបំផុតនិងជាបទពិសោធន៍មួយសម្រាប់ជីវិតរបស់ ឌុច ដែលធ្លាប់ឆ្លងកាត់និងជួបប្រទះដោយផ្ទាល់កាលពីអំឡុងក្នុងឆ្នាំ១៩៦៧ ដល់ឆ្នាំ១៩៧០ គឺនៅពេលដែល ឌុច ជាប់គុកដោយសារជាប់ពាក់ពន្ធ័នឹងរឿងរ៉ាវបោះខិត្តប័ណ្ណឃោសនាបម្រើឲ្យចលនាខ្មែរក្រហម ។

ចម្លើយដែលត្រឹមត្រូវនិងដែលអង្គការចង់បានបំផុតនៅក្នុងមន្ទីរ ម-១៣ គឺត្រូវតែឆ្លើយថា "ធ្លាប់ធ្វើទាហាន ប៉ូលិស និងមន្ត្រីថ្នាក់ធំៗនៅសម័យសាធារណរដ្ឋខ្មែរ" ។ តាមប្រសាសន៍របស់ អ៊ីន ថា ឌុច ជាមនុស្សមានអត្តចរិតចម្លែកជាងមនុស្សផ្សេងទៀតបន្តិច ថ្វីដ្បិតតែ ឌុច ចូលចិត្តនិយាយលេងច្រើន និងសើចញៗជាមួយអ្នកទោសក៏ដោយ ប៉ុន្តែ ឌុច មិនដែលមានមេត្តាធម៌ជាមួយអ្នកទោសណាម្នាក់ឡើយ ។ អ៊ីន បាននិយាយថា "ជួនកាលពេលកំពុងតែជជែកលេងសើចជាមួយអ្នកទោស ស្រាប់តែ ឌុច នឹកឃើញថាចង់យកអ្នកទោសណាម្នាក់ទៅសម្លាប់ចោល គាត់ក៏បញ្ជាកងការពារឲ្យទៅដោះអ្នកទោសចេញពីខ្នោះ ហើយបណ្តើរយកទៅសម្លាប់ភ្លាម" ។ អ៊ីន ធ្លាប់បានឮការស្រែកបញ្ជានេះដោយផ្ទាល់ ហើយធ្វើឲ្យគាត់ភ័យឡើងញ័រខ្លួន ។ ឌុច ឧស្សាហ៍ហៅ អ៊ីន មកជជែកលេងជាមួយណាស់អំពីរឿងរ៉ាវដែលគាត់ធ្លាប់ជាប់គុកកាលពីសម័យសង្គមរាស្ត្រនិយមនិងរឿងជាច្រើនទៀត ។ អ៊ីន ក៏ធ្លាប់ត្រូវ ឌុច ស្តីបន្ទោសខ្លាំងណាស់ដែរ ។ អ៊ីន បាននិយាយដូច្នេះថា ថ្ងៃមួយគាត់បានដើរទៅកាន់រោងបាយដោយមិនដឹងថាមានការប្រជុំនៅទីនោះ ស្រាប់តែ ឌុច ចេញមកហើយស្រែកសម្លុតនិងចោទថា មានបំណងចង់យកការណ៍ឲ្យខ្មាំង ។ ប៉ុន្តែ អ៊ីន បានប្រាប់ពីមូលហេតុនិងគោលបំណងនៃការចូលមកកាន់រោងបាយនេះថា គាត់មកជួបប្រពន្ធរបស់ ចាន់ ជាប្រធានរោងបាយដើម្បីសួរនាំពីរឿងរកម្ហូបអាហារ ។ ក្រៅពីបញ្ជាឲ្យកងការពាររបស់ខ្លួនសម្លាប់អ្នកទោស ឌុច ក៏ធ្វើដោយខ្លួនឯងដែរ ដូចក្នុងករណីបាញ់សម្លាប់អ្នកទោសជាច្រើននាក់ដែល ចាន់ ខន និយាយឲ្យដឹងថា គាត់មិនចាំចំនួនជនរងគ្រោះដែល ឌុច បានសម្លាប់ឡើយ ។ ចាន់ ខន និយាយទៀតថា ក្រុមកងការពាររបស់គាត់ធ្លាប់បានទទួលបញ្ជាពី ឌុច ឲ្យបាញ់ប្រហារអ្នកទោសណាដែលលួចរត់ចេញ ។ អ៊ីន បាននិយាយថា ក្រុមកងការពារក៏ទទួលបញ្ជាឲ្យធ្វើទារុណកម្មអ្នកទោសដែរ ។ តាមការនិយាយរបស់ អ៊ីន ថា ចាន់ ខន ដែលជាកងការពារអ្នកទោសនៅទីនោះធ្លាប់បានធ្វើទារុណកម្មមកលើតារបស់ខ្លួនឈ្មោះ សុខ ដែលជាអ្នកទោសនៅ មន្ទីរម-១៣ ។ អ៊ីន និយាយទៀតថា តារបស់ ខន បានហៅ ខន ថា "បង" ចំណែក ខន វិញនិយាយតបភ្លាមថា "អើ! គេក្មេងមែន តែគេបងខាងបដិវត្តន៍" ។ នៅឆ្នាំ១៩៧៩ ខន បានលើកដៃសំពះសុំទោសតារបស់គាត់ចំពោះអំពើដែលខ្លួនបានធ្វើកាលពីនៅក្នុងមន្ទីរម-១៣ដោយលើកហេតុផលថា "មកពីនៅក្មេងមិនដឹងអី" ។

**ការងាររបស់អ្នកទោស**

អ្នកទោសដែលនៅសេសសល់ពីការសម្លាប់និងអ្នកទោសដែលចូលថ្មី ត្រូវធ្វើការងារជារៀងរាល់ថ្ងៃ ទាំងជាប់ច្រវាក់និងចំណង ដោយមានកងការពារជាអ្នកមើលការខុសត្រូវទៀតផង ។ ការឃ្លាំមើលរបស់កងការពារមានសភាពម៉ឺងម៉ាត់បំផុត ។ កងការពារអ្នកទោសមានសិទ្ធិបាញ់សម្លាប់អ្នកទោសនៅពេលអ្នកទោសព្យាយាមលួចរត់ចេញពីមន្ទីរសន្តិសុខក្នុងពេលបំពេញការងារ ។ អ្នកទោសមួយភាគស្លាប់ពេលបំពេញការងារ ដោយសារការបាក់កម្លាំង និងហូបអាហារមិនគ្រប់គ្រាន់ ។ ការងាររបស់អ្នកទោស

គឺលើកទំនប់ ដាំដំឡូង កាប់ឆ្ការព្រៃ និងរានដីធ្វើស្រែ ។ របបអាហារត្រូវពឹងផ្អែកទាំងស្រុងលើការចាត់ចែងរបស់កម្មាភិបាល ដែលជាអ្នកកាន់កាប់រោងបាយប្រចាំមន្ទីរ ។ អ្នកទោសម្នាក់អាចទទួលបានរបបអាហារក្នុងមួយពេលតែបបររាវកក្លុកមួយបំពង់ឫស្សីតូចប៉ុណ្ណោះ ។ ចំណែករបបអាហារក្នុងមួយពេលរបស់កងការពារអ្នកទោសវិញ គឺបាយមួយចានលាយជាមួយដំឡូងមី និងពោតដែលបានមកពីកម្លាំងពលកម្មរបស់អ្នកទោស ។ ប៉ុន្តែ ជួនកាលកងការពារក៏ទទួលរបបបបរមួយកូនចានដូចអ្នកទោសដែរ លើកលែងតែកម្មាភិបាលធំៗប៉ុន្មាននាក់ប៉ុណ្ណោះ ដែលទទួលបានរបបបាយគ្រប់ពេលនិងម្ហូបគ្រប់គ្រាន់ ។ អ៊ីន បានរៀបរាប់ពីបបររបស់អ្នកទោសថា ក្នុងមួយខ្ទះដាក់អង្ករតែពីរកំប៉ុងប៉ុណ្ណោះ ហើយលាយជាមួយពោតក្រហមខ្លះ និងលាយជាមួយស្លឹកដំឡូងមី ឬស្លឹកដំឡូងជ្វាខ្លះ ។

## សេដ្ឋកិច្ច



ហម អ៊ីន អតីតអ្នកទោសនៅមន្ទីរសន្តិសុខ ម-១៣

សេដ្ឋកិច្ចនៅមន្ទីរម-១៣ ពឹងផ្អែកទាំងស្រុងទៅលើការបង្កបង្កើនផល ការដាំបន្លែផ្លែឈើ និងការនេសាទត្រី របស់អ្នកទោសកម្រិតស្រាល ។ អ៊ីន ជាអ្នកនេសាទត្រីនៅក្នុងស្ទឹងដែលហូរកាត់មន្ទីរនិងត្រពាំងប្រាបដែលស្ថិតនៅក្បែរគ្នា ។ ឌុច បានប្រគល់តួនាទីឲ្យ អ៊ីន ធ្វើជាអ្នកនេសាទប្រចាំរោងបាយនៅមន្ទីរ ម-១៣ ។ អ៊ីន ជាមនុស្សម្នាក់មានជំនាញច្បាស់លាស់ក្នុងការចាប់ត្រីនឹងដៃ ។

## ប្រជុំនយោបាយ

ក្នុងមួយសប្តាហ៍ ឌុច បានកោះហៅសមាជិករបស់ខ្លួននៅតាមសាខាមួយចំនួនមកចូលរួមប្រជុំនៅនឹងមន្ទីររបស់ខ្លួន ។ រៀងរាល់បីសប្តាហ៍ ឬមួយខែម្តង ឌុច តែងតែស្លៀកពាក់ស្អាតចេញទៅប្រជុំនៅក្រៅមន្ទីរម-១៣ ។ យានជំនិះរបស់ ឌុច គឺម៉ូតូម៉ូប៊ីឡែត ។ អ៊ីន និយាយថា គាត់មិនដឹងថា ឌុច ទៅប្រជុំនៅទីណាទេ ប៉ុន្តែរាល់ពេលត្រឡប់មកពីប្រជុំវិញ ឌុច តែងតែបន្ថែមភារកិច្ចថ្មីៗទៀតដល់កងការពារកម្មាភិបាលថ្នាក់ក្រោមនិងអ្នកទោស ។ អ៊ីន និយាយទៀតថាៈ នៅពេល ឌុច មកដល់ភ្លាមគាត់បានដាក់បញ្ជាឲ្យកងការពារក្មេងៗយកអ្នកទោសមួយចំនួនទៅសម្លាប់ចោល ។

## គណៈគ្រប់គ្រងមន្ទីរ ម-១៣

១) ឌុច ជាប្រធានមន្ទីរ ម-១៣ និងមានភារកិច្ចមើលការខុសត្រូវកងការពារនិងសួរចម្លើយអ្នកទោសដែលមានឋានៈខ្ពស់ជាងគេ ។

២) ចាន់ ជាអនុប្រធានមន្ទីរម-១៣ មានភារកិច្ចមើលការខុសត្រូវក្នុងមន្ទីរនៅពេលដែល ឌុច អវត្តមាន និងសួរចម្លើយអ្នកទោសដែលមានឋានៈខ្ពស់បន្ទាប់ ។

៣) ប៊ុន ជាសមាជិកមន្ទីរ ម-១៣ មានភារកិច្ចសួរចម្លើយអ្នកទោសនិងធ្វើទារុណកម្ម ។

៤) ផល ជាសមាជិកមន្ទីរ ម-១៣ មានភារកិច្ចសួរចម្លើយអ្នកទោសនិងធ្វើទារុណកម្ម ។

៥) មាស ជាសមាជិកមន្ទីរ ម-១៣ មានភារកិច្ចសួរចម្លើយអ្នកទោស ធ្វើទារុណកម្ម និងសម្លាប់ ។ តាមសម្តីរបស់ ចាន់ ខន ជាកងការពារនៅមន្ទីរ ម-១៣និយាយថា មាស គឺជាកម្មា

ភិបាលដែលសម្លាប់អ្នកទោសអស់ច្រើនជាងគេ ។ អ៊ីន បាន ប្រាប់ថា ឌុច ក៏សម្លាប់អ្នកទោសអស់ច្រើននាក់ដែរ ព្រមទាំង ធ្លាប់វាយដំធ្វើទារុណកម្មធ្ងន់ៗលើអ្នកទោសជាច្រើននាក់ទៀត ។ ថ្វីដ្បិតតែការធ្វើទារុណកម្មរបស់ ឌុច មិនទាន់ធ្វើឲ្យអ្នកទោស ស្លាប់ភ្លាមៗក៏ដោយ ប៉ុន្តែ អ៊ីន និយាយថា រយៈពេលប៉ុន្មាន ថ្ងៃក្រោយមកអ្នកទោសទាំងនោះពិតជាត្រូវស្លាប់មិនខាន ។

កម្មាភិបាលទាំង៥នាក់ខាងលើនេះគឺជា“ជនចម្រើន” របស់ បដិវត្តន៍ ។ ចាន់ វឿន បានបង្ហើបរឿងនេះប្រាប់ថា “ជនចម្រើន” ជាអ្នកដែលអង្គការបក្សទុកចិត្តបំផុតមិនដូចកងការពារឡើយ ។

**កងការពារ**

កងការពារនៅមន្ទីរម-១៣ ត្រូវខ្មែរក្រហមជ្រើសរើស យកតែក្មេងៗដែលមានអាយុក្រោម១៥ឆ្នាំ ។ ឌុច ជាអ្នក ជ្រើសរើសកងការពារទាំងនេះដោយផ្ទាល់ ។ អ៊ឹម វន ហៅ ឌិន ដែលជាអតីតកងការពារ ត្រូវបាន ឌុច បំបែកចេញពីឪពុកម្តាយ នៅភូមិក្រាំង ឃុំប្រាំបីមុំ ស្រុកថ្ពង ។ ឌិន ជាឈ្មោះបដិវត្តនៅ ពេលមកធ្វើជាកងការពារមន្ទីរ ម-១៣ ។ ចំណែក វន ជា ឈ្មោះដែលគាត់ដាក់ក្រោយពេលគាត់ស្ម័គ្រចិត្តចូលបម្រើកងទ័ព រដ្ឋាភិបាលកម្ពុជាក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ។ ឌុច បានទៅ ជ្រើសរើស ចាន់ វឿន និងមិត្តភក្តិម្នាក់ទៀតពីទីលានហ៊ឹកហាត់ មួយកន្លែងក្នុងទឹកដីស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។ ចំណែក ចាន់ ខន ត្រូវ ឌុច ជ្រើសរើសយកមកតាមរយៈការសម្រិតសម្រាំងពីថ្នាក់ ភូមិនិងឃុំ ។ ចំណែកកងការពារផ្សេងទៀតក៏ត្រូវ ឌុច ជ្រើសរើស ដូច វន ខន និង វឿន ដែរ ។ តាមសម្តីរបស់ប្រជាជនរស់នៅក្នុង ស្រុកថ្ពង បានឲ្យដឹងថាឈ្មោះ ខែល គុន (កូនអ៊ំស្រី ញាំង យី) បេ (កូនអ៊ំស្រី ហែម) គឹម អុន (កូនអ៊ំស្រី ដួង នួច) ប៉ៅ កាក់ (ក្មួយពូ សី ជា) ហែម បឿន (កូនយាយ សឹម) និង អឿន (កូនយាយ យក់) ត្រូវខ្មែរក្រហមបំបែកចេញពីគ្រួសារមកធ្វើ ជាកងការពារនៅមន្ទីរម-១៣ ហើយមកដល់ពេលបច្ចុប្បន្ននេះ អ្នកទាំងអស់នេះមិនឃើញត្រឡប់មកផ្ទះវិញឡើយ ។ កងការពារ ទាំងប៉ុន្មានដែល ឌុច ជ្រើសរើសយកទៅបម្រើការងារនៅក្នុងមន្ទីរ ម-១៣ មានមួយចំនួនមិនបានហាត់រៀនក្បួនយុទ្ធសាស្ត្រអ្វីទាំង អស់ និងមិនដែលស្គាល់ការងារនោះពីមុនមកយ៉ាងម៉េចផង ។ អ៊ីន និយាយដូច្នេះថា “កងការពារសុទ្ធតែជាមនុស្សថ្មីនិងក្មេងៗ បំផុត” ។ ការប្រមែប្រមូលកងការពារវ័យក្មេងៗនេះបញ្ចប់ត្រឹម ដើមឆ្នាំ១៩៧៣ ។ កងការពារចំនួនជាង១០នាក់សុទ្ធតែជ្រើសរើស យកមកពីឃុំប្រាំបីមុំ ស្រុកថ្ពង ។ កងការពារទាំងនេះត្រូវបាន បែងចែកជាពីរក្រុមធំៗគឺ ១) កងការពារអ្នកទោសនៅក្នុងមន្ទីរ ឃុំឃាំង និង២) កងការពារអ្នកទោសពេលកំពុងបំពេញការងារ ។ ក្រៅពីភារកិច្ចការពារអ្នកទោស នៅមានការងារជាច្រើនទៀត ដែលក្រុមកងការពារត្រូវតែអនុវត្តតាម បញ្ជាដែលដាក់ចុះពីថ្នាក់ លើមក ។ អ៊ីន បាននិយាយ ថា អ្នកទោសមួយចំនួន ដែលចាប់មកពីកន្លែង ផ្សេងៗគឺកងការពារមន្ទីរ ម-១៣ ជាអ្នកទៅចាប់ ។ ចំពោះការធ្វើទារុណកម្ម អ្នកទោសនិងការនាំអ្នក ទោសយកទៅសម្លាប់ ក៏ជា តួនាទីមួយផ្នែករបស់កង ការពារដែរ ។


មន្ទីរសន្តិសុខបន្ទាយរោងគោ

ការបែងចែកពេលវេលា យាមអ្នកទោសត្រូវបាន

កំណត់យ៉ាងច្បាស់លាស់ ។ កងការពារពីរនាក់ត្រូវយាមអ្នកទោសរយៈពេលពីរម៉ោង បន្ទាប់មកត្រូវផ្លាស់ប្តូរវេនគ្នាបន្តបន្ទាប់ទៅទៀត ។ ក្នុងអំឡុងពេលយាម កងការពារពុំមានសិទ្ធិសម្រាកឬអង្គុយមួយកន្លែងឡើយ ។ ប្រសិនបើមានអ្នកទោសណាម្នាក់លួចរត់ចំវេនកងការពារណា កងការពារនោះនឹងត្រូវទទួលទណ្ឌកម្មពី ឌុច ។ វឿន ជាកងការពារតែម្នាក់គត់ដែលធ្វេសប្រហែសក្នុងពេលយាមអ្នកទោស ដោយបណ្តោយឲ្យអ្នកទោសបីនាក់រត់រួច ។ វឿន ត្រូវទទួលទណ្ឌកម្មពី ឌុច ជាមួយនឹងអ្នកទោសដទៃទៀត ។ ក្នុងចំណោមកងការពារទាំងអស់ពុំមានការចាត់តាំងឲ្យនរណាម្នាក់ធ្វើជាប្រធានឡើយ ។ ខន បាននិយាយថា ឌុច ជាអ្នកគ្រប់គ្រងកងការពារទាំង១០នាក់នោះ ។

បច្ចុប្បន្ន កងការពារមន្ទីរម-១៣ ដែលនៅមានជីវិតគឺ ចាន់ វឿន រស់នៅភូមិកុមាររមាស ឃុំអមលាំង ស្រុកថ្ពង ។ ជន (មិនស្គាល់ត្រកូល) រស់នៅថ្នល់បំបែកអមលាំង ឃុំអមលាំង ស្រុកថ្ពង ។ ណិន (មិនស្គាល់ត្រកូល) រស់នៅភូមិទំនាប ឃុំអមលាំង ស្រុកថ្ពង ។ ចាន់ ខន រស់នៅភូមិទេពភិរម្យ ហៅ ភូមិក្បាលចិន ឃុំវាលពន់ ស្រុកឧត្តុង្គ ។ អ៊ឹម វន ហៅ ឌិន រស់នៅភូមិស្តុកស្អាត ឃុំមានជ័យ ស្រុកឧត្តុង្គ ។

## ការមិនទុកចិត្តគ្នា

នៅចុងឆ្នាំ១៩៧៣ ទឹកជំនន់បានជន់លិចទីតាំងមន្ទីរសន្តិសុខទាំងមូល បណ្តាលឲ្យអ្នកទោសស្លាប់អស់ជាច្រើន ។ ប៉ុន្តែនៅពេលប្រជុំម្តងៗ ឌុច ពុំដែលរាយការណ៍ប្រាប់អង្គប្រជុំអំពីបញ្ហានេះឡើយ ។ ឌុច ត្រូវស្ថិតនៅក្នុងការសង្ស័យរបស់កម្មាភិបាលផ្សេងទៀត ដែលត្រូវបែងចែកឲ្យទៅនៅមន្ទីរសន្តិសុខប្រសិទ្ធិត្រ័យត្រិង្ស និងមន្ទីរម-៩៩ ។ អ៊ិន បានរៀបរាប់ពីការសង្ស័យនេះថា កម្មា-ភិបាលធំៗមួយចំនួនបានជជីកសួរ ឌុច ពីបញ្ហាអ្នកទោសស្លាប់នៅមន្ទីរម-១៣ និងទទួលការស្តីបន្ទោសខ្លះៗដោយសារមិនព្រមរាយការណ៍ទៅថ្នាក់លើពីហេតុការណ៍ដែលបានកើតឡើងនេះ ។ អ៊ិន បាននិយាយថា ស៊ុម បានសុំឲ្យគាត់ជួយរាយការណ៍រឿងនេះទៅប្រាប់ថ្នាក់លើផងចំពោះករណីដែល ឌុច មិនព្រមរាយ-ការណ៍អំពីមូលហេតុអ្នកទោសស្លាប់អស់ជាច្រើននាក់ ។

នៅដើមឆ្នាំ១៩៧៥ ទំនាស់ផ្ទៃក្នុងរវាងកម្មាភិបាលធំៗនៅក្នុងមន្ទីរបានកើតមានឡើងជាសម្ងាត់ ។ ផល ដែលជាកម្មាភិបាលម្នាក់បន្ទាប់ពី ឌុច, ប៉ុន និង ចាន់ ត្រូវកងការពារនាំយកទៅសម្លាប់ ។ រឿងហេតុនេះមានតែ អ៊ិន ម្នាក់គត់ដែលដឹងច្បាស់ជាងគេ ព្រោះគាត់បានទៅពិនិត្យមើលដោយផ្ទាល់តាមបញ្ជារបស់ ឌុច បន្ទាប់ពីមានការភ្ញាល់គ្នាជាមួយពួកកងការពារនិងអ្នកទោសកម្រិតស្រាលមួយចំនួន ។ អ៊ិន រំឭកថា ឌុច បានប្រកាសឲ្យកងមួយគ្រឿងប្រសិនបើនរណាម្នាក់ទាយត្រូវពីអ្នកទោសដែលគាត់បានចាប់ចងនោះ ។ ប៉ុន្តែគ្មាននរណានឹកស្មានដល់ថា អ្នកដែលត្រូវចាប់ខ្លួននោះជា ផល ទេ ។ ផល ត្រូវបានចាប់ខ្លួនតាមបញ្ជារបស់ ឌុច ។ ចាន់ ខន អតីតកងការពារនៅមន្ទីរម-១៣ និយាយថា ផល បានធ្វើខុសនឹងវិន័យអង្គការ ពីបញ្ហាខុសសីលធម៌និងអាងខ្លួនជាអ្នកធំនៅក្នុងមន្ទីរបន្ទាប់ពី ឌុច ។ ចំណែក ចាន់ វឿន និយាយថា ផល ជាមនុស្សស្លូតបូតជាងគេម្នាក់ក្នុងចំណោមកម្មាភិបាលទាំងអស់ដែលនៅទីនោះ ។

## ការសម្លាប់

វិធីសម្លាប់អ្នកទោសនៅមន្ទីរ ម-១៣ មានច្រើនប្រភេទ ។ អ្នកទោសខ្លះត្រូវសម្លាប់នៅពេលសួរចម្លើយ អ្នកទោសខ្លះត្រូវសម្លាប់ដោយបាញ់នឹងកាំភ្លើង ខ្លះទៀតត្រូវសម្លាប់ដោយកម្មាភិបាលដឹកនាំក្នុងមន្ទីរនៅពេលធ្វើទារុណកម្ម និងអ្នកខ្លះទៀតត្រូវនាំយកទៅសម្លាប់នៅទីតាំងពិឃាតតែម្តង ។ អ៊ិន បានរៀបរាប់ពីវិធីសម្លាប់មួយប្រភេទទៀតថា កងការពារបាននាំអ្នកទោសទៅកាន់រណ្តៅត្រង់ឈាមមួយ រួចយកក្រមារុំកពីរជុំ ហើយទាញដោយក្រមាម្ខាងម្នាក់ ហើយកងការពារម្នាក់ទៀតយកកាំបិតចំពុះទុងអ៊ែរកែងសំលៀងឲ្យស្តើងដូចស្លាបមាន់ចាក់ចូលបំពង់-ក ខ្វេះឲ្យហូរឈាមចូលក្នុងរណ្តៅត្រង់ឈាម ។ ចំណែកកងការពារផ្សេងទៀត ជាអ្នកជញ្ជូនសាកសពយកទៅតម្រៀបដាក់ក្នុងរណ្តៅកប់សាកសពរួមចំនួនបីដែលមានសណ្ឋានជាមុំចត្រ័ាន» ។ អ៊ិន និយាយទៀតថា នៅត្រង់ណាក៏ឃើញក្បាលខ្មោចដែរ ។ ដោយសារតែមានខ្មោចងាប់ច្រើនបែបនេះ ទើបធ្វើឲ្យគាត់លែងខ្លាចខ្មោចតាំងពីពេលនោះរហូតមក ។ អ៊ិន បានរាយការណ៍ពីចំនួនមនុស្សដែលត្រូវសម្លាប់ ស្លាប់ដោយសារជំងឺ និងដោយសារទឹកជំនន់ សរុបទាំងអស់មានចំនួនប្រហែលពាម៉ឺន

នាក់ ។ អ៊ីន បានប្រាប់ពីការយល់ឃើញរបស់គាត់ចំពោះអ្នកទោសដែលស្លាប់នៅក្នុងមន្ទីរម-១៣ថា គឺជាការទទួលខុសត្រូវរបស់ ឌុច តែម្នាក់គត់ ព្រោះបញ្ជារបស់ ឌុច ទាំងប៉ុន្មានត្រូវតែអនុវត្តដោយមិនអាចល្មើសបានឡើយ ។ ចាន់ ខន ប្រាប់ថា "បើខ្ញុំមិនធ្វើតាមបញ្ជាទេ កំហុសនឹងត្រូវធ្លាក់មកលើខ្លួនខ្ញុំវិញ" ។ អ៊ីន បានស្តាប់ឮអំពីការដាក់បញ្ជារបស់ ឌុច ឲ្យកងការពារមន្ទីរសម្លាប់ខ្មាំងក្នុងមួយថ្ងៃពីរនាក់ជាកំហិត ។ អ៊ីន នៅចាំសម្តីរបស់ ឌុច និយាយប្រាប់ក្មេងៗជាកងការពារថា "ក្នុងមួយថ្ងៃគេដាំដំឡូងមីបាន១០០គុម្ព ឯងគ្រាន់តែសម្លាប់ខ្មាំងដែលចាប់បានចំនួនពីរនាក់ក៏ពិបាកដែរ" ។

## ការផ្លាស់ប្តូរទីតាំងនិងការវិលត្រឡប់ក្រោយថ្ងៃជ័យជម្នះ៧ ខែមករា ឆ្នាំ១៩៧៩

នៅខែមេសា ឆ្នាំ១៩៧៥ មន្ទីរសន្តិសុខ ម-១៣ បានផ្លាស់ប្តូរទីតាំងមកក្រុងភ្នំពេញ ។ តាមសម្តីរបស់កងការពារឈ្មោះ ចាន់ ខន ថាទីកន្លែងដែលត្រូវប្តូរមកក្រុងភ្នំពេញនោះ គឺទួលស្លែង ។ ឌុច នៅតែមានតួនាទីជាប្រធានមន្ទីរសន្តិសុខដដែល ។ ឯ ចាន់ និង ប៉ុន ក៏នៅតែជាកម្មាភិបាលថ្នាក់លើរបស់មន្ទីរនេះដែរ ។ ឌុច បានប្រកាសប្រាប់បណ្តាកម្មាភិបាល កងការពារនិងអ្នកទោសថាត្រូវតែផ្លាស់ប្តូរកន្លែងធ្វើការ ។ ឌុច បាននិយាយទៀតថា គាត់នឹងប្រមូលកម្មាភិបាលនិងកងការពារណាដែលមានប្រវត្តិរូបល្អយកទៅធ្វើការជាមួយគាត់នៅភ្នំពេញ ។ ខន និយាយប្រាប់ថា ឌុច បានប្រកាសលិខិតដែលក្នុងដៃខ្លួន ដោះលែងអ្នកទោសដែលនៅសេសសល់ពីការសម្លាប់ ។ អ៊ីន ជាអ្នកនិយាយតាមការប្រាប់របស់ ឌុច ថា "ឥឡូវបក្សយើងទទួលបានជ័យជម្នះទាំងស្រុងហើយ ដូច្នេះយើងត្រូវតែប្តូរមន្ទីររបស់យើងទៅតាំងនៅភ្នំពេញវិញ" ។ ពាក្យសម្តីមួយឃ្លានេះបានធ្វើឲ្យកម្មាភិបាលទាំងអស់និងកងការពារសប្បាយរីករាយនិងអបអរចំពោះមហាជ័យជម្នះនេះគ្រប់ៗគ្នា ។ ចាន់ ខន បានរៀបរាប់ពីភាពសប្បាយរីករាយនិងការខកចិត្តរបស់គាត់ចំពោះអន្តការថា គាត់សង្ឃឹមខ្លាំងណាស់ថានឹងបានទៅធ្វើការនៅភ្នំពេញជាមួយ ឌុច ព្រោះគាត់ខិតខំធ្វើការគ្រប់បែបយ៉ាងតាមបញ្ជារបស់ ឌុច ។ ប៉ុន្តែគាត់បែជាត្រូវបញ្ជូនឲ្យទៅនៅកងចល័តជាមួយប្រជាជនឯទៀតនៅក្នុងស្រុកភូមិរបស់គាត់ទៅវិញ បន្ទាប់ពី ឌុច ស៊ើបដឹងថាគាត់មានគ្រួសារជាប់ពាក់ពន្ធ័នឹងមន្ត្រីនៃរបបសាធារណរដ្ឋខ្មែរ ។ ខន និយាយដូច្នេះថា "ខិតខំធ្វើការដើម្បីជ័យជម្នះ និងដើម្បីមានមុខមាត់នឹងគេ ។ លុះដល់ថ្ងៃជ័យជម្នះ ហើយបែរជាអស់សង្ឃឹមទៅវិញ" ។ ខន សោកស្តាយអំពើដែលខ្លួនបានធ្វើទៅលើអ្នកទោសដោយបាញ់សម្លាប់អ្នកទោសជាច្រើននាក់តាមបញ្ជារបស់ ឌុច ។ ខន ប្រាប់ថា គាត់ធ្លាប់បាញ់សម្លាប់អ្នកទោសតាមបញ្ជារបស់ ឌុច នៅពេលអ្នកទោសលួចរត់ចេញពីមន្ទីរឃុំឃាំង ។

ចាន់ ប៉ុន និងកងការពារខ្លះទៀតដែលមានប្រវត្តិរូបល្អ ត្រូវបាន ឌុច ហៅឲ្យទៅធ្វើការជាមួយនៅឯទួលស្លែង(ស-២១) ។ ចំណែកអ្នកទោសមួយចំនួនដែលនៅសេសសល់ពីការសម្លាប់ត្រូវបានដោះលែងឲ្យវិលត្រឡប់ទៅតាមការដ្ឋាន និងផ្ទះសម្បែងរៀងៗខ្លួន ហើយមួយចំនួនត្រូវបែងចែកឲ្យទៅនៅតាមមន្ទីរសន្តិសុខដែលជាសាខារបស់មន្ទីរ ម-១៣ ។ អ៊ីន និងបក្ខពួកគាត់បីនាក់ ត្រូវបានបញ្ជូនទៅកាន់មន្ទីរម-៩៩ ហើយអ្នកខ្លះទៀតត្រូវបញ្ជូនទៅកាន់ខេត្តពោធិ៍សាត់ ។ ចំណែកមន្ទីរម-១៣ ត្រូវបានបោះបង់ចោល ។

តំណែងជាប្រធានសន្តិសុខស-២១របស់ ឌុច បានបញ្ចប់នៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ កម្មាភិបាលថ្នាក់ដឹកនាំមន្ទីរមួយចំនួនត្រូវបានសម្លាប់ ហើយមួយចំនួនទៀតបានរត់ប្រាសអាយុទៅកាន់តំបន់ដាច់ស្រយាល ។ ឌុច ប្រធានមន្ទីរស-២១ បានរត់ទៅកាន់ទឹកដីឃុំអមលាំង ស្រុកថ្ពងម្តងទៀត ដែលនៅទីនោះខ្មែរក្រហមបានប្រមូលប្រជាជនប្រហែល៤.៦០០នាក់ (ដោយរាប់បញ្ចូលទាំងយុទ្ធជនខ្មែរក្រហម ដែលចាប់មកពីខាងភូមិភាគបូព៌ាផង) យកទៅសម្លាប់ចោលនៅប៉ែកខាងជើងវត្តកន្សែងសមដោយឆ្លងស្ទឹងក្រាំងពន្លៃ ។ តាមប្រសាសន៍របស់អធិការប៉ូលិសស្រុកថ្ពងបានឲ្យដឹងថា ការកៀរជនរងគ្រោះពីកន្លែងផ្សេងមកសម្លាប់គឺ ឌុច ជាអ្នកអនុវត្តផែនការនេះដោយផ្ទាល់ បន្ទាប់ពីគាត់ត្រឡប់ពីភ្នំពេញទៅវិញ ។

នៅក្នុងឯកសារ"សំណុំរឿងតុលាការកាត់ទោសបនប្រល័យពូជសាសន៍ ប៉ុល ពត- អៀង សារី" មានរៀបរាប់ពីការដឹកជញ្ជូនមនុស្សចំនួន១.២០០នាក់ផ្សេងទៀតយកទៅសម្លាប់ចោលនៅ

នឹងទីតាំងខាងជើងវត្តកន្សែងសមដែរ គឺនៅក្នុងអំឡុងខែកុម្ភៈ ឆ្នាំ ១៩៧៩ ។

## ទីតាំងត្រពាំងប្រាបពីឆ្នាំ១៩៧៥រហូតមកដល់បច្ចុប្បន្ន

ចាប់តាំងពីឆ្នាំ១៩៧៥-១៩៧៩ អតីតមន្ទីរម-១៣ ឬ ត្រពាំងប្រាប ពុំមានប្រជាជន ឬខ្មែរក្រហមណាម្នាក់ដើរឆ្លងកាត់ទីនោះឡើយ ព្រោះជាវាលរហោឋាននិងសម្បូរសត្វព្រៃ ។ ប៉ុន្តែបច្ចុប្បន្ន ផ្នែកខ្លះនៃទីតាំងត្រពាំងប្រាបត្រូវប្រជាជនដែលរស់នៅក្នុងភូមិថ្មគុប ឃុំអមលាំង រានដីយកធ្វើជាស្រែរបស់ខ្លួន ហើយ មួយផ្នែកធំទៀតទុកទំនេរចោល ។ រណ្តៅជ្រៅៗពីមុនសព្វថ្ងៃនេះ ប្រែជារាក់ៗអស់ ។ បន្តោលក្រាក់ដែលពីមុនមានកម្ពស់៥ទៅ៦ម៉ែត្រ ឥឡូវនៅសល់តែប្រហែលមួយម៉ែត្រប៉ុណ្ណោះ ។ ស្ទឹងដែលហូរកាត់ទីតាំងមន្ទីរសន្តិសុខម-១៣ និងមានប្រភពមកពីភ្នំឱរ៉ាល់ នៅតែហូរកាត់ទីតាំងនេះដដែល ។ ត្រពាំងប្រាបដែលជាជម្រកត្រីនិងជាកន្លែងដែលផ្តល់សេដ្ឋកិច្ចសំខាន់សម្រាប់មន្ទីរសន្តិសុខ ម-១៣ ក៏ស្ថិតនៅដូចមុន ព្រមទាំងបម្រើសេចក្តីត្រូវការរបស់ប្រជាជនក្នុងការធ្វើស្រែចម្ការនិងចិញ្ចឹមសត្វពាហនៈផង ។ មនុស្សច្រើននាក់ នៅក្នុងទឹកដីស្រុកថ្ពង ខេត្តកំពង់ស្ពឺ សុទ្ធតែដឹងពីការសម្លាប់ មនុស្សនៅក្នុងមន្ទីរសន្តិសុខ ម-១៣ ក្រោមការគ្រប់គ្រងរបស់ ឌុច ។

## ទិន្នន័យសង្ខេប

**ទីតាំង** ៖ មន្ទីរសន្តិសុខ ម-១៣ ស្ថិតនៅភូមិថ្មគុប ឃុំអមលាំង ស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

**ស្ថិតិ** ៖ ឌុច បានបង្កើតមន្ទីរសន្តិសុខ ម-១៣ នេះតាំងពីឆ្នាំ១៩៧១ ។ ដំបូងមន្ទីរនេះមានទីតាំងនៅក្នុងបរិវេណថ្មយោង និងក្រោយមកបានផ្លាស់មកកាន់ទីតាំងត្រពាំងប្រាបវិញ ។ ឌុច ជាប្រធានមន្ទីរទាំងមូល រួមជាមួយនឹងកម្មាភិបាល៥នាក់ផ្សេងទៀត ។ ក្រៅពីនេះនៅមានកងសន្តិសុខក្មេងៗ១៥នាក់ទៀត ។ មន្ទីរនេះចែកចេញជា៣សាខាគឺ មន្ទីរសន្តិសុខនគរបាលមន្ទីរសន្តិសុខភ្នំប្រសិទ្ធិ៍ត្រ័យត្រិង្សនិងមន្ទីរម-៩៩ ។ នៅខែមេសា ឆ្នាំ១៩៧៥ មន្ទីរម-១៣ ត្រូវបានផ្លាស់ទីតាំងមកនៅ“ទួលស្លែង”វិញ ឬហៅថា “មន្ទីរស-២១” ។

**ផេង ពង្សរ៉ាស៊ី**



ទីតាំងសម្លាប់នៅភូមិក្រាំងក្រូច ឃុំក្រាំងដីបាយ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ

# ចំណោទឧក្រិដ្ឋកម្ម
# មន្ទីរសន្តិសុខភូមិភាគនិរតី
# ការកកើត ប្រតិបត្តិការ និង ធំនាក់ធំនង

***(តពីលេខមុន)***

***ការសួរចម្លើយ និងទារុណកម្ម***

ដំណើរការសួរចម្លើយអ្នកទោសក្នុងមន្ទីរសន្តិសុខតំបន់មានលក្ខណៈបន្តបន្ទាប់ដូចដំណើរការសួរចម្លើយនៅក្នុងមន្ទីរស-២១ដែរ ។ លក្ខណៈដូចគ្នាបន្តបន្ទាប់ រួមមានការបង្ខាំងអ្នកទោសទុកពី ២ទៅ៦ថ្ងៃ ដើម្បីបំបាក់ស្មារតីមុនពេលនាំចេញទៅសួរចម្លើយ និងប្រើគ្រប់វិធីសាស្ត្រសួរចម្លើយ ដែលរាប់ទាំងវិធីសាស្ត្រត្រជាក់និងក្ដៅផង ។

ការសួរចម្លើយតាមវិធីត្រជាក់ដើម្បីយកចម្លើយសារភាពជាទិសដៅទៅថ្ងៃមុខរបស់មន្ទីរស-២១ ប៉ុន្តែវិធីសួរចម្លើយដោយក្ដៅដាច់ខាតនិងទាំងស្រុង នៅតែត្រូវរក្សាទុក "ចំពោះខ្មាំងយួននិងសេ.អ៊ី.អា" ។ វិធីសួរចម្លើយដោយត្រជាក់ គឺអ្នកទោសត្រូវកម្មាភិបាលសួរចម្លើយលួងលោម មិនប្រើការវាយដំឡើយ ។ វិធីសួរចម្លើយដោយក្ដៅ អ្នកទោសត្រូវកម្មាភិបាលសួរចម្លើយវាយដំ ធ្វើទារុណកម្មដើម្បីយកចម្លើយសារភាព ។ សៀវភៅការងារសន្តិបាលមន្ទីរស-២១ សរសេរក្នុងវគ្គសិក្សាផ្នែកសួរចម្លើយអំពីវិធីសួរចម្លើយដោយត្រជាក់និងក្ដៅថា "ការលួងលោម គឺជាវិធីសំខាន់ទីមួយ ចំណែកការធ្វើទារុណកម្មជាវិធីទីពីរ" ។ វិធីសួរចម្លើយក្ដៅមានសរសេរបញ្ជាក់នៅលើជញ្ជាំងក្នុងបន្ទប់សួរចម្លើយមន្ទីរស-២១ "សួរអីឆ្លើយហ្នឹងកុំបង្វែរសំណួរអញ ។ សួរភ្លាមឆ្លើយភ្លាម មិនឲ្យដំអក់មួយនាទីឡើយ ។ ប្រឆាំងវិន័យអញមួយចំណុចត្រូវរងរំពាត់១០រំពាត់ បុរសឆក់ខ្សែភ្លើង៥ឆាប់..." ។

ដំណើរការបង្ខាំងទុកបង្អត់បាយដើម្បីបំបាក់ស្មារតី វិធីសួរត្រជាក់និងវិធីសួរក្ដៅត្រូវបានគណៈស៊ើបអង្កេតមន្ទីរសន្តិសុខតំបន់ប្រើប្រាស់ក្នុងការសួរចម្លើយអ្នកទោសក្នុងមន្ទីរសន្តិសុខតំបន់នៅភូមិភាគនិរតី ។ បន្ទាប់ពីបានបញ្ជូនខ្លួនដាក់ឃុំឃាំង បង្អត់អាហារនៅក្នុងមន្ទីរសន្តិសុខតំបន់២៥អស់រយៈពេល៣-៤ថ្ងៃ សុង ត្រូវគណៈស៊ើបអង្កេតនាំចេញទៅសួរចម្លើយ ។ សុង រៀបរាប់ថា "ពេលទៅដល់បន្ទប់សួរចម្លើយ គណៈស៊ើបអង្កេតដកបារីឲ្យខ្ញុំមួយដើម ។ បន្ទាប់មកនិយាយលួងលោមខ្ញុំថា "មិត្តយើងឥឡូវត្រូវឆ្លើយប្រាប់អង្គការឲ្យត្រង់ អង្គការអត់ធ្វើអីទេ អង្គការស្រឡាញ់តែអ្នកត្រង់និយាយឲ្យត្រង់ទៅកុំលាក់អង្គការ" ។ ឡោះ អ្នកទោសមន្ទីរសន្តិសុខតំបន់៣៥ នៅចាំថ្ងៃដែលគាត់ត្រូវបាននាំទៅសួរចម្លើយដោយសារពេលនោះគាត់ទទួលបានបារីមួយដើមពីគណៈស៊ើបអង្កេត ។ ឡោះ ប្រាប់ថា បារី មួយដើមធ្វើឲ្យគាត់ "មានកម្លាំង ស្វាង ស្រឡះខ្លួន" បន្ទាប់ពីគាត់ដេកជាប់ខ្នោះអត់បាយអត់ទឹកអស់រយៈពេល២ថ្ងៃក្នុងគុកងងឹត ។

រិន ប្រាប់ឲ្យដឹងថា ពេលសួរចម្លើយដំបូង អ្នកទោសត្រូវអង្គុយលើកៅអីធម្មតា សួរនាំនិយាយឆ្លើយឆ្លង មិនទាន់សម្លុតធ្វើទារុណកម្មឡើយ ប៉ុន្តែការសួរលើកក្រោយបន្តបន្ទាប់មកទៀតនោះ គឺសម្លុតគំរាមកំហែងនិងធ្វើទារុណកម្មតែម្ដង ។ រិន បញ្ជាក់ពាក្យគំរាមកំហែងរបស់គណៈស៊ើបអង្កេតថា "ពេលសួរស្អីត្រូវឆ្លើយហ្នឹង ។ បើប្រឆាំងគឺច្បាស់ជាត្រូវដំបងនិងខ្សែភ្លើងមិនខាន" ។ ឡោះ រំឭកពីការសួរចម្លើយគាត់លើកទីពីរ "ពេលនាំទៅដល់បន្ទប់សួរចម្លើយ ដំបូងគណៈស៊ើបអង្កេតប្រាប់ឲ្យខ្ញុំអង្គុយលើកៅអី ហើយចាប់ផ្ដើមសួរ ។ សំណួរទីមួយដែលសួរខ្ញុំគ្រប់ពេលនោះគឺ "តើឯងដឹងខ្លួនទេហេតុអីបានជាអង្គការចាប់ខ្លួនឯងមកទីនេះ?" ខ្ញុំឆ្លើយថា "អត់ដឹង" ពេលនោះ វាវាយខ្ញុំ រួចវានិយាយថា "ឯងគិតសិនទៅបន្តិចទៀតយើងមកវិញ" ពេលមកវិញចាប់ផ្ដើមសួរបន្តទៀត "ម៉េចនឹកឃើញឬនៅ?" ខ្ញុំឆ្លើយ "អត់ដឹងទេ" ។ ៣ថ្ងៃក្រោយមក ឡោះ ត្រូវបាននាំចេញទៅសួរ

ចម្លើយម្តងទៀត ប៉ុន្តែដំណើរការសួរលើកទីពីរនេះមិនដូចមុនឡើយ ។ ឡោះ រៀបរាប់ថា "វាសួរសំណួរដដែល ខ្ញុំឆ្លើយថាអត់ដឹងដដែល ។ វាសម្លុតខ្ញុំឲ្យសារភាព ។ ខ្ញុំថាអត់ដឹង ។ បន្ទាប់មក វាយកដំបងក្តគោនិងយកថង់ផ្លាស្ទិចមករុំក្បាលខ្ញុំរហូតសន្លប់បាត់ស្មារតី ។ ពេលដឹងខ្លួនឡើង ខ្ញុំដេកនៅក្នុងគុកងងឹតវិញទៅហើយ" ។

ដោយសារអ្នកទោសមានលក្ខណៈសំខាន់ ទាំងទោសកំហុសនិងឋានៈតួនាទី ការសួរចម្លើយនៅក្នុងមន្ទីរសន្តិសុខតំបន់មានសភាពខ្លាំងក្លានិងស្រួចស្រាល់បំផុតដែរ ។ ការសួរចម្លើយនិងទារុណកម្មធ្វើឡើងចំពោះអ្នកទោសយ៉ាងតិចពីរដង ។ ម្តងៗប្រើពេលវេលាជាច្រើនម៉ោង ។ ការសួរចម្លើយកើតឡើងចំពោះអ្នកទោសច្រើនដង ដោយសារកម្មាភិបាលមន្ទីរសន្តិសុខយល់ថាការឆ្លើយសារភាពរបស់អ្នកទោសលើកទី១ និងទី២ "ពុំទាន់ឆ្លើយច្បាស់លាស់លម្អិតអស់រឿងឡើយ ហើយការសួរនៅពេលបន្តបន្ទាប់ទៀតនោះ ជាចលនាវិវត្តបន្តិចម្តងៗទៅមុខជានិច្ច" ។ ឡោះ ត្រូវគណៈស៊ើបអង្កេតមន្ទីរសន្តិសុខតំបន់៣៥សួរចម្លើយចំនួនបីដង ។ ពេលល្ងាចម្តងៗប្រើពេលអស់ជាង៤ម៉ោង ។ តាមឯកសារចម្លើយសារភាពរបស់ ជូ កាន បញ្ជាក់ថា គាត់ត្រូវបានគណៈស៊ើបអង្កេតមន្ទីរសន្តិសុខតំបន់២៥សួរចម្លើយចំនួន៤លើក ។ លើកទី១នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ពីម៉ោង៨ព្រឹកដល់ម៉ោង១២ថ្ងៃត្រង់ ។ លើកទី២សួរនៅថ្ងៃទី៤ ខែធ្នូ ឆ្នាំ១៩៧៥ ពីម៉ោង១២:២០នាទីដល់ម៉ោង៤រសៀល ។ លើកទី៣នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ ពីម៉ោង ៥:៣០នាទី ល្ងាចដល់ម៉ោង៦ល្ងាច និងលើកទី៤គឺនៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៧៥ ពីម៉ោង៩ព្រឹកដល់ម៉ោង១១ថ្ងៃត្រង់ ។

គោលបំណងនៃការសួរចម្លើយដ៏សស្រាក់សស្រាំនិងអមនុស្សធម៌នៅក្នុងមន្ទីរសន្តិសុខតំបន់ ក៏មិនខុសពីគោលបំណងនៃការសួរចម្លើយអ្នកទោសក្នុងមន្ទីរស-២១ដែរ ។ គោលបំណងក្នុងការសួរចម្លើយអ្នកទោសមាន៣គឺ ទី១) ដើម្បីបង្ខំឲ្យអ្នកទោសព្រមឆ្លើយសារភាពថាខ្លួនមានកំហុស ។ ទី២) ឲ្យអ្នកទោសសារភាពអំពីមូលហេតុនៃការក្បត់ ។ និងទី៣) ឲ្យអ្នកទោសសារភាពអំពីខ្សែសង្វាក់ចាត់តាំងដែលក្បត់ជាមួយខ្លួន ។ ថន ត្រូវបាននាំចេញទៅសួរចម្លើយចំនួន៦ដងក្នុងរវាង៥ទៅ៦ថ្ងៃ ។ ថន អះអាងថា "ដំណើរការសួរចម្លើយដ៏តឹងរ៉ឹងនិងខ្លាំងក្លា គឺក្នុងបំណងរុញទម្លាក់អ្នកទោសដែលត្រូវសួរចម្លើយឲ្យក្លាយជាខ្មាំងពិតប្រាកដរបស់អង្គការ អំពីផែនការក្បត់និងខ្សែសង្វាក់ដែលពាក់ព័ន្ធក្នុងផែនការនោះ" ។ រិន បញ្ជាក់អំពីវិធីទម្លាក់កំហុសដោយការដេញដោលសួររបស់គណៈស៊ើបអង្កេតមន្ទីរសន្តិសុខតំបន់២៥ រួមមានសំណួរដូចជា "ពេលនៅភ្នំពេញធ្វើស្អីខ្លះ? ពេលចុះមកមានបក្សពួកប៉ុន្មាននាក់? បានធ្វើសកម្មភាពអ្វីខ្លះ?" ។

ក្រោមការសួរចម្លើយរបស់គណៈស៊ើបអង្កេតមន្ទីរសន្តិសុខតំបន់ អ្នកទោសភាគច្រើនឆ្លើយសារភាព ។ នៅពេលសួរចម្លើយ កាន ឆ្លើយសារភាពកំហុសនៃការចាប់ខ្លួនរបស់គាត់ប្រាប់គណៈស៊ើបអង្កេតមន្ទីរសន្តិសុខតំបន់២៥ឈ្មោះ ម៉ុង, ហាក់ និងស្រេង ថា "ខ្ញុំពិតជាមានបំណងរត់ទៅប្រទេសសៀមពិតប្រាកដមែន" ។ ដូច កាន ដែរ ហួរ ត្រូវបានសួរចម្លើយដោយគណៈស៊ើបអង្កេតមន្ទីរសន្តិសុខតំបន់២៥ចំនួន២នាក់ គឺសមមិត្ត ជាម និងសមមិត្ត ហាក់ អស់រយៈពេល២ម៉ោង ។ ហួរ បានឆ្លើយសារភាពអំពីផែនការក្បត់និងខ្សែក្បត់របស់គាត់ចំនួន៤០នាក់ ។

អ្នកទោសឆ្លើយសារភាពទាំងការពិតនិងទាំងការប្រឌិត ក្នុងគោលបំណងបានការសន្តោសប្រណីនិងការរស់រានមានជីវិត ។ ប្រាហ៊ីម ត្រូវបានបញ្ជូនពីមន្ទីរសន្តិសុខតំបន់២៥មកដល់មន្ទីរស-២១ នៅថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៧៦ ។ ៥ខែក្រោយមក គាត់ត្រូវបានបក្សចារសម្រេចឲ្យនាំយកទៅប្រហារជីវិត ។ តាមចម្លើយសារភាពរបស់ ប្រាហ៊ីម មូលហេតុដែលនាំដល់ការចាប់ខ្លួនគាត់ គឺដោយសារគាត់មានឈ្មោះជាប់ខ្សែក្បត់ក្នុងចម្លើយសារភាពរបស់ យូសុះ ។ "ខ្ញុំគ្មានកូនចិត្តណាមួយលាក់លៀមអ្វីជាមួយអង្គការបដិវត្តន៍ឡើយ ព្រោះខ្ញុំបានយល់ច្បាស់ហើយថាអង្គការ បដិវត្តន៍ ទាមទារតែសេចក្តីស្មោះត្រង់ទេ ទោសកំហុសទាំងប៉ុន្មានដែលមានពីមុនមក អង្គការបដិវត្តន៍នឹងលើកលែងទោសឲ្យទាំងអស់ ហេតុនេះខ្ញុំបាទបេះតែរង់ចាំនូវការវិនិច្ឆ័យរបស់អង្គការបដិវត្តន៍ដោយសង្ឃឹមជានិច្ច" ។ ក្តីសង្ឃឹមរបស់ ប្រាហ៊ីម ចំពោះ ការសន្តោសប្រណីរបស់បក្សបានកើតឡើងមែន គឺកើតឡើង ៥ខែបន្ទាប់ពីសួរចម្លើយចុងក្រោយបំផុត ។

ប្រាហ៊ីម ត្រូវបានបក្សសម្រេចនាំយកទៅប្រហារជីវិតនៅថ្ងៃទី ១៨ ខែឧសភា ឆ្នាំ ១៩៧៦ ។ ឈ្មោះ ប្រាហ៊ីម ស្ថិតក្នុងលំដាប់លេខរៀងទី៨៧ ក្នុងចំណោមអ្នកទោសចំនួន៣៣៧នាក់ដែលបក្សសម្រេចប្រហារជីវិត ។ តាមការសិក្សារបស់លោក អ៊ីសា ឧស្មាន អ្នកនិពន្ធសៀវភៅ "អ៊ូគូបះ" បង្ហាញថា អ្នកទោសជាប់ក្នុងចម្លើយសារភាពរបស់ ប្រាហ៊ីម មានចំនួនសរុប១១នាក់ ។ អ្នកទោសចំនួន១០នាក់ បានស្លាប់បាត់បង់ជីវិត ។ អ្នកទោសម្នាក់ក្នុងចំណោម១០នាក់ មានចម្លើយសារភាពនៅមន្ទីរស-២១ ។ អ្នកទោសម្នាក់នោះ ឈ្មោះ យ៉ាសយ៉ា ។ តាមបញ្ជីអ្នកទោសមន្ទីរស-២១ យ៉ាសយ៉ា ស្លាប់ដោយគ្រាំស្លឹកនៅថ្ងៃទី២ ខែឧសភា ឆ្នាំ១៩៧៦ ។

ករណីអ្នកទោសមន្ទីរសន្តិសុខតំបន់ ក្នុងភូមិភាគនិរតី បានកើតឡើងដូចករណីអ្នកទោសក្នុងមន្ទីរស-២១ដែរ ។ ការឆ្លើយសារភាពរបស់អ្នកទោសក្រោមការលួងលោមនិងធ្វើទារុណកម្មធ្វើឲ្យអ្នកទោសរួចផុតពីភាពសង្រេគនិងទារុណកម្ម ។ ប៉ុន្តែចម្លើយសារភាពរបស់អ្នកទោសធ្វើឲ្យអ្នកទោសខ្លួនឯងនិងអ្នកជាប់ក្នុងចម្លើយភាពរបស់ខ្លួនក្លាយជាខ្មាំងរបស់អង្គការ ។ បន្ទាប់ពីឆ្លងកាត់ការសួរចម្លើយ ណុប ទ្រី សារភាពអំពីខ្សែសង្វាក់ក្បត់របស់គាត់ចំនួន២៧នាក់ ។ ចំណែកខ្សែក្បត់របស់ ហួរ មានរហូតដល់៤០នាក់ ។ ភាពជាខ្មាំងនិងជាខ្សែសង្វាក់របស់ខ្មាំងត្រូវបានចាប់ខ្លួននិងប្រហារជីវិត ។ ដូចសមមិត្ត គេង ប្រធានមន្ទីរសន្តិសុខតំបន់២៥បញ្ជាក់ថា "ពេលសួរចម្លើយហើយ ឃើញច្បាស់ថាជាភ្នាក់ងារចារកិច្ចរបស់ខ្មាំងពួកអា លន់ នល់" តាមបញ្ជារបស់លេខាតំបន់ គឺត្រូវតែ"កម្ទេច" ។

រិន ដឹងច្បាស់ពីបំណងរបស់គណៈស៊ើបអង្កេតក្នុងការសួរដដឹករកខ្សែរយៈចាត់តាំង ដូច្នេះ រិន ឆ្លើយប្រាប់ឈ្មោះមនុស្សដែលត្រូវបានចាប់ខ្លួនជាមួយគាត់ ប៉ុន្តែគាត់មិនព្រមឆ្លើយដាក់អ្នកផ្សេង ជាអតីតទាហាន លន់ នល់ ដែលគាត់បានស្គាល់តាមសំណួររបស់គណៈស៊ើបអង្កេតតំបន់២៥ឡើយ ។ រិន ប្រាប់ហេតុផលថា "អាណិតប្រពន្ធកូនគ្នា នៅផ្ទះអត់ដឹងអីសោះ ។ សុខចិត្តស្លាប់តែម្នាក់ឯងទៅវាល្អជាង" ។

វិធីធ្វើទារុណកម្មលើអ្នកទោសបន្ទុំយកចម្លើយរបស់គណៈស៊ើបអង្កេតមន្ទីរសន្តិសុខតំបន់ក្នុងភូមិភាគនិរតីរួមមាន ៖ ◆ ឆក់ខ្សែភ្លើង ◆ ដកក្រចក ◆ វាយនឹងដំបង ◆ វាយនឹងខ្សែតី ខ្សែភ្លើង ◆ វាយបំបាក់ដៃជើង ◆ វាយបំបាក់ឆ្អឹងជំនីរ ◆ ប្របាច់ក ◆ រុំស្បោងផ្លាស្ទិចឲ្យថប់ដង្ហើម ។

សុង បានឲ្យដឹងថា "អ្នកទោសខ្លះត្រូវឆក់ខ្សែភ្លើងរហូតឆ្អួតលែងស្មៀកខោអាវ ខ្លះត្រូវវាយរហូតបាក់ឆ្អឹងជំនីរ" ។ ម៉ៅ និង រិន បញ្ជាក់ថា ការធ្វើទារុណកម្មដោយឆក់ខ្សែភ្លើង និងរុំស្បោងផ្លាស្ទិកធ្វើឡើងតែចំពោះអ្នកទោសដែលគណៈស៊ើបអង្កេតមន្ទីរសន្តិសុខយល់ថា ជាខ្មាំងមានតួនាទីសំខាន់ជាទាហាន ជាយុទ្ធជនខ្មែរក្រហម ដែលត្រូវបានចោទថាក្បត់ និងអតីតទាហានរបប លន់ នល់ មន្ត្រីផ្សេងៗ ។

ការសួរចម្លើយរបស់គណៈស៊ើបអង្កេត ដោយការធ្វើទារុណកម្ម ដោយការបន្ទុំលើអ្នកទោសក្នុងសភាពទន់ខ្សោយស្រាប់នោះ ពេលខ្លះបណ្តាលឲ្យអ្នកទោសស្លាប់បាត់បង់ជីវិតក្នុងពេលនោះ និងថ្ងៃបន្តបន្ទាប់មកទៀត ។ ម៉ឹង គេង ហៅ សំណាង ប្រធានមន្ទីរសន្តិសុខតំបន់២៥ បានវាយសួរចម្លើយអ្នកទោសចំនួនពីរនាក់ឈ្មោះ ខ្វៃន និងឈ្មោះ ចន្ថា ។ គេង វាយរហូតដល់អ្នកទាំងពីរស្លាប់ ។ គេង បញ្ជាក់ថា "ខ្ញុំអនុវត្តតាមការណែនាំរបស់ តាជ័យ (លេខាតំបន់២៥) ដោយបានចាប់ឈ្មោះ ខ្វៃន យកទៅមន្ទីរសន្តិសុខសួរចម្លើយរួចឃុំឃាំងនៅទីនោះ រហូតជននេះស្លាប់ក្នុងមន្ទីរឃុំឃាំង ។ ក្រោយមកទៀត ខ្ញុំបានទៅចាប់ ឈ្មោះ ចន្ថា យកមកសន្តិសុខ រួចវាយសួរចម្លើយអំពីរឿងគិញបង្កប់ ។ ដោយមិនអាចទទួលចម្លើយតាមការចោទបាន តាជ័យក៏បានជំរុញឲ្យខ្ញុំវាយសួរខ្លាំងថែមទៀត រហូត ចន្ថា នោះស្លាប់ម្នាក់ទៀត" ។

អ្នកទោសដែលឆ្លើយសារភាពដើម្បីចៀសផុតពីការធ្វើទារុណ-កម្មនិងក្នុងក្តីសង្ឃឹមថាត្រូវបានដោះលែង ទីបំផុតត្រូវបានដោះលែងមែន ។ អ្នកទោសត្រូវបានដោះលែងពីបន្ទប់ឃុំឃាំង ហើយបញ្ជូនទៅមាត់រណ្តៅដើម្បីប្រហារជីវិតដោយត្បូងចប គល់ឫស្សី និងដែកក្បៀរទេះ ។

**(នៅមានត)**

**អៀ ម៉េងទ្រី**

# ជីវិតសល់ពីសេចក្តីស្លាប់

ដោយសារតែស្រុកកើតសង្គ្រាមនៅឆ្នាំ១៩៧៣ នេត ត្រូវបង្ខំចិត្តឈប់រៀនត្រឹមថ្នាក់ទី១០ ។ ពេលនោះចលនាខ្មែរក្រហមបានរីកដុះដាលពេញស្រុករមាសហែក ខេត្តស្វាយរៀង ។ ប្រជាជនជាច្រើនបាននាំគ្នាចូលធ្វើបដិវត្តន៍ ។ យាយហែម ម្តាយរបស់ នេត មានការព្រួយបារម្ភយ៉ាងខ្លាំង ព្រោះប្អូនប្រុសរបស់ នេត បានចូលធ្វើទាហានខ្មែរក្រហមម្នាក់ទៅហើយ ។ ដោយខ្លាចបាត់បង់ នេត ម្នាក់ទៀត យាយហែម បានសម្រេចចិត្តឲ្យ នេត ទៅបួសនៅវត្តតាសួសអស់បីវស្សា ។

ពេលខ្មែរក្រហមទទួលជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ នេត និងព្រះសង្ឃប្រហែលដប់អង្គក្នុងវត្តតាសួសត្រូវខ្មែរក្រហមចាប់ផ្សឹកទាំងអស់ ។ នេត បានត្រឡប់មកធ្វើស្រែចម្ការនៅក្នុងភូមិដូចប្រជាជនដទៃទៀតដែរ ។ មិនយូរប៉ុន្មានខ្មែរក្រហមបានប្រកាសជ្រើសរើសមនុស្សមួយចំនួនក្នុងភូមិឲ្យទៅធ្វើកម្មករនៅភ្នំពេញ ។ នេត មិនមានប្រតិកម្មអ្វីទាំងអស់ចំពោះសេចក្តីប្រកាសនេះ ។ ក្រោយមក នេត បានចាកចេញពីភូមិកំណើតទៅធ្វើការនៅភ្នំពេញ តាមការចាត់តាំងរបស់គណៈភូមិ ។

មុនពេលចេញដំណើរទៅភ្នំពេញ នេត ត្រូវចូលរៀនវគ្គសិក្សារយៈពេលមួយខែនៅសាលា ស-២០០ ដែលជាសាលាបង្ហាត់បង្រៀននយោបាយនិងយោធារបស់ភូមិភាគបូព៌ា ។ ក្រោយមកអង្គការបញ្ជូន នេត ឲ្យទៅរៀននៅវត្តរូងដំរីក្នុងខេត្តព្រៃវែងរយៈពេលបីថ្ងៃទៀត ។ ចុងក្រោយ នេត ត្រូវអង្គការបញ្ជូនតាមកាណូតមកធ្វើកម្មករនៅភ្នំពេញ ។

មកដល់ទីក្រុងភ្នំពេញ អង្គការចាត់តាំងឲ្យ នេត ធ្វើការនៅសាលាបង្រៀននយោបាយនៅម្តុំបុរីកីឡា ។ កិច្ចការរបស់ នេត គឺបោសសម្អាតនិងភ្លក់ម្ហូបដែលត្រូវរៀបចំឲ្យកម្មាភិបាលរបស់បក្សដែលមករៀនសូត្រនយោបាយនៅសាលានេះបរិភោគ ។ វគ្គសិក្សានីមួយៗមានរយៈពេលមួយខែ ក្រោមការបង្ហាត់បង្រៀនផ្ទាល់ពី ប៉ុល ពត, ខៀវ សំផន និង នួន ជា ។ អង្គការប្រយ័ត្នប្រយែងណាស់ ខ្លាចក្រែងមានការលួចដាក់ថ្នាំបំពុលនៅក្នុងម្ហូប ព្រោះអ្នកចូលរួមវគ្គរៀនសូត្រមួយចំនួនជាកម្មាភិបាលជាន់ខ្ពស់របស់បក្សដែលមកពីតាមភូមិភាគនិងតំបន់នានាទូទាំងប្រទេស ។ អ្នកភ្លក់ម្ហូបមានចំនួនប្រាំនាក់ រួមទាំង នេត ផង ។ ពេលរៀបចំម្ហូបអាហារម្តងៗក្រុមនេះត្រូវភ្លក់ម្ហូបគ្រប់មុខទាំងអស់ ។ បន្ទាប់ពីភ្លក់ម្ហូបបានប្រហែលប្រាំនាទី នេត ប្រកាសប្រាប់កម្មាភិបាលទាំងអស់តាមមីក្រូថា មានសុវត្ថិភាពអាចបរិភោគបានហើយ ទើបកម្មាភិបាលទាំងនោះចាប់ផ្តើមបរិភោគ ។ នេត បានបញ្ជាក់ថា ទោះបីជាម្ហូបត្រូវបានភ្លក់រួចរាល់និងមានសុវត្ថិភាពយ៉ាងណាក៏ដោយ ក៏ ប៉ុល ពត, ខៀវ សំផន និង នួន ជា មិនដែលចូលរួមបរិភោគអាហារជាមួយកម្មាភិបាលទាំងនោះដែរ ។

ក្រៅពីការងារបោសសម្អាតនិងភ្លក់ម្ហូប នេត ធ្វើការបន្ទាប់បន្សំខ្លះទៀតដូចជាភារមីននិងសកអំពៅ ។ នេត ធ្វើការនៅទីនោះអស់រយៈពេលបីឆ្នាំ ក្រោមការដឹកនាំរបស់សមមិត្ត ប៉ង់ និងសមមិត្ត ភុម ។ នៅចុងឆ្នាំ១៩៧៨ក្រោយពី សោ ភឹម លេខាភូមិភាគបូព៌ាត្រូវអង្គការចោទថាក្បត់និងចូលដៃជាមួយវៀតណាម នេត ដែលជាយុទ្ធជនមកពីភូមិភាគបូព៌ាដែរនោះ ត្រូវអង្គការដកពីអង្គភាពបុរីកីឡាឲ្យទៅធ្វើការនៅសហករណ៍ស៊ឹង ។ កម្មាភិបាលគ្រប់គ្រងនៅទីនោះប្រាប់ នេត ថា *«សមមិត្តកុំអន់ចិត្តអី ភារកិច្ចបក្សទោះកន្លែងណាក៏របស់បក្សដែរ ។ យើងមិនមែន នៅកន្លែងហ្នឹងរហូតទេ តែងតែប្រែប្រួលជានិច្ច»* ។ នេត គិតថា ជំនាន់នោះគ្មានចាយលុយទេ ដូច្នេះទៅណាក៏មានបាយហូបដែរ ។ តាមពិតអង្គការបញ្ជូន នេត ទៅសហករណ៍ស៊ឹងដើម្បីលត់ដំ ។

ទៅដល់សហករណ៍ស៊ឹងបានប្រហែលដប់ថ្ងៃ អង្គការចាត់តាំងឲ្យ នេត ឃ្វាលក្របីមួយនឹម ។ នេត និយាយថា បើសិនជាមានអ្នកណាមួយធ្វើឲ្យបាក់ជន្ទញនង្គ័ល អង្គការនឹងចោទថាខ្មាំង ហើយអ្នកនោះនឹងត្រូវអង្គការយកទៅវាយចោលមិនខាន ។ នេត សន្និដ្ឋានថា នៅសហករណ៍ស៊ឹង អង្គការយកមនុស្សទៅសម្លាប់រៀងរាល់ថ្ងៃ ។ នេត និយាយថា *«ឲ្យតែឃើញម៉ូតូសេអិលកញ្ចាស់មួយគ្រឿងមកល្ងាចពេលបាយច្បាស់ជាមកដឹកមនុស្សទៅវៃចោលហើយ»* ។

នៅពេលយប់មួយទៀតគឺ អង្គការបានដឹកក្មេងដាស់មនុស្សទាំងអស់ឲ្យក្រោកឡើងតម្រង់ជួរ ហើយបញ្ជាឲ្យអ្នកដែលមានឈ្មោះទាំងប៉ុន្មានចេញមកក្រៅជួរ ។ អង្គការបានប្រាប់ថា អ្នកដែលមានឈ្មោះទាំងអស់នឹងត្រូវបញ្ជូនឲ្យទៅវ៉ៃវៀតណាម ព្រោះវៀតណាមចូលមកកាន់តែខ្លាំងហើយ ។ នេត ក៏មានឈ្មោះដែរ ។ មិនយូរប៉ុន្មាន រថយន្តមួយគ្រឿងបានមកដឹក នេត និងមិត្តរួមការងារមួយចំនួនទៀតប្រហែល៥០នាក់ចេញទៅ ។ តាមពិតអង្គការមិនបានបញ្ជូនឲ្យទៅធ្វើទាហានទេ អង្គការយកអ្នកទាំងនោះទៅលើកទំនប់ផ្លូវរថភ្លើងថ្មីក្នុងខេត្តកំពង់ស្ពឺ ។ ធ្វើការនៅទីនោះបានរយៈពេលប្រហែលកន្លះខែ នេត និងមិត្តភក្តិមួយចំនួនត្រូវអង្គការបញ្ជូនទៅធ្វើលូនៅម្តុំស្ទឹងហាវក្រោមការគ្រប់គ្រងរបស់សមមិត្ត ហឿន ។ ការងារនៅទីនោះមានការលំបាកខ្លាំងដោយសារហូបមិនគ្រប់គ្រាន់ ហើយទទួលការចោទប្រកាន់និងការធ្វើទុក្ខបុកម្នេញឥតឈប់ឈរពី ហឿន ។ នេត និងមិត្តភក្តិបានបះបោរនិងចាប់ ហឿន យកទៅឲ្យមេធំនៅបន្ទាយកងទ័ពក្បែរនោះ ។ មួយថ្ងៃក្រោយមក កងទ័ពម្នាក់បានមកហៅ នេត និងមិត្តភក្តិរបស់គាត់ទៅប្រជុំ ។ ពេលទៅដល់ទីនោះ ក្រុមទាហានបានដោះលែង ហឿន ហើយបែរមកចាប់ នេត និងមិត្តភក្តិទាំងអស់ចង ហើយចោទប្រកាន់ពីបទបះបោរប្រឆាំងនឹងអង្គការទៅវិញ ។

នេត ត្រូវខ្មែរក្រហមឃុំខ្លួននៅជើងភ្នំម្តុំស្ទឹងហាវ ធ្វើទារុណកម្ម និងឆក់ខ្សែភ្លើងអស់រយៈពេលប្រហែលដប់ថ្ងៃ ។ ខ្មែរក្រហមបានយកខ្សែភ្លើងចង នេត ផ្អោបទៅនឹងដើមត្របែកព្រៃ រួចវាយសំបុកអង្ក្រងបីសំបុកដាក់ឲ្យខាំ ។ បន្ទាប់ពីសួរចម្លើយរួច នេត និងមិត្តភក្តិ ត្រូវអង្គការបញ្ជូនទៅសម្លាប់នៅព្រៃក្បែរនោះ ។ ខ្មែរក្រហមចងអ្នកទាំងអស់ជាខ្សែ ក្នុងមួយខ្សែមានគ្នាដប់នាក់ ហើយបណ្តើរឆ្ពោះទៅទួលនៅក្បែរនោះ ។ យុទ្ធជនខ្មែរក្រហមបីនាក់កំពុងរង់ចាំនៅទីនោះ ដែលមានម្នាក់ជាអ្នកបញ្ជា ម្នាក់ជាអ្នកវាយ និងម្នាក់ទៀតជាអ្នកចាក់នឹងចំពុះទុង ។ អ្នកទោសម្នាក់ៗត្រូវវាយមួយដំបងនិងចាក់បីចំពុះទុងបន្ថែមទៀត ។ ខ្មែរក្រហមយកមនុស្សចេញពីក្រុមរបស់ នេត ម្តងម្នាក់ៗទៅសម្លាប់ ហើយ នេត ជាមនុស្សទីប្រាំក្នុងចំណោមអ្នកទោសប្រហែល ៥០នាក់ ។ ខ្មែរក្រហមបញ្ជាឲ្យអ្នកទោសអង្គុយ រួចវាយនឹងដំបងឈើបួនជ្រុង ។ ពេលអ្នកទោសដួលដល់ដីយុទ្ធជនខ្មែរក្រហមម្នាក់ទៀតចាក់ថែមបីចំពុះទុងទៀតព្រោះខ្លាចមិនទាន់ស្លាប់ ។

ដោយសារជីវិតមិនទាន់អស់ ឆ្លងកាត់រយៈពេលមួយយប់ នេត ក៏បានដឹងខ្លួនវិញ ។ ក្នុងចំណោម អ្នកទោសទាំងអស់មានតែ នេត និង តាកាន ប៉ុណ្ណោះ ដែលបានរួចពីសេចក្តីស្លាប់នេះ ។ នេត និង តាកាន បានជួយស្រាយចំណងឲ្យគ្នាទៅវិញទៅមក ។ អ្នកទាំងពីរអស់កម្លាំងយ៉ាងខ្លាំង ដោយសារតែអត់អាហារយូរថ្ងៃនិងរបួសពេញខ្លួន ។ នេត និង តាកាន បានជួយគ្នាយកភក់មកបិទមុខរបួស រួចនាំគ្នាដើរទៅរកអាហារ ។ ដោយស្រេកទឹកខ្លាំងពេក នេត បានបង្ខំចិត្តផឹកទឹកនោមខ្លួនឯង ។ អ្នកទាំងពីរធ្វើដំណើរទាំងយប់ងងឹត ហើយក៏បានប្រទះនឹងចម្ការដំឡូងនិងចម្ការអំពៅ ។ ដំឡូងនិងអំពៅបានជួយឲ្យអ្នកទាំងពីរមានកម្លាំងបន្តិចឡើងវិញ ។

ក្រោយឆ្នាំ១៩៧៩ បន្ទាប់ពីបានឆ្លងកាត់គ្រោះកាចនេះហើយ នេត បានវិលត្រឡប់ទៅអង្គភាពនៅម្តុំស្ទឹងហាវវិញ ដើម្បីរកអង្ករ ។ ប៉ុន្តែ កងទ័ពខ្មែរក្រហមបានរត់ចេញពីទីនោះអស់ទៅហើយ ព្រោះខ្លាចកងទ័ពវៀតណាមចូលមកដល់ ។ ដោយមានការភ័យខ្លាចចំពោះកងទ័ពវៀតណាម នេត និង តាកាន បានរត់ឡើងភ្នំជាមួយខ្មែរក្រហម ។ ក៏ប៉ុន្តែ ដោយសារនឹករឭកឪពុកម្តាយនិងបងប្អូននៅស្រុកកំណើតពេក នេត បានបបួល តាកាន ចុះមកភូមិឃុំជើងគោវិញ ។ មួយខែកន្លះក្រោយមក មេឃុំជើងគោបានចាត់តាំងឲ្យ នេត ធ្វើជាឈ្លបភូមិ ។ ការងារនេះបានធ្វើឲ្យ នេត ពើបប្រយុទ្ធជាមួយកងទ័ពខ្មែរក្រហមជាញឹកញាប់ ដែលពេលខ្លះស្ទើរតែធ្វើឲ្យគាត់បាត់បង់ជីវិត ។ ដោយសារហេតុការណ៍នេះ នេត បានសម្រេចចិត្តលាឈប់ពីការងារ ហើយវិលត្រឡប់មកស្រុកកំណើតវិញ ។

នេត រស់នៅជួបជុំសាច់ញាតិយ៉ាងសប្បាយរីករាយ ។ នេត បានកត់ត្រាពីរឿងរ៉ាវជីវិតរបស់ខ្លួនទុកក្នុងកូនសៀវភៅតូចមួយដែលមានចំណងជើងថា «១៣យប់១៣ថ្ងៃ» ។ សៀវភៅនេះ រៀបរាប់ជាពិសេសអំពីរឿងរ៉ាវជីវិតរបស់គាត់ពេលចេញពីអង្គភាពបុរីកីឡា និងពេលខ្មែរក្រហមយកគាត់ទៅសម្លាប់ និងការដែលគាត់បានតស៊ូយ៉ាងស្វិតស្វាញដើម្បីវាយដណ្តើមយកជីវិតរបស់គាត់មកវិញ ។

**ឆាយ ណារឿន**

# ប្រភេទនៃអំពើប្រល័យពូជសាសន៍នៅកម្ពុជា

អំពើប្រល័យពូជសាសន៍គឺជាប្រភេទឧក្រិដ្ឋកម្មអន្តរជាតិ ដែលទាំងសហគមន៍អន្តរជាតិនិងសាមីប្រទេសមានកាតព្វកិច្ចទទួលខុសត្រូវរួមក្នុងការនាំយកជនសង្ស័យមកកាត់ទោសនិងដោះស្រាយរាល់បញ្ហាដែលកើតឡើងដែលជាលទ្ធផលនៃអំពើប្រល័យពូជសាសន៍។ ជាទូទៅ អំពើប្រល័យពូជសាសន៍គឺជាលទ្ធផលនៃសង្គ្រាម ។ នៅក្នុងសតវត្សរ៍ទី២០នេះ ភាគច្រើនអំពើប្រល័យពូជសាសន៍ច្រើនកើតឡើងក្នុងអំឡុងសង្គ្រាមលោកលើកទី១ (១៩១៤-១៩១៨) សង្គ្រាមលោកលើកទី២ (១៩៣៩-១៩៤៥) និងសង្គ្រាមស៊ីវិលដែលកើតមានឡើងក្នុងប្រទេសជាច្រើននៅលើពិភពលោក ។ ជាលទ្ធផល ជីវិតមនុស្សរាប់សិបលាននាក់ត្រូវបានសម្លាប់ ឬត្រូវបានធ្វើទុក្ខបុកម្នេញរហូតដល់ស្លាប់ ។ ប្រជាជនរាប់លាននាក់ផ្សេងទៀតបានទទួលរងផលប៉ះពាល់ពីអំពើប្រល័យពូជសាសន៍ ដោយអ្នកខ្លះបាត់បង់សមាជិកគ្រួសារ ធ្លាក់ខ្លួនពិការ និងបាត់បង់ឱកាសរៀនសូត្រដែលជាកត្តារួមផ្សំនាំទៅដល់ភាពក្រីក្រនិងអស្ថិរភាពក្នុងសង្គម ។

ពាក្យ "ប្រល័យពូជសាសន៍"ទើបតែត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៤៤ ដោយអ្នកច្បាប់ជាតិប៉ូឡូញមួយរូបគឺលោក រ៉ាហ្វុល លឹមគិន ។ ក្រោយពីការពិភាក្សានិងការចរចាគ្នាយ៉ាងយូរក្នុងចំណោមអ្នកច្បាប់ អ្នកជំនាញការខាងការសិក្សាពីអំពើប្រល័យពូជសាសន៍ និងតំណាងរដ្ឋជាសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិនៅឆ្នាំ១៩៤៨ មហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័ត "អនុសញ្ញាអន្តរជាតិស្តីពីការបង្ការនិងផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍" ។ អនុសញ្ញានេះចូលជាធរមាននៅឆ្នាំ១៩៥១ បន្ទាប់ពីប្រទេសជាង៥០នៃសមាជិកអង្គការសហប្រជាជាតិបានផ្តល់សច្ចាប័នទទួលស្គាល់ ។

ទោះជាពាក្យសព្ទនិងនិយមន័យនៃអំពើប្រល័យពូជសាសន៍ទើបតែត្រូវបានបង្កើតនិងប្រកាសឲ្យប្រើជាផ្លូវការនៅពាក់កណ្តាលសតវត្សរ៍ទី២០ក្តី អ្នកជំនាញការនិងប្រវត្តិវិទូជាច្រើនបានអះអាងថា អំពើប្រល័យពូជសាសន៍បានកើតមានឡើងនៅគ្រប់សម័យកាលនៃប្រវត្តិសាស្ត្រមនុស្សជាតិនិងក្នុងគោលបំណងផ្សេងៗគ្នា ។ នៅក្នុងសៀវភៅ"ប្រវត្តិវិទ្យានិងសង្គមវិទ្យានៃអំពើប្រល័យពូជសាសន៍" លោក សាស្ត្រាចារ្យ ហ្វ្រែង ឆក និង យឺត ចនសុន បានបែងចែកអំពើប្រល័យពូជសាសន៍ជាបួនប្រភេទ ដោយផ្អែកការសិក្សាស្រាវជ្រាវរបស់លោកទៅលើគោលបំណងរបស់ជនដៃដល់ ។ ប្រភេទនៃអំពើប្រល័យពូជសាសន៍ទាំងនេះរួមមាន ១)កម្ទេចចោលនូវភាគីដែលគំរាមកំហែងដល់សុវត្ថិភាព និងស្ថិរភាពអំណាចរបស់ខ្លួន ២)កម្ទេចសត្រូវសក្តានុពល ៣)ដណ្តើមយកផលប្រយោជន៍ផ្នែកសេដ្ឋកិច្ច និង៤)អនុវត្តជំនឿទ្រឹស្តីឬមនោគមវិជ្ជា ។


ប៉ុល ពត

អំពើប្រល័យពូជសាសន៍មួយចំនួនត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងច្រើន ប៉ុន្តែដំណើរការនៃការអនុវត្តផែនការប្រល័យពូជសាសន៍គឺមានលក្ខណៈតែមួយ ។ ជាទូទៅ ក្នុងការអនុវត្តផែនការដ៏ឃោរឃៅក្នុងទ្រង់ទ្រាយធំបែបនេះ ជនប្រល័យពូជសាសន៍តែងតែបានរៀបចំនិងដាក់ចេញនូវគម្រោងការក្នុងការកំណត់ក្រុមមនុស្សដែលខ្លួនយល់ថា ជាគ្រឿងគ្រោះថ្នាក់នាពេលអនាគត ជាឧបសគ្គក្នុងការពង្រីកនិងពង្រឹងអំណាច ឬជារនាំងរាំង

ខ្ទប់ដល់ការផ្សព្វផ្សាយមនោគមវិជ្ជា ។ ជនប្រល័យពូជសាសន៍ភាគច្រើនជាជនមានអំណាចឬជាថ្នាក់ដឹកនាំប្រទេស ដែលមានលទ្ធភាពបង្កើត អនុម័ត និងអនុវត្តនយោបាយប្រល័យពូជសាសន៍បាន ។ តើមេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលប្រជាជនខ្មែរស្គាល់ជាទូទៅថា«មេដឹកនាំខ្មែរក្រហម»នោះ បានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ដែរឬទេ? តើអ្នកទាំងនេះប្រព្រឹត្តអំពើប្រល័យពូជសាសន៍ក្នុងគោលបំណងអ្វី?

មេដឹកនាំខ្មែរក្រហមដែលបានគ្រប់គ្រងប្រទេសកម្ពុជាពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ បានដាក់ចេញនូវគោលនយោបាយជាច្រើនដែលប្រមាថជីវិតមនុស្សនិងបានបណ្តាលឲ្យប្រជាជនខ្មែរប្រមាណពីរលាននាក់ស្លាប់បាត់បង់ជីវិត ។ អស់រយៈពេលជិតបីទសវត្សរ៍មកហើយ មិនមានមេដឹកនាំណាម្នាក់ត្រូវបាននាំយកមកកាត់ទោសពីបទប្រល័យពូជសាសន៍នៅចំពោះមុខតុលាការមួយដែលមានកម្រិតស្តង់ដាអន្តរជាតិនៅឡើយទេ ។ តាមផ្លូវច្បាប់យើងមិនអាចនិយាយថា ជនទាំងនេះបានប្រព្រឹត្តឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឬឧក្រិដ្ឋកម្មផ្សេងៗទៀតបានឡើយ ។ នៅក្នុងផ្នត់គំនិតប្រជាជនខ្មែរភាគច្រើន និងតាមរយៈការស្រាវជ្រាវរបស់ប្រវត្តិវិទូមួយចំនួនវាពិបាកនឹងជឿណាស់ដែលថា មេដឹកនាំកម្ពុជាប្រជាធិបតេយ្យមិនបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ។ ហើយរឿងនេះស្ថិតនៅជាប្រធានបទដែលអ្នកស្រាវជ្រាវភាគច្រើនមិនទាន់អាចរកចំណុចប្រសព្វឃើញនៅឡើយ ។

លោក អ៊ីសា ឧស្មាន អ្នកស្រាវជ្រាវជាន់ខ្ពស់អំពីជនជាតិចាមក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានអះអាងថា ខ្មែរក្រហមបានសម្លាប់រង្គាលជនជាតិចាមអស់រាប់សែននាក់និងបានធ្វើទុក្ខបុកម្នេញជីវិតរស់នៅប្រចាំថ្ងៃ ដោយបង្ខំឲ្យជនជាតិចាមប្រព្រឹត្តផ្ទុយទៅនឹងគោលការណ៍សាសនារបស់ខ្លួន ។ នៅក្នុងសៀវភៅ «អ៊ូគូបះ» អ្នកស្រាវជ្រាវ អ៊ីសា ឧស្មាន បានអះអាងថាខ្មែរក្រហមព្យាយាមធ្វើឲ្យជនជាតិចាមតាមដាននិងរាយការណ៍ពីគ្នាទៅវិញទៅមក ។ ជាងនេះទៅទៀត ខ្មែរក្រហមបានកម្ទេចគម្ពីគូរ៉ាន លុបបំបាត់ចោលទំនៀមទម្លាប់ថ្វាយបង្គំរបស់អ៊ីស្លាម បង្ខំឲ្យស្ត្រីកាត់សក់ខ្លី និងបង្ខំឲ្យជនជាតិចាមហូបសាច់ជ្រូក ។ អ៊ីសា ឧស្មាន បានហៅគោលការណ៍ទាំងនេះថាជាការប៉ុនប៉ងកម្ទេចចោលទំនៀមទម្លាប់ប្រពៃណីរបស់ជនជាតិមួយដែលជាជំហានឆ្ពោះទៅរកការលុបបំបាត់ពូជសាសន៍មួយ ឬក្រុមសាសនាមួយដែលប្រកាន់យកប្រពៃណីទំនៀមទម្លាប់និងជំនឿសាសនាអស់រាប់សតវត្សរ៍មកហើយ ។

ខ្មែរក្រហមក៏មានផែនការលុបបំបាត់ជនជាតិវៀតណាមនិងចិនដែរ ដោយអះអាងថា ខ្លួននឹងធ្វើឲ្យកម្ពុជាមានជនជាតិតែមួយពោលគឺជនជាតិខ្មែរ ។ ទោះបីជាវៀតណាមគឺជាចំណែកធំមួយក្នុងការនាំឲ្យបដិវត្តន៍ខ្មែរក្រហមទទួលជោគជ័យក្នុងឆ្នាំ១៩៧៥ក្តី មេដឹកនាំខ្មែរក្រហមជាពិសេស ប៉ុល ពត បានចាត់ទុកវៀតណាមជាអ្នកឈ្លានពានដែលមានបំណងលេបយកទឹកដីខ្មែរជាយូរមកហើយ ។ នៅខែកញ្ញា ឆ្នាំ១៩៧៨ នាយកដ្ឋានព័ត៌មាននៃក្រសួងការបរទេសរបស់កម្ពុជាប្រជាធិបតេយ្យបានបោះពុម្ពផ្សាយ «សៀវភៅខ្មៅ ៖ ការពិតនិងភ័ស្តុតាងអំពីសកម្មភាពឈ្លានពានរបស់វៀតណាមប្រឆាំងនឹងកម្ពុជា» ។ សៀវភៅនេះចែកចេញជា៧ជំពូកនិងត្រូវបានសរសេរឡើងដោយ ប៉ុល ពត ដែលបានរៀបរាប់យ៉ាងលម្អិតអំពីផែនការរបស់វៀតណាមក្នុងការលេបទឹកដីខ្មែរ ។ មេដឹកនាំខ្មែរក្រហមមិនពេញចិត្តទាល់តែសោះ ចំពោះគំនិតបង្កើតសហព័ន្ធឥណ្ឌូចិនរបស់វៀតណាម ហើយបានចាត់ទុកវៀតណាមជាសត្រូវស្ងួនពូជរបស់ខ្លួន ។ ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យជនជាតិវៀតណាមត្រូវបានសម្លាប់រង្គាល ។ អ្នកទាំងឡាយណាដែលជាប់ខ្សែស្រឡាយ ឬមានទំនាក់ទំនងជាមួយវៀតណាមត្រូវបានសម្លាប់ ។ ជនបដិវត្តន៍កម្ពុជាមួយចំនួនដែលភៀសខ្លួនទៅវៀតណាមក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៥០ ហើយដែលបានវិលត្រឡប់មកវិញដើម្បីជួយបដិវត្តន៍ មិនទទួលបានការទុកចិត្តពីបក្សឡើយ ហើយថែមទាំងត្រូវបានបក្សមើលឃើញថាជាភ្នាក់ងារស៊ើបការណ៍សម្ងាត់របស់វៀតណាម និងត្រូវបានធ្វើវិសុទ្ធកម្មស្ទើរគ្មានសល់ ។ ជាពិសេស ប្រជាជននៅភូមិភាគបូព៌ាដែលត្រូវបានចោទប្រកាន់ថា «ក្បាលយួនខ្លួនខ្មែរ» ទទួលរងការកាប់សម្លាប់យ៉ាងរង្គាលក្នុងវិសុទ្ធកម្មឆ្នាំ១៩៧៧ ។ នៅចុងឆ្នាំ១៩៧៨ នួន ជា (អនុលេខាបក្សកុម្មុយនិស្តកម្ពុជា និងជាប្រធានសភាតំណាងប្រជាជនកម្ពុជារបស់កម្ពុជាប្រជាធិបតេយ្យ) បានផ្ញើសារទូរលេខមួយច្បាប់ឲ្យ ឌុច (ប្រធានមន្ទីរស-២១) ដោយ

បញ្ជាឲ្យ ឌុច សម្លាប់អ្នកទោសជាតិវៀតណាមប្រមាណជាង ៣០០នាក់ដែលជាប់ឃុំក្នុងមន្ទីរស-២១ ។ ក្រៅពីការកាប់សម្លាប់ជនជាតិចាមនិងជនជាតិវៀតណាម ខ្មែរក្រហមក៏បានធ្វើការវាយប្រហារយ៉ាងខ្លាំងក្លាទៅលើក្រុមព្រះសង្ឃ កាន់ព្រះពុទ្ធសាសនា ដោយបង្ខំឲ្យព្រះសង្ឃលាចាកសិក្ខាបទនិងបញ្ជូនឲ្យទៅធ្វើស្រែចម្ការដូចប្រជាជនធម្មតា ។ ជាងនេះទៅទៀត ខ្មែរក្រហមបានដុតបំផ្លាញនិងប្រែក្លាយវត្តអារាមទៅជាគុក មន្ទីរសម្លាប់មនុស្ស និងកន្លែងចិញ្ចឹមសត្វ ។

ទោះបីជាយ៉ាងណា ប្រវត្តិវិទូនិងអ្នកជំនាញខាងការសិក្សាពីអំពើប្រល័យពូជសាសន៍មួយចំនួនទៀតយល់ឃើញផ្ទុយពីនេះ ។ អ្នកទាំងនេះបានអះអាងថា ការសម្លាប់រង្គាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យមិនមែនជាអំពើប្រល័យពូជសាសន៍ទេ ។ ខ្មែរក្រហមមិនមានផែនការលុបបំបាត់ពូជសាសន៍ណាមួយឡើយ ព្រោះថាភាគច្រើននៃជនរងគ្រោះគឺជាជនជាតិខ្មែរ ហើយខ្មែរក្រហមខ្លួនឯងក៏ជាជនជាតិខ្មែរដែរ ។ ជាងនេះទៅទៀត ការកាប់សម្លាប់និងការធ្វើទុក្ខបុកម្នេញទាំងឡាយត្រូវបានចាត់ទុកថា ជាការបង្ក្រាបផ្នែកនយោបាយ ដែលរដ្ឋាភិបាលមួយនៅក្នុងស្ថានភាពសង្គ្រាមនិងចលាចលបែបនេះចាំបាច់ត្រូវតែធ្វើដើម្បីរក្សាស្ថិរភាពនយោបាយនិងសន្តិសុខនៅក្នុងប្រទេស ។

ប្រវត្តិវិទូ មៃឃើល វិកឃើរី បានអះអាងថា មកទល់ឆ្នាំ ១៩៧៥ មានជនជាតិវៀតណាមមួយចំនួនតូចប៉ុណ្ណោះដែលបានបន្តរស់នៅក្នុងប្រទេសកម្ពុជា ។ លោកអះអាងបន្តថា ការសម្លាប់ជនជាតិវៀតណាមទាំងនេះមិនអាចវិនិច្ឆ័យបានថា ខ្មែរក្រហមមានបំណងលុបបំបាត់ពូជសាសន៍វៀតណាមនោះទេ ។ លោកបានសន្និដ្ឋានថា ការសម្លាប់រង្គាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺបណ្តាលមកពីបរាជ័យនៃប្រព័ន្ធរដ្ឋាភិបាលក្នុងការគ្រប់គ្រងប្រទេសនិងអ្នកនៅក្រោមបង្គាប់ ។ វិកឃើរី បានរិះគន់ការកំណត់ចំនួនតួលេខមនុស្សស្លាប់របស់ប្រវត្តិវិទូនិងអ្នកស្រាវជ្រាវមួយចំនួនថា មានចំនួនច្រើនលើសលប់ ។ លោកបានកំណត់យកចំនួនតួលេខប្រជាជនកម្ពុជាស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យតែជាង៧សែននាក់ប៉ុណ្ណោះ ។ រដ្ឋាភិបាលសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលបានស្រង់ស្ថិតិប្រជាជនទូទាំងប្រទេស បានអះអាងថា ប្រជាជនកម្ពុជាជាង៣លាន៣សែននាក់បានស្លាប់បាត់បង់ជីវិត ។ ប្រវត្តិវិទូ ប៉ែន យៀវនិន តាមរយៈបទសម្ភាសន៍ជាមួយប្រជាជន៥០០នាក់ បានសន្និដ្ឋានថាមនុស្សប្រមាណ ១លាន៧សែននាក់បានស្លាប់ ។ ចំណែកលោក គ្រេក អេចឆេសាន់ តាមរយៈការស្រាវជ្រាវរណ្តៅសាកសពនៅទូទាំងប្រទេស បានកំណត់យកតួលេខ២លាន២សែននាក់ ។ ទោះជាយ៉ាងនេះក្តី មិនមានអ្នកស្រាវជ្រាវណាមួយអាចកំណត់ឲ្យបានច្បាស់លាស់ទៅលើចំនួនប្រជាជនកម្ពុជា ដែលបានស្លាប់ក្នុងរបបកម្ពុជាប្រជាធិបតេយ្យនៅឡើយទេ ។

ផ្ទុយពីការអះអាងទាំងពីរខាងលើ អាចារ្យសាសនាគ្រិស្តជាតិបារាំង ហ្វ្រង់ស័រ ប៉ុងសូ ដែលបានរស់នៅប្រទេសកម្ពុជារហូតដល់ថ្ងៃដែលខ្មែរក្រហមកាន់កាប់ទីក្រុងភ្នំពេញ បានហៅការសម្លាប់រង្គាលនៅកម្ពុជាចន្លោះឆ្នាំ១៩៧៥ - ១៩៧៩ថា "ជាការប្រល័យពូជសាសន៍ឯង" ។ យ៉ាងណាមិញ ពាក្យសព្ទនេះមិនស្ថិតក្នុងនិយមន័យនៃអំពើប្រល័យពូជសាសន៍ ដែលកំណត់ដោយដោយអនុសញ្ញាអន្តរជាតិទេ ។

អំពើប្រល័យពូជសាសន៍នៅកម្ពុជាត្រូវបានប្រព្រឹត្តឡើងក្នុងគោលបំណងអនុវត្តគោលនយោបាយជាតិតាមលទ្ធិម៉ាក្សលេនីន និងលទ្ធិម៉ៅនិយម ដែលមេដឹកនាំជាន់ខ្ពស់បក្សកុម្មុយនិស្តកម្ពុជាជាច្រើនរូបដូចជា ប៉ុល ពត, ខៀវ សំផន, អៀង សារី សុន សេន ទទួលបានក្នុងរយៈពេលនៃការស្នាក់អាស្រ័យរៀនសូត្រនៅប្រទេសបារាំង ។ អ្នកទាំងអស់បានចូលជាសមាជិកបក្សកុម្មុយនិស្តបារាំង ហើយបានសិក្សារៀនសូត្រនិងផ្សារភ្ជាប់ជីវិតនយោបាយរបស់ខ្លួនទៅនឹងលទ្ធិកុម្មុយនិស្ត ។

ក្រៅពីការដឹកនាំប្រទេសតាមបែបកុម្មុយនិស្ត មេដឹកនាំខ្មែរក្រហមបានតាំងចិត្តធ្វើការផ្លាស់ប្តូរសង្គមកម្ពុជាពីសង្គមអភិជននាយទុន សង្គមរបស់វណ្ណៈគហបតី និងសង្គមមូលធននិយមទៅជាសង្គមកសិករនិងកម្មករដែលជាសង្គមមួយស្អាតស្អំប្រកបដោយសច្ចធម៌ យុត្តិធម៌ និងសមភាព ។ ជាងនេះទៅទៀត មេដឹកនាំខ្មែរក្រហមដឹកនាំប្រទេសដោយយកចំណុចអសកម្មមួយចំនួនក្នុងប្រវត្តិសាស្ត្រខ្មែរមកធ្វើជាមូលដ្ឋានក្នុងការបង្កើតជំនឿ ទ្រឹស្តីនិងមាគ៌ានយោបាយ ហើយដាក់ឲ្យប្រជាជនទូទាំងប្រទេសអនុវត្ត

តាម ។ ប៉ុល ពត យល់ឃើញថាតាំងពីការកកើតទីកដីមក កម្ពុជា មិនដែលមានឯករាជ្យបរិបូណ៌ ហើយប្រជាជនខ្មែរភាគច្រើន ដែលជាកសិករក្រីក្រនិងកម្មករតែងតែត្រូវបានជិះជាន់សង្កត់សង្កិន និងកេងប្រវ័ញ្ចពីសំណាក់អ្នកមានអំណាចនិងពួកអភិជននាយទុន ។ ប្រវត្តិវិទូ អេឡិច ហ៊ិនតុន បានអះអាងថា ក្នុងទសវត្សរ៍ឆ្នាំ១៩៥០ ដីស្រែប្រមាណ៩០ភាគរយនៅស្រុកថ្មគោល ខេត្តបាត់ដំបង ត្រូវបានកាន់កាប់ដោយម្ចាស់ដីនិងនាយទុនធំៗ ។ កសិករក្រីក្រ និងអ្នកគ្មានដីធ្វើស្រែចម្ការកាន់តែមានចំនួនច្រើនឡើង ។ ប៉ុល ពត បានសន្និដ្ឋានថា បញ្ហាបែបនេះកើតមានឡើងនៅគ្រប់ទីកន្លែងទាំងអស់ក្នុងផ្ទៃប្រទេស ។ រហូតមកដល់ឆ្នាំ ១៩៦៧ ប្រជាជននៅស្រុកសំឡូត បានធ្វើការបះបោរប្រឆាំងទល់នឹងគោលនយោបាយរបស់រដ្ឋាភិបាលក្នុងការប្រមូលទិញស្រូវពីប្រជាជនក្នុងតម្លៃថោកជាងតម្លៃទីផ្សារ ។ ហេតុការណ៍នេះបានបណ្តាលឲ្យមានការបង្ក្រាបយ៉ាងធ្ងន់ធ្ងរទៅលើប្រជាកសិករក្រីក្រ ។ តាមការអះអាងរបស់ប្រវត្តិវិទូ ហ៊ីនតុន ព្រឹត្តិការណ៍នេះបានធ្វើឲ្យមេដឹកនាំខ្មែរក្រហម ជាពិសេស ប៉ុល ពត យល់ឃើញថា ការតស៊ូប្រដាប់អាវុធត្រូវតែចាប់ផ្តើមដើម្បីរំដោះប្រទេស និងប្រជាជនឲ្យចាកផុតពីអំពើពុករលួយនិងការកេងប្រវ័ញ្ច ។

ប៉ុល ពត មានគំនិតស្រមើស្រមៃចង់កសាងកម្ពុជាមួយដែលប្រជាជនរស់នៅ ហូបចុក ស្លៀកពាក់ និងបំពេញការងារស្មើៗគ្នា ពោលគឺគ្មានអ្នកមានគ្មានអ្នកក្រ ។ មេដឹកនាំខ្មែរក្រហមបានចាត់ទុកការអនុវត្តតាមទ្រឹស្តីរបស់ខ្លួនថាមានសារសំខាន់ខ្លាំងណាស់ក្នុងការរំដោះប្រជាជនកម្ពុជាទូទាំងប្រទេសចេញពីភាពខ្ញុំគេ ហើយថាការគោរពតាមមាគ៌ានិងលក្ខន្តិកៈរបស់បក្សឲ្យបានខ្ជាប់ខ្ជួន គឺជាមធ្យោបាយតែមួយគត់ដែលកម្ពុជាអាចរំដោះខ្លួនចេញពីនឹមអាណានិគមនិងចាកផុតពីឥទ្ធិពលរបស់ចក្រពត្តិនិយម ។ អេឡិច ហ៊ិនតុន បានអះអាងថា មេដឹកនាំខ្មែរក្រហមបានចាត់ទុកទ្រឹស្តីថ្មីរបស់ខ្លួនថាមានលក្ខណៈប្រាកដនិយមជាងការត្រាស់ដឹងរបស់ព្រះសមណគោតមទៅទៀត ។ មេដឹកនាំទាំងនេះបានចាត់ទុកទ្រឹស្តីពុទ្ធសាសនាក៏ដូចជាលទ្ធិសាសនាដទៃទៀតថាជាគ្រឿងស្រវឹងនិងជាគ្រឿងបំពុលខួរក្បាលមនុស្ស ។ ដើម្បីសម្រេចឲ្យបាននូវផែនការនេះ និងដើម្បីពង្រឹងមនោគមវិជ្ជាកុម្មុយនិស្ត ក៏ដូចជាជំនឿបែបអត្តនោម័តិនិយម មេដឹកនាំខ្មែរក្រហមបានអនុវត្តនយោបាយចង្អៀតចង្អល់និយមជ្រុលហួសហេតុមួយដែលខ្លួនយល់ថាត្រឹមត្រូវ

ពីឆ្វេងទៅស្តាំ : វន វេ៉ត, អៀង សារី, នួន ជា, ខៀវ សំផន, ទួន ប្រាសិទ្ធ
ក្នុងការទទួលស្វាគមន៍គណៈប្រតិភូរជនជាតិចិននៅឯព្រលានយន្តហោះអន្តរជាតិពោចិនតុង រាជធានីភ្នំពេញ ឆ្នាំ១៩៧៧



និងក្តីស្មានអស្ចារ្យជាងពេលណាៗទាំងអស់ក្នុងប្រវត្តិសាស្ត្រកម្ពុជាជិតពីរពាន់ឆ្នាំកន្លងមកនេះ ។ ដូច្នេះ ប្រជាជនណាដែលប្រឆាំងជំទាស់ ឬបង្ហាញការមិនពេញចិត្តចំពោះគោលនយោបាយទាំងនេះត្រូវបានចាត់ទុកថាជាខ្មាំង ជាជនក្បត់ជាតិ ឬជាជនក្បត់បដិវត្តន៍ ។ ជនប្រភេទនេះត្រូវតែកម្ទេចចោលជាដាច់ខាតដើម្បីឲ្យការអនុវត្តទ្រឹស្តីនិងគោលការណ៍ទាំងឡាយរបស់បក្សដំណើរការទៅមុខដោយជោគជ័យ ។

នយោបាយកម្ទេចខ្មាំងបង្កប់ស៊ីរូងផ្ទៃក្នុង ការបោសសម្អាតសមាសភាពមិនល្អ សហករណ៍ភាវូបនីយកម្ម និងការតស៊ូវណ្ណៈបានក្លាយទៅជាគោលការណ៍ដ៏សំខាន់សម្រាប់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យក្នុងការកសាងកម្ពុជាមួយស្អាតស្អំ ឯករាជ្យ

ម្ចាស់ការខ្លួនទីពឹងខ្លួន ។ មេដឹកនាំខ្មែរក្រហមបាននិយាយអួតអាងថា ខ្លួននឹងធ្វើឲ្យប្រទេសកម្ពុជារុងរឿងជាងសម័យអង្គរទៅទៀត ។ អ្នកទាំងនេះយល់ឃើញថា វិធីតែមួយគត់ដើម្បីសម្រេចឲ្យបាននូវផែនការនេះគឺត្រូវទាញកង់ប្រវត្តិសាស្ត្រកម្ពុជាថយក្រោយដោយចាប់ផ្តើមកសាងជាតិពីចំណុចសូន្យឡើងទៅ ។ ក្នុងន័យនេះ អ្វីដែលមានលក្ខណៈបរទេស និងអ្វីដែលខ្លួនយល់ថាជាគំរូមិនល្អពីរបបមុនៗត្រូវបានកម្ទេចចោលទាំងអស់ ។ និស្សិត បញ្ញវន្ត អ្នកបច្ចេកទេស គ្រូបង្រៀន វេជ្ជបណ្ឌិត អ្នករដ្ឋការ ត្រូវបានមេដឹកនាំខ្មែរក្រហមចាត់ទុកថាជាមនុស្សដែលធ្លាប់ទទួលឥទ្ធិពលអាក្រក់ពីបរទេស ។ អ្នកទាំងនេះត្រូវបានមើលឃើញថាជាជំពូកជនពុករលួយនិងជាអ្នកដែលបង្កឲ្យមានអំពើអយុត្តិធម៌ក្នុងសង្គម ។ ក្រោយជ័យជម្នះ ១៧ មេសា ១៩៧៥មក អ្នកទាំងអស់នេះមួយចំនួនត្រូវបានប្រហារជីវិតភ្លាមៗ ។ មួយចំនួនទៀតត្រូវបានបញ្ជូនឲ្យទៅធ្វើស្រែចម្ការនៅទីជនបទ ដូចពាក្យស្លោកមួយលើកឡើងថា "ពួកបច្ចេកទេសត្រូវជម្លៀសចូលព្រៃ កសាងជីវភាពពីបាតដៃទទេ" ។ ខ្មែរក្រហមបានយកកសិករក្រីក្រដែលខ្លួនអះអាងថា ជាប្រភពធនធាននិងជាប្រភពចំណេះវិជ្ជាគ្រប់បែបយ៉ាងទាំងអស់របស់កម្ពុជាប្រជាធិបតេយ្យឲ្យមកកាន់តំណែងថ្នាក់ដឹកនាំនៅគ្រប់តំបន់ទាំងអស់ក្នុងប្រទេស ។ មានតែមេដឹកនាំជាន់ខ្ពស់របស់បក្សប៉ុន្មាននាក់ប៉ុណ្ណោះដែលទទួលបានសញ្ញាប័ត្រខ្ពស់ៗពីបរទេស ។

តាមការស្រាវជ្រាវរបស់សាស្ត្រាចារ្យ ហ្វ្រែង ឆក នយោបាយបដិវត្តន៍របស់ខ្មែរក្រហមមានលក្ខណៈសាហាវឃោរឃៅជាងនយោបាយបដិវត្តន៍របស់ចិននិងវៀតណាម ។ ចិន និងវៀតណាមជាញឹកញយព្យាយាមអប់រំបញ្ចុះបញ្ចូលចំណាប់ខ្មាំងនិងប្រជាជនឲ្យចូលរួមក្នុងដំណើរការបដិវត្តន៍របស់ខ្លួន ។ ផ្ទុយទៅវិញ ការលើកលែងទោសចំពោះខ្មាំងសត្រូវនិងសូម្បីតែចំពោះប្រជាជនសាមញ្ញដែលបានប្រព្រឹត្តកំហុសបន្តិចបន្តួច គឺជារឿងមួយដែលមេដឹកនាំខ្មែរក្រហមមិនអាចទទួលយកបានជាដាច់ខាត ។ ការរិះគន់ចំពោះគោលនយោបាយរបស់បក្សការត្អូញត្អែរចំពោះកិច្ចការដែលបក្សឲ្យធ្វើ ឬការធ្វេសប្រហែសបន្តិចបន្តួចត្រូវបានចាត់ទុកថាជាទង្វើប្រឆាំងនឹងអង្គការ ដែលជាទោសកំហុសមិនអាចលើកលែងឲ្យបាន ។ ខ្មែរក្រហមបានលើកពាក្យស្លោកមួយចំនួននិយាយថា "បើដំទាស់នឹងផែនការបក្ស ខុសដៃយកដៃ ខុសជើងយកជើង ។ សម្លាប់ច្រឡំអ្នកដែលគ្មានទោសកំហុសម្នាក់ជាជាងទុកឲ្យសល់ខ្មាំងសត្រូវម្នាក់" ។

ការសម្លាប់រង្គាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានអ្នកស្រាវជ្រាវភាគច្រើនមើលឃើញថាគឺជាអំពើព្រៃផ្សៃ និងជាការរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរបំផុតមួយក្នុងសតវត្សរ៍ទី២០នេះ ។ ដើម្បីសម្រេចឲ្យបាននូវគំនិតជ្រុលនិយមនិងនយោបាយផ្សងព្រេងរបស់ខ្លួន មេដឹកនាំខ្មែរក្រហមមិនបានខ្វល់ខ្វាយពីការរស់នៅនិងសុខុមាលភាពរបស់ប្រជាជនទេ ។ មេដឹកនាំខ្មែរក្រហមបានបង្កើតរបបមួយដែលបានប្រែក្លាយប្រទេសកម្ពុជាទៅជាជំរំពលកម្ម ជំរំធ្វើទារុណកម្ម និងជំរំសម្លាប់មនុស្ស ។ និយាយម្យ៉ាងទៀត មេដឹកនាំខ្មែរក្រហមបានប្រែក្លាយកម្ពុជាឲ្យទៅជាវាលស្រែដ៏ធំមួយ និងបានប្រែក្លាយប្រជាជនកម្ពុជាទាំងអស់ឲ្យទៅជាទាសកររបស់សង្គម ។ ប្រជាជនគ្រប់រូបត្រូវតែលះបង់ចោលអ្វីៗគ្រប់បែបយ៉ាង សូម្បីតែជីវិតរបស់ខ្លួនដើម្បីបម្រើ និងដើរតាមមនោគមវិជ្ជានិងទ្រឹស្តីរបស់មេដឹកនាំខ្មែរក្រហម ។

ជាលទ្ធផលនៃការអនុវត្តមនោគមវិជ្ជានិងទ្រឹស្តីជ្រុលនិយមទាំងនេះ ប្រទេសទាំងមូលត្រូវខ្ទេចខ្ទាំស្ទើរគ្មានសល់ ។ ប្រជាជនខ្មែរទាំងអស់ទទួលរងផលប៉ះពាល់យ៉ាងខ្លាំងទាំងផ្លូវកាយនិងផ្លូវចិត្ត ។ គ្រួសារនីមួយៗយ៉ាងហោចណាស់ក៏មានសមាជិកម្នាក់ស្លាប់ឬបាត់ខ្លួនដែរ ។ ហេដ្ឋារចនាសម្ព័ន្ធជាតិត្រូវបានបំផ្លិចបំផ្លាញស្ទើរគ្មានសល់ ។ ស្ត្រីរាប់ម៉ឺននាក់បានក្លាយជាស្ត្រីមេម៉ាយ ។ កុមាររាប់សែននាក់ក្លាយជាកុមារកំព្រា ។ ប្រជាជនកម្ពុជារាប់សែននាក់ផ្សេងទៀតបានរត់ចេញពីមាតុភូមិទៅជ្រកកោននៅបរទេស ហើយបានក្លាយខ្លួនទៅជាជនភៀសខ្លួន ។ ប្រជាជនកម្ពុជារាប់សិបពាន់នាក់មានជំងឺផ្លូវចិត្តដោយសារតែបទពិសោធន៍ដែលខ្លួនជួបប្រទះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទាំងអស់នេះសុទ្ធតែជាមរតកដែលបន្សល់ទុកពីការអនុវត្តនយោបាយតាមបែបម៉ាក្ស-លេនីននិងម៉ៅនិយម និងទ្រឹស្តីដ៏មហាភ្ញាក់ស្មាងរបស់មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ។

**ឌី ខាំបូលី**

# ក្រុមគ្រួសាររបស់ មឿង ផាន

មឿង ផាន នៅជាក្មេងជំទង់នៅឡើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ប៉ុន្តែ ផាន អាចចាំបាននូវព្រឹត្តិការណ៍ដែលខ្មែរក្រហមប្រព្រឹត្តមកលើបងប្រុសពីរនាក់របស់គាត់ដែលត្រូវខ្មែរក្រហមសម្លាប់យ៉ាងព្រៃផ្សៃ ។ ខាងក្រោមនេះគឺជាការរៀបរាប់របស់ ផាន អំពីបទពិសោធន៍ដែលគាត់បានជួបប្រទះក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ៖

«ខ្ញុំរៀបការជាមួយ វ៉ឹង ក្នុងឆ្នាំ១៩៩២ នៅក្នុងភូមិខ្ពប ស្រុកឈូក ខេត្តកំពត ។ ប្តីរបស់ខ្ញុំពិការជើងម្ខាងដោយសារគ្រាប់មីនកាលពីសម័យតស៊ូ នៅក្នុងព្រៃ ។ សព្វថ្ងៃខ្ញុំនិងគ្រួសារប្រកបរបរធ្វើស្រែចម្ការ ។ ខ្ញុំមានកូន៥នាក់ តែកូនទីពីររបស់ខ្ញុំស្លាប់ដោយសារជំងឺគ្រុនឈាម ។ ឪពុកខ្ញុំឈ្មោះ យិន ស្លាប់តាំងពីខ្ញុំនៅក្មេង ។ ម្តាយខ្ញុំឈ្មោះ ភី ស្លាប់ដោយសារជំងឺក្រោយពេលរបបខ្មែរក្រហមដួលរលំ គឺក្នុងខណៈពេលដែលក្រុមគ្រួសារ ខ្ញុំនាំគ្នាភៀសខ្លួនទៅរស់នៅក្នុងព្រៃក្នុងខេត្តពោធិសាត់ ។ ក្នុងចំណោមបងប្អូន៥នាក់ (ស្រីបីនាក់ ប្រុសពីរនាក់) ខ្ញុំគឺជាកូនទីបួន ។ មានតែខ្ញុំនិងបងស្រីខ្ញុំប៉ុណ្ណោះដែលនៅរស់រានមានជីវិតដល់ពេលបច្ចុប្បន្ន ។ បងស្រីម្នាក់ទៀតស្លាប់នៅពេលឆ្លងទន្លេ ហើយបងប្រុសពីរនាក់ទៀតត្រូវខ្មែរក្រហមសម្លាប់ ។


មឿង ផាន និងកូន

ក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ខ្ញុំជាក្មេងជំទង់នៅឡើយ ។ ប៉ុន្តែខ្ញុំអាចចាំបានពីព្រឹត្តិការណ៍និងហេតុការណ៍ជាច្រើនដែលធ្វើឲ្យខ្ញុំមិនអាចបំភ្លេចបានឡើយ ។ ក្របីទាំង៨ក្បាលរបស់ក្រុមគ្រួសារខ្ញុំត្រូវប្រមូលដាក់ជាកម្មសិទ្ធិរួម ។ ខ្ញុំនៅចាំបានថា ប៉ុន្តែខ្មែរក្រហមបានចាប់ផ្តើមបង្កើតសហករណ៍និងកងជាច្រើន ។ នៅពេលនោះខ្ញុំមិនទាន់ត្រូវបញ្ចូលឲ្យធ្វើការនៅក្នុងកងកុមារនៅឡើយទេ ។ រឿងដែលនឹកស្មានមិនដល់នោះគឺ នៅក្នុងឆ្នាំ១៩៧៨ ខ្មែរក្រហមបានចាប់ឪពុកម្តាយ បងប្អូនខ្ញុំ និងខ្ញុំដាក់នៅក្នុងគុកភ្នំម្លូរយៈពេល៦ខែ ដោយចោទថា ជាក្រុមចោរព្រៃ ។ យើងមិនដឹងខ្លួនថាបានប្រព្រឹត្តអ្វីខុសឡើយ ។ ក្រៅពីដេកនៅក្នុងគុកដូចជាសត្វពាហនៈ ខ្ញុំត្រូវធ្វើការផ្សេងៗទៀតដូចជាដាំដំឡូង និងសណ្តែកដីជាដើម ។ យប់ឡើងទើបខ្មែរក្រហមបញ្ជូនខ្ញុំឲ្យមកដេកនៅក្នុងគុកដែលមានរបងព័ទ្ធជុំវិញប្រៀបដូចជា ក្រោលគោ ។ ដោយសារតែខ្ញុំនៅតូច ខ្មែរក្រហមមិនបានដាក់ខ្នោះខ្ញុំឡើយ ។ ចំណែកអ្នកផ្សេងៗទៀត ត្រូវជាប់ខ្នោះច្រវាក់ទាំងអស់ ។ ប្រសិនបើខ្មែរក្រហមនិយាយថា «អាចទៅផ្ទះបាន ហើយអង្គការនឹងដាំបាយសម្លឲ្យហូប ឬបាយស្រួយ» មានន័យថា ខ្មែរក្រហមនឹងយកអ្នកទាំងនោះ ទៅវាយចោលនៅមន្ទីរគាលាន់ ឬនៅភ្នំម្លូមិនខាន ។

នៅពេលខ្ញុំត្រូវបានដោះលែងពីគុកភ្នំម្លូ ខ្ញុំដើរសំដៅមកក្នុងភូមិវិញ ។ ខ្ញុំដើរសសៀរក្បែរមន្ទីរឈ្លប ស្រាប់តែខ្ញុំឮពួកឈ្លបនិយាយថា «យីវ៉េយ ៤-១០នាក់ ក្បាលរឹងជាងគេ លើកលែងតែ អាសាម ម្នាក់» ។ ខ្មែរក្រហមនិយាយថា ពួកវាវាយ បងសាម ពីរថ្ងៃ ហើយតែមិនស្លាប់ ។ កងទ័ពទាំងនេះសង្ស័យថា គាត់មានគ្រូកាន់ ព្រោះគាត់មានសក់កណ្តាញ់ ។ ដូច្នេះខ្មែរក្រហមសម្លាប់គាត់ ដោយកន្ត្រាក់លិង្គរបស់គាត់ឲ្យស្លាប់តែម្តង ។ ការពិតបងរបស់ខ្ញុំ មានសក់កណ្តាញ់និងមានគ្រូកាន់មែន ។ នៅពេលខ្ញុំមកដល់ផ្ទះ ខ្ញុំបាននិយាយប្រាប់ម្តាយ

របស់ខ្ញុំពីការស្លាប់របស់ បងសាម ។ ម្តាយខ្ញុំយំអាណិតបងប្រុសខ្ញុំខ្លោចចិត្តតែគាត់មិនហ៊ានយំឲ្យគេឮឡើយ ។ គាត់ចង់ធ្វើបុណ្យឧទ្ទិសជូនបងរបស់ខ្ញុំណាស់ ប៉ុន្តែយើងគ្មានសិទ្ធិធ្វើបុណ្យសពតាមប្រពៃណីខ្មែរបានឡើយ ។ ចំណែកឯបងប្រុសរបស់ខ្ញុំម្នាក់ទៀតក៏ត្រូវខ្មែរក្រហមសម្លាប់ស្របាលពេលនឹង បងសាម ដែរ ។ អ្នកភូមិបាននិយាយថា បងប្រុសខ្ញុំត្រូវយុទ្ធជនខ្មែរក្រហមចាប់ចងនៅខាងត្បូងដើមចំបក់ខាងលិចភូមិត្រពាំងរុន ។ បងប្រុសរបស់ខ្ញុំទាំងពីរនាក់មិនដែលធ្វើទាហានអ្វីឡើយ ។ ខ្មែរក្រហមបានចោទគាត់ថាជាក្រុម «ចោរព្រៃ» ។

ក្រោយពីការបាត់បង់ជីវិតរបស់បងប្រុសខ្ញុំទាំងពីរ អង្គការចាប់ផ្តើមជ្រើសរើសក្មេងជំទង់ៗក្នុងមួយភូមិៗ ៤-៥នាក់ដែលមានអាយុចាប់ពី១៥ឆ្នាំឡើងទៅដើម្បីទៅលើកទំនប់កោះស្លា ។ ខ្ញុំមិនទាន់ត្រូវបានជ្រើសរើសទេ ដោយសារខ្ញុំមិនទាន់គ្រប់អាយុ ប៉ុន្តែពីរឆ្នាំបន្ទាប់មក អង្គការក៏បញ្ជូនខ្ញុំឲ្យទៅលើកទំនប់ជាមួយគេដែរ ។ ខ្ញុំត្រូវចេញទៅធ្វើការពីម៉ោង៥កន្លះព្រឹករហូតដល់ម៉ោង១១ព្រឹក ពីម៉ោង១រសៀលដល់ម៉ោង៥រសៀល និងពីម៉ោង៧ដល់ម៉ោង៨យប់ ។ ពេលខ្លះទំនប់កោះស្លាបាក់ដី ដូច្នេះប្រជាជនទាំងអស់ត្រូវធ្វើការរហូតដល់ម៉ោង១រំលងអធ្រាត្រក៏មាន ។

មានថ្ងៃមួយខ្ញុំធ្លាក់ខ្លួនឈឺ ។ ខ្ញុំទៅសម្រាកនៅឯមន្ទីរពេទ្យ ។ ថ្ងៃមួយខ្ញុំបានឃើញហេតុការណ៍មួយគួរឲ្យរន្ធត់ ។ តាមសំយាបបង្អួចមន្ទីរពេទ្យ ខ្ញុំឃើញខ្មែរក្រហមយួរថ្លើមមនុស្សស្រស់ៗ ។ ចៅហ្វាយស្រុកឈ្មោះ តាឃុំ ដែលជាប្រធានទំនប់កោះស្លាគំរាមខ្ញុំមិនឲ្យមើលឡើយ ។ តាំងពីខ្ញុំចាប់ផ្តើមធ្វើការលើកទំនប់កោះស្លានិងធ្វើការនៅក្នុងកងចល័ត ខ្ញុំមិនដែលប្រឆាំងនឹងបញ្ជារបស់អង្គការឡើយ ។ ខ្ញុំតែងតែខិតខំធ្វើការជានិច្ច ហើយមិនដែលធ្វើអ្វីខុសមួយទាល់តែសោះ ។

ក្រោយពីលើកទំនប់កោះស្លា ខ្ញុំត្រូវអង្គការចាត់តាំងឲ្យទៅស្នងនៅឯកងចល័តវិញ ។ ការងារនៅកងចល័តមានលក្ខណៈប្រសើរជាងមុន ដោយសារតែប្រធានឃុំកោះតូចជាមនុស្សចិត្តធម៌ ។ ប្រជាជនត្រូវបានបែងចែកឲ្យទៅធ្វើការតាមកន្លែងផ្សេងៗពីគ្នា ។

នៅក្នុងរយៈពេលបីឆ្នាំកត់នៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្ញុំមិនដែលឃើញមុខម្តាយខ្ញុំឡើយ ហើយខ្ញុំសប្បាយចិត្តណាស់នៅពេលដែលរបបនេះបានកន្លងផុតទៅ ។

ទោះបីជាខ្ញុំមិនបាននិយាយប្រាប់កូនចៅខ្ញុំអំពីហេតុការណ៍នៅសម័យនោះឲ្យបានក្បោះក្បាយក៏ដោយ ប៉ុន្តែខ្ញុំតែងរំពឹកកូនៗរបស់ខ្ញុំឲ្យខិតខំធ្វើការងារស្រែចម្ការនិងការងារផ្ទះដើម្បីជាប្រយោជន៍ដល់ខ្លួនផ្ទាល់និងក្រុមគ្រួសារទាំងមូល ។ វាខុសពីសម័យខ្មែរក្រហមដែលខ្ញុំធ្វើការស្ទើរស្លាប់ស្ទើររស់ ប៉ុន្តែលទ្ធផលផ្លែផ្កាបានតែទៅលើអង្គការមួយប៉ុណ្ណោះ ។

**នន ឧត្តតារា**

# ស្តាប់រឿងរ៉ាវប្រវត្តិសាស្ត្រតាមវិទ្យុ

មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្កើតឲ្យមានកម្មវិធីអានអត្ថបទទស្សនាវដ្តីស្វែងរកការពិតនិងសៀវភៅផ្សេងទៀតដែលបោះពុម្ពដោយមជ្ឈមណ្ឌលឯកសារកម្ពុជាផ្សាយតាមវិទ្យុមួយចំនួនដូចតទៅ ÷

- វិទ្យុ FM១០២MHz របស់មណ្ឌលព័ត៌មានស្ត្រីកម្ពុជា រៀងរាល់ថ្ងៃពុធនិងព្រហស្បតិ៍ វេលាម៉ោង ៧ៈ៣០-៧ៈ៤៥ល្ងាច ។
- វិទ្យុ FM៩៣.២៥MHz ខេត្តកំពត រៀងរាល់ថ្ងៃនៅម៉ោង៧-៧ៈ៣០ព្រឹក និងម៉ោង៧ៈ០០-៧ៈ៣០ល្ងាច ។
- វិទ្យុ FM៩៩MHz ខេត្តព្រះវិហារ រៀងរាល់ថ្ងៃនៅម៉ោង៧ៈ០០-៧ៈ៣០ព្រឹក និងម៉ោង៦ៈ៣០-៧ៈ០០ល្ងាច ។
- វិទ្យុ FM១០៣.២៥MHz ខេត្តបាត់ដំបង រៀងរាល់ថ្ងៃនៅម៉ោង៩ៈ០០-៩ៈ៣០ព្រឹក និងម៉ោង៣ៈ០០-៣ៈ៣០រសៀល ។

នៅក្នុងពេលដ៏ខ្លីខាងមុខនេះមជ្ឈមណ្ឌលយើងនឹងពង្រីកការផ្សព្វផ្សាយនៅវិទ្យុខេត្តសៀមរាបទៀត ។

យើងខ្ញុំសង្ឃឹមថា កម្មវិធីនេះនឹងចូលរួមចំណែកក្នុងការផ្តល់ឱកាសឲ្យប្រជាជនកម្ពុជាស្វែងយល់អំពីប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមបានកាន់តែប្រសើរឡើង និងទប់ស្កាត់ការកើតមានឡើងវិញនៃរបបនេះ ។

**ឡាត់ សោភ័ណ និង ឡេង រតនៈ**

# ការសងសឹកមិនមែនជាដំណោះស្រាយ

ប៉ាន់ ជាកូនទីពីរក្នុងចំណោមបងប្អូន៦នាក់ ដែលមានស្រុកកំណើតនៅភូមិកំពង់ស្រឡៅ ឃុំរមណីយ៍ ស្រុករវៀង ខេត្តព្រះវិហារ ។ ឪពុករបស់ប៉ាន់ ឈ្មោះ សៅ នុត ស្លាប់ក្នុងរបបខ្មែរក្រហម និងម្តាយឈ្មោះ សុខ កែវ រស់នៅក្នុងខេត្តព្រះវិហារ ។ សព្វថ្ងៃ ប៉ាន់ មានអាយុ៤៤ឆ្នាំ រស់នៅស្រុកស្ទឹងត្រែង ខេត្តស្ទឹងត្រែង ។ ទោះបីរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំអស់រយៈពេលជិត៣០ឆ្នាំហើយក៏ដោយ ក៏ នុត ប៉ាន់ នៅចាំជានិច្ចពីព្រឹត្តិការណ៍ដែលឈ្លបខ្មែរក្រហមយកឪពុករបស់គាត់ទៅសម្លាប់ និងការដែលខ្មែរក្រហមធ្វើទុក្ខបុកម្នេញមកលើរូបគាត់និងក្រុមគ្រួសារ ។ រឿងនេះហាក់ដូចជានៅថ្មីៗនៅឡើយសម្រាប់ ប៉ាន់ ។



នុត ប៉ាន់

ពេលកងទ័ពខ្មែរក្រហមចូលកាន់កាប់ភូមិកំណើតនៅឆ្នាំ១៩៧៥ ប៉ាន់ ទើបតែអាយុ១៣ឆ្នាំប៉ុណ្ណោះ ។ ប៉ាន់ នៅជួយឪពុកម្តាយធ្វើស្រែចម្ការដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសារនៅឡើយ ។

ក្នុងឆ្នាំ១៩៧៧ ខ្មែរក្រហមចាប់ផ្តើមបង្កើតកងឈ្លបភូមិ និងជម្លៀសប្រជាជនចេញពីក្នុងភូមិ ។ ក្រុមគ្រួសាររបស់ ប៉ាន់ ក៏ត្រូវជម្លៀសទៅភូមិជីអោក ឃុំរមណីយ៍ ស្រុករវៀង ។ នៅឆ្នាំ១៩៧៨ ឈ្លបឃុំបានស្នើ ប៉ាន់ ឲ្យចូលធ្វើយុវជនចល័តនៅឃុំកំពង់ស្រឡៅ ។ ចាប់តាំងពីពេលនោះមក ប៉ាន់ ត្រូវទៅរស់នៅឆ្ងាយពីឪពុកម្តាយ និងត្រូវដើរទៅធ្វើការតាមកងចល័តក្នុងស្រុកឆែប ខេត្តព្រះវិហារ ដែលកងចល័តនោះមានសមាជិកសរុបទាំងអស់៥០នាក់ ។ ក្រុមកងចល័តរបស់ ប៉ាន់ ដើរជីកប្រឡាយលើកទំនប់នៅរដូវប្រាំង និងធ្វើស្រែនៅរដូវវស្សា ។

ធ្វើការក្នុងកងចល័តបាន៣ខែ ប៉ាន់ ឈឺហើមស្មានិងថ្ពោះ ចង្កេះ ដោយសារសែងដីហួសកម្លាំង ។ ប៉ាន់ បានសុំច្បាប់ប្រធានកងទៅសម្រាកនៅមន្ទីរពេទ្យឃុំ ។ នៅទីនោះ ប៉ាន់ បានជួបជីតារបស់គាត់ដែលកំពុងសម្រាកព្យាបាលជំងឺដែរ ។ ពីរ-បីថ្ងៃក្រោយមក ពេទ្យខ្មែរក្រហមបានប្រាប់ ប៉ាន់ ថាជីតារបស់គាត់បានជាសះស្បើយពីជំងឺនិងចេញពីមន្ទីរពេទ្យហើយ ។ ប៉ាន់ មិនបានចាប់អារម្មណ៍ថាពាក្យដែលខ្មែរក្រហមនិយាយគ្រាន់តែជាការបង្វែងដាននោះទេ ។ មិនយូរប៉ុន្មានក្រុមគ្រួសារ ប៉ាន់ បានមកតាមរកជីតានៅឯមន្ទីរពេទ្យ ។ ប៉ាន់ មានការភ្ញាក់ផ្អើលជាខ្លាំងនៅពេលឮថាជីតារបស់គាត់មិនបានត្រឡប់ទៅរកគ្រួសារវិញ ។ ជីតារបស់ ប៉ាន់ ក៏បាត់ខ្លួនរហូតចាប់តាំងពីថ្ងៃនោះមក ។

ថ្ងៃមួយក្នុងឆ្នាំ១៩៧៨ បងប្រុសរបស់ ប៉ាន់ បានមកតាម ប៉ាន់ នៅកងចល័ត ហើយប្រាប់ថា ឪពុករបស់ខ្លួនត្រូវឈ្លបខ្មែរក្រហមដែលត្រូវជាបងប្អូនសាច់ឆ្ងាយឈ្មោះ ចាន់ នឹង យកទៅសម្លាប់ ។ ពេលឮដំណឹងនេះភ្លាម ប៉ាន់ បានសុំការអនុញ្ញាតពីមេកងទៅមើលឪពុក ។ មេកងនោះបដិសេធថា "គ្មានអ្នកណាសម្លាប់មនុស្សទេ" ។ ប៉ុន្តែ ប៉ាន់ បានអង្វរមេកងរហូតទទួលបានការយល់ព្រម ។ ប៉ាន់ បានជិះសេះមកជួបម្តាយនៅភូមិជីអោក ដើម្បីសួរនាំអំពីរឿងហេតុនៃការស្លាប់របស់ឪពុក ។ ម្តាយរបស់ ប៉ាន់ បានប្រាប់ថា "ឪពុករបស់ឯងត្រូវក្មួយជីដូនមួយរបស់គាត់យកទៅសម្លាប់ហើយ ។ ចាន់ នឹង និងឈ្លប២នាក់ទៀតបានមកហៅឪពុកឯងទៅដឹកទឹកត្នោតជូរជាមួយគ្នា ។ ឪពុកឯងក៏ព្រមទៅជាមួយ" ។ ក្រោយសម្លាប់ហើយ ចាន់ នឹង បានមកប្រាប់បងប្រុសរបស់ ប៉ាន់ ថា "ចាំប្រាប់កូន (ម្តាយរបស់ ប៉ាន់) ផង ខ្ញុំសម្លាប់គាត់បាត់ហើយ" ។ ឪពុករបស់ ប៉ាន់ និងមនុស្ស៥នាក់ត្រូវបានសម្លាប់នៅពាក់កណ្តាលអធ្រាត្រនៅក្នុងព្រៃជិតវត្តព្រៃទទឹង ក្នុងភូមិជីអោក ឃុំរមណីយ៍ ស្រុករវៀង ។ ម្តាយរបស់ ប៉ាន់ លួចដើរទៅក្នុងព្រៃដើម្បីរកមើលសាកសព ហើយគាត់

ប្រទះឃើញកំណាត់ជើងប្តីរបស់គាត់ម្ខាងដែលសល់ពីសត្វព្រៃស៊ី (ដោយគាត់ចំណាំស្បែកជើង) ។ ម្តាយ ប៉ាន់ ក៏បានរើសជើងនោះមកដុតយកធាតុមកទុក ។ ចាន់ នឹង ឃើញម្តាយរបស់ ប៉ាន់ ធ្វើដូច្នោះ ក៏គំរាមយកម្តាយរបស់ ប៉ាន់ ទៅសម្លាប់ទៀត ។ ប៉ុន្តែសំណាងល្អ ប៉ាន់ មកជួយម្តាយទាន់ពេល ។

ប៉ាន់ បានឮដឹងថា កន្លែងដែលខ្មែរក្រហមសម្លាប់ឪពុករបស់គាត់និងអ្នកភូមិផ្សេងទៀតនោះ គឺជារណ្តៅសាកសពរួមមួយដែលមានបណ្តោយប្រវែង២០ម៉ែត្រនិងទទឹង៥ម៉ែត្រ ហើយមនុស្សប្រហែល៣៥នាក់ត្រូវបានសម្លាប់និងកប់នៅក្នុងរណ្តៅនោះ ។

នៅដើមខែមករា ឆ្នាំ១៩៧៩ កងទ័ពវៀតណាមវាយរំដោះបានទីក្រុងភ្នំពេញ ។ ខ្មែរក្រហមបានកៀរប្រជាជនទៅភាគខាងលិចតាមព្រំដែនប្រទេសថៃ ។ ប៉ាន់ ក៏បានធ្វើដំណើរទៅតាមខ្មែរក្រហមដែរ ហើយ ប៉ាន់ តែងស៊ើបសួរដំណឹងពីក្រុមគ្រួសារតាមផ្លូវរហូត ។ ធ្វើដំណើរបានពាក់កណ្តាលផ្លូវ ប៉ាន់ ទទួលដំណឹងពីអ្នកភូមិដែលធ្វើដំណើរតាមខ្មែរក្រហមថា ក្រុមគ្រួសាររបស់គាត់កំពុងរង់ចាំនៅភូមិអូរពោធិ៍ក្នុងឃុំរមណីយ៍ ។ ប៉ាន់ ក៏បន្លំខ្លួនក្នុងហ្វូងមនុស្សហើយធ្វើដំណើរត្រឡប់មករកក្រុមគ្រួសារវិញ ។ ប៉ាន់ បានមកដល់ភូមិកំណើតនៅក្នុងខែកញ្ញា ។

នៅឆ្នាំ១៩៨៧ ប៉ាន់ បានផ្លាស់ចេញពីភូមិកំណើតមកធ្វើការនៅខេត្តស្ទឹងត្រែង និងបានរៀបការជាមួយ យី រុណ និងមានកូនពីរនាក់ ។ ក្រុមគ្រួសាររបស់ ប៉ាន់ នៅតែរាប់អាន ចាន់ នឹង ជាបងប្អូនដដែល ព្រោះថា ចាន់ នឹង បានសុំទោសនិងសារភាពអំពីទោសកំហុសរបស់ខ្លួននៅចំពោះមុខក្រុមគ្រួសាររបស់ ប៉ាន់ ថា "ខ្ញុំខុសហើយ ខ្ញុំសម្លាប់គាត់មែន ។ គេប្រើខ្ញុំដែរ ខ្ញុំមិនដឹងធ្វើម៉េច បើនេះជាបញ្ជាពីថ្នាក់លើ" ។ ម្យ៉ាងទៀត រឿងនេះកន្លងហួសយូរឆ្នាំហើយ ប៉ាន់ យល់ថាការគាស់កកាយ ឬរកខុសរកត្រូវក៏គ្មានប្រយោជន៍ដែរ ពីព្រោះឪពុកគាត់បានស្លាប់ទៅហើយ ។ ប្រសិនបើ ប៉ាន់ សងសឹកដោយការសម្លាប់វិញនោះ កូនរបស់ ចាន់ នឹង នឹងក្លាយជាកូនកំព្រានិងរស់នៅដោយខ្វះភាពកក់ក្តៅក្នុងគ្រួសារមិនខាន ។

**ណាយ សុផារី**

# បែកប្តីព្រោះភាពអត់ឃ្លាន

"ខ្ញុំបែកបាក់ពីប្តីរបស់ខ្ញុំ ព្រោះគ្រួសារខ្ញុំក្រពេកពេលបែកពីរបបខ្មែរក្រហមមកវិញ ។ គាត់មិនព្រមរស់នៅជាមួយខ្ញុំនៅឯស្រុកកំណើតនេះទេ ។ គាត់សុខចិត្តទៅរស់នៅទីក្រុងភ្នំពេញ ព្រោះនៅទីនោះមានជីវភាពធូរធារជាងនៅស្រុកកំណើត" ។ នេះជាសម្តី របស់ គីម យឿង ។

គីម យឿង គឺជាស្ត្រីមេម៉ាយ រស់នៅឃុំកោះដាច់ ខេត្តកណ្តាល ។ ក្រោយបែកពីរបបខ្មែរក្រហម យឿង មានកូនពីរនាក់នៅក្នុងបន្ទុក ។ សព្វថ្ងៃ យឿង ប្រកបរបរត្បាញជាមួងនិងធ្វើចម្ការបន្តិចបន្តួចសម្រាប់ផ្គត់ផ្គង់ជីវភាពក្នុងគ្រួសារ ។ គាត់ចេះត្បាញហូលជាមួងតាំងពីមុនរបបខ្មែរក្រហម ម្ល៉េះ ប៉ុន្តែ គាត់មិនអាចប្រើចំណេះដឹងនេះក្នុងរយៈកាលនៃរបបខ្មែរក្រហមបានទេ ។

នៅក្នុងរបប លន់ នល់ ក្រុមគ្រួសាររបស់ យឿង ប្រកបរបរត្បាញជាមួងនិងធ្វើចម្ការ ។ ភូមិរបស់ យឿង ជួបប្រទះនូវសង្គ្រាមមិនអាចរស់នៅបាន ។ ក្រុមគ្រួសាររបស់ យឿង និងអ្នកភូមិផ្សេងទៀតធ្វើដំណើរចាកចេញពីភូមិកំណើត ទៅតាមទីកន្លែងដែលមានសុវត្ថិភាពរៀងៗខ្លួន ។ ក្រុមគ្រួសាររបស់ យឿង បានទៅរស់នៅម្តុំជ្រោយចង្វារជាមួយមិត្តភក្តិធ្លាប់ស្គាល់គ្នា ។ នៅទីនោះ យឿង បន្តប្រកបរបរត្បាញជាមួង ព្រោះពេលចេញពីស្រុកកំណើត គាត់បានយកឧបករណ៍ត្បាញនេះទៅជាមួយដែរ ។ ក្រុមគ្រួសាររបស់ យឿង បានទទួលការឧបត្ថម្ភគាំទ្រពីអង្គការកាកបាទក្រហមខាងផ្នែកគ្រឿងឧបភោគ ដូចជាអង្ករ ទឹកត្រី ឆែប៉ូវ ទឹកស៊ីអ៊ីវ ។ល។ យឿង ទទួលបានរបប

អាហារនេះជារៀងរាល់ខែ ។ ចំណែកផាមួងដែលត្បាញបាន គាត់យកទៅលក់នៅផ្សារដែលមានម៉ូយចាំទទួលទិញនៅទីនោះស្រាប់ ។

នៅមុនថ្ងៃជម្លៀសឆ្នាំ១៩៧៥ គ្រាប់ផ្លោងធ្លាក់នៅក្បែរផ្ទះរបស់គាត់ ។ យឿង ឃើញកងទ័ពខ្មែរក្រហមកាន់កាំភ្លើង ហើយស្រែកប្រកាសថា ប្រទេសបានសន្តិភាពហើយ ។ យឿង ជឿជាក់ថា ប្រទេសនឹងមានសន្តិភាពមែននៅពេលនោះ ។ យឿង សប្បាយចិត្តណាស់ ហើយគិតថាខ្លួននឹងអាចវិលត្រឡប់មកស្រុកកំណើតវិញ ។ ផ្ទុយទៅវិញ កងទ័ពខ្មែរក្រហមបានបង្ខំឲ្យ យឿង ចាកចេញពីជ្រោយចង្វារ ធ្វើដំណើរទៅតាមផ្លូវជាតិលេខ៦ ។ យឿង យល់ថា ខ្មែរក្រហមឲ្យប្រជាជនចាកចេញដើម្បីរៀបចំក្រុងនិងបោសសម្អាតខ្មាំង ។ យឿង យកបានចានឆ្នាំង អង្ករ និងសម្លៀកបំពាក់តែមួយបង្វេចប៉ុណ្ណោះ ។ តាមផ្លូវ យឿង ត្រូវឈប់សម្រាកជាច្រើនយប់ ទើបទៅដល់ព្រែកព្នៅ ។ ថ្ងៃបន្ទាប់ កងទ័ពខ្មែរក្រហមបានដឹកក្រុមគ្រួសាររបស់ យឿង និងគ្រួសារមួយចំនួនទៀតតាមរថយន្តឆ្ពោះទៅខេត្តកំពង់ចាម ។ អង្គការបានចាត់តាំងឲ្យគ្រួសាររបស់ យឿង រស់នៅស៊ីងធំក្នុងស្រុកក្រូចឆ្មារ ខេត្តកំពង់ចាម ។ យឿង ធ្វើការនៅក្នុងកងមនុស្សវ័យចំណាស់ដែលមានភារកិច្ចធ្វើស្រែចម្ការ ។ ចំណែកកូនៗរបស់ យឿង ត្រូវអង្គការបែងចែកឲ្យធ្វើការនៅក្នុងកងចល័តផ្សេងៗគ្នា ។ រយៈពេលមួយខែទើប យឿង បានជួបមុខកូនម្ដង ។ យឿង ត្អូញត្អែរថា ការរស់នៅជួបការលំបាកយ៉ាងខ្លាំង ដោយសារគ្មានអាហារហូបគ្រប់គ្រាន់ និងគ្មានកម្លាំងធ្វើការ និងការប្រជុំទិតៀនដ៏គួរឲ្យធុញទ្រាន់និងព្រឺព្រួចជាញឹកញាប់ ។

យឿង និយាយថាប្រជាជនមូលដ្ឋាននៅទីនោះកាចណាស់ ។ អ្នកទាំងនោះតែងតែមើលងាយ យឿង ថាជាប្រជាជនថ្មីមិនចេះធ្វើការអ្វី ហើយហូបច្រើនទើបបង្កឲ្យមានជំងឺ ។ ម្ដាយរបស់ យឿង ស្លាប់ដោយសារជំងឺគ្រុនចាញ់ ។ អង្គការធ្លាប់បានបញ្ជូនគាត់ទៅព្យាបាលនៅមន្ទីរពេទ្យ ដោយឲ្យគាត់លេបថ្នាំអាចម៍ទន្សាយ និងព្យួរសេរ៉ូមទឹកដូង ប៉ុន្តែជំងឺរបស់គាត់មិនបានស្រាកស្រាន្តសោះ ។ បងប្អូនទាំងអស់មិនអាចមកសួរសុខទុក្ខគាត់បានទេ ដោយជាប់រវល់នៅតាមកងចល័តរៀងៗខ្លួន ។ ពេលម្ដាយឈឺធ្ងន់ ទើបអង្គការអនុញ្ញាតឲ្យ យឿង និងបងប្អូនមកមើលម្ដាយ ។ ជាអកុសល យឿង មកទាន់ដង្ហើមម្ដាយ ។ ប៉ុន្តែ យឿង មិនត្រូវបានអនុញ្ញាតយកសពម្ដាយទៅកប់ដោយខ្លួនឯងទេ ជាហេតុធ្វើឲ្យ យឿង មិនដឹងពីកន្លែងកប់សាកសពម្ដាយរហូតមកទល់សព្វថ្ងៃ ។

ពេលកងទ័ពវៀតណាមផ្ដួលរំលំខ្មែរក្រហមបាន យឿង និងក្រុមគ្រួសារបានវិលត្រឡប់មកស្រុកកំណើតវិញ ដោយធ្វើដំណើរថ្មើរជើងអស់រយៈពេលមួយខែ ។ យឿង បានបែកពីប្ដីរបស់គាត់នៅពេលនោះ ដោយសារប្ដីរបស់គាត់ចង់ទៅរកកន្លែងដែលមានជីវភាពធូរធារជាងនៅស្រុកកំណើត ។ ដូច្នេះ យឿង រស់នៅជាស្ត្រីមេម៉ាយ ហើយទទួលបន្ទុកចិញ្ចឹមកូនទាំងពីរតែម្នាក់ឯង ។ យឿង ប្រកបរបរត្បាញផាមួងនិងធ្វើចម្ការដដែល ។

រហូតមកដល់បច្ចុប្បន្ននេះ យឿង នៅតែមិនអាចបំភ្លេចបាននូវរឿងរ៉ាវខ្លោចផ្សាក្នុងរបបខ្មែរក្រហម ។ យឿង ត្រេកអរយ៉ាងខ្លាំងនៅពេលឮថាតុលាការមួយត្រូវបានបង្កើតឡើងដើម្បីរកយុត្តិធម៌ ជូនជនរងគ្រោះនៃរបបខ្មែរក្រហម ជាពិសេសម្ដាយរបស់គាត់ដែលឈឺស្លាប់ដោយគ្មានថ្នាំព្យាបាល ។

**ប៊ាង ពីវ័ន**

## រឿងរ៉ាវពិតដើម្បីប្រវត្តិសាស្ត្រ

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហមបាននិងកំពុងសរសេរអត្ថបទឬសៀវភៅអំពីរឿងរ៉ាវពិតផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមអាសយដ្ឋានខាងក្រោម ៖

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@online.com.kh
Home page: www.dccam.org

# សហគមន៍ចាមនៅភូមិព្រែកប្រធាតុ

នៅចម្ងាយប្រហែលជា៦០គីឡូម៉ែត្រពីទីក្រុងភ្នំពេញមាន សហគមន៍ចាមតូចមួយដែលមានប្រជាជនប្រហែល៣៥គ្រួសារ ។ សហគមន៍នេះកកើតឡើងនៅឆ្នាំ១៩៨៣ បន្ទាប់ពីមានការស្រុះស្រួលមតិគ្នារកកន្លែងដីសមរម្យមួយដើម្បីបោះទីតាំងនេសាទត្រី ។ ភាគច្រើនអ្នកដែលរស់នៅក្នុងសហគមន៍នេះមានដើមកំណើតនៅភូមិកោះទាវ(ត្រើយកោះ) នៅជិតព្រំប្រទល់កម្ពុជា-វៀតណាម ។ សហគមន៍នេះមិនបានឆ្លងកាត់របបខ្មែរក្រហមទេ ព្រោះប្រជាជនភាគច្រើនដឹងសភាពការណ៍មុន ហើយបានភៀសខ្លួនទៅប្រទេសវៀតណាមនៅឆ្នាំ១៩៧៣ ។ ដំណាក់កាលដំបូងជនជាតិចាម ដែលភៀសខ្លួនពីភូមិកោះទាវបានទៅជ្រកកោននៅក្នុងភូមិព្រៃស្បូវដែលជាភូមិចាមនៅប្រទេសវៀតណាម ។ ប៉ុន្តែដោយសារមានការបាញ់ផ្លោងនៅតាមព្រំដែនកម្ពុជា-វៀតណាម អ្នកភូមិចាមទាំងអស់ត្រូវបង្ខំចិត្តភៀសខ្លួនទៅខេត្តក្រមួនស និងផ្លាស់ទីកន្លែងបន្តបន្ទាប់ដើម្បីរកកន្លែងសុវត្ថិភាព ។ អ្នកភៀសខ្លួនទាំងអស់នេះបានទទួលការឧបត្ថម្ភជាស្បៀងអាហារ សម្លៀកបំពាក់និងសម្ភារមួយចំនួនពីកាកបាទក្រហមនៅក្នុងប្រទេសវៀតណាម ។ ប្រជាជនចាមមានឱកាសថ្វាយបង្គំ សាសនាអ៊ីស្លាម ប៉ុន្តែអារម្មណ៍ភ័យខ្លាចនៅតែមាននៅក្នុងចិត្ត (ចំពោះការរត់គេចពីការវាយប្រហាររបស់កងទ័ពខ្មែរក្រហម) ។ នៅក្នុងអំឡុងពេលរស់នៅក្នុងប្រទេសវៀតណាម អ្នកទាំងអស់នេះបានជួបប្រទះនូវការលំបាកយ៉ាងខ្លាំង ។ អ្នកភូមិតែងសុំពីព្រះអាល់ឡោះជាម្ចាស់ ដើម្បីឲ្យរបបខ្មែរក្រហមផុតរលត់ទៅឲ្យបានឆាប់ ។



សូរ៉ាវ (វិហារ) ភូមិព្រែកប្រធាតុ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល

ក្រោយឆ្នាំ១៩៧៩ ប្រជាជនចាមបានវិលត្រឡប់មករស់នៅភូមិនៅកោះទាវវិញដែលជាភូមិកំណើតរបស់ខ្លួន ហើយប្រកបរបរនេសាទតាមទូក ។ ក្រោយមកអ្នកដែលរស់នៅកោះទាវបានផ្លាស់មករស់នៅភូមិព្រែកប្រធាតុ ។ អ្នកភូមិទាំងអស់រស់នៅលើដីជួលមួយប្លង់ដែលតែងលិចទឹកជានិច្ចនៅរដូវវស្សា ។

របរនេសាទគឺជារបរចម្បងរបស់អ្នកភូមិ ក្រៅពីនេះក៏មានការលក់ដូររបស់របរប្រើប្រាស់នៅតាមភូមិដើម្បីផ្គត់ផ្គង់ជីវភាព ។ ក្រោមការដឹកនាំរបស់ហាកិម យ៉ាម៉ាត់ ដែលជាចាស់ទុំនៅក្នុងភូមិបានផ្តួចផ្តើមបង្កើតឲ្យមានសូរ៉ាវ (វិហារ) សម្រាប់ដឹកនាំការថ្វាយបង្គំនិងប្រារព្ធពិធីបុណ្យតាមសាសនាអ៊ីស្លាម ។

ហាកិម យ៉ាម៉ាត់ បានរៀបរាប់អំពីជីវិតតស៊ូរបស់គាត់និង សហគមន៍ចាមនៅភូមិព្រែកប្រធាតុនេះ ។

ភូមិនេះពីដើមមានតាចាស់ៗឈ្មោះ តាហ៊ីម, តាឡេះ, តាសុះ, តាម៉ាត់ ដែលរត់មកពីប្រទេសចម្ប៉ាបានមកបង្កបង្កើតជាភូមិមួយមានសមាជិកតិចតួច ។ ក្រោយមកក៏មានសមាជិកគ្រួសារកើនឡើងតាមរយៈការរៀបការនិងបង្កើតកូនពូនជាចៅនៅក្នុងភូមិ ។ នេសាទជាមុខរបរដែលជនជាតិចាម ប្រកាន់យកតាំងពីយូរណាស់មកហើយ ។

ជាមួយមុខរបរនេសាទ ខ្ញុំបានផ្លាស់ទីលំនៅជាច្រើនកន្លែង ។ ខ្ញុំនៅភូមិដើមមៀន ឃុំដើមមៀន ស្រុកតាខ្មៅ ខេត្តកណ្តាល

ក្រោយមកក៏ទៅរស់នៅភូមិត្រើយកោះ ដើម្បីនេសាទត្រីនៅទីនោះ ។ ខ្ញុំទៅនេសាទជាមួយឪពុកម្តាយនៅខេត្តកំពង់ឆ្នាំង ទន្លេមុខ៤ និងទន្លេមេគង្គ ។ កាលណោះ នៅប្រទេសកម្ពុជាសម្បូរត្រីណាស់ ។ ខ្ញុំនេសាទបានត្រីប្រា ត្រីកែស ត្រីឆ្តោក ត្រីឆ្លាំង ត្រីសណ្តាយ ត្រីឆ្តិន ។ល ។ បន្ទាប់ពីនេសាទបាន យើងយកទៅលក់នៅកម្ពុជាក្រោមប្រទេសវៀតណាម ។

ពេលខ្ញុំអាយុ២០ឆ្នាំ ខ្ញុំបានស្ម័គ្រចិត្តចូលធ្វើទាហានដើម្បីការពារប្រទេសជាមួយមេបញ្ជាការទ័ពស័ក្តិ៥ឈ្មោះ កសិម ។ ខ្ញុំឡើងសមរភូមិរហូតដល់ខេត្តរតនគិរី ។ នៅឆ្នាំ១៩៦៣ ដោយសារការនឿយហត់ពេកខ្ញុំក៏ឈប់ធ្វើទាហាន ហើយមករស់នៅជាមួយឪពុកម្តាយនៅត្រើយកោះវិញដែលក្រោយមកភូមិនេះមានប្រទាញប្រទង់គ្នារវាងទាហានធីវគីជាមួយលន់នល់ ពួកខ្ញុំនាំគ្នារត់គេចទៅរកកន្លែងផ្សេងដើម្បីស្នាក់នៅនិងប្រកបរបរនេសាទ ។ បងស្រីខ្ញុំឈ្មោះ ស្នាក់ បានទៅរស់នៅជាមួយប្តីគាត់នៅភូមិឃ្លាំងស្បែក ឃុំកំពង់ចម្លងខេត្តកណ្តាល ។ គ្រួសារខ្ញុំនាំគ្នាភៀសខ្លួនតាមទូកទៅប្រទេសវៀតណាម ។ យើងបានទៅដល់ភូមិព្រៃស្បូវដែលជាភូមិចាមនិងមានជនជាតិចាមជាច្រើននាក់រស់នៅ ។ នៅទីនោះមានវិហារអ៊ីស្លាមមួយឈ្មោះ ម៉ូកោរ៉ម៉ាស់ យើងតែងនាំគ្នាទៅថ្វាយបង្គំនៅក្នុងវិហារនេះ ។ យើងសង់ផ្ទះស្បូវតូចៗ ដើម្បីស្នាក់នៅបណ្តោះអាសន្នជាមួយនឹងកង្វះខាតសម្ភារគ្រប់បែបយ៉ាង ។ អង្គការកាកបាទក្រហមបានចែកគ្រឿងឧបភោគបរិភោគ និងសម្លៀកបំពាក់ដល់អ្នកភៀសខ្លួនដែលទៅរស់នៅភូមិព្រៃស្បូវ ។ ដំបូងយើងជួបប្រទះការលំបាកជាច្រើន ដូចជាការប្រើប្រាស់ភាសាវៀតណាម សម្រាប់ការទំនាក់ទំនងគ្នា ។

ឆ្នាំ១៩៧៤ ខ្ញុំបានរៀបការប្រពន្ធឈ្មោះ ម៉ាស់ ដែលជាអ្នកភូមិព្រៃស្បូវ ។ ខ្ញុំប្រកបរបរនេសាទត្រី ដួញដូរអង្ករនិងឆៀតលក់ថ្នាំបុរាណខ្មែរ ដោយសារខ្ញុំស្គាល់ថ្នាំនិងចេះផ្សំថ្នាំបុរាណតាមឪពុកម្តាយខ្ញុំ ។ ខ្ញុំប្រឹងប្រែងប្រកបរបររកស៊ីច្រើនមុខដែរ ប៉ុន្តែមិនសូវកាក់កបសោះ ពីព្រោះអារម្មណ៍របស់ខ្ញុំមិនស្ងប់នៅតែមមៃគិតអំពីសុវត្ថិភាពជាចម្បង ខ្លាចក្រែងកងទ័ពខ្មែរក្រហមវាយលុកចូលភូមិទៀត ។ អ្វីដែលខ្ញុំបារម្ភបានមកដល់ ។

ថ្ងៃមួយកងទ័ពខ្មែរក្រហមនិងកងទ័ពវៀតណាមបានវាយប្រយុទ្ធគ្នានៅតាមព្រំដែន ។ កងទ័ពខ្មែរក្រហមបានចូលភូមិដុតផ្ទះសម្បែងនិងវិហារអ៊ីស្លាមឆេះឡើងសន្ធោសន្ធៅ ។ ប្រជាជនចាមបាននាំគ្នារត់ចេញពីភូមិដោយយកវ៉ាន់បន្តិចរួចភៀសខ្លួនទៅរកកន្លែងសុវត្ថិភាព ។ ខ្ញុំបានយកគម្ពីរគូរ៉ានទៅជាមួយដែរ ។ យើងបានទៅរស់នៅភូមិចាមមួយទៀត ។ ក្រោយពីមានព្រឹត្តិការណ៍នោះកើតឡើង ប្រធានភូមិបានចាត់អ្នកភូមិឲ្យជួយយាម



ហាកិម យ៉ាម៉ាត់ និងអ្នកភូមិកំពុងអង្គុយនៅក្នុងសូរ៉ាវ (វិហារ) ភូមិព្រែកប្រធាតុ ឃុំព្រែកស្តី ស្រុកកោះធំ ខេត្តកណ្តាល

ពេលយប់ ដោយផ្លាស់វេនគ្នាយាមរៀងរាល់៣យប់ម្តង ខ្ញុំមានអារម្មណ៍ភ័យខ្លាចនិងអាម៉ាស់ចំពោះទង្វើដែលកងទ័ពខ្មែរក្រហមប្រព្រឹត្តមកលើប្រជាជនកម្ពុជាដូចគ្នា ។ ខ្ញុំរកថាមិនត្រូវនៅពេលដែលខ្ញុំជាអ្នកកើតនៅប្រទេសកម្ពុជា ហើយបែរមកការពារទឹកដីវៀតណាមតទល់និងខ្មែរក្រហមទៅវិញ ។

ខ្ញុំទទួលដំណឹងតាមបងប្អូនចាមដែលបណ្តែតខ្លួនតាមដើមចេកទៅប្រទេសវៀតណាមថា អ្នកដែលភៀសខ្លួនទៅប្រទេសវៀតណាមនៅមុនឆ្នាំ១៩៧៥ចំនួន១៣នាក់ បានវិលត្រឡប់មកប្រទេសកម្ពុជាវិញព្រោះតែនឹកស្រុកកំណើត ហើយត្រូវខ្មែរក្រហមយកទៅសម្លាប់នៅគុកពោធិ៍ទន្លេ ។ នៅពេលឮដំណឹងនេះ ខ្ញុំព្រួយបារម្ភដល់សុវត្ថិភាពក្រុមគ្រួសារបងស្រីខ្ញុំណាស់ ។

ការប្រយុទ្ធគ្នានៅតាមព្រំដែនរវាងកងទ័ពវៀតណាមនិងកងទ័ពខ្មែរក្រហមចាប់ផ្តើមយ៉ាងខ្លាំងក្លា បន្ទាប់ពីវៀតណាមប្រកាសឲ្យខ្មែរក្រហមដកទ័ពចេញពីព្រំដែនចម្ងាយ១២០ម៉ែត្រ ។ កងទ័ពច្រើនណាស់ បានបាត់បង់ជីវិតក្នុងពេលប្រយុទ្ធគ្នា ។ កងទ័ពខ្មែរក្រហមដឹកលេណដ្ឋានហើយវាយសម្រុកចូលមកខាងវៀត-ណាម ។ ទ័ពវៀតណាមចាញ់ទ័ពខ្មែរក្រហម ។ ពួកខ្ញុំត្រូវបានជ្រើសរើសឲ្យធ្វើឈ្លបការពារភូមិពីការរាតត្បាតរបស់កងទ័ពខ្មែរក្រហម ។ កងទ័ពខ្មែរក្រហមចូលកាន់កាប់ភូមិជិតខាងនោះ បានតែរយៈពេលមួយខែ ក៏ត្រូវកងទ័ពវៀតណាមបណ្តេញចេញអស់ ។

រយៈកាលដែលខ្ញុំរស់នៅវៀតណាម ខ្ញុំឮដំណឹងថាខ្មែរក្រហមកាប់សម្លាប់ប្រជាជនកម្ពុជាស្លូតត្រង់និងបង្ខំឲ្យជនជាតិចាមហូបសាច់ជ្រូក ។ ពេលនោះខ្ញុំនឹកទៅដល់សុខទុក្ខបងស្រីរបស់ខ្ញុំដែលបែកគ្នា ហើយទៅរស់នៅស្រុកពញាឮ ។

បន្ទាប់ពីជ័យជម្នះឆ្នាំ១៩៧៩ ខ្ញុំរស់នៅក្នុងប្រទេសវៀត-ណាមនៅឡើយ ។ ប្រធានភូមិចែកដីប្រវែង១២ម៉ែត្រឲ្យសង់ផ្ទះនៅ ។ ខ្ញុំនៅតែយាមភូមិក្រែងខ្មែរក្រហមចូលមកអុកឡុកទៀត ។ ដោយសារនឹកស្រុកកំណើតពេកខ្ញុំបានធ្វើដំណើរតាមទូកត្រឡប់មករស់នៅភូមិត្រើយកោះវិញ ។ ខ្ញុំសោកស្តាយភូមិឋានដែលធ្លាប់តែមានផ្ទះ មានអ្នកភូមិរស់នៅច្រើន ប៉ុន្តែនៅពេលខ្ញុំត្រឡប់មកវិញ ផ្ទះសម្បែងទាំងអស់ខ្ទេចខ្ទីគ្មានសល់ ។ ខ្ញុំសង្កេតឃើញថា ការរស់នៅរបស់បងប្អូនជនជាតិចាមមានការលំបាកខ្លាំងណាស់ ។ អ្នកខ្លះគ្មានទូក ខ្លះមានទូកតូចៗ នាំគ្នាទៅបង់ត្រី ។ ខ្ញុំសង់រោងលើគោកឲ្យកូនស្នាក់នៅ ចំណែកប្រុសៗដេកលើទូក ។ ការរស់នៅរបស់យើងនៅត្រើយកោះនេះយូរៗទៅត្រីកាន់តែខ្សត់ ហើយទឹកនាចភូមិរៀងរាល់ឆ្នាំ ។ នៅឆ្នាំ១៩៨៣ ពួកខ្ញុំបានស្វែងរកកន្លែងសំចតថ្មី ហើយបានមកដល់ភូមិព្រែកប្រធាតុ ។ ដោយយល់ឃើញថាទីតាំងនេះអំណោយផលដល់ការនេសាទត្រី យើងទាំងអស់គ្នាបានចតទូកតាំងទីស្នាក់អាស្រ័យ ។ យើងរស់នៅលើទូកអស់រយៈពេល៦ខែ ក្រោយមកដោយសារខ្យល់បោកបក់ខ្លាំងពេក យើងនាំគ្នាឡើងគោកសង់ខ្ទមវិញ ។ យើងបានជួលដីអ្នកភូមិក្នុងតម្លៃ១៥ម៉ឺនរៀលក្នុងមួយខែ ។ ក្រោយមកទៀតមានមនុស្សជាច្រើនបានមករស់នៅក្នុងភូមិនេះជាបន្តបន្ទាប់ ហើយបង្កបង្កើតបានជាសហគមន៍ចាមមួយឡើយ ។

នៅឆ្នាំ១៩៨៥ មុហ្វតី (ចាងហ្វាងគណៈដឹកនាំជាន់ខ្ពស់នៃសាសនាអ៊ីស្លាមកម្ពុជា) បានតែងតាំងខ្ញុំជាហាកិមភូមិព្រែកប្រធាតុនេះ ។ ខ្ញុំបានអប់រំអ្នកភូមិនិងក្មេងៗអំពីសាសនាអ៊ីស្លាម ដើម្បីឲ្យមនុស្សដើរទៅរកផ្លូវល្អ ។ នៅឆ្នាំ១៩៩២ យើងទាំងអស់គ្នា បានមូលមតិគ្នាកសាងសូរ៉ាវតូចមួយសម្រាប់ថ្វាយបង្គំរួមគ្នា ។ ប៉ុន្តែយើងជួបប្រទះការលំបាកជាច្រើន ជាពិសេសនៅរដូវទឹកឡើង ។ ភូមិរបស់ខ្ញុំលិចទឹក ផ្ទះនិងសូរ៉ាវទឹកលិចត្រឹមសសរ ។ ដោយសារតែបញ្ហាជីវភាព យើងស្ទើរតែមិនអាចរកប្រាក់បង់ថ្លៃឈ្នួលដីឲ្យគេក្នុងមួយខែៗ ។ ឥឡូវនេះភូមិរបស់ខ្ញុំមានប្រជាជនចំនួន៣៥គ្រួសារដែលកាលពីមុនមានត្រឹម២៨គ្រួសារប៉ុណ្ណោះ ។

ថ្វីដ្បិតតែខ្ញុំមិនបានឆ្លងកាត់របបខ្មែរក្រហមដោយផ្ទាល់ ក៏ខ្ញុំអាណិតអាសូរដល់អ្នកដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបនោះ ។ ខ្ញុំយល់ថាខ្មែរក្រហមជាទមិឡឥតសាសនាទើបហ៊ានសម្លាប់មនុស្សឥតត្រាប្រណីបែបនេះ ។

ខ្ញុំសូមឲ្យមានការចងក្រងប្រវត្តិរឿងរ៉ាវរបស់ជនជាតិចាមនៅក្រោមរបបខ្មែរក្រហមឲ្យបានពិស្តារ ដើម្បីទុកជាឯកសារសម្រាប់ក្មេងជំនាន់ក្រោយនិងអ្នកដែលមិនបានឆ្លងកាត់របបនោះដោយផ្ទាល់ដឹងឮរឿងទាំងអស់ ។ ខ្ញុំយល់ស្របចំពោះសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហម ប៉ុន្តែខ្ញុំប្រកាន់ធម៌ អហោសិកម្ម ដល់អ្នកទាំងនោះដើម្បីឲ្យអ្នកទាំងនោះដើរទៅរកផ្លូវល្អ ។ **ស្វ ហ្វារីណា**

# ការចូលរួមរបស់ជនរងគ្រោះ : ដំណើរទស្សនកិច្ចលើកទី៨ទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

នៅថ្ងៃទី២៥និង២៦ ខែកញ្ញា អ្នកភូមិចំនួន៥១០នាក់ (ភាគច្រើនជាអ្នកដែលត្រូវបានសម្ភាសដោយក្រុមជំរុញឲ្យមានការទទួលខុសត្រូវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា) បានអញ្ជើញចូលរួមក្នុងដំណើរទស្សនកិច្ចលើកទី៨ទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរៀបចំឡើង និងឧបត្ថម្ភដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ អ្នកចូលរួមបានទៅទស្សនាទីតាំងបូជនីយដ្ឋានប្រល័យពូជសាសន៍មួយចំនួន និងជួបសំណេះសំណាលជាមួយមន្ត្រីជាន់ខ្ពស់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ជារួមដំណើរទស្សនកិច្ចលើកនេះទទួលបានជោគជ័យយ៉ាងត្រចះត្រចង់ ។ ប្រជាជនដែលអញ្ជើញចូលរួមមានការចាប់អារម្មណ៍យ៉ាងខ្លាំង នៅពេលបានឃើញសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងរណ្ដៅសាកសពនៅវាលពិឃាតបឹងជើងឯក ។ ប្រជាជនជាច្រើនបានសួរ សំណួរទៅលោក រាជ សម្បត្តិ មន្ត្រីព័ត៌មាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោក ស៊ាន វិសុទ្ធ (ប្រធានរដ្ឋបាល) និងអ្នកស្រី មីសែល លី (អនុប្រធានរដ្ឋបាល) ។ ប្រជាជនក៏បានសួរសំណួរជាច្រើនផងដែរ នៅក្នុងពេលជួបសំណេះសំណាលជាមួយឯកឧត្តម ម៉ោញ សាផាន អនុប្រធានគណៈកម្មការនីតិកម្មនៃរដ្ឋសភាជាតិ ។ ដំណើរទស្សនកិច្ចលើកនេះមានការអញ្ជើញចូលរួមពីប្រជាជនមកពីខេត្តចំនួន៩ ដែលរួមមានខេត្តបាត់ដំបង ៤៣នាក់ កំពង់ចាម៧១នាក់ កំពង់ស្ពឺ៣៤នាក់ កំពង់ធំ១២៩នាក់ កំពត៣២នាក់ ព្រៃវែង៣១នាក់ រតនគិរី៣នាក់ ស្វាយរៀង ១៦នាក់ និងតាកែវ១៥១នាក់ ។ ដំណើរទស្សនកិច្ចនេះបានផ្ដល់ឱកាសឲ្យប្រជាជនចែករំលែកបទពិសោធន៍និងរឿងរ៉ាវទាំងឡាយ និងទស្សនាទីតាំងប្រល័យពូជសាសន៍សំខាន់ៗមួយចំនួន ។ ក្នុងចំណោមអ្នកចូលរួមទាំងអស់ មានប្រុស៣៥៤នាក់ ស្រី១៥៦នាក់ ។ ភាគច្រើននៃអ្នកចូលរួមគឺជាជនរងគ្រោះ ហើយមួយចំនួនតូច គឺជាអតីតកម្មាភិបាលខ្មែរក្រហម ។ មុនដើរទស្សនា បុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាបានចែកឯកសារបួនប្រភេទ ដែលរួមមានៈ សៀវភៅណែនាំអំពីសាលាក្ដីខ្មែរក្រហមនិងតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា សៀវភៅណែនាំស្ដីអំពីច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជានិងអង្គការសហប្រជាជាតិ ទស្សនាវដ្ដីលេខពិសេសរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងសៀវភៅណែនាំអំពីសាលាក្ដីខ្មែរក្រហមរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដំណើរទស្សនកិច្ចលើកនេះមានសារសំខាន់ខ្លាំងណាស់ ពីព្រោះមិនត្រឹមតែបង្ហាញឲ្យប្រជាជនឃើញផ្ទាល់ភ្នែកថាអំពើប្រល័យពូជសាសន៍នៅកម្ពុជាត្រូវបានយកចិត្តទុកដាក់ពីប្រទេសផ្សេងៗប៉ុណ្ណោះទេ ថែមទាំងបានបង្ហាញពីតួនាទីដ៏សំខាន់របស់ជនរងគ្រោះនៅក្នុងការដំណើរការរបស់សាលាក្ដីទៀតផង ។ នេះគឺជាគោលដៅចម្បងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។ របាយការណ៍សង្ខេបស្ដីអំពីដំណើរទស្សនកិច្ចលើកនេះមានដូចខាងក្រោម ។

បន្ទាប់ពីទទួលទានអាហារពេលព្រឹកហើយ នៅព្រឹកថ្ងៃច័ន្ទ ទី២៥ ខែកញ្ញា វេលាម៉ោង៧និង៣០នាទី ប្រជាជនបានអញ្ជើញមកដល់សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ដែលជាអតីតកន្លែងធ្វើទារុណកម្មនិងជាមណ្ឌលឃុំឃាំងក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកចូលរួមទាំងអស់ទទួលបានខិតប័ណ្ណរៀបរាប់ពីសារមន្ទីរទួលស្លែង ។ សម្រាប់ប្រជាជនភាគច្រើននេះគឺជាលើកទីមួយ ហើយដែលគាត់បានឃើញអតីតវិទ្យាល័យដ៏ល្អស្អាត និងជាកន្លែងដែលកម្មាភិបាលខ្មែរក្រហមថតរូបបង្ខំឲ្យអ្នកទោសសរសេរចម្លើយសារភាព ធ្វើទារុណកម្ម ហើយទីបំផុតដឹកយកទៅសម្លាប់ចោលនៅបឹងជើងឯក ។ គ្រាន់តែខ្លោងទ្វាររបស់សារមន្ទីរនេះបានធ្វើឲ្យប្រជាជនចូលរួមទាំងអស់មានការចាប់អារម្មណ៍យ៉ាងខ្លាំង ។ មនុស្សជាច្រើនបានផ្ដុំគ្នាជុំវិញផ្ទាំងក្ដារដែលមានបិទរូបថតមេដឹកនាំ

ជាន់ខ្ពស់ខ្មែរក្រហម ។ សម្រាប់មនុស្សមួយចំនួន នេះជាលើកទីមួយហើយដែលគាត់បានឃើញមុខមាត់របស់ ប៉ុល ពត, នួន ជា, ខៀវ សំផន, តាម៉ុក, អៀង សារី និងមេដឹកនាំជាន់ខ្ពស់ដទៃទៀត ។ បុរសម្នាក់នៅក្នុងចំណោមនោះបានសួរថា "តើមួយណាជាតាម៉ុក?" បុរសម្នាក់ទៀតបានឆ្លើយយ៉ាងលឿនថា "មួយនេះ" ។ សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែងចែកចេញជាច្រើនអគារ ហើយអគារនីមួយៗមានបន្ទប់ជាច្រើនដែលមានដាក់តាំងរូបថត គ្រែ សម្ភារធ្វើទារុណកម្ម និងសម្ភារសំខាន់ដទៃទៀតសម្រាប់ប្រើនៅក្នុងគុកក្នុងរយៈកាលនៃរបបនោះ ។ អ្នកចូលរួមទាំងអស់បានដើរទស្សនាពីបន្ទប់មួយទៅបន្ទប់មួយទៀត ។ ប្រជាជនជាច្រើនបញ្ចេញទឹកមុខសោកសៅ ហួសចិត្ត និងឈឺចាប់ ។ អ្នកផ្សេងទៀតកំពុងជូតទឹកភ្នែកនឹងក្រមា ។

បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានសម្ភាសប្រជាជនមួយចំនួន ។ ស្ត្រីម្នាក់ឈ្មោះ ផែត សុខ អាយុ៥៨ឆ្នាំ បានរកឃើញរូបថតសាច់ញាតិរបស់គាត់ជាលើកទីមួយ ។ នោះគឺជារូបថតបងប្រុសរបស់គាត់ដែលត្រូវបានដាក់តាំងនៅក្នុងផ្ទាំងកញ្ចក់មួយនៅជួរខាងលើ លេខរៀងទីបី (រាប់ពីខាងឆ្វេង) ។ ជាយូរមកហើយ បងប្អូនរបស់គាត់នៅទីក្រុងភ្នំពេញបានប្រាប់ថាមានរូបថតបងប្រុសរបស់គាត់នៅសារមន្ទីរទួលស្លែង ។ ប៉ុន្តែថ្ងៃច័ន្ទនេះគឺជាថ្ងៃទីមួយដែល សុខ មានឱកាសធ្វើដំណើរមកភ្នំពេញ និងឃើញរូបថតបងប្រុសរបស់គាត់ដែលបានបាត់ខ្លួនតាំងពីឆ្នាំ១៩៧៦ ។ ពេលយើងសួរគាត់អំពីទស្សនផ្ទាល់ខ្លួនចំពោះសាលាក្តីខ្មែរក្រហម ហើយថាតើសាលាក្តីនេះនឹងនាំមកនូវយុត្តិធម៌ទេ គាត់បានឆ្លើយថា គាត់មានការចាប់អារម្មណ៍ក្នុងការចូលរួមការកាត់សេចក្តី ហើយថា រឿងយុត្តិធម៌ឬអត់នោះវាអាស្រ័យទៅលើអ្នកចេះដឹង និងអ្នកដែលធ្វើការលើរឿងនេះ ។ សុខ បានបន្ថែមថា គាត់មិនដឹងនិយាយយ៉ាងណាអំពីរឿងនេះទេ ។ សុខ សង្ឃឹមថាសាលាក្តីនេះនឹងក្លាយទៅជាមេរៀនមួយសម្រាប់កូនចៅខ្មែរជំនាន់ក្រោយទៀត ។

លោក ហួត ថន អាយុ៦២ឆ្នាំ ក៏មានសាច់ញាតិម្នាក់ដែលត្រូវបាននាំយកមកទួលស្លែងក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ រូបថតបងប្រុសរបស់គាត់ត្រូវដាក់តាំងនៅក្នុងផ្ទាំងកញ្ចក់មួយ នៅជួរទីបួន លេខរៀងទីពីរពីខាងស្តាំ ។ ថន ដឹងថា បងប្រុសរបស់គាត់ត្រូវបានចាប់បញ្ជូនមកទួលស្លែង(មន្ទីរស-២១) នៅចុងឆ្នាំ១៩៧៨ ដោយត្រូវបានចោទប្រកាន់ពីបទបាចទឹកអាស៊ីត ។ នៅក្នុងរយៈកាលនោះប្រជាជនក្នុងខេត្តបាត់ដំបងត្រូវបានសង្ស័យថាជាជនក្បត់ ។ ថន ធ្លាប់បានឃើញរូបថតនេះម្តងនៅឆ្នាំ១៩៨២ ប៉ុន្តែនៅពេលនោះមិនទាន់មានការដាក់តាំងឲ្យបានល្អនៅឡើយទេ ។ ជាងម្ភៃឆ្នាំក្រោយមកទៀត ទើប ថន បានឃើញរូបថតជាលើកទីពីរ ។ គាត់នៅតែមានអារម្មណ៍សោកសៅដដែល ។ ការដើរទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ធ្វើឲ្យអ្នកចូលរួមទាំងអស់នឹកឃើញឡើងវិញនូវទុក្ខវេទនាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ដោយប្រឈមមុខទៅនឹងអតីតកាលឈឺចាប់ទាំងនេះ ប្រជាជនមួយចំនួនមានអារម្មណ៍ធូរស្បើយពីរឿងរ៉ាវដែលខ្លួនបានកប់ទុកជាយូរមកហើយ ។ ផែត សុខ និយាយថា ទោះជាការឈឺចាប់និងទុក្ខវេទនារបស់គាត់មិនអាចត្រូវបានលុបបំបាត់ទាំងស្រុងក៏ដោយ ក៏គាត់មានអារម្មណ៍ធូរស្រាលខ្លះដែរនៅពេលឃើញរូបថតបងប្រុសរបស់គាត់ ។

បន្ទាប់ពីបញ្ចប់ដំណើរទស្សនកិច្ចនៅទួលស្លែង ប្រជាជនទាំងអស់បានអញ្ជើញចូលរួមស្តាប់ការរៀបរាប់ពីទិដ្ឋភាពច្បាប់និងសួរសំណួរទៅកាន់ ឯកឧត្តម ម៉ោញ សាផាន (អនុប្រធានគណៈកម្មការនីតិកម្ម នៃរដ្ឋសភាជាតិ) និងលោក វ៉ាន់ថាន់ ពៅដារ៉ា (នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា) នៅក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ។ ឯកឧត្តម ម៉ោញ សាផាន ជាអ្នកដែលធ្លាប់ចូលរួមជជែកពិភាក្សាធ្វើការកែប្រែនិងអនុម័តច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។

បន្ទាប់ពី ឯកឧត្តម ម៉ោញ សាផាន និងលោក វ៉ាន់ថាន់ ពៅដារ៉ា បានរៀបរាប់ខ្លឹមសារច្បាប់រចនាសម្ព័ន្ធនិងនីតិវិធីរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារួចមកអ្នកចូលរួមទាំងអស់បានសួរសំណួរជាច្រើនទៅកាន់វាគ្មិនទាំងពីរ ។ សំណួរទាំងនោះរួមមាន តើសហគមន៍អន្តរជាតិបានដឹងថា តើអំពើប្រល័យពូជសាសន៍កំពុងតែកើតមាននៅកម្ពុជាដែរឬទេនៅពេលនោះ? បើបានដឹងហេតុអ្វីបានជាអង្គការសហប្រជាជាតិមិនមានវិធានការអ្វីទាំងអស់? តើអ្នកណាខ្លះជាមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម?

ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ប្រជាជនច្រើនម៉្លេះ? តើមេដឹកនាំខ្មែរក្រហមប៉ុន្មាននាក់ដែលនៅរស់មកដល់សព្វថ្ងៃ ហើយដែលនឹងត្រូវនាំយកមកកាត់ទោស? តើបរទេសណាខ្លះដែលនៅពីក្រោយអំពើប្រល័យពូជសាសន៍នៅកម្ពុជា? ក្នុងរយៈពេលតែមួយម៉ោងប៉ុណ្ណោះ សំណួរចម្លើយចំនួន១០ត្រូវបានចោទសួរនិងឆ្លើយ ។ ជាការពិតណាស់សំណួរមួយចំនួនពិបាកក្នុងការឆ្លើយ ។ ដោយសារពេលវេលាមានកំណត់អ្នកចូលរួមទាំងអស់ត្រូវបានស្នើឲ្យទុកសំណួរដែលខ្លួនចង់សួរសម្រាប់ថ្ងៃបន្ទាប់ ដែលពួកគាត់នឹងអញ្ជើញទៅទស្សនាអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលនៅទីនោះពួកគាត់នឹងជួបជាមួយមន្ត្រីជាន់ខ្ពស់ជាច្រើនរូបទៀត ។

នៅម៉ោង១២ថ្ងៃត្រង់ បន្ទាប់ពីទទួលអាហារថ្ងៃត្រង់រួច ក៏មានការបញ្ចាំងខ្សែភាពយន្តរឿង«មន្ទីរស-២១ ៖ ម៉ាស៊ីនសម្លាប់មនុស្សរបស់ខ្មែរក្រហម» ។ ភាពយន្តឯកសារនេះគឺជាព័ត៌មានបន្ថែមលើការទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ។


ប្រជាជនកំពុងអានវិន័យសន្តិបាលនៅគុកទួលស្លែង


ប្រជាជនចូលរួមស្តាប់ការបកស្រាយរបស់ឯកឧត្តម ម៉ោញ សាផាន


ប្រជាជនធ្វើដំណើរទស្សនកិច្ចគុកទួលស្លែង


ប្រជាជនចូលរួមស្តាប់ការបកស្រាយរបស់ឯកឧត្តម ម៉ោញ សាផាន

តាមរយៈខ្សែភាពយន្តនេះ ប្រជាជនមានឱកាសឃើញនិងស្តាប់អ្នកដែលនៅរស់រានមានជីវិតពីគុកទួលស្លែង និងអតីតកងសន្តិសុខក៏ដូចជាអតីតជាងគំនូររបស់ ប៉ុល ពត ។ ភាពយន្តឯកសារនេះចែកចេញជាច្រើនឈុត ហើយមានលក្ខណៈរន្ធត់យ៉ាងខ្លាំង ដោយបានបង្ហាញពីហេតុការណ៍ដែលជនរងគ្រោះ ប្រឈមមុខផ្ទាល់ទៅនឹងកងសន្តិសុខ ឬឈុតដែលអ្នកដែលនៅរស់រានមានជីវិតអានចម្លើយសារភាពរបស់ខ្លួន ដែលគាត់បានសរសេរក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ អ្នកចូលរួមទាំងអស់ចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះខ្សែភាពយន្តឯកសារនេះ ។

នៅម៉ោង៣រសៀល ប្រជាជនទាំងអស់បានអញ្ជើញទៅទស្សនាទីតាំងវាលពិឃាតបឹងជើងឯក ដែលជាកន្លែងអ្នកទោសនៅមន្ទីរស-២១ទាំងអស់ត្រូវបានដឹកយកមកសម្លាប់បន្ទាប់ពីបញ្ចប់ចម្លើយសារភាព ។ នៅចំពីមុខ មានបូជនីយដ្ឋានមួយខ្ពស់តម្កល់ឆ្អឹងនិងលលាដ៍ក្បាលជនរងគ្រោះដែលត្រូវបានសម្លាប់នៅជើងឯក ។ នៅពីក្រោយបូជនីយដ្ឋាននេះ មានវាលស្មៅនិងផ្កាក

សញ្ញា ជាច្រើនដែលចង្អុលបង្ហាញពីរណ្តៅសាកសពផ្សេងៗគ្នា ។ ឧទាហរណ៍ សញ្ញាខ្លះបង្ហាញពីរណ្តៅសាកសព ហើយខ្លះទៀត បង្ហាញពីដើមឈើដែលក្មេងៗត្រូវបានបោកសម្លាប់ ។ បុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជាក៏បានជួបសម្ភាសន៍ប្រជាជនមួយចំនួននៅទីនោះដែរ ។ យុន យ៉ាង អាយុ៤៧ឆ្នាំ មេភូមិមកពីខេត្តព្រៃវែង ជឿជាក់ថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងនាំមកនូវយុត្តិធម៌ជូនជនរងគ្រោះប្រមាណពីរលាននាក់ដែលបានស្លាប់ក្នុងរយៈកាលនោះ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ យ៉ាង បាត់បង់បងប្រុសម្នាក់ ឪពុកម្តាយនិងពូមីងស្ទើរតែទាំងអស់ ។ មុនដំណើរទស្សនកិច្ច យ៉ាង មិនប្រាកដក្នុងចិត្តថានឹងមានការកាត់ទោសទេ ពីព្រោះគាត់គ្រាន់តែឮពីនេះពីនោះអំពីវត្តមាននៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ប៉ុន្តែ បន្ទាប់ពីបានដើរទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង និងបានស្តាប់ការបកស្រាយច្បាប់ពីសំណាក់ឯកឧត្តម ម៉ោញ សាផាន រួចមក យ៉ាង ជឿជាក់ថាមានតុលាការមួយពិតជាត្រូវបានបង្កើតឡើងមែន ហើយគាត់ចង់ចូលរួមក្នុងដំណើរការកាត់សេចក្តីដែរ ។

ជាងនេះទៅទៀត យ៉ាង បាននិយាយថា នៅពេលគាត់ត្រឡប់ទៅភូមិឃុំវិញ គាត់នឹងចែករំលែកព័ត៌មានដែលគាត់ទទួលបានទៅអ្នកភូមិដែលមិនបានមកចូលរួម ។ ដំណើរទៅកាន់វាលពិឃាតជើងឯកគឺជាសកម្មភាពចុងក្រោយនៃដំណើរទស្សនកិច្ចនៅខែកញ្ញានេះ ។ បន្ទាប់មក អ្នកភូមិទាំងអស់បានអញ្ជើញទៅពិសាអាហារពេលល្ងាចនៅភោជនីយដ្ឋាន ។


ប្រជាជនដើរទស្សនាកន្លែងសម្លាប់នៅវាលពិឃាតបឹងជើងឯក


ប្រជាជនសួរសំណួរទៅកាន់មន្ត្រីតុលាការ


ប្រជាជនដើរទស្សនាកន្លែងសម្លាប់នៅវាលពិឃាតបឹងជើងឯក


ប្រជាជនក្នុងអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ថ្ងៃទីពីរគឺជាដំណើរទស្សនកិច្ចទៅកាន់អគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ អ្នកចូលរួមទាំងអស់បានជួបសំណេះសំណាលជាមួយមន្ត្រីជាន់ខ្ពស់នៅទីនោះ និងត្រូវបានផ្តល់ឱកាសឲ្យសួរសំណួរ ។ កម្មវិធីនេះចាប់ផ្តើមនៅពេលព្រឹកនៅក្នុងអគារតុលាការដែលអាចផ្ទុកមនុស្សបានប្រហែល៦០០នាក់ ។ លោក រាជ សម្បត្តិ មន្ត្រីព័ត៌មាននៃអង្គជំនុំជម្រះវិសាមញ្ញបានថ្លែងសុន្ទរកថាស្វាគមន៍និងពន្យល់អំពីច្បាប់និងរចនាសម្ព័ន្ធ

តុលាការ ។ ក្រោយមក ប្រធានរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ គឺ លោក ស៊ាន វិសុទ្ធ និងអនុប្រធានរដ្ឋបាល លោកស្រី មីសែល លី ក៏បានចូលរួមថ្លែងសុន្ទរកថាស្វាគមន៍ដែរ ។ លោក រាជ សម្បត្តិ បានឆ្លើយចំពោះសំណួរទាំងឡាយដែលប្រជាជនចោទសួរ ។ ប្រជាជនបានសួរសំណួរជាច្រើនដូចជា ៈ តើច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមមានប្រភពមកពីណា? ហេតុអ្វីបានជាអង្គការសហប្រជាជាតិអនុញ្ញាតឲ្យក្រុមខ្មែរក្រហមកាន់កាប់អាសនៈរបស់កម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិ? អ្នកណាជាអ្នកទទួលខុសត្រូវនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ? អ្នកភូមិមួយចំនួន (ដែលក្នុងនោះមានដូនជីម្នាក់ផង) បានរៀបរាប់ពីរឿងរ៉ាវផ្ទាល់ខ្លួន ដែលគាត់បានជួបប្រទះក្នុងរយៈកាលប្រល័យពូជសាសន៍ ។

សកម្មភាពនៃដំណើរទស្សនកិច្ចលើកនេះត្រូវបានផ្សព្វផ្សាយដោយបណ្តាសារព័ត៌មានជាតិនិងអន្តរជាតិជាច្រើនរួមមាន សារព័ត៌មានអា-អេហ្វ-ប៉េ កាសែតរស្មីកម្ពុជា និងកាសែតកាំបូជស័រជាដើម ។

សកម្មភាពដំណើរទស្សនកិច្ចលើកទី៨បានដំណើរការទៅដូចប្រក្រតី ។ ក្នុងចំណោមអ្នកដែលត្រូវបានអញ្ជើញចំនួន៥៥៨នាក់ ឬ៩១ភាគរយ មាន៥១០នាក់បានមកចូលរួមដំណើរទស្សនកិច្ចនេះ ។ ទោះបីជាយ៉ាងណាក៏ដោយនឹងមានការកែលម្អប្រសើរជាងនេះសម្រាប់ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញលើកក្រោយទៀត ។ ទាក់ទិននឹងទំនាក់ទំនងជាមួយអ្នកស្រុកអ្នកភូមិ មានការយល់ច្រឡំបន្តិចបន្តួចពីអ្នកស្រុកម្នាក់ ដែលគាត់បានគិតថាមជ្ឈមណ្ឌលឯកសារកម្ពុជានឹងផ្តល់មធ្យោបាយធ្វើដំណើរពីលំនៅដ្ឋានរបស់គាត់មកកាន់ទីក្រុងភ្នំពេញ ។ លិខិតអញ្ជើញត្រូវបានផ្ញើជូនទៅឲ្យសាលាស្រុក ហើយមេភូមិជាអ្នកទទួលសំបុត្រអញ្ជើញទាំងនោះ ។ ព័ត៌មានទាក់ទិននឹងពេលវេលា ទីកន្លែងភស្តុភារ និងសកម្មភាពផ្សេងៗនៃដំណើរទស្សនកិច្ចនេះ គឺមាននៅក្នុងលិខិតអញ្ជើញជាស្រេច ដូចនេះមេឃុំមាននាទីបញ្ជូនលិខិតទៅឲ្យអ្នកស្រុកអ្នកភូមិដែលត្រូវបានអញ្ជើញ ។ ដើម្បីកាត់បន្ថយការទាក់ទងមិនត្រឹមត្រូវទៅថ្ងៃក្រោយ មជ្ឈមណ្ឌលឯកសារកម្ពុជាសង្កត់ទៅលើសារសំខាន់របស់មេឃុំក្នុងការពន្យល់បញ្ហាទាំងនេះដល់ប្រជាជនដែលត្រូវបានអញ្ជើញ ។ បញ្ហាតូចមួយទៀត គឺការកំណត់ពេលវេលាដំណើរទស្សនកិច្ច ។ នៅថ្ងៃទី១នៃដំណើរទស្សនកិច្ច អ្នកចូលរួមទាំងអស់ទស្សនាភាពយន្តឯកសារភ្លាមបន្ទាប់ពីបរិភោគអាហារថ្ងៃត្រង់រួច ។ ក្នុងនោះដែរ អ្នកចូលរួមខ្លះគេង ជាពិសេសអ្នកចូលរួមដែលមានវ័យចំណាស់ ដែលជាទម្លាប់ធម្មតារបស់ប្រជាពលរដ្ឋខ្មែរដែលត្រូវសម្រាកបន្ទាប់ពីការបរិភោគអាហារថ្ងៃត្រង់រួច ។ ដើម្បីដោះស្រាយបញ្ហានេះ សកម្មភាពបញ្ចាំងខ្សែភាពយន្តនិងការទស្សនាវាលពិឃាតបឹងជើងឯកត្រូវបានធ្វើការកែប្រែ ។

បន្ទាប់ពីការបរិភោគអាហារថ្ងៃត្រង់ អ្នកស្រុកអ្នកភូមិធ្វើដំណើរទៅកាន់វាលពិឃាតបឹងជើងឯក ដែលនៅទីនោះពួកគាត់អាចដើរលំហែបាន និងបន្ទាប់មកវិលត្រឡប់ទៅសកលវិទ្យាល័យភូមិន្ទភ្នំពេញ២ ដើម្បីទស្សនាខ្សែភាពយន្តឯកសារ ។ បញ្ហាចុងក្រោយដែលត្រូវបានកែសម្រួលល្អប្រសើរនោះ គឺដំណើរទស្សនកិច្ចទៅជួបមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានៅថ្ងៃទីពីរនៃដំណើរទស្សនកិច្ចនេះ ។ ជាកិត្តិយសសម្រាប់អ្នកស្រុកអ្នកភូមិដែលបានជួបសំណេះសំណាលជាមួយប្រធាន និងអនុប្រធានការិយាល័យរដ្ឋបាល ក៏ប៉ុន្តែប្រធាននិងអនុប្រធានការិយាល័យមានពេលវេលាខ្លីពេក ហើយពួកគាត់បានចាកចេញមុនការសួរសំណួរបន្តទៅទៀត ។ ក្នុងថ្ងៃអនាគតប្រសិនបើអាចធ្វើទៅបានយើងសង្ឃឹមយ៉ាងមុតមាំថាមន្ត្រីអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានឹងនៅជួបសំណេះសំណាលយូរជាងនេះ យ៉ាងហោចណាស់អាចឆ្លើយបាននូវសំណួរពីរបីដែរ ។ ប្រការនេះនឹងមិនត្រឹមតែជួយកែលម្អនូវគុណភាពនៃចម្លើយទេ ថែមទាំងធ្វើឲ្យអ្នកស្រុកអ្នកភូមិយល់ថា វាមានសារសំខាន់ណាស់ក្នុងការដែលបានមើលឃើញដោយផ្ទាល់នូវទីតាំងអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងពង្រឹងការជឿទុកចិត្តរបស់ពួកគាត់ទៅលើតុលាការនេះ ។ មជ្ឈមណ្ឌលឯកសារកម្ពុជាមានគម្រោងតាមដាន ដើម្បីធ្វើការវាយតម្លៃយ៉ាងពេញលេញនូវភាពខ្លាំងនិងខ្សោយរបស់មជ្ឈមណ្ឌល ព្រមទាំងធ្វើការវាយតម្លៃទៅលើផលប៉ះពាល់ផ្សេងៗទៅលើអ្នកចូលរួមដំណើរទស្សនកិច្ចនេះ ។

**កែវ ដាស៊ីល**

# សេចក្តីសម្រេចអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ស្តីពីគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបាននូវដំណោះស្រាយ និងសំណងលើការខូចខាតសម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើ ច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ

***មហាសន្និបាតអង្គការសហប្រជាជាតិ***

*ដោយយោងលើធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្ស លិខិតូបករណ៍សិទ្ធិមនុស្សដែលពាក់ព័ន្ធផ្សេងៗ និងសេចក្តីប្រកាសទីក្រុងវីយែននិងកម្មវិធីសកម្មភាពធ្វើដោយផ្ទាល់ ។*

*ដោយអះអាងបញ្ជាក់អំពីសារសំខាន់នៃការដោះស្រាយនូវបញ្ហាដំណោះស្រាយនិងសំណងលើការខូចខាតសម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិក្នុងលក្ខណៈជាប្រព័ន្ធនិងហ្មត់ចត់នៅក្នុងកម្រិតជាតិនិងអន្តរជាតិ ។*

*ដោយទទួលស្គាល់ថា ដោយគោរពសិទ្ធិជនរងគ្រោះក្នុងការទទួលបានអត្ថប្រយោជន៍ពីដំណោះស្រាយនិងការជួសជុលសំណងលើការខូចខាត សហគមន៍អន្តរជាតិត្រូវឈរលើគោលការណ៍មិនលម្អៀងចំពោះស្ថានភាពអាក្រក់របស់ជនរងគ្រោះ អ្នករស់រានមានជីវិតនិងជនជំនាន់ក្រោយ និងត្រូវធានាឡើងវិញនូវច្បាប់អន្តរជាតិដែលទាក់ទិននឹងរឿងនោះ ។*

*ដោយរំឭកឡើងវិញនូវការអនុម័តគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបាននូវដំណោះស្រាយនិងការជួសជុលសំណងលើការខូចខាតសម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ដោយគណៈកម្មការទទួលបន្ទុកសិទ្ធិមនុស្សក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ២០០៥/៣៥ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៥ និងដោយក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមក្នុងសេចក្តីសម្រេចរបស់ខ្លួនលេខ២០០៥/៣០ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៥ ដែលក្រុមប្រឹក្សាសេដ្ឋកិច្ចនិងសង្គមដាក់ជូនមហាសន្និបាតអង្គការសហប្រជាជាតិ អនុម័តគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំនេះ ។*

*អនុម័តគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំស្តីពីសិទ្ធិទទួលបាននូវដំណោះស្រាយនិងការជួសជុលសំណងលើការខូចខាតសម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិដែលត្រូវបានបន្ថែមទៅក្នុងសេចក្តីសម្រេចបច្ចុប្បន្ននេះ ។*

*ផ្តល់អនុសាសន៍ទៅឲ្យរដ្ឋទាំងឡាយត្រូវពិនិត្យពិចារណាអំពីគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំនេះ ត្រូវជំរុញឲ្យមានការគោរព និងត្រូវផ្សព្វផ្សាយឲ្យសមាជិកអង្គនីតិប្រតិបត្តិបានដឹង ជាពិសេស មន្ត្រីអនុវត្តច្បាប់ កងកម្លាំងសន្តិសុខ កងកម្លាំងយោធា អង្គនីតិបញ្ញត្តិតុលាការ ជនរងគ្រោះ និងតំណាងជនរងគ្រោះ ក្រុមច្បាប់ការពារសិទ្ធិមនុស្សនិងមេធាវី បណ្តាញផ្សព្វផ្សាយព័ត៌មាននិងសាធារណជន ។*

*ស្នើសុំលោកអគ្គលេខាធិការចាត់វិធានការក្នុងការធានាឲ្យមានការផ្សព្វផ្សាយយ៉ាងទូលំទូលាយស្តីពីគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំគ្រប់ភាសាទាំងអស់នៃសមាជិកអង្គការសហប្រជាជាតិ ដោយរាប់បញ្ចូលទាំងការចម្លងគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំនេះជូនទៅរាជរដ្ឋាភិបាល អង្គការអន្តររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល និងការបញ្ចូល គោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំនេះទៅក្នុងការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិដែលមានឈ្មោះថា សិទ្ធិមនុស្ស ៖ កម្រងលិខិតូបករណ៍ច្បាប់អន្តរជាតិ*

*សម័យប្រជុំពេញអង្គលើកទី៦៤*

*ថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០០៥*

**បុព្វកថា** ៖ *មហាសន្និបាតអង្គការសហប្រជាជាតិ*

*ដោយរំព្ញកឡើងវិញនូវបទប្បញ្ញត្តិស្តីអំពីសិទ្ធិទទួលបាននូវដំណោះស្រាយសំណងលើការខូចខាតសម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលមានចែងក្នុងលិខិតូបករណ៍ច្បាប់អន្តរជាតិជាច្រើន ជាពិសេសមាត្រា៨នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២នៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ មាត្រា៦នៃអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ មាត្រា១៤នៃអនុសញ្ញាប្រឆាំងអំពើទារុណកម្មនិងការផ្តន្ទាទោសឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស មាត្រា៣៩នៃអនុសញ្ញាស្តីពីសិទ្ធិរបស់កុមារ និងច្បាប់មនុស្សធម៌អន្តរជាតិដែលមានចែងក្នុងមាត្រា៣នៃអនុសញ្ញាទីក្រុងឡាអេទាក់ទិននឹងច្បាប់សង្គ្រាមនិងទំនៀមទម្លាប់សង្គ្រាមដែនគោក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ១៩០៧ (អនុសញ្ញាទី៤) មាត្រា៩១នៃពិធីសារបន្ថែមទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងទាក់ទិននឹងការការពារជនរងគ្រោះដោយជម្លោះប្រដាប់អាវុធអន្តរជាតិ (ពិធីសារបន្ថែមទី១) ចុះថ្ងៃទី៨ ខែមិថុនា ឆ្នាំ១៩៧៧ និងមាត្រា៦៨និង៧៥នៃលក្ខន្តិកៈ ទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ។*

*ដោយរំព្ញកឡើងវិញនូវបទបញ្ញត្តិស្តីពីសិទ្ធិទទួលបាននូវដំណោះស្រាយសំណងលើការខូចខាតសម្រាប់ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើសិទ្ធិមនុស្សអន្តរជាតិដែលមានចែងនៅក្នុងអនុសញ្ញាតំបន់ ជាពិសេសក្នុងមាត្រា៧នៃធម្មនុញ្ញអាហ្វ្រិកស្តីពីសិទ្ធិមនុស្សនិងសិទ្ធិប្រជាជន មាត្រា២៥នៃអនុសញ្ញាអាមេរិកស្តីពីសិទ្ធិមនុស្ស និងមាត្រា១៣នៃអនុសញ្ញាស្តីពីការការពារសិទ្ធិមនុស្សនិងសិទ្ធិសេរីភាពជាសារវន្ត ។*

*ដោយរំព្ញកឡើងវិញនូវសេចក្តីប្រកាសនៃគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសម្រាប់ជនរងគ្រោះដោយអំពើឧក្រិដ្ឋកម្មនិងការរំលោភបំពានលើសិទ្ធិអំណាចដែលមានប្រភពចេញពីការពិភាក្សាយ៉ាងហ្មត់ចត់របស់សភាលើកទី៧របស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់អំពើឧក្រិដ្ឋកម្មនិងការប្រព្រឹត្តរបស់ឧក្រិដ្ឋជន និងសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ ៤០/៣៤ ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ដែលមហាសន្និបាតអង្គការសហប្រជាជាតិបានអនុម័តគ្រន់ដែលស្មើដោយសម័យប្រជុំពិសេស ។*

*ដោយអះអាងបញ្ជាក់ឡើងវិញថាគោលការណ៍នេះមានចែងនៅក្នុងសេចក្តីប្រកាសនៃគោលការណ៍យុត្តិធម៌ជាមូលដ្ឋានសម្រាប់ជនរងគ្រោះដោយអំពើឧក្រិដ្ឋកម្មនិងដោយការរំលោភបំពានលើសិទ្ធិអំណាច ដោយរាប់បញ្ចូលដែលថា ជនរងគ្រោះទទួលបាននូវសេចក្តីអាណិតអាសូរនិងការគោរពដល់សេចក្តីថ្លៃថ្នូររបស់ខ្លួន មានសិទ្ធិទទួលបាននូវយុត្តិធម៌ និងទទួលបាននូវយន្តការដែលត្រូវបានគោរពយ៉ាងពេញលេញ និងទាំងការបង្កើតការពង្រីង និងការបន្ថែមថវិកាជាតិសម្រាប់ជាសំណងជូនដល់ជនរងគ្រោះត្រូវផ្តល់ការលើកទឹកចិត្តរួមគ្នាជាមួយនឹងការបង្កើតឲ្យបានឆាប់នូវសិទ្ធិនិងដំណោះស្រាយសមស្របសម្រាប់ជនរងគ្រោះ ។*


អ្នកស្រុកកំពុងមើលរូបថតអ្នកទោសដែលដាក់តាំ

*ដោយកត់សម្គាល់ឃើញថាលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិតម្រូវឲ្យមានការបង្កើត “គោលការណ៍ទាំងឡាយដែលទាក់ទិននឹងការជួសជុលសំណងលើការខូចខាតដល់ឬចំពោះជនរងគ្រោះ រួមមានបដិទាន ការសងជំងឺចិត្ត និងការស្តារកាយនីតិសម្បទា” តម្រូវឲ្យសភានៃភាគីរដ្ឋបង្កើតមូលនិធិស្ម័គ្រចិត្តដើម្បីជាប្រយោជន៍ដល់ជនរងគ្រោះដោយអំពើឧក្រិដ្ឋកម្មនៅក្នុងដែនយុត្តាធិការរបស់តុលាការនិងផ្តល់អាណត្តិឲ្យតុលាការ “ក្នុងការការពារសុវត្ថិភាព សុខុមាលភាពផ្នែករូបរាងកាយនិងផ្លូវចិត្ត សេចក្តីថ្លៃថ្នូរ និងភាពជាឯកជនរបស់ជនរងគ្រោះ» និងដើម្បីទុកឱកាសឲ្យជនរងគ្រោះចូលរួមក្នុង“គ្រប់ដំណាក់កាលនៃដំណើរការកាត់សេចក្តីដែលតុលាការបានកំណត់ថាមានភាពត្រឹមត្រូវ ។*

ដោយបញ្ជាក់ថាគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំដែលមានចែងនៅទីនេះ ទាក់ទិនផ្ទាល់ទៅនឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ដែលប្រមាថមើលងាយយ៉ាងធ្ងន់ធ្ងរដល់សេចក្តីថ្លៃថ្នូរបស់មនុស្ស ។

ដោយសង្កត់ធ្ងន់ថាគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំដែលមានចែងនៅទីនេះមិនបានចែងយ៉ាងលម្អិតអំពីកាតព្វកិច្ចច្បាប់ជាតិឬអន្តរជាតិថ្មីទេ ក៏ប៉ុន្តែបង្ហាញពីយន្តការបែបបទនីតិវិធី និងវិធីទាំងឡាយសម្រាប់ការអនុវត្តកាតព្វកិច្ចច្បាប់ដែលមានស្រាប់តាមច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិដែលបំពេញបន្ថែមទៅលើបទដ្ឋាននៃគោលការណ៍ទាំងនេះ បើទោះបីជាមានភាពខុសប្លែកគ្នាទៅនឹងបទដ្ឋាននេះក៏ដោយ ។


ងនៅក្នុងបន្ទប់នៅមន្ទីរ ស-២១

ដោយរំឭកឡើងវិញថាច្បាប់អន្តរជាតិមានកាតព្វកិច្ចវិនិច្ឆ័យទោសឧក្រិដ្ឋជនលើឧក្រិដ្ឋកម្មអន្តរជាតិ ដោយអនុលោមតាមកាតព្វកិច្ចអន្តរជាតិនៃភាគីរដ្ឋនិងការតម្រូវឲ្យមានក្នុងច្បាប់ជាតិ ឬដូចដែលមានចែងក្នុងលក្ខន្តិកៈនៃអង្គការយុត្តិធម៌អន្តរជាតិ និងដោយរំឭកឡើងវិញថាករណីយកិច្ចក្នុងការវិនិច្ឆ័យទោស ជួយពង្រឹងបន្ថែមនូវការអនុវត្តកាតព្វកិច្ចច្បាប់អន្តរជាតិដោយអនុលោមតាមតម្រូវការនិងនីតិវិធីនៃច្បាប់ជាតិ និងគាំទ្រគំនិតបំពេញបន្ថែម ។

ដោយកត់សម្គាល់ឃើញថា ទម្រង់នៃការនាំឲ្យមានជនរងគ្រោះបច្ចុប្បន្ន បើទោះបីជាទម្រង់នេះ ប្រឆាំងនឹងជាពិសេសបុគ្គលមួយចំនួន ក៏អាចប្រឆាំងនឹងក្រុមនៃបុគ្គលដែលជាមុខសញ្ញារួមដែរ ។

ដោយទទួលស្គាល់ថា ដោយគោរពសិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវដំណោះស្រាយនិងសំណងលើការខូចខាត សហគមន៍អន្តរជាតិឈរលើគោលការណ៍យុត្តិធម៌ ចំពោះស្ថានភាពអាក្រក់របស់ជនរងគ្រោះ អ្នកដែលនៅរស់រានមានជីវិត និងអ្នកជំនាន់ក្រោយៗទៀត និងត្រូវអះអាងបញ្ជាក់ឡើងវិញនូវគោលការណ៍ច្បាប់អន្តរជាតិនៃការទទួលខុសត្រូវ យុត្តិធម៌ និងនីតិរដ្ឋ ។

ដោយជឿទុកចិត្តថា ដោយអនុម័តយល់ព្រមទស្សនវិស័យរបស់ជនរងគ្រោះ សហគមន៍អន្តរជាតិត្រូវបញ្ជាក់ពីភាពរឹងប៉ឹងរបស់ខ្លួនចំពោះជនរងគ្រោះដោយការរំលោភបំពានលើច្បាប់អន្តរជាតិ ដោយរាប់បញ្ចូលទាំងការរំលោភបំពានលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ព្រមទាំងចំពោះមនុស្សជាតិយ៉ាងទូលំទូលាយដោយអនុលោមទៅតាមគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំដូចខាងក្រោម ។

អនុម័តគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំដូចខាងក្រោម ៖

## ១) កាតព្វកិច្ចក្នុងការគោរព ធានាឲ្យមានការគោរព និងអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ

កាតព្វកិច្ចក្នុងការគោរព ធានាឲ្យមានការគោរព និងអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ដូចដែលមានចែងក្នុងអង្គការនៃច្បាប់រៀងៗខ្លួនដែលមានប្រភពមកពី ៖ ក) សន្ធិសញ្ញាដែលមានរដ្ឋជាភាគីជាសមាជិក ខ) ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង គ) ច្បាប់ជាតិនៃភាគីរដ្ឋនីមួយៗ ។

ប្រសិនបើភាគីរដ្ឋពុំមានច្បាប់ចែងអំពីកាតព្វកិច្ចក្នុងការគោរព ធានាឲ្យមានការគោរព និងអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរ-ជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ដូចដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ ភាគីរដ្ឋត្រូវធានាថាច្បាប់ជាតិរបស់ខ្លួនមានលក្ខណៈសមស្របទៅតាមកាតព្វកិច្ចច្បាប់អន្តរជាតិតាមរយៈ ៖ ក) ការបញ្ចូលបទដ្ឋាននៃច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិទៅក្នុងច្បាប់ជាតិរបស់ខ្លួន ឬអនុវត្តបទដ្ឋានទាំងនេះនៅក្នុងប្រព័ន្ធច្បាប់ជាតិរបស់ខ្លួន ខ) ការអនុម័តនីតិវិធីរដ្ឋបាលនិងបញ្ញត្តិដែលសមស្របនិងមានប្រសិទ្ធភាព និងវិធានការសមស្របផ្សេងៗទៀតដែលផ្តល់នូវសិទ្ធិទទួលបាននូវយុត្តិធម៌យ៉ាង

ត្រឹមត្រូវយ៉ាងមានប្រសិទ្ធភាព និងយ៉ាងទៀតទាត់ គ) ដំណោះស្រាយយ៉ាងត្រឹមត្រូវយ៉ាងមានប្រសិទ្ធភាពយ៉ាងទៀងទាត់ និងយ៉ាងសមស្រប ដោយរាប់បញ្ចូលទាំងសំណងលើការខូចខាត ដូចដែលកំណត់យ៉ាងច្បាស់ខាងក្រោមនេះ និង ឃ) ការធានាដែលថាច្បាប់ជាតិត្រូវការពារជនរងគ្រោះយ៉ាងហោចណាស់ដូចនឹងកម្រិតការការពារដែលតម្រូវឲ្យមាននៅក្នុងកាតព្វកិច្ចអន្តរជាតិដែរ ។

## ២) វិសាលភាពនៃកាតព្វកិច្ច

កាតព្វកិច្ចក្នុងការគោរព ធានាឲ្យមានការគោរព និងអនុវត្តច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ដូចដែលមានចែងនៅក្នុងអង្គការនៃច្បាប់រៀងៗខ្លួន រួមមានករណីយកិច្ចក្នុងការ ៖ ក) ចាត់វិធានការច្បាប់និងរដ្ឋបាលដែលសមស្រប និងវិធានការដែលសមស្របផ្សេងៗទៀតក្នុងការទប់ស្កាត់ការរំលោភបំពាន ខ) ស៊ើបអង្កេតការរំលោភបំពានទាំងឡាយយ៉ាងមានប្រសិទ្ធភាពទៀងទាត់ ហ្មត់ចត់ និង មិនលម្អៀង និងនៅពេលដែលមានលក្ខណៈសមស្រប ចាត់វិធានការប្រឆាំងនឹងជនដែលប្រព្រឹត្តខុសច្បាប់ដោយអនុលោមទៅតាមច្បាប់ជាតិនិងអន្តរជាតិ គ) ផ្តល់ជនដែលបណ្តឹងតវ៉ាថាខ្លួនជាជនរងគ្រោះដោយការរំលោភបំពានលើច្បាប់សិទ្ធិមនុស្សឬច្បាប់មនុស្សធម៌នូវសិទ្ធិស្មើគ្នា និងមានប្រសិទ្ធភាពក្នុងការទទួលបាននូវយុត្តិធម៌ ដូចដែលបានរៀបរាប់ខាងក្រោមនេះ ដោយមិនគិតថាចុងក្រោយជននោះជាអ្នកទទួលខុសត្រូវចំពោះការរំលោភបំពាននេះទេ និង ឃ) ផ្តល់ដំណោះស្រាយសំណងលើការខូចខាតដែលមានប្រសិទ្ធភាពដល់ជនរងគ្រោះ ដោយរាប់បញ្ចូលទាំងសំណងលើការខូចខាត ដូចដែលមានរៀបរាប់ខាងក្រោមនេះ ។

## ៣) ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌អន្តរជាតិដែលក្លាយជាអំពើឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ

នៅក្នុងរឿងក្តីនៃការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌ អន្តរជាតិដែលក្លាយជាអំពើឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិ ភាគីរដ្ឋមានករណីយកិច្ចស៊ើបអង្កេតរឿងក្តីនេះ និងប្រសិនបើមានភ័ស្តុតាងត្រឹមត្រូវនិងគ្រប់គ្រាន់ ភាគីរដ្ឋមានករណីយកិច្ចបញ្ជូនភ័ស្តុតាងទាំងនេះទៅព្រះរាជអាជ្ញាជំនុំជម្រះទោសជនដែលទទួលខុសត្រូវការរំលោភបំពានលើច្បាប់នេះ និងប្រសិនបើរកឃើញថាមានទោស ភាគីរដ្ឋមានករណីយកិច្ចដាក់ទោសឧក្រិដ្ឋជននេះ ។ ជាងនេះទៀត ក្នុងករណីនេះ ដោយអនុលោមទៅតាមច្បាប់អន្តរជាតិ ភាគីរដ្ឋត្រូវសហប្រតិបត្តិការគ្នាទៅវិញទៅមក និងជួយអង្គការយុត្តិធម៌អន្តរជាតិដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត និងការជំនុំជម្រះទោសចំពោះការរំលោភច្បាប់ទាំងនេះ ។

ដោយហេតុនេះ ដូចមានចែងនៅក្នុងសន្ធិសញ្ញាដែលកំពុងតែអនុវត្តសព្វថ្ងៃ ឬតាមកាតព្វកិច្ចច្បាប់ អន្តរជាតិផ្សេងៗទៀត ភាគីរដ្ឋត្រូវបញ្ចូល ឬបន្ថែមទៅក្នុងច្បាប់ជាតិរបស់ខ្លួនដែលសមស្របតាមបទបញ្ញត្តិស្តីពីដែនយុត្តាធិការសកល ។ ម្យ៉ាងវិញទៀត ដោយមានចែងនៅក្នុងសន្ធិសញ្ញាដែលកំពុងតែអនុវត្តសព្វថ្ងៃ ឬក្នុងកាតព្វកិច្ចច្បាប់អន្តរជាតិផ្សេងៗទៀត ភាគីរដ្ឋត្រូវជួយសម្រួលដល់ការផ្តល់បត្យាប័ន ឬត្រូវប្រគល់ឧក្រិដ្ឋជនទៅឲ្យភាគីរដ្ឋផ្សេងៗទៀត និងទៅឲ្យអង្គការយុត្តិធម៌ អន្តរជាតិដែលសមស្រប និងផ្តល់ជំនួយយុត្តិធម៌និងទម្រង់ផ្សេងៗទៀតនៃកិច្ចសហប្រតិបត្តិការ ដែលទាក់ទិននឹងយុត្តិធម៌អន្តរជាតិ ដោយរាប់បញ្ចូលទាំងការជួយនិងការការពារដល់ជនរងគ្រោះ និងសាក្សី ស្របតាមបទដ្ឋានច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងស្របទៅនឹងសេចក្តីសម្រេចនៃច្បាប់អន្តរជាតិ ដូចជាច្បាប់ស្តីពីការហាមប្រាមមិនឲ្យមានអំពើទារុណកម្ម និងការប្រព្រឹត្តឬទណ្ឌកម្មយ៉ាងឃោរឃៅ អមនុស្សធម៌ ឬដែលធ្វើឲ្យបាត់បង់តម្លៃជាមនុស្ស ។

## ៤) ការកំណត់លក្ខន្តិកៈ

ដូចមានចែងនៅក្នុងសន្ធិសញ្ញាដែលកំពុងតែអនុវត្តសព្វថ្ងៃ ឬក្នុងកាតព្វកិច្ចច្បាប់អន្តរជាតិផ្សេងៗទៀត ការកំណត់លក្ខន្តិកៈមិនត្រូវបានយកមកអនុវត្តចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិដែលជាអំពើឧក្រិដ្ឋកម្មក្រោមច្បាប់អន្តរជាតិនោះឡើយ ។

ការកំណត់លក្ខន្តិកៈជាតិសម្រាប់ប្រភេទផ្សេងៗនៃការរំលោភបំពានដែលមិនមែនជាអំពើឧក្រិដ្ឋកម្ម ក្រោមច្បាប់អន្តរ

ជាតិ ដោយរាប់បញ្ចូលទាំងការកំណត់ពេលវេលាដែលអនុវត្តចំពោះបណ្តឹងតវ៉ា ផ្នែករដ្ឋប្បវេណីនិងនីតិវិធីផ្សេងៗទៀតមិនត្រូវបានរឹតត្បិតជ្រុលពេកទេ ។

### ៥) ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ

សម្រាប់គោលបំណងនៃគោលការណ៍នេះ ជនរងគ្រោះគឺជាបុគ្គលទាំងឡាយដែលទទួលរងផលប៉ះពាល់មកលើរូបខ្លួនឯងផ្ទាល់ ឬដោយសមូហភាពនូវការខូចខាតខាងរាងកាយឬផ្លូវចិត្ត ការឈឺចាប់ក្នុងអារម្មណ៍ ការខូចប្រយោជន៍ខាងសេដ្ឋកិច្ច ឬខូចខាតនូវសិទ្ធិជាសារវន្តតាមរយៈអំពើ ឬការលុបបំបាត់ចោល ដែលក្លាយជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងទៅលើច្បាប់មនុស្សធម៌អន្តរជាតិ ។ នៅពេលដែលមានលក្ខណៈសមស្របនិងដោយអនុលោមទៅតាមច្បាប់ជាតិ ពាក្យថា “ជនរងគ្រោះ” ក៏រាប់បញ្ចូលទាំងក្រុមគ្រួសារផ្ទាល់ឬអ្នកនៅក្រោមបន្ទាប់របស់ជនរងគ្រោះផ្ទាល់ និងបុគ្គលដែលទទួលរងនូវផលប៉ះពាល់ដោយការធ្វើអន្តរាគមន៍ជួយដល់ជនរងគ្រោះដែលស្ថិតក្នុងសភាពគ្រោះថ្នាក់ឬជួយទប់ស្កាត់ការធ្វើឲ្យរងគ្រោះ ។

បុគ្គលម្នាក់ត្រូវបានចាត់ទុកថាជាជនរងគ្រោះ ដោយមិនគិតថាជនដៃដល់នៃការរំលោភបំពាននេះ ត្រូវបានរកឃើញ ចាប់ខ្លួន កាត់ទោស ឬដាក់ទោស និងដោយមិនគិតអំពីទំនាក់ទំនងគ្រួសាររវាងជនដៃដល់និងជនរងគ្រោះ ។

### ៦) ការថែរក្សាជនរងគ្រោះ

ត្រូវថែរក្សាជនរងគ្រោះដោយមនុស្សធម៌និងដោយមានការគោរពចំពោះសិទ្ធិនិងសេចក្តីថ្លៃថ្នូររបស់ជនរងគ្រោះ និងត្រូវចាត់វិធានការដែលសមស្របក្នុងការធានាសុវត្ថិភាព សុខុមាលភាពផ្នែករាងកាយនិងផ្លូវចិត្ត និងសិទ្ធិរបស់ជនរងគ្រោះ ព្រមទាំងសុវត្ថិភាព សុខុមាលភាពផ្នែករាងកាយនិងផ្លូវចិត្ត និងសិទ្ធិរបស់ក្រុមគ្រួសារនៃជនរងគ្រោះ ។ ភាគីរដ្ឋត្រូវធានាឲ្យបានថាច្បាប់ជាតិរបស់ខ្លួនមានចែងថា ជនរងគ្រោះដែលទទួលរងនូវអំពើហិង្សាឬការប៉ះទង្គិចផ្លូវចិត្តត្រូវតែទទួលបាននូវផលប្រយោជន៍ពីការគិតពិចារណាពិសេសនិងការថែទាំពិសេសដើម្បីបញ្ចៀសការវិលត្រឡប់មកវិញនូវការប៉ះទង្គិចផ្លូវចិត្តទៅតាមនីតិវិធីរដ្ឋបាលនិងច្បាប់ដែលត្រូវបានបង្កើតដើម្បីផ្តល់យុត្តិធម៌និងសំណងលើការខូចខាត ។

### ៧) សិទ្ធិរបស់ជនរងគ្រោះក្នុងការទទួលបាននូវដំណោះស្រាយសំណងលើការខូចខាត

ដំណោះស្រាយសំណងលើការខូចខាតចំពោះការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ រួមមានសិទ្ធិរបស់ជនរងគ្រោះក្រោមច្បាប់អន្តរជាតិក្នុងការទទួលបាននូវ ៖ ក) សិទ្ធិស្មើភាពគ្នានិងប្រកបដោយប្រសិទ្ធភាពក្នុងការទទួលបាននូវយុត្តិធម៌ ខ) ការជួសជុលសំណងគ្រប់គ្រាន់ មានប្រសិទ្ធភាពនិងទៀងទាត់ ទៅលើការទទួលរងនូវផលប៉ះពាល់ និង គ) សិទ្ធិទទួលបាននូវព័ត៌មានស្តីអំពីការរំលោភបំពាននិងយន្តការជួសជុលសំណង ។

### ៨) សិទ្ធិទទួលបាននូវយុត្តិធម៌

ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិត្រូវមានសិទ្ធិស្មើគ្នាក្នុងការទទួលបាននូវដំណោះស្រាយសំណងលើការខូចខាតដោយយុត្តិធម៌និងមានប្រសិទ្ធភាពដែលមានចែងនៅក្នុងច្បាប់អន្តរជាតិ ។ ដំណោះស្រាយផ្សេងៗទៀតដែលសមស្របចំពោះជនរងគ្រោះ រួមមានសិទ្ធិទទួលបានពីស្ថាប័នរដ្ឋបាលនិងស្ថាប័នផ្សេងៗទៀត ព្រមទាំងយន្តការ បែបបទ និងដំណើរការជំនុំជម្រះក្តីដោយអនុលោមតាមច្បាប់ជាតិ ។ កាតព្វកិច្ចដែលលើកឡើងតាមច្បាប់អន្តរជាតិក្នុងធានាឲ្យបាននូវសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ត្រឹមត្រូវ និងមិនលម្អៀង ត្រូវតែមានចែងនៅក្នុងច្បាប់ជាតិ ។ ដូចនេះ ភាគីរដ្ឋត្រូវ ៖ ក) ផ្សព្វផ្សាយតាមរយៈយន្តការជាសាធារណៈនិងជាឯកជននូវព័ត៌មានស្តីអំពីគ្រប់ដំណោះស្រាយដែលអាចធ្វើបានទាំងអស់សម្រាប់ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ខ) ចាត់វិធានការក្នុងការបន្ថយការលំបាករបស់ជនរងគ្រោះនិងតំណាងជនរងគ្រោះឲ្យនៅត្រឹមកម្រិតអប្បបរមា ការពារការជ្រៀតជ្រែកដោយខុសច្បាប់ទៅលើសិទ្ធិរបស់ជនរងគ្រោះ និងធានាសុវត្ថិភាពជនរងគ្រោះពីការបំភិតបំភ័យនិងការសងសឹក ក៏ដូចជាសុវត្ថិភាពរបស់ក្រុមគ្រួសារជនរងគ្រោះ

និងសាក្សី នៅមុនពេល ក្នុងអំឡុងពេល និងក្រោយពេលដំណើរការតុលាការ រដ្ឋបាល និងដំណើរការផ្សេងៗទៀតដែលប៉ះពាល់ដល់ផលប្រយោជន៍របស់ជនរងគ្រោះ គ) ផ្តល់ជំនួយដែលសមស្របដល់ជនរងគ្រោះក្នុងការស្វែងរកសិទ្ធិទទួលបាននូវយុត្តិធម៌ និង ឃ) បង្កើតគ្រប់មធ្យោបាយដែលសមស្របតាមច្បាប់ការទូត និងការផ្តល់ប្រឹក្សាក្នុងការធានាឲ្យជនរងគ្រោះអាចប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុងការទទួលបាននូវដំណោះស្រាយសម្រាប់ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ។

ក្រៅពីសិទ្ធិរបស់បុគ្គលក្នុងការទទួលបាននូវយុត្តិធម៌ ភាគីរដ្ឋត្រូវខិតខំបង្កើតនូវវិធានផ្សេងៗដែលជួយជនរងគ្រោះក្នុងការទាមទារសំណងលើការខូចខាតនិងទទួលបាននូវសំណង ដោយសមរម្យ ។

ដំណោះស្រាយសំណងលើការខូចខាតដែលគ្រប់គ្រាន់ មានប្រសិទ្ធភាព និងទៀងទាត់សម្រាប់ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ត្រូវរាប់បញ្ចូលគ្រប់ដំណើរការជាអន្តរជាតិដែលសមស្របនិងដែលអាចទទួលយកបាន ដែលជនរងគ្រោះអាចមានតម្លៃតាមផ្លូវច្បាប់ និងមិនត្រូវមានការរើសអើងចំពោះដំណោះស្រាយរបស់ជាតិផ្សេងៗទៀតឡើយ ។

## ៩) សំណងលើការទទួលរងនូវផលប៉ះពាល់

សំណងលើការខូចខាតដែលត្រឹមត្រូវ មានប្រសិទ្ធភាព និងទៀតទាត់ មានបំណងជំរុញឲ្យមានយុត្តិធម៌ ដោយការដោះស្រាយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ។ ការជួសជុលសំណងត្រូវសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាន និងការទទួលរងនូវផលប៉ះពាល់ ។ ដោយអនុលោមតាមច្បាប់ជាតិនិងកាតព្វកិច្ចច្បាប់អន្តរជាតិ ភាគីរដ្ឋត្រូវផ្តល់ជាសំណងលើការខូចខាតទៅដល់ជនរងគ្រោះចំពោះទង្វើឬការខកខានដែលបង្កឡើងដោយភាគីរដ្ឋនិងដែលក្លាយជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ។ ក្នុងករណីដែលបុគ្គលអ្នកច្បាប់ ឬអង្គភាពផ្សេងៗទៀតត្រូវបានរកឃើញថា ទទួលខុសត្រូវចំពោះសំណងលើការខូចខាតទៅដល់ជនរងគ្រោះ ភាគីបែបនេះ ត្រូវតែផ្តល់សំណងលើការខូចខាតដល់ជនរងគ្រោះ ឬសងជំងឺចិត្តភាគីរដ្ឋ ប្រសិនបើភាគីរដ្ឋបានផ្តល់សំណងលើការខូចខាតដល់ជនរងគ្រោះរួចហើយនោះ ។

ភាគីរដ្ឋត្រូវខិតខំរៀបចំបង្កើតឲ្យមានកម្មវិធីជាតិសម្រាប់សំណងលើការខូចខាតនិងជំនួយផ្សេងៗទៀតទៅឲ្យជនរងគ្រោះ




ប្រជាជនឈរនៅមុខអគារសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ក្នុងករណីដែលជនទទួលខុសត្រូវលើការទទួលរងនូវផលប៉ះពាល់ មិនមានលទ្ធភាព ឬសុឆន្ទៈក្នុងការឆ្លើយតបទៅនឹងកាតព្វកិច្ចរបស់ខ្លួន ។

ដោយផ្អែកលើបណ្តឹងតវ៉ារបស់ជនរងគ្រោះ ភាគីរដ្ឋត្រូវពង្រីងការវិនិច្ឆ័យជាតិទៅលើសំណងដែលប្រឆាំងនឹងបុគ្គលឬអង្គភាពទាំងឡាយដែលទទួលខុសត្រូវការទទួលរងនូវផលប៉ះពាល់ និងខិតខំជំរុញឲ្យមានសេចក្តីសម្រេចច្បាប់បរទេស ដែលមានសុពលភាពសម្រាប់ការជួសជុលសំណងដោយអនុលោមតាមច្បាប់ជាតិ និងកាតព្វកិច្ចច្បាប់អន្តរជាតិ ។ ដូចនេះ តាមច្បាប់ជាតិរបស់ខ្លួន ភាគីរដ្ឋត្រូវមានប្រព័ន្ធច្បាប់ដែលមានប្រសិទ្ធភាពសម្រាប់ការអនុវត្តនូវសេចក្តីសម្រេចចំពោះសំណងលើការខូចខាត ។

ដោយអនុលោមតាមច្បាប់ជាតិនិងអន្តរជាតិ និងដោយពិនិត្យពិចារណាទៅលើកាលៈទេសៈរបស់ ជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិដោយសមស្របនិងសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាននិងកាលៈទេសៈនៃករណីនីមួយៗ ជនរងគ្រោះត្រូវទទួលបាននូវសំណងលើការខូចខាតយ៉ាងពេញលេញ និងមានប្រសិទ្ធភាព ដូចដែលមានចែងនៅក្នុងគោលការណ៍ទី១៩ ទៅដល់ទី២៣ ដែលរួមមានទម្រង់ខាងក្រោមនេះ ៖ បដិទាន ការសងជំងឺចិត្ត ការស្តារនីតិសម្បទា សេចក្តីពេញចិត្ត និងការធានាមិនឲ្យកើតជាថ្មីម្តងទៀត ។

*បដិទាន* បើអាចធ្វើទៅបានត្រូវស្តារឡើងវិញនូវស្ថានភាពដើមរបស់ជនរងគ្រោះមុនពេលមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ។ បដិទាន រួមមានការស្តារសិទ្ធិសេរីភាពឡើងវិញ ការទទួលបានសិទ្ធិមនុស្ស អត្តសញ្ញាណ ជីវភាពគ្រួសារ និងសិទ្ធិជាពលរដ្ឋ ការវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់ខ្លួនវិញ និងការទទួលបានការងារឡើងវិញ និងការប្រគល់ទ្រព្យសម្បត្តិមកវិញ ។

*ការសងជំងឺចិត្ត* ត្រូវបានផ្តល់ឲ្យលើការខូចខាតដែលអាចវាយតម្លៃលើផលប្រយោជន៍សេដ្ឋកិច្ច ដោយសមស្របនិងសមាមាត្រនឹងភាពធ្ងន់ធ្ងរនៃការរំលោភបំពាននិងកាលៈទេសៈនៃករណីនីមួយៗ ដែលបង្កឡើងដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ដូចជា ៖ ក) ផលប៉ះពាល់លើរូបរាងកាយឬសតិបញ្ញា ខ) ការបាត់បង់ឱកាស ដូចជាការងារ ការអប់រំ និងផលប្រយោជន៍ក្នុងសង្គម គ) ការខូចខាតផ្នែកសម្ភារ និងការខាតបង់ចំណូល ដូចជាការបាត់បង់សក្តានុពលក្នុងការរកចំណូល ឃ) ការខូចខាតផ្នែកសីលធម៌ និង ង) ការចំណាយទៅលើជំនួយផ្នែកច្បាប់ឬអ្នកជំនាញការឱសថ និងសេវាកម្មសុខាភិបាល និងសេវាកម្មសង្គម និងចិត្តសាស្ត្រ ។

*ការស្តារនីតិសម្បទា* ត្រូវរាប់បញ្ចូលទាំងសេវាកម្មថែទាំសុខភាព ដោយថ្នាំពេទ្យនិងចិត្តសាស្ត្រ ព្រមទាំងសេវាកម្មផ្នែកច្បាប់និងសង្គម ។

*សេចក្តីពេញចិត្ត* បើសិនជាអាចត្រូវរាប់បញ្ចូលចំណុចណាមួយឬទាំងអស់ដូចខាងក្រោមនេះ ៖ ក) វិធានការដែលមានប្រសិទ្ធភាពក្នុងទិសដៅបញ្ឈប់ការបន្តការរំលោភបំពាន ខ) ការបញ្ជាក់ឲ្យបានច្បាស់លាស់អំពីអង្គហេតុនិងការបង្ហាញគ្រប់គ្រាន់និងជាសាធារណៈនូវការពិតដែលការបង្ហាញការពិតបែបនេះមិនត្រូវបង្កឲ្យមានផលប៉ះពាល់បន្ថែមទៀតឬគំរាមកំហែងដល់សុវត្ថិភាព និងផលប្រយោជន៍របស់ជនរងគ្រោះ សាច់ជាតិរបស់ជនរងគ្រោះ ឬបុគ្គលដែលអន្តរាគមន៍ជួយជនរងគ្រោះឬទប់ស្កាត់ការកើតឡើងការរំលោភបំពានបន្ថែមទៀត គ) ការស្វែងរកទីដែលជនបាត់ខ្លួន អត្តសញ្ញាណកម្មនៃកុមារដែលត្រូវបានចាប់ព្រាត់ និងសាកសពអ្នកដែលត្រូវបានសម្លាប់ និងការជួយស្វែងរកឲ្យឃើញអ្នកដែលបានបាត់ខ្លួន ការកំណត់អត្តសញ្ញាណ និងការបញ្ចុះសពឡើងវិញអ្នកដែលបានស្លាប់ ដោយយោងទៅតាមការបំណងប្រាថ្នារបស់ជនរងគ្រោះដែលត្រូវបានសម្តែងឲ្យឃើញឬសន្មតជាមុន ឬទៅតាមវប្បធម៌ នៃក្រុមគ្រួសាររបស់ជនរងគ្រោះនិងសហគមន៍ ឃ) សេចក្តីប្រកាសជាផ្លូវការឬសេចក្តីសម្រេចរបស់តុលាការក្នុងការស្តារឡើងវិញនូវសេចក្តីថ្លៃថ្នូរ កេរ្តិ៍ឈ្មោះ និងសិទ្ធិរបស់ជនរងគ្រោះនិងបុគ្គលទាំងឡាយដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងជនរងគ្រោះ ង) ការសុំទោសជាសាធារណៈ ដូចជា ការទទួលស្គាល់ហេតុការណ៍និងកំហុស ច) ការដាក់ទណ្ឌកម្មពីតុលាការនិងរដ្ឋបាលទៅលើបុគ្គលដែលទទួលខុសត្រូវចំពោះការរំលោភ

បំពាននេះ ឆ) ការធ្វើបុណ្យខួបរំឭក និងការរួមវិភាគទានដល់ជនរងគ្រោះ និង ជ) ការរាប់បញ្ចូលរឿងរ៉ាវដែលត្រឹមត្រូវនៃការរំលោភបំពានដែលមាននៅក្នុងវគ្គហ្វឹកហ្វឺនច្បាប់សិទ្ធិមនុស្សអន្តរ-ជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ និងនៅក្នុងឯកសារអប់រំគ្រប់កម្រិត ។

ការធានាមិនឲ្យកើតឡើងវិញរួមមានវិធានការណាមួយ ឬទាំងអស់ក្នុងចំណោមវិធានការខាងក្រោមនេះ ដែលក៏នឹងចូលរួមចំណែកក្នុងការទប់ស្កាត់ការរំលោភបំពាននេះ ៖ ក) ធានាឲ្យបាននូវការគ្រប់គ្រងជនស៊ីវិលពីកងកម្លាំងយោធា និងសន្តិសុខយ៉ាងមានប្រសិទ្ធភាព ខ) ធានាឲ្យបានគ្រប់ការជំនុំជម្រះជនស៊ីវិលនិងយោធាដែលត្រូវអនុវត្តទៅតាមស្តង់ដារអន្តរជាតិនៃនីតិវិធីត្រឹមត្រូវយុត្តិធម៌ និងមិនលម្អៀង គ) ពង្រឹងឯករាជ្យភាពរបស់តុលាការ ឃ) ការការពារបុគ្គលដែលជាមេធាវី គ្រូពេទ្យ និងអ្នកថែទាំសុខភាព អ្នកសារព័ត៌មាននិងមុខងារសារព័ត៌មាន និងក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្ស ង) ដោយផ្អែកលើមូលដ្ឋានជាអាទិភាពដែលកំពុងតែបន្តផ្តល់ការអប់រំស្វែងយល់អំពីច្បាប់សិទ្ធិមនុស្សនិងច្បាប់មនុស្សធម៌អន្តរជាតិទៅដល់សង្គមគ្រប់ផ្នែកទាំងអស់ និងបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់ ព្រមទាំងកងកម្លាំងយោធានិងសន្តិសុខ ច) ជំរុញឲ្យមានការអង្កេតទៅលើក្រមសីលធម៌និងបទដ្ឋានសីលធម៌ក្នុងកម្រិតស្តង់ដាពិសេស ជាអន្តរជាតិដោយមន្ត្រីមុខងារសាធា-រណៈ ដោយរាប់បញ្ចូលទាំងការអនុវត្តច្បាប់ សេវាកម្មកែតម្រូវ ផ្សព្វផ្សាយ សុខាភិបាល ចិត្តសាស្ត្រ សង្គម និងមន្ត្រីយោធា ព្រមទាំងសហគ្រាសសេដ្ឋកិច្ចនានា ឆ) ជំរុញឲ្យមានយន្តការទប់ស្កាត់និងត្រួតពិនិត្យបញ្ហាជម្លោះក្នុងសង្គមនិងដំណោះស្រាយនៃជម្លោះនេះ ជ) ពិនិត្យនិងកែទម្រង់ឡើងវិញនូវច្បាប់ដែលនាំឲ្យមានការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ។

## ១០) សិទ្ធិទទួលបាននូវព័ត៌មានដែលសមស្របស្តីពីការរំលោភបំពាននិងយន្តការសំណងលើការខូចខាត

ភាគីរដ្ឋត្រូវមានមធ្យោបាយក្នុងការផ្តល់ព័ត៌មានឲ្យសា-ធារណជនទូទៅ និងជាពិសេសជនរងគ្រោះដោយការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ យល់ដឹងអំពីសិទ្ធិនិងដំណោះស្រាយដែលមានចែងក្នុងគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំទាំងនេះ និងស្តីអំពីសេវាកម្មច្បាប់ សុខាភិបាល រដ្ឋបាល ចិត្តសាស្ត្រ សង្គម និងសេវាកម្មផ្សេងៗទៀតដែលជនរងគ្រោះអាចមានសិទ្ធិទទួលបាន ។ ជាងនេះទៀត ជនរងគ្រោះនិងតំណាងជនរងគ្រោះត្រូវបានផ្តល់សិទ្ធិក្នុងការស្វែងរកនិងទទួលបាននូវព័ត៌មានស្តីពីបុព្វហេតុដែលនាំឲ្យរងគ្រោះនិងបុព្វហេតុនិងល័ក្ខខ័ណ្ឌទាំងឡាយដែលទាក់ទិននឹងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ និងមានសិទ្ធិក្នុងការសិក្សានូវការពិតស្តីអំពីការរំលោភបំពាននេះ ។

## ១១) គ្មានការរើសអើង

ការអនុវត្តនិងការបកស្រាយគោលការណ៍មូលដ្ឋាន និងគោលការណ៍ណែនាំនេះត្រូវឲ្យស្របតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ និងមិនត្រូវមានការរើសអើងដោយបែប ឬហេតុផលណាមួយនោះទេ ។

## ១២) គ្មានការធ្វើបដិប្បញ្ញត្តិ

ពុំមានបទបញ្ញត្តិណាមួយដែលមានចែងក្នុងគោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំនេះត្រូវបានបកស្រាយថាជាការរិតត្បិត ឬការធ្វើបដិប្បញ្ញត្តិសិទ្ធិ ឬកាតព្វកិច្ចដែលនៅក្រោមច្បាប់អន្តរជាតិនិងជាតិនោះទេ ។ ជាពិសេស គោលការណ៍មូលដ្ឋាននិងគោលការណ៍ណែនាំនេះ ត្រូវបានយល់ថា មិនត្រូវផ្ទុយទៅនឹងសិទ្ធិទទួលបាននូវដំណោះស្រាយនិងសំណងលើការខូចខាតសម្រាប់ជនរងគ្រោះដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិនិងច្បាប់មនុស្សធម៌អន្តរជាតិ ។ ម្យ៉ាងទៀត គោលការណ៍នេះមិនត្រូវផ្ទុយទៅនឹងច្បាប់ពិសេសនៃច្បាប់អន្តរជាតិទេ ។

## ១៣) សិទ្ធិរបស់ជនផ្សេងៗទៀត

ពុំមានបទបញ្ញត្តិណាមួយនៅក្នុងគោលការណ៍នេះបានបកស្រាយនូវការធ្វើបដិប្បញ្ញត្តិសិទ្ធិរបស់ជនផ្សេងៗទៀតដែលត្រូវបានការពារជាលក្ខណៈជាតិនិងអន្តរជាតិ ជាពិសេសសិទ្ធិរបស់ចុងចោទក្នុងការទទួលផលប្រយោជន៍ពីបទដ្ឋាននៃនីតិវិធីត្រឹមត្រូវ ។

**ប្រែសម្រួលពី UN A/RES/60/147 ដោយ បាន់ ចំរើន**

# ការិយាល័យព័ត៌មានសាធារណៈ

"ការិយាល័យព័ត៌មានសាធារណៈ" នៃមជ្ឈមណ្ឌលឯកសារកម្ពុជាឥឡូវនេះបានចាប់ផ្តើមបើកបម្រើជូននិស្សិត អ្នកស្រាវជ្រាវ បុគ្គលិករដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ចង់យល់ដឹងអំពីប្រវត្តិសាស្ត្ររបស់របបកម្ពុជាប្រជាធិបតេយ្យនិងព្រឹត្តិការណ៍វិវត្តន៍នៃអង្គជំនុំជម្រះវិសាមញ្ញដែលនឹងត្រូវបង្កើតឡើងនៅពេលខាងមុខឆាប់ៗនេះ ។

មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំនិងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត ។ តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចអាននិងស្រាវជ្រាវឯកសារទាំងនេះបាន ។ ឯកសារទាំងនេះរួមមាន ៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាព កំណត់ហេតុរបស់បក្ស ទូរលេខឆ្លើយឆ្លង ព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍ ។

"ការិយាល័យព័ត៌មានសាធារណៈ" មានផ្តល់ជូននូវសេវា៣យ៉ាង ៖

១) **បណ្ណាល័យ** ៖ នៅក្នុងបណ្ណាល័យរបស់យើង សាធារណជនអាចអានឯកសារ សៀវភៅ និងទស្សនាវដ្តី ស្តាប់កាសែតសំឡេង ទស្សនាខ្សែភាពយន្តឯកសារ និងមើលរូបថតដែលបានមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង បណ្ណសារដ្ឋានជាតិកម្ពុជា និងពីប្រភពផ្សេងៗទៀត ។

២) **មជ្ឈមណ្ឌលអប់រំ** ៖ មជ្ឈមណ្ឌលមានបញ្ចាំងជូននូវខ្សែភាពយន្តឯកសារ និងបង្រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជា-ធិបតេយ្យ ប្រធានបទទាក់ទងនឹងអង្គជំនុំជម្រះវិសាមញ្ញ និងប្រធានបទដទៃៗទៀត ។ ភាពយន្តឯកសារអំពីខ្មែរក្រហមមានបញ្ចាំងជូនទស្សនានៅរៀងរាល់ថ្ងៃអង្គារនិងថ្ងៃព្រហស្បតិ៍ នៅវេលាម៉ោង៩ព្រឹកនិង៣រសៀល ។

៣) **ក្រុមការងារផ្នែកតុលាការ** ៖ ទីប្រឹក្សាផ្នែកឯកសារនិងផ្នែកច្បាប់របស់យើងនឹងផ្តល់ជំនួយផ្នែកស្រាវជ្រាវដល់អ្នកជំនាញផ្នែកច្បាប់កម្ពុជានិងអង្គការសហប្រជាជាតិដែលធ្វើការងារផ្នែកតុលាការ ក៏ដូចជាដល់សាធារណជនទូទៅដែរ ។

ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ ខាងកើតវិមានឯករាជ្យ ។ ការិយាល័យរបស់យើងបើកជូនសាធារណជនពីថ្ងៃច័ន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង៨ដល់ម៉ោង១២ និងពេលរសៀលពីម៉ោង២ដល់ម៉ោង៥ ។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង អែម សុខឃីម តាមរយៈ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។



ឯកឧត្តម ម៉ោញ សាផាន, ស្ទួ ប៊ុនស៊ូ និងបុគ្គលិកស្ម័គ្រចិត្តផ្នែកច្បាប់ នៅក្នុងវគ្គហ្វឹកហ្វឺនផ្នែកច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា



ក្រុមនិស្សិតដែលបានចូលរួមវគ្គហ្វឹកហ្វឺនផ្នែកច្បាប់នៅមជ្ឈមណ្ឌលឯកសារកម្ពុជា

# នយោបាយអភិរក្សមជ្ឈមណ្ឌលប្រល័យពូជសាសន៍នៅរ៉្វាន់ដា

*(តចប់)*

***ទីតាំងប្រល័យពូជសាសន៍នៅរ៉្វាន់ដា ៖ សាលាបច្ចេកទេសមូរ៉ាមប៊ី***

ព្រឹកថ្ងៃទី៨ ខែសីហា ឆ្នាំ២០០០ ខ្ញុំបានចេញដំណើរពីការិយាល័យទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិប្រចាំនៅទីក្រុងឃីហ្គាលីដោយជិះនៅក្នុងរថយន្តតូយ៉ូតាឡេនគ្រីស័រជាមួយអ្នករួមដំណើរចំនួន៩នាក់ទៀតទៅទស្សនាទីតាំងប្រល័យពូជសាសន៍ដ៏ល្បីល្បាញមួយនៅក្នុងខេត្តហ្គីកុងហ្គោរ៉ូ ។ នៅពេលនោះអាកាសធាតុក្តៅល្មម ហើយផ្ទៃមេឃស្រឡះ យើងបានធ្វើដំណើរឆ្ពោះទៅភាគខាងត្បូងតាមបណ្តោយផ្លូវជាតិលេខ១ដ៏តូចចង្អៀត និងមានក្រាលកៅស៊ូពីទីក្រុងឃីហ្គាលីទៅកាន់ទីក្រុងប៊ូតារ៉េ ដែលជាទីក្រុងធំទីពីរនៃប្រទេសរ៉្វាន់ដា ។ ប្តីរបស់ខ្ញុំជាជនជាតិទុតស៊ីអង្គុយនៅខាងមុខជាមួយអ្នកបើករថយន្ត (បុគ្គលិកទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិជាតិរ៉្វាន់ដា) ពិភាក្សាគ្នាពីការបោះឆ្នោតដែលកំពុងកើតឡើងនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ ។ ខ្ញុំអង្គុយនៅខាងក្រោយជាមួយកូនប្រុសអាយុ២ឆ្នាំរបស់ខ្ញុំ ដែលកំពុងតែសម្លឹងមើលយ៉ាងជក់ចិត្តនូវសត្វគោអាន់ហ្គោលដែលមានស្នែងវែងៗកំពុងតែស៊ីស្មៅនៅតាមផ្លូវនិងម៉ូតូធ្វើពីឈើសម្រាប់ប្រើប្រាស់តាមផ្ទះត្រូវបានប្រើប្រាស់សម្រាប់ដឹកមនុស្សនិងទំនិញឆ្លងកាត់ភ្នំ ។ តំណាងទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិរបស់យើងជាស្ត្រីវ័យក្មេងជនជាតិអាមេរិកាំងម្នាក់ដែលធ្វើការងារលើគម្រោងអភិបាលកិច្ចនិងប្រជាធិបតេយ្យ អង្គុយនៅខាងក្រោយជាមួយនិស្សិតជនជាតិប៊ែលហ្សិកម្នាក់ដែលកំពុងតែសិក្សាស្រាវជ្រាវអំពីប្រល័យពូជសាសន៍ ។ ក្នុងចំណោមយើងទាំងអស់ពុំមាននរណាម្នាក់ធ្លាប់មកទស្សនាទីតាំងប្រល័យពូជសាសន៍ មូរ៉ាមប៊ីពី ដែលជាទីសម្លាប់រង្គាលដ៏ធំមួយនៅក្នុងខេត្តហ្គីកុងហ្គោរ៉ូពីមុនមកទេ ។ បើទោះបីជាយើងមិនយកចិត្តទុកដាក់នឹងអ្វីដែលយើងនិយាយគ្នាយ៉ាងណាក៏ដោយ យើងម្នាក់ៗនឿងឆ្ងល់ថា តើយើងមានប្រតិកម្មតបដោយរូបកាយ ដោយអារម្មណ៍ និងដោយមានភាពវង្វេងទៅនឹងទិដ្ឋភាពអដ្ឋិធាតុរបស់ជនរងគ្រោះរាប់ពាន់នាក់ដែលត្រូវបានសម្លាប់នៅឯបរិវេណសាលាបច្ចេកទេសមូរ៉ាមប៊ីកាលពី៦ឆ្នាំមុនដោយរបៀបណា ។

យើងបានឈប់សម្រាកដើម្បីទទួលទានអាហារថ្ងៃត្រង់នៅក្នុងទីក្រុងប៊ូតារ៉េ និងបន្ទាប់មកយើងបានបន្តដំណើរទៅភាគខាងលិចឆ្ពោះទៅកាន់ខេត្តហ្គីកុងហ្គោរ៉ូ ។ ការស្វែងរកទីតាំងប្រល័យពូជសាសន៍មូរ៉ាមប៊ី គឺមិនងាយស្រួលដូចដែលយើងគិតស្មានទុកនោះទេ ។ ប្រជាជនរ៉្វាន់ដាដែលយើងបានឈប់សាកសួរនៅតាមផ្លូវមិនយល់ច្បាស់អំពីអ្វីដែលយើងកំពុងតែនិយាយទេ និងប្រាប់ថាឲ្យយើងបន្តដំណើរទៅមុខទៀតនឹងឃើញព្រះវិហារមួយឬផ្លូវតូចមួយ ដែលហាក់ដូចជាមិនចំកន្លែងដែលយើងចង់ទៅនោះឡើយ ។ ចុងក្រោយ យើងបានឈប់សួរបុរសមួយចំនួនដែលស្លៀកពាក់អៀមពណ៌ផ្កាឈូកខ្ចីដែលកំពុងធ្វើការនៅក្នុងសាលាបច្ចេកទេសមូរ៉ាមប៊ី ។ ពួកគាត់បានចង្អុលទៅផ្លូវដីដែលមានស្នាមកង់ជ្រៅ និងនិយាយភាសាឃិនយ៉ារ៉្វាន់ដាដែលប្រែថា "អ្នកមកត្រូវចំកន្លែងហើយ" ។ នៅពេលដែលយើងវិលកញ្ចក់បង្អួចរថយន្តឡើង និងបន្តដំណើរទៅមុខទៀត ខ្ញុំស្រាប់តែនឹកឃើញនូវពាក្យណែនាំរបស់ក្រុមជនដែលដែលប្រាប់ពីទិសដៅឆ្ពោះទៅកាន់ទីតាំងប្រល័យពូជសាសន៍ ។

នៅពេលដែលយើងបានមកដល់ទីតាំងប្រល័យពូជសាសន៍ យើងឃើញពលរដ្ឋរ៉្វាន់ដាមួយក្រុមតូចកំពុងតែរង់ចាំយើង ក្នុងនោះរួមមានទាហានប្រដាប់ដោយអាវុធម្នាក់កំពុងការពារអដ្ឋិធាតុជនរងគ្រោះពីជនបំផ្លាញទ្រព្យសម្បត្តិសាធារណៈ អ្នកថែរក្សាទីតាំងប្រល័យពូជសាសន៍ពីរបីនាក់ និងបុរសជាជនរងគ្រោះបុរសនេះមានរូបរាងខ្ពស់និងមុខមាំដែលបានរួចផុតពីអំពើប្រល័យពូជសាសន៍ឈ្មោះ អែមមែន ញូអែល ដែលមានស្នាមប្រហោងនៅលើថ្ងាកទំហំប៉ុនកូនឃ្លីធំមួយ ។ ស្នាមរបួសនេះត្រូវបានព្យាបាលជាសះស្បើយរួចហើយ ក៏ប៉ុន្តែវាជាស្នាមរបួសដែលធ្វើឲ្យនឹកឃើញជានិច្ចនូវអំពើហិង្សាដែលបានកើតឡើងនៅទីតាំង

ប្រល័យពូជសាសន៍នេះ ។ ទីតាំងប្រល័យពូជសាសន៍នេះ ស្ថិតក្នុងបរិវេណវិទ្យាល័យបច្ចេកទេសមួយ ដែលជិតនឹងសាងសង់រួច ប៉ុន្តែមិនត្រូវបានប្រើប្រាស់នៅឡើយ ។ វិទ្យាល័យនេះស្ថិតនៅលើភ្នំគ្មានដីជាតិដែលអាចសម្លឹងមើលឃើញភ្នំផ្សេងៗទៀតបានគ្រប់ជ្រុងជ្រោយ ។ ដំណើរទស្សនកិច្ចនេះពុំមានភ្ញៀវទទួលយ៉ាងអធិកអធមនោះឡើយ ។ អែមមែនញូអែល បានដើរឆ្ពោះទៅកាន់អគារបន្ទប់រៀនមួយក្នុងចំណោមអគារបន្ទប់រៀនជាច្រើនទៀត ហើយយើងបានដើរតាមពីក្រោយគាត់ ។

សាលារៀននេះមានបន្ទប់រៀនជាច្រើន ដែលបន្ទប់នីមួយៗប្រក់ដោយដំបូលដែក ។ នៅពេលដែលយើងដើរជិតដល់អគារទីមួយ អែមមែនញូអែល បានប្រាប់យើងថា មានបន្ទប់រៀនជាច្រើនដែលយើងអាចចូលទស្សនាបាន ដូចនេះយើងពុំចាំបាច់ចំណាយពេលវេលាដើរមើលបន្ទប់មួយៗយូរពេកទេ ។ សពជនរងគ្រោះដែលដេកនៅលើក្រណាត់កៅស៊ូលើកម្រាលឥដ្ឋក្នុងបន្ទប់រៀននិងចង្ក្រានលើដំបូលឈើ ត្រូវបានថែរក្សាដោយម្សៅក្រូចឆ្មារ ។ សពជនរងគ្រោះភាគច្រើននៅមានសក់ និងសម្លៀកបំពាក់ខ្លះនៅជាប់នឹងខ្លួន និងមានក្លិនស្អុយពេញក្នុងបន្ទប់រៀន ។ ដោយពុំមានខ្សែពួរនិងរបាំងរាំងស្កាត់ យើងបានដើរចូលទៅក្នុងបន្ទប់ដែលពេញទៅដោយសាកសពជនរងគ្រោះ ។

សពជនរងគ្រោះទាំងនេះត្រូវបានរៀបជាក្រុមទៅតាមអាយុនិងភេទ ។ នៅចំហៀងមួយផ្នែកនៃថ្នាក់រៀនដំបូង យើងឃើញសពជនរងគ្រោះជាបុរសកំពុងការពារខ្លួនពីការវាយនឹងកាំបិតផ្គាក់ និងមួយចំហៀងទៀតនៃបន្ទប់ដដែលនេះ សពជនរងគ្រោះជាស្ត្រីកំពុងតែបាំងមុខនិងខ្លះកំពុងតែឱបកូនយ៉ាងណែននៅក្នុងដៃ ។ បន្ទប់ខ្លះទៀតពេញទៅដោយសាកសពកុមារ ។ ខ្ញុំមិនបានហាមឃាត់កូនប្រុសរបស់ខ្ញុំដែលមានអាយុពីរឆ្នាំមិនឲ្យមើលសពជនរងគ្រោះទាំងនេះទេ ពីព្រោះខ្ញុំគិតថាវាមិនអាចចំណាំអ្វីដែលវាកំពុងតែមើលឃើញនោះទេ ។ ខ្ញុំបានចាប់ផ្តើមគិតម្តងទៀតនៅពេលដែលវាសួរខ្ញុំថា "ម៉ែ! តើហេតុអ្វីបានជាមនុស្សទាំងនេះដេកដូច្នេះ?"

ក្នុងឋានៈជាភ្ញៀវបរទេសនិងជាសាក្សីដែលមកទស្សនាទីតាំងប្រល័យពូជសាសន៍នេះ យើងត្រូវតាំងអារម្មណ៍ឲ្យស្ងប់ស្ងាត់ និងសម្លឹងមើលសាកសពជនរងគ្រោះម្តងមួយៗតាមបន្ទប់នីមួយៗជាច្រើននាទី ។ ទោះបីជាយ៉ាងណាក៏ដោយ អែមមែនញូអែល បាននាំយើងដើរយ៉ាងប្រញាប់ប្រញាល់ ពីព្រោះគាត់ព្រួយបារម្ភខ្លាចថាយើងមើលមិនបានគ្រប់ជ្រុងជ្រោយ ។ អែមមែនញូអែល ហាក់ដូចជាពន្យល់ប្រាប់ពួកយើងពីលក្ខណៈ ដូចគ្នានៃបន្ទប់រៀនពីមួយទៅមួយដែលផ្ទុកទៅដោយសាកសពជនរងគ្រោះដែលគ្មានមុខនិងគ្មានអត្តសញ្ញាណ និងជនស្លូតត្រង់ជាច្រើននាក់ទៀត ។

យោងតាមសម្តីរបស់ អែមមែនញូអែល អះអាងថា សពជនរងគ្រោះដែលដាក់តាំងបង្ហាញនេះ គឺជាសាកសពដែលមិនត្រូវបានញាតិសន្តានរបស់គេដែលនៅរស់ទាមទារយកទៅបូជា បន្ទាប់ពីសាកសពទាំងនេះត្រូវបានគេគាស់ចេញពីរលូទឹកដ៏ធំមួយនៅខាងក្រោយសាលារៀន ដែលពួកពេជ្ឈឃាតយកមកចាក់ចោលនៅទីនេះ ។ យើងមានការងឿងឆ្ងល់ថាតើហេតុអ្វីបានជាសពជនរងគ្រោះទាំងនេះមិនត្រូវបានញាតិសន្តានរបស់ខ្លួនយកទៅបូជាដូច្នេះ ។ អែមមែនញូអែល យល់ថា នេះប្រហែលមកពីញាតិសន្តានមិនស្គាល់អត្តសញ្ញាណសពដែលស្អុយរលួយរួចទៅហើយ ឬប្រហែលជាក្នុងគ្រួសារនៃសពពុំមានសមាជិកណាម្នាក់នៅរស់ក៏មិនដឹង ។ អែមមែនញូអែល បាននិយាយទៀតថា ប្រជាជនរ៉្វាន់ដាភាគច្រើនមានជីវភាពក្រខ្សត់ពុំមានលទ្ធភាពបញ្ចុះសពញាតិសន្តានរបស់ខ្លួនបាន (ដូចជាការចំណាយទៅលើការដឹកសពត្រឡប់មកភូមិដ្ឋានដែលគ្រួសារសពរស់នៅ ការទិញក្តារមឈូស និងការចំណាយទៅលើការរៀបចំពិធីបូជាសពជាដើម) ដូចនេះ ពលរដ្ឋរ៉្វាន់ដាបង្ខំចិត្តទុកសាកសពចោល ។ អែមមែនញូអែល មិនបានដឹងចំនួនពិតប្រាកដថាតើមានសពជនរងគ្រោះចំនួនប៉ុន្មាននាក់ទេដែលត្រូវបានទុកតាំងបង្ហាញនៅសាលារៀននេះ ក៏ប៉ុន្តែគាត់គ្រាន់តែបានដឹងថាមានមនុស្សប្រហែលជា៥ ទៅ៦ម៉ឺននាក់ត្រូវបានយកសម្លាប់នៅទីកន្លែងនេះនៅខែសីហា ឆ្នាំ១៩៩៤ ។

បើទោះបីជាភាគច្រើនសពជនរងគ្រោះនៅសល់តែគ្រោងឆ្អឹងក៏ដោយ ក៏មានបន្ទប់ខ្លះពេញទៅដោយគំនរឆ្អឹងលលាដ៍និងឆ្អឹងផ្សេងៗទៀត ។ អែមមែនញូអែល បាននិយាយប្រាប់យើង

ថា ត្រង់ចំណុចទាក់ទិននឹងការប្រឹងប្រែងថែរក្សាអដ្ឋិធាតុនិងសាកសពជនរងគ្រោះ ពួកគាត់ពុំមានថ្នាំគីមីនិងថវិកាសម្រាប់ការថែរក្សាសពទាំងនេះទេ ដូចនេះហើយបានអដ្ឋិធាតុជនរងគ្រោះត្រូវទុកគរចោលនៅក្នុងបន្ទប់រៀនមួយក្នុងចំណោមបន្ទប់រៀនជាច្រើនទៀត ។

អែមមែនញូអែល មិនបានប្រាប់យើងឲ្យដឹងថាតើ សពជនរងគ្រោះត្រូវបានយកដាក់នៅសាលារៀនដោយរបៀបណា ឬថាតើជនរងគ្រោះទាំងនោះត្រូវបានសម្លាប់ដោយបែបណា ឬថាតើគាត់បានរួចរស់រានមានជីវិតដោយរបៀបណានោះទេ ដូចនេះបានជាយើងសួរគាត់នូវសំណួរទាំងនេះទៅកាន់គាត់ក្នុងខណៈដែលពួកយើងកំពុងឈរនៅចុងម្ខាងលូទឹកដែលសពជនរងគ្រោះភាគច្រើនត្រូវបានគេយកមកកប់នៅក្នុងរណ្តៅដ៏ធំមួយនេះ ។ អែមមែនញូអែល បានពន្យល់ថា ជនរងគ្រោះទាំងនោះមិនបានមកប្រមូលផ្តុំគ្នានៅទីនេះដោយខ្លួនឯងនោះទេ ជនរងគ្រោះទាំងនោះត្រូវបានកោះហៅឲ្យមកប្រជុំនៅព្រះវិហារមួយក្បែរសាលារៀនមូរ៉ាមប៊ីនេះ និងបន្ទាប់មកទៅកាន់សាលរៀនមូរ៉ាមប៊ី "សម្រាប់ការពារ" ។ ការពន្យល់នេះគឺមានលក្ខណៈស្រដៀងគ្នានឹងសាច់រឿងដែលចុះផ្សាយក្នុងទស្សនាវដ្តីមួយដែលមានចំណងជើងថា មិនត្រូវទុកនរណាម្នាក់ឲ្យរៀបរាប់រឿងរ៉ាវនេះនោះឡើយ (Leave None to Tell the Story) ដែលរៀបរាប់អំពីក្រុមទុតស៊ីមួយក្រុម និងដែលត្រូវបានគេចាប់យកមកពីឃុំ មូសេប៊ីយ៉ា និងដឹកយកមកកាន់ព្រះវិហារគ្រិស្តនៅក្នុងទីក្រុងហ្គីកុងហ្គោរ៉ូមុនគេបង្អស់ និងចុងក្រោយនៅសាលារៀនមូរ៉ាមប៊ី ដែលនៅទីនោះក្រុមនេះ"ត្រូវបានសម្លាប់ដំណាលគ្នាជាមួយប្រជាជនទុតស៊ីរាប់ពាន់នាក់ផ្សេងទៀត" ។ អែមមែនញូអែល បាននិយាយថា គាត់ជាមនុស្សម្នាក់ក្នុងចំណោមមនុស្សបួននាក់ដែលបានរួចរស់ជីវិតពីការសម្លាប់រង្គាលនេះ ។ គាត់ធ្លាប់ត្រូវគេបាញ់ចំក្បាល ប៉ុន្តែគាត់អាចវារលួនគេចពីការស្លាប់និងលាក់ខ្លួននៅក្នុងព្រៃក្បែរជើងភ្នំ ។ ត្រង់ចំណុចនេះ គាត់នៅចងចាំថា គាត់បានឃើញជនដែលកំពុងតែយកដីលុបរណ្តៅ ពីព្រោះទាហានបារាំងចុះធ្វើ"ប្រតិបត្តិការបៃតង" ដែលជាការផ្តាច់ទំនាក់ទំនង"មនុស្សធម៌" ដែលបានការពារយ៉ាងមានប្រសិទ្ធភាពនូវកងកម្លាំងប្រល័យពូជសាសន៍ ពីព្រោះទាហានបារាំងទាំងនោះត្រូវដកចេញពីទឹកដីរ៉្វាន់ដាមុនការមកដល់មុននៃកងកម្លាំងរណសិរ្សស្នេហាជាតិរ៉្វាន់ដា ។ អែមមែនញូអែល បាននិយាយថា ទាហានបារាំងពិតជាបានជួយឧក្រិដ្ឋជនលុបរណ្តៅសាកសព និងបន្ទាប់មកសង់បង្គោលសំណាញ់បាល់ទះពីលើរណ្តៅនោះដើម្បីទុកលេងកំសាន្តសប្បាយជាមួយនឹងក្រុមយោធាអ៊ីនធឺរ៉ាហាវី (ក្រុមយោធាដ៏ល្បីល្បាញដែលពាក់ព័ន្ធនឹងការសម្លាប់) ។ ក្នុងចំណោមសមាជិកគ្រួសាររបស់គាត់ដែលមានសមាជិក៤៩នាក់ អែមមែនញូអែល ជាមនុស្សតែម្នាក់គត់ដែលនៅរស់រានមានជីវិតពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៩៤ ។

នៅពេលដែលក្រុមរបស់យើងបម្រុងនឹងចាកចេញពីសាលរៀនបច្ចេកទេសមូរ៉ាមប៊ី អែមមែនញូអែល បានសុំយើងទិញ "ភេសជ្ជៈខ្លះ" ។ គាត់និយាយសុំភេសជ្ជៈដោយខ្សឹបៗជាភាសាឃិនយ៉ារ៉្វាន់ដា ដោយគាត់សង្ឃឹមថាប្តីរបស់ខ្ញុំនឹងបកប្រែពាក្យនេះឲ្យយើងយល់ ហើយយើងបានឲ្យប្រាក់កាសខ្លះទៅឲ្យគាត់យ៉ាងប្រុងប្រយ័ត្ន ។ ភ្លាមៗនោះ វាបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ថា អែមមែនញូអែល កំពុងតែធ្វើការងារក្រៅពីគោលការណ៍ជាអ្នកថែរក្សាទីតាំងប្រល័យពូជសាសន៍ដែលកំពុងតែឈរនៅក្នុងម្លប់ក្បែររថយន្តរបស់យើងដើម្បីត្រួតពិនិត្យឲ្យដឹងច្បាស់ថាតើយើងបានចុះហត្ថលេខាក្នុងសៀវភៅកត់ត្រាភ្ញៀវចូលទស្សនានិងបរិច្ចាគប្រាក់វិភាគទានខ្លះដែរឬទេ ។ អ្នកថែរក្សាទីតាំងប្រល័យពូជសាសន៍ទាំងនោះបានពន្យល់ថាការអភិរក្សឬការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនៅសាលាបច្ចេកទេសមូរ៉ាមប៊ីត្រូវបានធ្វើឡើងជាលើកដំបូងដោយអាណិកជនរ៉្វាន់ដាមួយក្រុម (អាណិកជនទាំងនោះដូចនឹងប្តីរបស់ខ្ញុំដែលបានរត់ភៀសខ្លួនគេចពីភាពតានតឹងរវាងជាតិពន្ធុនៅរ៉្វាន់ដាឆ្នាំ១៩៥១) ដែលមានទំនាក់ទំនងជាមួយនឹងទីក្រុងហ្គីកុងហ្គោរ៉ូ ។ វាមិនច្បាស់ថាតើក្រុមនេះរកប្រាក់ចំណូលបានចំនួនពិតប្រាកដប៉ុន្មាននោះទេ ក្នុងការចំណាយទៅលើការជីកគាស់រណ្តៅសាកសព ការថែរក្សាសាកសព និងការចំណាយផ្សេងៗទៀត ។ ការបរិច្ចាគរបស់ពួកគេធ្វើឡើងតែមួយដងគត់ ។ ដូចនេះ ភ្ញៀវទេសចរដែលមកទស្សនាទីនេះ ត្រូវបានលើកទឹកចិត្តឲ្យបរិច្ចាគថវិកាដោយកត់ត្រាទុកក្នុងសៀវភៅកំណត់ហេតុភ្ញៀវទេសចរ ។ ថវិកា ដែលត្រូវបានបរិច្ចាគនេះត្រូវ

បានចែករំលែកទៅឲ្យមគ្គុទ្ទេសក៍ទេសចរនិងប្រជាជនរស់នៅក្នុងតំបន់នោះ ដែលជាអ្នកជួយថែរក្សាទីតាំងប្រល័យពូជសាសន៍ ។

ទីតាំងប្រល័យពូជសាសន៍មូរ៉ាមប៊ី ដូចគ្នានឹងទីតាំងប្រល័យពូជសាសន៍ផ្សេងៗទៀតនៅរ៉ាន់ដា បង្ហាញពីការប្រឹងប្រែងក្នុងការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះព្រមទាំងថែរក្សានូវអ្វីដែលបានកើតឡើងនៅទីនោះ ។ តាមស្ថានភាពបច្ចុប្បន្ននៃទីតាំងប្រល័យពូជសាសន៍មូរ៉ាមប៊ី ទីតាំងនេះមិនទាន់បានរៀបចំឡើងវិញនូវទីកន្លែងសម្លាប់ ហើយសពជនរងគ្រោះមិនត្រូវបានគេទុកចោលនៅត្រង់ទីកន្លែងដែលជនរងគ្រោះត្រូវបានសម្លាប់នោះឡើយ និងសពខ្លះទៀតដែលដាក់តាំងបង្ហាញប្រហែលជាត្រូវបានសម្លាប់នៅទីកន្លែងផ្សេងៗទៀត ។ រណ្ដៅសាកសពត្រូវបានគេជីកកាស់និងទុកចោល ។ ដូច្នេះ រណ្ដៅសាកសពប្រល័យពូជសាសន៍មូរ៉ាមប៊ីមិនទាន់ត្រូវបានគេរៀបចំឡើងវិញដើម្បីបង្ហាញពីពេលវេលាជាក់លាក់ណាមួយក្នុងអំពើប្រល័យពូជសាសន៍នៅឡើយ ។ ផ្ទុយទៅវិញ វាបង្ហាញពីរយៈពេលនៃដំណើរការក្នុងអំពើប្រល័យពូជសាសន៍និងក្រោយអំពើប្រល័យពូជសាសន៍ ។ អគារសាលារៀនស្ថិតក្នុងសភាពជិតសាងសង់រួចដូចដែលអគារនេះស្ថិតនៅក្នុងរយៈពេលនៃការសម្លាប់ ។ រណ្ដៅសាកសពស្ថិតនៅក្នុងសភាពដូចដែលរណ្ដៅសាកសពត្រូវបានជីកកាស់នៅខែសីហាឆ្នាំ១៩៩៦ ។ សាកសពបង្ហាញយ៉ាងច្បាស់អំពីទំហំនិងសារជាតិនៃអំពើហិង្សានេះ ក៏ប៉ុន្តែ មិនត្រូវបានគេថែរក្សាដើម្បីបង្ហាញពីរបៀប ទីកន្លែង ឬពេលវេលាដែលជនរងគ្រោះត្រូវបានសម្លាប់នោះឡើយ ។ និយាយរួមទីតាំងប្រល័យពូជសាសន៍នេះប្រើប្រាស់ជាបូជនីយដ្ឋានប្រាកដមួយជូនចំពោះប្រជាជនស្លូតត្រង់ដែលត្រូវបានសម្លាប់នៅទីនោះ ក៏ប៉ុន្តែព័ត៌មានលម្អិតស្ដីពីអំពើហិង្សាត្រូវតែប្រមូលយកពីរឿងរ៉ាវផ្ទាល់មាត់របស់ជនរងគ្រោះនិងមគ្គុទ្ទេសក៍ទេសចរ ឬត្រូវតែធ្វើការស្រាវជ្រាវតាមរយៈប្រភពឯកសារទីពីរ ។ អដ្ឋិធាតុជនរងគ្រោះដាក់ស្ដែងផ្ទាល់មិនអាច«រៀបរាប់រឿងរ៉ាវនេះបានឡើយ» ។

ភាគច្រើននៃការទំប្រឹងប្រែងនាបច្ចុប្បន្ននេះក្នុងការថែរក្សានិងរៀបចំពិធីរំឭកទីតាំងប្រល័យពូជសាសន៍នៅរ៉ាន់ដានោះគឺជាការងារក្នុងតំបន់ដែលប្រើប្រាស់នូវថវិកាដែលបានមកពីប្រភពឯកជនមួយផ្នែកធំ ។ មន្ត្រីនៃក្រសួងយុវជន វប្បធម៌និងកីឡា បានអះអាងថាទីតាំងប្រល័យពូជសាសន៍ ដែលត្រូវបានចាត់ទុកជា«ទីតាំងប្រល័យពូជសាសន៍របស់ជាតិ» រួមមានទីតាំងប្រល័យពូជសាសន៍នីយ៉ាម៉ាតា និង ឃីប៊ីហូ ជាបន្ទុករបស់រដ្ឋាភិបាលក្នុងការមើលថែរក្សា ដោយឡែកទីតាំងប្រល័យពូជ-សាសន៍មួយភាគធំផ្សេងៗទៀតត្រូវបានសហគមន៍ឬបុគ្គលនៅក្នុងតំបន់ជាអ្នកមើលថែរក្សា ។

ផែនទី «រ៉ាន់ដា ៖ ទីតាំងធំៗនៃអំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាលពីខែមេសាដល់ខែកក្កដា ឆ្នាំ១៩៩៤» ចុះក្នុងបញ្ជីឈ្មោះទីតាំងចំនួន១១៨កន្លែងទូទាំងប្រទេសរ៉ាន់ដា ។ ផែនទីនេះចែកចេញជា«ទីកន្លែងខាងសាសនា»(៣៣កន្លែង) «ទីកន្លែងជាសាធារណៈ»(៧៩កន្លែង) និង«ទីកន្លែងនៃការតស៊ូប្រឆាំង»(៦កន្លែង) ។ ការបែងចែកទីកន្លែងទាំងនេះនៅក្នុងផែនទីផ្ដល់ភាពងាយស្រួលក្នុងការធ្វើកំណត់សម្គាល់ ។ ស្ទើរតែគ្រប់តំបន់តស៊ូប្រឆាំងទាំងអស់ស្ថិតនៅត្រង់ព្រំប្រទល់ភាគខាងលិចនៃប្រទេសរ៉ាន់ដា (ជាប់នឹងប្រទេសហ្សៃរ) និងពុំមានទីតាំងប្រល័យពូជសាសន៍នៅភាគខាងជើងប្រទេសនេះទេ ។

## ឥរិយាបថ និងគំនិតយល់ឃើញចំពោះការថែរក្សាទីតាំងប្រល័យពូជសាសន៍នៅរ៉ាន់ដា

ដំណើរទស្សនកិច្ចរបស់ខ្ញុំទៅកាន់ទីតាំងប្រល័យពូជសាសន៍មូរ៉ាមប៊ី បង្ហាញឲ្យឃើញថាវត្តមាននៃទីតាំងប្រល័យពូជសាសន៍មានសារសំខាន់ខុសគ្នាៗសម្រាប់ក្រុមមនុស្សផ្សេងៗគ្នា ។ ក្រុមភ្ញៀវបរទេសដែលរួមដំណើរជាមួយខ្ញុំ(ដោយរាប់បញ្ចូលទាំងប្ដីរបស់ខ្ញុំដែលមានដើមកំណើតជាជនជាតិរ៉ាន់ដា) បានរំពឹងទុកថាការមកទស្សនាទីតាំងប្រល័យពូជសាសន៍មូរ៉ាមប៊ីនេះនិងបង្ហាញពីរបៀបវារៈរបស់សហគមន៍អន្តរជាតិស្ដីអំពីទីតាំងប្រល័យពូជ-សាសន៍ ។ យើងចង់ចំណាយពេលវេលារបស់យើង ដើម្បីឆ្លុះបញ្ចាំងអំពីសោកនាដកម្មដែលកើតឡើងនៅមូរ៉ាមប៊ីតាមរយៈការធ្វើដំណើររបស់យើងផ្ទាល់ ។ យើងមានការភ្ញាក់ផ្អើល និងខកចិត្តដែលមគ្គុទ្ទេសក៍របស់យើងបានដឹកនាំយើងទស្សនាទីតាំងប្រល័យពូជសាសន៍យ៉ាងប្រញាប់ប្រញាល់ដូច្នេះ ។ យើងនៅមិនទាន់ច្បាស់អំពីលំដាប់លំដោយនៃព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ ដែល

បានកើតឡើងនៅទីនេះនៅឡើយ ។ យើងត្រូវធ្វើការងារយ៉ាងលំបាកដាងការរំពឹងទុករបស់យើងដែលថានឹងរកបានរឿងរ៉ាវពិតតាមការចងចាំរបស់យើង ។ វាបែរជាមានភាពផ្ទុយផ្ទុងនិងមិនទាក់ទងគ្នាទាល់សោះនៅពេលដែលមគ្គុទេសក៍ទេសចរ និងអ្នកថែរក្សាទីតាំងប្រល័យពូជសាសន៍ រៀបរាប់សុំថវិកាពីយើងតាមរយៈការតថ្លៃគ្នាទៅវិញទៅមក ។ ម្យ៉ាងទៀត កង្វះនូវសាច់រឿងដែលទាក់ទងគ្នានឹងព្រឹត្តិការណ៍ដែលបានកើតឡើងនៅមូរ៉ាមប៊ីដែលមាននៅក្នុងកូនសៀវភៅប្បបទុះលោហៈ ឬតាមរយៈដំណើរទស្សនកិច្ច គឺជារឿងដែលគួរឲ្យភ្ញាក់ផ្អើល ។ ខ្ញុំបានគិតយ៉ាងច្បាស់លាស់ថាការរំពឹងទុករបស់ខ្ញុំទៅលើដំណើរទស្សនកិច្ចនេះនឹងបង្រៀនខ្ញុំអំពីប្រវត្តិសាស្ត្រខ្លះៗ ធ្វើឲ្យខ្ញុំមានអារម្មណ៍តក់ស្លុត និងធ្វើឲ្យការស្វែងយល់របស់ខ្ញុំអំពីបទពិសោធន៍នៃអំពើប្រល័យពូជសាសន៍កាន់តែស៊ីជម្រៅ ។ ខ្ញុំចង់បានអ្វីៗដែលត្រឹមត្រូវពិតប្រាកដ និងដែលអាចងាយស្វែងរកបាន ។

ដើម្បីស្វែងយល់កាន់តែច្បាស់អំពីគំនិតផ្ទាល់របស់ពលរដ្ឋរ៉ាន់ដាទាក់ទិននឹងទីតាំងប្រល័យពូជសាសន៍នេះ ខ្ញុំបានជួបសម្ភាសមនុស្សមួយចំនួនដែលផ្តើមចេញពីទស្សនវិស័យនយោបាយនិងស្ថាប័នដូចជាតំណាងខាងរដ្ឋាភិបាល មេធាវីរបស់ជនរងគ្រោះ អ្នកស្រាវជ្រាវជាន់ខ្ពស់ និងប្រជាពលរដ្ឋរ៉ាន់ដាសាមញ្ញ ។ ឥរិយាបថនិងគំនិតយល់ដឹងរបស់ពួកគេឆ្លុះបញ្ចាំងអំពីការបែងចែកដ៏សំខាន់រវាងរបៀបវារៈរបស់រដ្ឋាភិបាលនិងអង្គការក្រៅរដ្ឋាភិបាល ។ តាមទស្សនវិស័យរបស់រដ្ឋាភិបាល ការថែរក្សាទីតាំងប្រល័យពូជសាសន៍និងការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះជាផ្នែកមួយនៃផែនការជាតិស្តីពីការផ្សះផ្សាជាតិ និងការជំរុញឲ្យមានវប្បធម៌សន្តិភាពនៅរ៉ាន់ដា ។ មន្ត្រីរដ្ឋាភិបាលមិនបានទទួលយកការខ្វែងគំនិតគ្នាណាមួយរវាងគោលបំណងទាំងនោះឡើយ ។ ដោយឡែកតំណាងអង្គការក្រៅរដ្ឋាភិបាលនិងអ្នកស្រាវជ្រាវយល់ថា ការថែរក្សានិងការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះជាផ្នែកមួយនៃតម្រូវការជាចាំបាច់ឲ្យមានការចងក្រងជាឯកសារយ៉ាងត្រឹមត្រូវនូវព្រឹត្តិការណ៍ឆ្នាំ១៩៩៤ ហើយអ្នកទាំងនេះត្រូវទទួលស្គាល់ថាមានឧបសគ្គយ៉ាងពិតប្រាកដក្នុងសង្គមនិងនយោបាយដែលរារាំងដល់ការថែរក្សានិងការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ ។ គ្រប់អ្នកដែលខ្ញុំបានសម្ភាសជាមួយមានទស្សនវិស័យយល់ឃើញដារួមមួយនោះ គឺការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនិងការប្រមូលឯកសារអំពើប្រល័យពូជសាសន៍នៅរ៉ាន់ដាមានសារសំខាន់ជាងការអភិរក្សទីតាំងប្រល័យពូជសាសន៍ដែលបម្រើឲ្យគោលការណ៍នៃការធ្វើកោសល្យវិច័យប្ញគរិដ្ឋា ។

ប្រសិនបើមាននរណាម្នាក់សង្កត់ធ្ងន់លើសារសំខាន់នៃការអភិរក្សទីតាំងប្រល័យពូជសាសន៍សម្រាប់ការស៊ើបអង្កេតផ្នែកកោសល្យវិច័យ ខ្ញុំគិតថាជននោះគឺជាមន្ត្រីដែលបំពេញការងារនៅក្នុងផ្នែកយុត្តិធម៌តែប៉ុណ្ណោះ ។ ហេតុដូច្នេះ ការសន្ទនារបស់ខ្ញុំជាមួយលោកអាល់បឺតតូ បាសូមីនជីវ៉ា នៃក្រសួងយុត្តិធម៌រ៉ាន់ដាបានផ្តោតជាសំខាន់ទៅលើទិដ្ឋភាពច្បាប់ស្តីពីការអភិរក្សទីតាំងប្រល័យពូជសាសន៍ ។ ខ្ញុំបានសួរ បាសូមីនជីវ៉ា ថា តើក្រសួងយុត្តិធម៌យល់ថាវាមានសារសំខាន់ដែរឬទេ ក្នុងការអភិរក្សទីតាំងប្រល័យពូជសាសន៍ ដែលការអភិរក្សនេះមិនបានប៉ះពាល់ទៅលើភស្តុតាងជាក់ស្តែង ឬធ្វើឲ្យអន្តរាយដល់ដំណើរការប្រមូលភស្តុតាងផ្សេងៗទៀត ។ លោក បាសូមីនជីវ៉ា បានមានប្រសាសន៍ថាក្រសួងយុត្តិធម៌រ៉ាន់ដាកំពុងតែអនុវត្តនូវប្រព័ន្ធតុលាការប្រជាជន (កាឆាឆា) ដែលភាគច្រើននៃភស្តុតាងទាំងនេះគឺផ្អែកទៅលើចម្លើយសារភាពរបស់កសិណសាក្សី ។ ហេតុដូចនេះ បានជាពួកគេមិនចាប់អារម្មណ៍នឹងការអភិរក្សភស្តុតាងកោសល្យវិច័យដែលបានមកពីទីតាំងប្រល័យពូជសាសន៍នោះឡើយ ។ លោក បាសូមីនជីវ៉ា បានបន្ថែមថាវាប្រហែលជាមានតែក្នុងរឿងក្តីថ្នាក់ខ្ពស់ដែលត្រូវបានកាត់ទោសដោយតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដានៅទីក្រុងអារូហ្សាដែលទាក់ទិននឹងភស្តុតាងកោសល្យវិច័យប៉ុណ្ណោះ ។ លោកយល់ថាត្រឹមថ្នាក់តំបន់មានប្រជាជនជាច្រើនដឹងរឿងរ៉ាវដែលបានកើតឡើងនិងដឹងថានរណាជាអ្នកប្រព្រឹត្ត ព្រមទាំងដឹងថាចម្លើយសារភាពរបស់កសិណសាក្សីគឺ គ្រប់គ្រាន់លើសពីការកាត់សេចក្តីរឿងក្តីជាក់លាក់ទៅទៀត ។ ដូចនេះ ភស្តុតាងកោសល្យវិច័យជាវត្ថុតាងដ៏មានតម្លៃដែលប្រជាជនរ៉ាន់ដាមិនអាចរកបាន និងដែលប្រជាជនរ៉ាន់ដាពុំចាំបាច់រកនោះផង ។

មន្ត្រីពីររូបដែលមកពីគណបក្សរណសិរ្សស្នេហាជាតិរ៉ាន់ដា

គឺលោក វុត្តា បាជីរូ និង ស្យាម៉ាកូសីរ៉ា ចាត់ទុកការទប់ស្កាត់អំពើហិង្សាក្នុងថ្ងៃអនាគតថាជាគោលបំណងសំខាន់ក្នុងការអភិរក្សទីតាំងប្រល័យពូជសាសន៍ ។ ពួកគាត់បានកត់សម្គាល់ឃើញថា អ្នកប្រព្រឹត្តអំពើប្រល័យពូជសាសន៍អាចនឹងយល់ថាការអភិរក្ស ឬការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះធ្វើឲ្យសាធារណជនដឹងនិងចងចាំជានិច្ចនូវទង្វើអាក្រក់របស់ខ្លួន ក៏ប៉ុន្តែនេះមិនមែនជាហេតុផលដែលថាមិនធ្វើនោះទេ ។ ភាពតានតឹងនឹងនៅតែបន្តមានរវាងអ្នកដែលចង់ឲ្យមានការរំឭកអំពើប្រល័យពូជសាសន៍និងអ្នកដែលចង់បំភ្លេចអំពើប្រល័យពូជសាសន៍ ក៏ប៉ុន្តែគណបក្សរណសិរ្សស្នេហាជាតិរ៉ាន់ដាជឿថាការរំឭករឿងរ៉ាវដែលបានកើតឡើង គឺជាជំហានដ៏សំខាន់មួយក្នុងការឆ្ពោះរកឲ្យមានការធានាឲ្យបាននូវសន្តិសុខសម្រាប់ប្រជាជនរ៉ាន់ដា យ៉ាងហោចណាស់នៅក្នុងពេលអនាគតឆាប់ៗនេះ ។ ពួកគាត់សំដៅយកប្រទេសអាហ្វ្រិកខាងត្បូងដែលមានស្ថានភាពស្រដៀងគ្នានឹងរបបផ្តាច់ការអាប៉ាថេត ដែលជាផ្នែកមួយនៃដំណើរការផ្សះផ្សាខាងនយោបាយនិងសង្គម ។

នៅក្នុងជួររដ្ឋាភិបាលរ៉ាន់ដា ក្រសួងយុវជន វប្បធម៌ និងកីឡារ៉ាន់ដាជាអ្នកទទួលខុសត្រូវជាចម្បងក្នុងការរៀបចំពិធីរំឭកអភិរក្ស និងប្រមូលឯកសារអំពើប្រល័យពូជសាសន៍ ។ ផែនការរបស់ក្រសួងយុវជនវប្បធម៌និងកីឡាសម្រាប់សកម្មភាពទាំងបីនេះត្រូវបានបកស្រាយយ៉ាងច្បាស់នៅក្នុងឯកសារមួយដែលមានចំណងជើងថា “ការិយាល័យជាតិបូជនីយដ្ឋានអំពើប្រល័យពូជសាសន៍និងការសម្លាប់រង្គាលនៅរ៉ាន់ដា” ដែលបង្កើតឡើងដោយក្រសួងអប់រំជាន់ខ្ពស់ ការស្រាវជ្រាវតាមបែបវិទ្យាសាស្ត្រ និងវប្បធម៌នៅឆ្នាំ១៩៩៦ ។ អត្ថបទនេះបានពន្យល់អំពីវត្ថុបំណងយុទ្ធសាស្ត្រ វិធីសាស្ត្រ និងថវិកាសម្រាប់ផែនការជាតិនៃការរៀបចំបូជនីយដ្ឋានអំពើប្រល័យពូជសាសន៍ ។ គោលបំណងសំខាន់នៃសកម្មភាពទាំងនេះដែលមាននៅក្នុងផែនការជាតិ គឺ“ការអប់រំពលរដ្ឋរ៉ាន់ដាអំពីវប្បធម៌ មនុស្សធម៌ និងការឈានមុនគេនៃការបញ្ចប់អំពើប្រល័យពូជសាសន៍នៅអាហ្វ្រិកនិងនៅលើពិភពលោក” ។ ចំណុចសំខាន់នៃផែនការគឺការស្ថាបនានូវបូជនីយដ្ឋានជាតិអំពើប្រល័យពូជសាសន៍នៅរីបឺរ៉ូ ឡូរីហ្សុន ក្នុងទីក្រុងឃីហ្គាលី ដែលមានសារមន្ទីរ ទីកប់ខ្មោច មជ្ឈមណ្ឌលឯកសារ និងការជួយសម្រួលរៀបចំការប្រជុំ ។ សារមន្ទីរប្រហាក់ប្រហែលគ្នាត្រូវបានគេគ្រោងនឹងសាងសង់នៅក្នុងខេត្តចំនួន១២នៃប្រទេសរ៉ាន់ដា ។

ផែនការរំឭកអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៩៤មានលក្ខណៈស្រដៀងគ្នាទៅនឹងបទអត្ថាធិប្បាយដោយមន្ត្រីក្រសួងយុវជន វប្បធម៌ និងកីឡា ។ ផែនការនោះបានលើកឡើងថា ការសំខាន់នៃផែនការមជ្ឈការឆ្នាំ១៩៩៦នេះផ្ទុយពីគំនិតដែលលើកឡើងដោយអគ្គលេខាធិការ ជេន មុគីមបឺរី ដែលក្រសួងពុំមានគោលបំណងចង់ឲ្យដំណើរការនេះក្លាយទៅផែនការមជ្ឈការនោះទេ ពីព្រោះមន្ត្រីទាំងនេះមិនចង់ចងចាំនូវកម្លាំងនយោបាយដែលបង្កើតឲ្យមានអំពើប្រល័យពូជសាសន៍នៅទីនេះនោះឡើយ ។ ជេន មុគីមបឺរី បានសង្កត់ធ្ងន់ទៅលើទិសដៅអនាគតយូរអង្វែងដូចជាការអប់រំដល់ពលរដ្ឋទូទៅ ការទប់ស្កាត់ជម្លោះផ្សេងៗ និងការផ្សះផ្សាសង្គមនិងនយោបាយ ។ តាមទស្សនៈរបស់លោក ជេន មុគីមបឺរី ថា វត្ថុបំណងទាំងពីរ គឺការចងចាំនិងសន្តិភាព មិនមែនជាវត្ថុបំណងពីរដែលផ្ទុយគ្នាឬដាច់ដោយឡែកពីគ្នានោះទេ ។ ក្រៅពីបូជនីយដ្ឋាន ក្រសួងនឹងឧបត្ថម្ភគាំទ្រឲ្យមានគម្រោងឲ្យមានការរៀបចំជាសន្និសីទ ជាកម្មវិធីពិភាក្សា បញ្ចាំងខ្សែភាពយន្តឯកសារ ការស្រាវជ្រាវដែលនឹងពិនិត្យទៅលើព្រឹត្តិការណ៍ឆ្នាំ១៩៩៤ និងការជំរុញឲ្យមានការផ្សះផ្សានិងសន្តិភាព ។

ដោយចងចាំវត្ថុបំណងទាំងនេះ លោកអគ្គលេខាធិការ ជេន មុគីមបឺរី បានសម្គាល់ឃើញថា មានបញ្ហាបន្ទាន់មួយចំនួនដែលចាំបាច់ឲ្យមានការយកចិត្តទុកដាក់មួយរយៈពេលខ្លី ។ មានពលរដ្ឋរ៉ាន់ដាជាច្រើនមិនទាន់បានបញ្ចុះសាកសពគ្រួសារ ឬញាតិសន្តានរបស់ខ្លួន ហើយសេចក្តីត្រូវការបន្ទាន់មួយទៀត គឺតម្រូវការអ្នកជំនាញបច្ចេកទេសដែលមានជំនាញក្នុងការថែរក្សាសាកសពរណ្តៅសាកសព អគារ ។ល ។ លោកអគ្គលេខាធិការ បានបន្ថែមទៀតថា សម្រាប់ពេលបច្ចុប្បន្ននេះ សហគមន៍នៅក្នុងតំបន់ត្រូវបន្តទទួលខុសត្រូវ(ផ្នែកហិរញ្ញវត្ថុនិងភ័ស្តុភារ) លើការរៀបចំពិធីរំឭកព្រឹត្តិការណ៍ដែលបានកើតឡើង ។ ហើយប្រទេសផ្សេងៗជាច្រើនទៀតដែលជាប់ជំពាក់ជំពិនដោយប្រយោលនៅក្នុងព្រឹត្តិការណ៍អំពើប្រល័យពូជសាសន៍នេះ (ដោយរាប់បញ្ចូលទាំងសហរដ្ឋអាមេរិក) មិនគួរ“ធ្វើពហិការ”មិនចូលរួមជាមួយប្រទេស

រ៉ាន់ដា ឬសិក្សានិងចងចាំអំពើប្រល័យពូជសាសន៍ ដោយភ័យខ្លាចថាវាអាចបង្ហាញការចូលដៃក្នុងអំពើប្រល័យពូជសាសន៍នោះទេ ។ រដ្ឋាភិបាលរ៉ាន់ដាកំពុងតែស្វះស្វែងយ៉ាងសកម្មក្នុងការស្វែងរកដៃគូអន្តរជាតិជួយឧបត្ថម្ភគាំទ្រគោលបំណងទាំងនេះ ។ ដូចគ្នានេះដែរ លោកអគ្គលេខាធិការបានមានប្រសាសន៍ថា ដោយសារតែជនជាតិហ៊ូទូទាំងអស់មិនមែនសុទ្ធតែជាជនដៃដល់ពលរដ្ឋរ៉ាន់ដាស្ទើរតែទាំងអស់បានរួមចំណែកយ៉ាងសកម្មក្នុងការកាត់សេចក្តីនូវរឿងរ៉ាវដែលបានកើតឡើងនៅឆ្នាំ១៩៩៤ ដូចនេះបុគ្គលម្នាក់ៗត្រូវទទួលខុសត្រូវចំពោះហេតុការណ៍នេះ គឺមិនមែនជាក្រុមនោះទេ ។ ដេន មុគីមប៊ីរី បន្តថា នៅចុងសតវត្សរ៍ទី២០ ពលរដ្ឋរ៉ាន់ដាខិតខំប្រឹងប្រែងកាន់តែខ្លាំងៗឡើងដើម្បីបែងចែងជាក្រុមហ៊ូទូនិងទុតស៊ីជាជាងបង្រួបបង្រួមក្រុមទាំងពីរ ហើយរដ្ឋាភិបាលយកបញ្ហានេះលើកដាក់ខ្លួនឯងដើម្បីបង្កើនទិន្នាការនេះ ។

ឥរិយាបថនិងគំនិតយល់ដឹងដែលខ្ញុំបានប្រមែប្រមូលពីតំណាងរដ្ឋាភិបាលដូចមានសង្ខេបខាងក្រោមនេះ ៈ

ការអភិរក្សឬការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះត្រូវឲ្យស៊ីគ្នានឹងគោលបំណងនយោបាយ ដែលរួមមានការផ្សះផ្សានិងការទប់ស្កាត់ជម្លោះ ។

ពុំត្រូវមានឧបសគ្គក្នុងសង្គមនិងនយោបាយដែលធ្វើឲ្យរាំងស្ទះដល់ការរំឭកអំពើប្រល័យពូជសាសន៍តាមរយៈការអភិរក្សទីតាំងការសាងសង់បូជនីយដ្ឋាន និងការប្រមូលឯកសារប្រវត្តិសាស្ត្រនោះទេ ។

ផែនការវិមជ្ឈការក្នុងការសម្រេចបានដំណើរការនេះ ត្រូវមានលក្ខណៈសមស្របតាមផែនការដែលរដ្ឋអំណាចមជ្ឈការអាចគ្រប់គ្រងស្ថានភាពជម្លោះនៅក្នុងប្រទេសរ៉ាន់ដា ហើយក្នុងពេលនោះរដ្ឋាភិបាលខ្លួនឯងផ្ទាល់មិនត្រូវឋិតក្នុងគោលជំហរមួយក្នុងការផ្តល់ថវិកាទៅឲ្យសកម្មភាពទាំងនេះឡើយ ។

ជាមួយនឹងតំណាងដែលមកពីអង្គការក្រៅរដ្ឋាភិបាល ខ្ញុំបានសម្ភាសជាមួយលោក ហ្វ្រង់ស័រ-រីហ្គីស រាគុនដាយូវ៉ុហ្កា ដែលនៅពេលនោះគាត់ជាលេខាប្រតិបត្តិនៃអង្គការអាយប៊ូកា *(IBUKA)* ជាអង្គការជួយសង្គ្រោះជនរងគ្រោះធំបំផុតមួយនៅក្នុងប្រទេសរ៉ាន់ដា ។ បើទោះបីជា«ការរំឭក»នេះជាវិស័យសំខាន់មួយក្នុងចំណោមវិស័យសំខាន់បីនៃកម្មវិធីរបស់អង្គការអាយប៊ូកា (ក្រៅពី«យុត្តិធម៌»និង«ការជួយដល់ជនរងគ្រោះ») ផ្នែកនេះបង្កើតជាសកម្មភាពតូចៗនៃអង្គការអាយប៊ូកា ជាពិសេសដោយសារតែកង្វះខាតនូវថវិកាតែម្តង ។ អ្វីដែលអង្គការអាយប៊ូកាបានធ្វើក្នុងការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពុំសូវធ្វើជាមួយនឹងអដ្ឋិធាតុជាក់ស្តែងរបស់ជនរងគ្រោះដោយអំពើហិង្សានៅនឹងទីតាំងប្រល័យពូជសាសន៍នោះទេ គឺច្រើនតែប្រមូលឯកសារប្រល័យពូជសាសន៍តាមរយៈការប្រើប្រាស់រឿងរ៉ាវរបស់ជនរងគ្រោះដែលជាប្រភពឯកសារទីមួយ ។ ខ្ញុំបានសួរលោក រ៉ាគុនដាយូវ៉ុហ្កា ថាតើគាត់ចង់ឃើញអ្វីនៅក្នុងផ្នែកនៃការរំឭកនេះ ។ រ៉ាកយុនដាយូវ៉ុហ្កា បានឆ្លើយដោយមិនស្ទាក់ស្ទើរក្នុងចិត្តថា កិច្ចការជាអាទិភាពដំបូងបំផុតរបស់លោក គឺគម្រោងឯកសារដោយប្រមែប្រមូលនិងដាក់បញ្ចូលគ្នានូវព័ត៌មានទាំងអស់ស្តីពីអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៩៤ ។ រ៉ាគុនដាយូវ៉ុហ្កា គ្រោងនឹងប្រមែប្រមូលនូវចម្លើយកសិណសាក្សីជាបុគ្គលពីជនរងគ្រោះនិងជនដៃដល់ស្តីពីបទពិសោធន៍របស់ពួកគេនៅក្នុងឆ្នាំ១៩៩៤ ព្រមទាំងរឿងរ៉ាវជីវិតរបស់ជនរងគ្រោះក្រោយអំពើប្រល័យពូជសាសន៍ ។ រ៉ាគុនដាយូវ៉ុហ្កា សង្ឃឹមថា អង្គការអាយប៊ូកានឹងគាំទ្រដល់ការស្រាវជ្រាវទៅលើបុព្វហេតុដែលនាំឲ្យមានអំពើប្រល័យពូជសាសន៍និងកាលប្បវត្តិលម្អិតនៃរឿងរ៉ាវដែលបានកើតឡើងពីខែមេសាដល់កក្កដា ឆ្នាំ១៩៩៤ ។ ចក្ខុវិស័យរបស់អង្គការអាយប៊ូកាគឺការប្រមែប្រមូលព័ត៌មានទាំងអស់នេះ និងផ្សព្វផ្សាយតាមរយៈការបោះពុម្ព ជាឯកសារ កាសែត ឬទស្សនាវដ្តី និងតាមរយៈបច្ចេកទេសអេឡិចត្រូនិច ហើយបន្ទាប់មកធ្វើឲ្យព័ត៌មាននេះអាចនឹងផ្សព្វផ្សាយទូទាំងប្រទេសរ៉ាន់ដាតាមរយៈការតាំងពិព័រណ៍ចល័ត ។

ទាក់ទិននឹងសំណួរថាតើកិច្ចការរៀបចំរំឭកអំពើប្រល័យពូជសាសន៍អាចរារាំងដល់កិច្ចខិតខំប្រឹងប្រែងបង្រួបបង្រួមនិងផ្សះផ្សានៅរ៉ាន់ដាដែរឬទេ? រ៉ាគុនដាយូវ៉ុហ្កា បានមានប្រសាសន៍ថាពិតប្រាកដណាស់ ការងារនេះអាចរារាំងដល់កិច្ចខិតខំប្រឹងប្រែងបង្រួបបង្រួមនិងការផ្សះផ្សានៅក្នុងប្រទេសរ៉ាន់ដា ។ តាមទស្សនៈផ្ទាល់របស់លោកក្នុងនាមជាមេធាវីជនរងគ្រោះ រ៉ាគុនដាយូវ៉ុហ្កា ទទួលស្គាល់ថារបៀបវារៈរបស់អង្គការអាយប៊ូកាជារឿយៗ

ប៉ះទង្គិចផ្ទាល់ មិនត្រឹមតែជាមួយនឹងបញ្ហារបស់ជនដែលរងគ្រោះផ្ទាល់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាបញ្ហារបស់ក្រុមទុតស៊ីផងដែរ ទៀតនិងរដ្ឋាភិបាលផ្ទាល់ (ព្រមទាំងក្រុមជនរងគ្រោះ ប្រសិនបើការអត្ថាធិប្បាយរបស់ អែមមែនញូអែល ផ្តល់នូវសញ្ញាណឲ្យឃើញណាមួយនោះ) ។ លោកយល់ថា ត្រូវតែវែកញែកពិភាក្សាអំពីផលប្រយោជន៍ជនរងគ្រោះដោយសំអាងលើផលប្រយោជន៍របស់រដ្ឋាភិបាលនិងប្រទេសជាតិទាំងមូល ។ ទោះបីជាយ៉ាងណាក៏ដោយ អង្គការអាយប៊ូកាបេ្តជ្ញាសម្រេចឲ្យបាននូវគោលដៅក្នុងការ"ទប់ស្កាត់ការស្ងាប់របស់ពលរដ្ឋរ៉ាន់ដា" និងឧបត្ថម្ភគាំទ្រផលប្រយោជន៍សមាជិករបស់ខ្លួនដោយមិនគិតពីឧបសគ្គនៅក្នុងសង្គមឬនយោបាយដែលអ្នកទាំងនោះបានជួបប្រទះឡើយ ។

ចុងក្រោយនេះ ខ្ញុំបានជួបសម្ភាសដាច់ដោយឡែកជាមួយអ្នកស្រាវជ្រាវជាន់ខ្ពស់ពីររូបនៃសកលវិទ្យាល័យជាតិរ៉ាន់ដា ។ អ្នកស្រាវជ្រាវទាំងពីររូបនេះមានគំនិតដូចគ្នាច្រើនទៅនឹងការបកស្រាយរបស់ រ៉ាគុនដាយូវ៉ុហ្គា ស្តីពីបញ្ហាអភិរក្ស ការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ និងការប្រមូលឯកសារ ។ អ្នកស្រាវជ្រាវម្នាក់យល់ថា ដំណើរការនៃការរំឭកអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៩៤ ជាការដាក់បន្ទុកទៅលើនយោបាយ គឺពុំដឹងថាតើត្រូវចាប់ផ្តើមដំណើរការនេះដោយមធ្យោបាយបែបណា ដែលនឹងបំពេញតម្រូវចិត្តរបស់គំណាងឲ្យប្រជាជននៅក្នុងប្រទេសរ៉ាន់ដានោះទេ ។ ដូចនេះ សកម្មភាពអភិរក្សនិងរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះគួរតែប្រគល់ទៅឲ្យសហគមន៍ក្នុងតំបន់ធ្វើប្រសើរជាងការសម្រេចចិត្តរបស់សហគមន៍អាចធ្វើឡើងដោយផ្អែកទៅលើទស្សនៈយល់ឃើញ ក្នុងតំបន់និងរូបភាពពិតប្រាកដនៃអំពើប្រល័យពូជសាសន៍ដែលប៉ះពាល់ដល់តំបន់នោះតែម្តង ។

តួនាទីរបស់សកលវិទ្យាល័យជាតិរ៉ាន់ដានៅក្នុងដំណើរការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះអាចបង្កើតជាមណ្ឌលឯកសារជាតិតម្កល់ឯកសារប្រវត្តិសាស្ត្រដែលទាក់ទងនឹងអំពើប្រល័យពូជសាសន៍ ដោយរាប់បញ្ចូលបណ្ណសារដ្ឋានស្តីពីរបបមុន ភាពយន្តឬរូបថត ចម្លើយកសិណសាក្សី ។ល។ មណ្ឌលឯកសារជាតិមិនត្រឹមតែរំឭកនូវរឿងរ៉ាវដែលបានកើតឡើងប៉ុណ្ណោះទេ តែថែមទាំងអាចជាប្រភពឯកសារដ៏សំខាន់សម្រាប់អ្នកដែលមានបំណងសិក្សាស្វែងយល់អំពីព្រឹត្តិការណ៍ឆ្នាំ១៩៩៤ផងដែរ ។ តាមទស្សនៈវិស័យរបស់អ្នកស្រាវជ្រាវជាន់ខ្ពស់ពីររូបនេះ យល់ថា ការប្រមូលឯកសារត្រឹមត្រូវនិងហ្មត់ចត់ជាជំហានដំបូងនៅក្នុងដំណើរការអភិរក្សនិងរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ ។ អ្នកទាំងពីរបានឲ្យហេតុផលថា ប្រសិនបើគ្មានការកាត់សេចក្តីដែលអាចជឿទុកចិត្តនិងយកជាការបានទៅលើអង្គហេតុដែលបានកើតឡើងទេនោះ ការខិតខំប្រឹងប្រែងក្នុងការរំឭកនិងចងចាំអំពើប្រល័យពូជសាសន៍នឹងរៀបរាប់រឿងរ៉ាវដោយមានភាពលម្អៀង ដោយអត្តនោម័តិនិងដោយការអូសទាញខាងនយោបាយ ។

ឥរិយាបថនិងការយល់ដឹងដែលខ្ញុំបានប្រមែប្រមូលពីតំណាងអង្គការក្រៅរដ្ឋាភិបាលនិងផ្នែកសិក្សាស្រាវជ្រាវមានសង្ខេបដូចខាងក្រោមនេះ ÷

ការប្រមូលឯកសារជាជំហានសំខាន់ក្នុងការរំឭកនិងចងចាំអំពើប្រល័យពូជសាសន៍ និងមានអាទិភាពជាងការអភិរក្សទីតាំងប្រល័យពូជសាសន៍ ។

ឧបសគ្គសំខាន់ៗក្នុងសង្គមនិងនយោបាយដែលរារាំងដល់ការរំឭកអំពើប្រល័យពូជសាសន៍ ក៏ប៉ុន្តែពុំមែនមានន័យថាមិនអាចពុះពារជម្នះមិនបាននោះទេ ។

## សន្និដ្ឋាន

បើទោះបីជារដ្ឋាភិបាលរ៉ាន់ដាមានផែនការច្បាស់លាស់ក្នុងការរៀបចំរំឭកអំពើប្រល័យពូជសាសន៍តាមរយៈការសាងសង់នូវសារមន្ទីរ ហើយសកលវិទ្យាល័យជាតិរ៉ាន់ដានិងអង្គការអាយប៊ូកាមានគំនិតរួមគ្នាមួយក្នុងមធ្យោបាយដែលពួកគេនឹងចាប់ផ្តើមប្រមែប្រមូលឯកសារអំពើប្រល័យពូជសាសន៍យ៉ាងណាក៏ដោយ ក៏ពុំមាននរណាម្នាក់ដែលខ្ញុំបានជួបសម្ភាសមានផែនការ ឬគម្រោងច្បាស់លាស់ ហើយដំណើរការអំពីការថែរក្សាទីតាំងប្រល័យពូជសាសន៍ដែលមិនត្រូវបានគេកំណត់យ៉ាងទូលំទូលាយដែរ ។ ដោយផ្អែកយុត្តិធម៌នៅរ៉ាន់ដាមិនតវ៉ាទាមទារឲ្យមានការការពារនូវភ័ស្តុតាងកោសល្យវិច័យហាក់ដូចជាពុំមានហេតុផលច្បាស់លាស់ ដែលពេញចិត្តនឹងដំណើរការអភិរក្សទីតាំងប្រល័យពូជសាសន៍ ជាងការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនិងការប្រមូលឯកសារទេ ។ ជាការពិតណាស់ ការខិតខំប្រឹងប្រែងមួយចំនួនក្នុងការរំឭកវិញ្ញាណក្ខន្ធជន

រងគ្រោះមានទំនាក់ទំនងនឹងការរក្សាទុកវត្ថុតាងមិនឲ្យប៉ះពាល់ ដើម្បី“ថែរក្សាឲ្យបានយូរ”នូវរូបភាពនៃអំពើប្រល័យពូជសាសន៍ ឬលទ្ធផលក្រោយអំពើប្រល័យពូជសាសន៍ (ករណី នៅមូរ៉ាមប៊ី ក៏ប៉ុន្តែប្រហែលជាច្រើនជាងនេះនៅនីយ៉ាម៉ាតា) ។ ម្យ៉ាងទៀត ឯកសារប្រវត្តិសាស្ត្រតែងទាមទារឲ្យមានការថែរក្សាឯកសារ បណ្ណសារដ្ឋានដូចជា ឯកសារ រូបថត និងវត្ថុតាងផ្សេងៗទៀត ។ ក៏ប៉ុន្តែការរៀបចំឡើងវិញនិងការអភិរក្សទីតាំងប្រល័យពូជសាសន៍តាមចិត្តចង់ហាក់ដូចជាមិនមានសារសំខាន់នៅឡើយ នៅក្នុងប្រទេសរ៉្វាន់ដានាពេលបច្ចុប្បន្ននេះ ។

ដោយការកសាងបូជនីយដ្ឋានរំឭកអំពើប្រល័យពូជសាសន៍ បម្រើឲ្យគោលនយោបាយជាក់លាក់មានហេតុផលយូរអង្វែងដែលអាចជឿទុកចិត្តបានសម្រាប់ការចាប់ផ្ដើមដំណើរការគម្រោងនេះ ។ ការអប់រំពលរដ្ឋរ៉្វាន់ដាបច្ចុប្បន្ននិងជំនាន់ក្រោយអំពីអំពើប្រល័យពូជសាសន៍ក្នុងទិសដៅទប់ស្កាត់អំពើប្រល័យពូជសាសន៍ក្រោយៗទៀតនិងការបង្រៀនអំពីវប្បធម៌គោរពសិទ្ធិមនុស្ស គឺជាគោលបំណងដែលស្តែងចេញយ៉ាងច្បាស់របស់រដ្ឋាភិបាលរ៉្វាន់ដា ។ បើទោះបីជាពលរដ្ឋរ៉្វាន់ដាបដិសេធនឹងគំនិតដែលថាទីតាំងប្រល័យពូជសាសន៍ជាឱកាសសម្រាប់រកចំណូលពីភ្ញៀវទេសចរបរទេសយ៉ាងណាក៏ដោយ បំណងប្រាថ្នាចង់ឲ្យពិភពលោកបានដឹងអំពីការពិតដែលគួរឲ្យខ្ញើមរអើមដែលបានកើតឡើងនៅប្រទេសរ៉្វាន់ដាឆ្នាំ ១៩៩៤ នេះក៏ជាភស្តុតាងផងដែរ ។ សំណួរដែលមិនទាន់មានចម្លើយនោះគឺ ថាតើគោលបំណងនៃការអប់រំគួរតែប្រើប្រាស់តាមរយៈបូជនីយដ្ឋានឬសារមន្ទីរ ឬតាមរយៈការថែរក្សា យ៉ាងយកចិត្តទុកដាក់នូវទីតាំងប្រល័យពូជសាសន៍ (ឬទាំងពីរ) ដែរឬយ៉ាងណា ។ ក៏ប៉ុន្តែ គំនិតដែលខ្ញុំជួបប្រទះនៅរ៉្វាន់ដាហាក់ដូចជាពេញចិត្តនឹងបំណងឲ្យមានការអប់រំតាមរយៈការសាងសង់បូជ-នីយដ្ឋាន ឬសារមន្ទីរជាងការអភិរក្សយ៉ាងយកចិត្តទុកដាក់នូវទីតាំងប្រល័យពូជសាសន៍ ។

តាមទស្សនៈរបស់បុគ្គលផ្ទាល់និងសាសនា (ដែលផ្ទុយគ្នាទៅនឹងទស្សនៈរបស់អ្នកនយោបាយ អ្នកច្បាប់ ឬបញ្ញវន្ត) វាច្បាស់ណាស់ថា សហគមន៍ទាំងឡាយដែលទទួលរងនូវការឈឺចាប់ដោយសារការបាត់បង់អាយុជីវិតនៅក្នុងអំឡុងនៃអំពើប្រល័យពូជសាសន៍ត្រូវបានជំរុញឲ្យមានការរំឭកដល់ព្រឹត្តិការណ៍ឆ្នាំ ១៩៩៤ ។ តាមរយៈការបញ្ចុះសពជនរងគ្រោះរួមគ្នានៅទីតាំងសម្លាប់តែមួយ (ដែលផ្ទុយពីទំនៀមទម្លាប់ប្រពៃណីនៃការបញ្ចុះសពជនរងគ្រោះនៅឯគេហដ្ឋានញាតិសន្តានរបស់ជនរងគ្រោះ) ឬតាមរយៈការសាងសង់បូជនីយដ្ឋាន ឬតាមរយៈការរក្សាទុករណ្ដៅសាកសព សាលារៀន ព្រះវិហារ ។ល។ ការមិនឲ្យប៉ះពាល់ដើម្បីជាការរំឭកដល់ការសម្លាប់នេះ ក៏មតិខ្លះចង់ឲ្យមានរំឭកនិងគោរពដល់សពជនរងគ្រោះយ៉ាងទូលំទូលាយនិងតាមធម្មជាតិ ។ ជាថ្មីម្តងទៀត ពុំមានការបង្ហាញណាមួយដែលថាការអភិរក្សឆ្លើយតបទៅនឹងសេចក្តីត្រូវការបែបនេះជាជាងការរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះនោះឡើយ ។

សកម្មភាពទាំងបីដែលរៀបរាប់ខាងលើនេះសុទ្ធតែមានប្រយោជន៍ដូចគ្នា បើទោះបីជាខ្ញុំបានរកឃើញនូវគំនិតដែលចង់ឲ្យមានគម្រោងរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះពីពលរដ្ឋរ៉្វាន់ដាភាគច្រើនយ៉ាងណាក៏ដោយ ។ អំពើប្រល័យពូជសាសន៍ដែលទើបតែកើតឡើងថ្មីៗនេះបញ្ចាំងពីអារម្មណ៍តក់ស្លុត ការប៉ះទង្គិចផ្លូវចិត្ត កំហឹង និងការមិនជឿទុកចិត្តដែលជនរងគ្រោះនិងសហគមន៍របស់ខ្លួនបានជួបប្រទះ ។ ការប្រមូលឯកសារដែលត្រូវចំណាយពេលវេលាយូរ និងឲ្យមានលក្ខណៈត្រឹមត្រូវស្តីអំពីការប្រល័យពូជសាសន៍ឆ្នាំ ១៩៩៤នេះ មានសារសំខាន់ក្នុងការធ្វើឲ្យអ្នកកែប្រែប្រវត្តិសាស្ត្រមានការខ្លាចញញើត និងអាចជួយដល់ការស្រាវជ្រាវទៅលើអំពើប្រល័យពូជសាសន៍តាមកម្រិតអន្តរជាតិបានល្អប្រសើរជាងមុន ។ ក្នុងខណៈពេលដែលពលរដ្ឋរ៉្វាន់ដាបន្តការងារអភិរក្ស រំឭក និងប្រមូលឯកសារអំពើប្រល័យពូជសាសន៍ឆ្នាំ១៩៩៤ ទំនាក់ទំនងនៃដំណើរការទាំងបីនេះនៅក្នុងសង្គមនិងនយោបាយ អាចនឹងកើតឡើងដោយជៀសមិនបាន ។ ដូចនេះរឿងរ៉ាវនៃទីតាំងប្រល័យពូជសាសន៍រ៉្វាន់ដា ក៏ជារឿងរ៉ាវនៃអំពើប្រល័យពូជសាសន៍របស់ប្រទេសរ៉្វាន់ដាដែរ ព្រមទាំងជារឿងរ៉ាវដែលអ្នកស្រុកសរសេររៀបរាប់អំពីអតីតកាលដ៏សែនខ្លោចផ្សា ហើយរឿងរ៉ាវនេះនឹងមិនទាន់បញ្ចប់នោះទេ ប្រសិនបើគេនៅតែមិនទាន់ដឹងអំពីរូបរាងនៃនយោបាយពិតប្រាកដ ។

**ស៊ូហ្សាន់ អ៊ី យុក**

# ខ្ញុំ និង ថ្នាំជក់

ជោគជ័យនៃការផ្តាច់ការញៀនបារីគឺជារឿងអស្ចារ្យខ្លាំងណាស់សម្រាប់ខ្ញុំ ។ ក៏ប៉ុន្តែអ្វីដែលសំខាន់ជាងនេះទៅទៀតនោះគឺ អនុស្សាវរីយ៍ដែលខ្ញុំមិនអាចបំភ្លេចបានពីមូលហេតុដែលនាំឲ្យខ្ញុំក្លាយខ្លួនជាអ្នកជក់បារី ហើយក្លិននិងផ្សែងបារីបានជិតជាប់ខ្លួនរបស់ខ្ញុំអស់រយៈពេលជិត៣០ឆ្នាំកន្លងមកហើយ ។ ខ្ញុំសូមរៀបរាប់ដោយសង្ខេបនូវប្រវត្តិរឿងរ៉ាវដែលនាំឲ្យខ្ញុំក្លាយខ្លួនជាអ្នកញៀនបារី ។

នារដូវវស្សាឆ្នាំ១៩៧៧ ឪពុកខ្ញុំត្រូវអង្គការចាប់យកទៅរៀនសូត្រនៅមន្ទីរសន្តិសុខកោះថ្មី (មន្ទីរ១៥) ក្នុងស្រុក២០ តំបន់២៥ ។ ខ្ញុំត្រូវប្រធានកងកុមារនៅការដ្ឋានស្អាងភ្នំក្រាំងយ៉ូវ បញ្ជូនខ្លួនទៅក្នុងកងចល័តយុវជនប្រចាំស្រុក២០(ស្រុកស្អាង ខេត្តកណ្តាល) ដើម្បីលត់ដំគោលជំហរបដិវត្តន៍ឲ្យមុតស្រួច ។ ពិធីប្រកាសចូលកងចល័តយុវជនត្រូវបានប្រព្រឹត្តទៅនៅវេលាយប់ក្នុងបរិវេណវត្តឬស្សីជ្រោយ ឃុំស្វាយប្រទាល ស្រុកស្អាង ។ ខ្មែរក្រហមបានបែងចែកយុវជនជាបួនកងធំៗគឺ កង១៤ កង១៥ កង១៦ និងកង១៧ ។ កង១៤ជាអ្នកពេញសិទ្ធិ ហើយកង១៥ និងកង១៦ ជាប្រជាជនមូលដ្ឋាន ។ ចំណែកកងរបស់ខ្ញុំ គឺកង១៧ ជាប្រជាជន១៧មេសា ។ កងទាំងបួននេះមានភារកិច្ចលើកទំនប់ និងជីកប្រឡាយសម្រាប់ឃុំចំនួនបួនក្នុងស្រុក២០គឺឃុំស្វាយប្រទាល ឃុំត្រើយស្លា ឃុំតាលន់ និងឃុំខ្ពប ។

កង១៨មានសិទ្ធិច្រើនជាងគេ និងទទួលបានការយកចិត្តទុកដាក់យ៉ាងពិសេសពីអង្គការ ។ ផ្ទុយទៅវិញ កង១៧ទទួលរ៉ាប់រងធ្វើការយ៉ាងធ្ងន់ធ្ងរ ទទួលទានអាហារក្រោយគេ ហើយទទួលរងការប្រមាថមើលងាយនិងលេងសើចដូចសត្វធាតុថែមទៀត ។ ប្រជាជនមូលដ្ឋានខ្លាចរអើមមិនហ៊ាននៅជិតទេ ។ ជាមួយវិន័យដ៏តឹងរឹងនិងការងារពលកម្មធ្ងន់ធ្ងរ ខ្ញុំសង្កេតឃើញវិធីមួយដែលកង១៧អាចដកឃ្លានិងឈប់សម្រាកពីការងារបានមួយភ្លែតៗ នោះគឺការសម្រាកជក់បារី ។ ទាំងមេកងនិងមេក្រុមហាក់ដូចជាមានការយោគយល់ច្រើនដល់អ្នកបេះជក់បារី ។

ក្នុងចំណោមយុវជន១៧មេសា គ្មាននរណាបេះជក់បារីទេ ។ ដូច្នេះ ខ្ញុំត្រូវតែសាកល្បងរៀនបឺតដុំផ្សែងបារីដើម្បីមានឱកាសឈប់សម្រាកដូចក្រុមផ្សេងៗដែរ ។ ដោយសារតែការបេះជក់បារីនេះហើយ ទើបខ្ញុំអាចចងមិត្តភាពជាមួយប្រជាជនមូលដ្ឋានបាន ។ សាកល្បងគិតទៅមើលថា ប្រសិនបើចង់ជក់បារីម្តងៗ ខ្ញុំត្រូវចំណាយពេលប៉ុន្មាន? ដំបូងខ្ញុំត្រូវមូរថ្នាំជក់ជាមួយស្លឹកសង្កែ ឬស្លឹកចេក (ដោយមិនសូវស្ទាត់) ហើយខ្ញុំត្រូវដើរសំដៅទៅភ្នក់ភ្លើង ដើម្បីកាយយករងើកភ្លើងមកអុជចុងបារី ។ បន្ទាប់មកខ្ញុំត្រូវដើរ ត្រឡប់មករកបង្គី-ដងវែករបស់ខ្ញុំវិញ រួចហើយខ្ញុំឈរជក់នៅលើខ្នងទំនប់ ដើម្បីទុកពេលឲ្យដៃគូកាប់ដីរបស់ខ្ញុំអាចឈរសម្រាកបាន ។ គិតៗទៅខ្ញុំសម្រាកបានយូរគួរសមដែរ ។

ចំណុចសំខាន់មួយទៀតនោះគឺថា មានថ្នាំជក់គឺមានអ្វីៗទាំងអស់ ។ មេដឹកនាំខ្មែរក្រហមមិនបានដឹងថា នៅតាមសហករណ៍នីមួយៗទាំង ប្រជាជនចាស់និងប្រជាជនថ្មីកំពុងនាំគ្នាធ្វើពាណិជ្ជកម្មតាមបែបសម័យបុព្វកាលទេមើលទៅ ។ ប្រជាជនទាំងនេះបានដោះដូរទំនិញគ្នាទៅវិញទៅមកដោយលួចលាក់ ។ ថ្នាំជក់គឺជាមុខទំនិញពេញនិយមជាងគេ ដែលអាចដោះដូរជាមួយស្ករត្នោត មេមាន់ ត្រីងៀត អំបិល ពោត និងដំឡូងជាដើម ។

នៅស្រុកខ្ញុំសម្បូរថ្នាំជក់គួរសមដែរ តែក្នុងកងចល័តខ្ញុំ មេកងបានចែករបបថ្នាំជក់ឲ្យតែអ្នកបេះជក់ប៉ុណ្ណោះ ។ ដូច្នេះនៅពេលទទួលរបបថ្នាំជក់ម្តងៗ ខ្ញុំអាចធ្វើការដោះដូរយកគ្រឿងបរិភោគសម្រាប់ខ្លួនឯងនិងសាច់ញាតិបងប្អូនដែលអាចរស់បានមួយគ្រាៗដែរ ។ ជួនកាល ខ្ញុំបានចែករំលែករបបថ្នាំជក់របស់ខ្ញុំឲ្យមេក្រុម ឬមេកង ដើម្បីជាថ្នូរនឹងការរួចរស់ជីវិត ។ នៅក្នុងកង១៧របស់ខ្ញុំ ដែលមានចំនួនមនុស្សប្រហែល៤០០នាក់ (គិតចាប់ពីពេលបង្កើតកងរហូតមកដល់ដើមខែមករា ឆ្នាំ១៩៧៩) អ្នកដែលរស់រានមានជីវិតនៅមិនដល់៦០នាក់ផង ។

សព្វថ្ងៃនេះ ទោះបីជាខ្ញុំឈប់ជក់បារីក៏ដោយ ខ្ញុំនៅតែដឹងគុណថ្នាំជក់ជានិច្ច ។ នៅពេលខ្ញុំទៅផ្សារ ខ្ញុំតែងក្រឡេកមើលតូប

លក់បារីថ្នាំខ្មែរ ស្ករត្នោត អំបិល គំនរដំឡូង ឬពោត ហើយឈរភ្លឹកនឹកទៅដល់ភាពអត់ឃ្លាន និងជនរងគ្រោះដែលស្លាប់ដោយដាច់ពោះអត់អាហារក្នុងរបបខ្មែរក្រហម ។ ជនរងគ្រោះខ្លះក៏ត្រូវឈ្លបចាប់យកទៅសម្លាប់ដោយសារលួចរបស់ទាំងនោះដើម្បីបំពេញនូវសេចក្ដីស្រេកឃ្លានរបស់ខ្លួន ។

ហេតុអ្វីបានជាអារម្មណ៍របស់ខ្ញុំនៅតែជិតជាប់ភាពសោកសៅនៃរបបខ្មែរក្រហមនិងមិនអាចបំភ្លេចបានដូច្នេះ? គឺមានតែការកាត់ទោសមេដឹកនាំខ្មែរក្រហមតាមផ្លូវច្បាប់អន្តរជាតិទេ ដែលអាចព្យាបាលរបួសផ្លូវចិត្តរបស់ខ្ញុំបាន ។ បើមិនដូច្នេះទេ អារម្មណ៍ខ្ញុំនៅតែវិលវល់ជាប់ជំពាក់នឹងភាពសោកសៅក្នុងរបបខ្មែរក្រហមនិងមិនអាចបំភ្លេចបានជារៀងរហូត ។

**ម៉េង រស្មី**

# តើ ពូ បងប្រុសខ្ញុំ និងជនរងគ្រោះ នឹងទទួលបានយុត្តិធម៌ត្រឹមកម្រិតណា?

នៅពេលខ្ញុំអានឯកសារស្វែងរកការពិត ធ្វើឲ្យខ្ញុំនឹកទៅដល់អតីតកាល ខ្ញុំនឹកទៅដល់ពូនិងបងខ្ញុំដែលស្លាប់កាលពីជំនាន់ ប៉ុល ពត ។ មិនតែប៉ុណ្ណោះ ជារឿយៗឪពុកខ្ញុំ ឬអ្នកភូមិតែងតែនិយាយ ពីអតីតកាលនៃជំនាន់ ប៉ុល ពត ។ រំឭកដល់រឿងនេះឪពុកខ្ញុំប្រាប់ខ្ញុំថា ពូខ្ញុំឈ្មោះ ប៉ាន់ វ៉ាត (ជាប្អូនរបស់ប៉ា ដែលសព្វថ្ងៃនៅរស់ប្រពន្ធនិងកូនពីរនាក់) គាត់រៀនពូកែណាស់ គាត់រៀនបានជាប់ចំណាត់ថ្នាក់សិស្សពូកែតាំងពីរៀនបឋមសិក្សារហូតមធ្យមសិក្សាដឺក្រហមឈូក) ។ ក្រោយពីប្រឡងជាប់សញ្ញាបត្រឌីប្លូម ពូខ្ញុំប្រឡងជាប់ជាគ្រូ និងរៀននៅសាលាគរុកោសល្យកំពង់កន្ទួត ។ ពេលបញ្ចប់ការសិក្សាគាត់ទៅបង្រៀននៅសាលាបឋមសិក្សាវត្តព្រៃនប់ក្រុងព្រះសីហនុ ។ ឯបងជីដូនមួយខ្ញុំឈ្មោះ តុង ផុន សព្វថ្ងៃមានប្រពន្ធនិងកូនស្រី៤នាក់) ក៏ជាសិស្សពូកែដែរ ។ អ្នកទាំងពីរចេញធ្វើគ្រូដំណាលគ្នានៅក្នុងអំឡុងឆ្នាំ១៩៦៨-១៩៦៩ និងបង្រៀននៅសាលាបឋមសិក្សាវត្តចក ដែលជាទឹកដីភូមិកំណើត ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ពូខ្ញុំបានវិលមករស់នៅស្រុកកំណើតវិញ នៅភូមិត្រពាំងប្រីយ៍ ឃុំស្រែសំរោង ស្រុកជុំគិរី ខេត្តកំពត ។ តាមពិតខ្ញុំបានឃើញមុខពូខ្ញុំជាលើកចុងក្រោយ នៅពេលដែលគាត់បររទេះឆ្លងកាត់ភូមិ និងមុខផ្ទះខ្ញុំដើម្បីទៅដឹកខ្សែ ។ ពូវ៉ាត បានចូលជួបឪពុកខ្ញុំមួយភ្លែត រួចក៏បររទេះឆ្ពោះទៅភ្នំខាងលិចភូមិ ។ ពេលគាត់ចេញផុតពីផ្ទះបានបន្តិចឪពុកខ្ញុំបានប្រាប់ខ្ញុំថា គាត់ជាពូរបស់ខ្ញុំ ប៉ុន្តែ ខ្ញុំពុំបានចាំមុខគាត់ច្បាស់ទេមុនគាត់ត្រូវបានយកទៅសម្លាប់ ។ ចំណែកកូនរបស់គាត់ទាំងពីរក៏មិនស្គាល់មុខគាត់ដែរ ឃើញតែរូបថតព្យួរនៅជញ្ជាំងផ្ទះប៉ុណ្ណោះ ។

បងជីដូនមួយខ្ញុំផ្សេងទៀតដែលស្គាល់ពូរបស់ខ្ញុំច្បាស់ គាត់បាននិយាយប្រាប់ខ្ញុំថា ពូខ្ញុំស្រឡាញ់និងចូលរួមចលនាខ្មែរក្រហមនិងជួយឃោសនាឲ្យខ្មែរក្រហមទៀត ប៉ុន្តែទីបំផុតខ្មែរក្រហមនៅតែយកគាត់ទៅសម្លាប់ដដែល ។ ពូបងជីដូនមួយខ្ញុំនិយាយរឿងនេះរឹតតែធ្វើឲ្យខ្ញុំឆ្ងល់កាន់តែខ្លាំងឡើង គិតមិនយល់សោះ ថាតើហេតុអ្វីអ្នកគាំទ្រជាមួយខ្មែរក្រហម ម្ដេចក៏ត្រូវខ្មែរក្រហមយកទៅសម្លាប់ចោល? តើខ្មែរក្រហមមានប៉ុន្មានប្រភេទ? ខ្មែរក្រហមឆ្កួត ឬខ្មែរក្រហមមានក្រុមផ្សេងចូលមកបន្លំខ្លួនក្នុងនោះ? នេះជាចម្ងល់ដែលនៅតែដក់ក្នុងអារម្មណ៍របស់ខ្ញុំជានិច្ច ។

អ្នកភូមិដែលរស់នៅជាមួយពូនិងបងខ្ញុំបាននិយាយថា រសៀលថ្ងៃមួយនារដូវប្រាំង ពេលពួកគាត់កំពុងច្រូតស្រូវ គាត់

បានឃើញឈ្លបខ្មែរក្រហមបណ្ដើរអ្នកទោស ដោយចងស្លាបសេកទាំងខ្សែមាន ៣ ពូ បងខ្ញុំ និងអ្នកផ្សេងប្រមាណ១០នាក់ទៀត ឆ្ពោះទៅកន្លែងសម្លាប់នៅវត្តស្រែក្នុងទឹកដីភូមិ ឃុំស្រែសំរោង ។ អ្នកភូមិនិយាយថា អ្នកទោសដែលបណ្ដើរយកទៅសម្លាប់នោះ ត្រូវឈ្លបជិះកង់ពីក្រោយស្រែកបញ្ជាឲ្យអ្នកទោសដើរពីក្រោយ ទាត់អ្នកដើរខាងមុខតៗគ្នា ចំពោះអ្នកទោសណាដើរយឺត ។ ពួកគាត់នឹកសង្វេគយ៉ាងខ្លាំង ។

នៅក្នុងអំឡុងឆ្នាំ១៩៨០ ពេលដែលខ្ញុំរៀននៅសាលាបឋមសិក្សាភូមិត្រពាំងប្រីយ៍ លោកគ្រូ អ្នកគ្រូបាននាំខ្ញុំនិងមិត្តរួមថ្នាក់ទៅលើកដីលុបរណ្ដៅសពជនរងគ្រោះនៅវត្តស្រែក្នុង ឲ្យបានស្អាតឡើងវិញ ដោយសាររណ្ដៅនោះលុបមិនបានល្អ មានធុំក្លិនអសោច ដៃជើងនិងលលាដ៍ក្បាលនៅរាយប៉ាយពាសវាលពាសកាល ។ នៅក្នុងរណ្ដៅនោះក៏មានសាកសពពូនិងបងខ្ញុំដែរ ។ ចំណែកបងជីដូនមួយខ្ញុំម្នាក់ទៀតឈ្មោះ តុង អេង ចេញពីសិស្សទៅធ្វើទាហាន លន់ នល់ នៅទូកមាស ស្រុកកំពង់ត្រាច ខេត្តកំពត ត្រូវកងទ័ពខ្មែរក្រហមចាប់បាននិងបណ្ដើរទៅសម្លាប់នៅគុកភ្នំម្លូ ឃុំស្រែចែង (អតីតស្រុកឈូក) និងបងម្នាក់ទៀតមិនដឹងយកទៅសម្លាប់នៅកន្លែងណា ។ អ្នកភូមិបានបញ្ជាក់ថា សហករណ៍នៅភូមិត្រពាំងប្រីយ៍ជាកន្លែងលត់ដំប្រជាជនខ្លាំងបំផុត បង្ខំឲ្យធ្វើការធ្ងន់ៗ ហូបបបររាវរាល់ថ្ងៃ និងជាពិសេសសម្លាប់ប្រជាជនអស់ជាច្រើន ។ មេភូមិត្រពាំ ប្រីយ៍ឈ្មោះ អុន សាហាវខ្លាំងណាស់ គាត់បានបបួលប្រជាជនកាច់ដៃជាមួយគាត់ដើម្បីសាកល្បងកម្លាំងគ្នា ពេលគាត់ប្រកួតចាញ់គេ គាត់យកអ្នកនោះទៅសម្លាប់ចោល ។

ចំពោះភូមិតាឥន្ទ (សព្វថ្ងៃជាភូមិត្រពាំងវែងខាងលិច) ដែលជាភូមិក្រុមគ្រួសារខ្ញុំរស់នៅ តាមខ្ញុំដឹងនិងចងចាំនោះ ការគ្រប់គ្រងសហករណ៍មិនមានភាពតឹងរ៉ឹងខ្លាំងក្លាដូចនៅភូមិត្រពាំងប្រីយ៍ទេ ពោលគឺប្រជាជនធ្វើការងារធម្មតាពុំមានការបង្ខិតបង្ខំឲ្យធ្វើការហួសហេតុពេកនោះទេ ។ គណៈភូមិអនុញ្ញាតឲ្យប្រជាជនសម្រាកពីការងារដូចជាពេលឈឺថ្កាត់ ឬមានធុរៈចាំបាច់ មិនថាប្រជាជនចាស់ថ្មីឡើយ ។ ម៉ោងធ្វើការសហករណ៍មានកំណត់ទៀងទាត់និងគោរពទៅតាមសំឡេងជួងជាសញ្ញា ។ ពេលព្រឹក ជាពេលមមាញឹកមិនថារដូវប្រាំងនិងវស្សាទេ ជួងវាយបន្លឺឡើងដាស់ប្រជាជនងើបទៅធ្វើការតាំងពីម៉ោងបួន ឬម៉ោងប្រាំភ្លឺ និងចេញពីធ្វើការប្រហែលម៉ោង១១:០០ ពេលល្ងាចចេញពីធ្វើការនៅម៉ោង៥:០០ឬអាចលើសម៉ោងបន្តិចបន្តួច ។ នៅរដូវមមាញឹក អង្គការដាក់ផែនការឲ្យប្រជាជនពេញកម្លាំងម្នាក់ៗធ្វើការតាមកំណត់ បើអ្នកណាធ្វើបានតាមផែនការអ្នកនោះនឹងមានរង្វាន់បានហូបបាយពិសេស ម្ហូបឆ្ងាញ់និងបង្អែមជាដើម ។ ក្នុងមួយឬពីរសប្ដាហ៍ ឬមួយខែម្ដង តែងតែមានកាប់ជ្រូកយកធ្វើម្ហូបអាហារមិនដែលខាន ។ ចំពោះអាហារប្រចាំថ្ងៃមានសម្លត្រី សាច់មាន់ ទា និងបន្លែជាដើម ។ ចំពោះបាយវិញសហករណ៍ខ្ញុំមិនដែលឲ្យប្រជាជនហូបបបរទេ ហូបបាយទាំងរដូវប្រាំងនិងវស្សា ប៉ុន្តែនៅរដូវវស្សាពេលខ្វះក៏មានហូបបាយលាយដំឡូងមីម្ដងម្កាលដែរ ។ មិនថាប្រជាជនចាស់ឬថ្មីទេ ខ្ញុំគិតថាអ្នករាល់គ្នាបានហូបបាយឆ្អែតសមរម្យ សូម្បីតែអ្នកដែលមកហូបបាយក្រោយគេក៏នៅតែមានបាយឲ្យហូបដែរ ។ ចំពោះខ្ញុំវិញខ្ញុំហូបបាយឆ្អែតគ្រប់ពេល ។ នៅរោងបាយមានការបែងចែកការហូបចុករវាងប្រជាជនចាស់និងថ្មី ប៉ុន្តែមិនដាច់ខាតទេ ប្រជាជនថ្មីក៏អាចហូបជាមួយប្រជាជនចាស់បានដែរ មានតែប្រជាជនចាស់មួយចំនួនតូចប្រកាន់អត្តចរិតមើលងាយប្រជាជនថ្មី ។ នៅពេលបាយខ្ញុំតែងឃើញប្រជាជនថ្មីស្លៀកពាក់ស្អាតបាតជារបៀបអ្នកទីក្រុងដើរមកហូបបាយ ។ ខ្ញុំគិតថាប្រជាជនថ្មីមករស់នៅភូមិខ្ញុំមានសំណាងជាងអ្នករស់នៅភូមិដទៃទៀត ដោយសារការរស់នៅក្នុងភូមិខ្ញុំពុំសូវមានការរើសអើងនិងសម្លាប់ច្រើន ឬអត់បាយដូចភូមិ-ឃុំដទៃទេ ។ ការរស់នៅភូមិខ្ញុំនាពេលនោះ ខ្ញុំតែងតែស្រមៃឃើញជានិច្ចថា បើពូនិងបងៗខ្ញុំបានមករស់នៅក្នុងភូមិខ្ញុំ ប្រហែលជាគាត់អាចមានជីវិតរស់នៅរហូតដល់សព្វថ្ងៃនេះជាមិនខាន ។ ប្រសិនណាបើគ្រួសារខ្ញុំទៅរស់នៅភូមិផ្សេងវិញ ម៉្លេះប្រហែលជាឪពុកខ្ញុំនឹងត្រូវឈ្លបសម្លាប់ចោលដែរហើយ ព្រោះប្រជាជនដែលរស់នៅផ្សារវត្តចកជាមួយគ្រួសារខ្ញុំកាលពីជំនាន់មុន ហើយដែលជម្លៀសទៅរស់នៅភូមិផ្សេងៗ ដូចជាភូមិត្រពាំងវែង ភូមិដំរីកូន និងភូមិដទៃទៀត នោះត្រូវបានសម្លាប់អស់ជាច្រើននាក់ ។ ខ្ញុំនៅតែឆ្ងល់ថា ហេតុ

ដូចម្តេចបានជាបញ្ញវន្តដែលបានរៀនសូត្រចេះដឹងជ្រៅជ្រះបែរជាចាញ់បោកនិងបម្រើពួកបដិវត្តន៍ (ដែលមានគណៈភូមិ កង-ឈ្លប ជាមនុស្សល្ងង់ខ្លៅ) និងបណ្តោយខ្លួនឲ្យអ្នកទាំងអស់នោះចាប់ខ្លួនយកទៅសម្លាប់ចោលទាំងខ្សែៗបានយ៉ាងងាយម៉្លេះ ។ ជាពិសេសទៅទៀត ហេតុអ្វីបានជាសហករណ៍នីមួយៗមានការគ្រប់គ្រងខុសៗគ្នាបើមេដឹកនាំតែមួយសោះ? នេះជារឿងនៃការចាញ់បោកពួកបដិវត្តន៍ដែលជាក្រុមកុម្មុយនិស្តបានប្រើប្រាស់យ៉ាងប៉ិនប្រសប់ បោកប្រាស់ដីពូកែ និងប្រើល្បិចគ្រប់រូបភាពដែលពួកវាអាចធ្វើបានមកលើជនស្លូតត្រង់ ។ នេះស្របតាមសំណេររបស់លោក វ៉ាន់ ឌីការុន,អតីតសាស្ត្រាចារ្យនៅខេត្តកំពតនិងជាអ្នកនិពន្ធសៀវភៅ បច្ចុប្បន្នជាអ្នកធ្វើការនៅវិទ្យុបារាំងអន្តរជាតិ....) សរសេរថា "ពាក្យពិតវាឥតសម្លស្ស" មែនឬ? ។ ឯពាក្យភូតកុហករបស់ ប៉ុល ពត ធ្វើឲ្យគេនាំគ្នាជឿយ៉ាងច្រើនកុះករ ។ ហេតុដូច្នេះ បានជា ប៉ុល ពត ធ្វើបដិវត្តន៍បានទទួលជ័យជម្នះទាំងស្រុង នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ ១៩៧៥?

ព្រឹត្តិការណ៍ទាំងឡាយនេះបានជំរុញទឹកចិត្តខ្ញុំនិងមិនអាចបំភ្លេចបានក្នុងមួយជីវិតរបស់ខ្ញុំ ហើយនៅតែគិតថាតើតុលាការចម្រុះជាតិសាសន៍ដែលមានសមាសភាពខ្មែរច្រើនជាងបរទេសនោះ អាចរកយុត្តិធម៌ជូនពូនិងបងខ្ញុំ ព្រមទាំងជនរងគ្រោះកម្ពុជាជាច្រើននាក់ទៀតបានត្រឹមកម្រិតណា? តាមទស្សនះរបស់ខ្ញុំៗយល់ថា យុត្តិធម៌មានត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ព្រោះតុលាការនឹងជំនុំជម្រះទោសកំហុសតែមេដឹកនាំសំខាន់ៗនៃរបបខ្មែរក្រហមប៉ុណ្ណោះ ។ ចំណែកអ្នកពាក់ព័ន្ធនិងអ្នកដទៃផ្សេងៗទៀតនៅមូលដ្ឋានផ្ទាល់មិនត្រូវបានយកកាត់ទោសឡើយ ។ ទោះបីយ៉ាងណា ខ្ញុំនៅតែមានជំនឿថា យុត្តិធម៌ត្រូវតែឈ្នះអយុត្តិធម៌ជានិច្ច ។

តាមអ្នកស្រុកដែលដឹងរឿងខ្មែរក្រហមបាននិយាយថា ភូមិត្រពាំងប្រីយ៍ស្រែក្នុង បានជាមានការសម្លាប់ប្រជាជនអស់ច្រើននិងបង្អត់បាយប្រជាជនខ្លាំងនោះគឺដោយសារតាចាបគណៈស្រុកឈូកដែលកាន់កាប់នៅកន្លែងនោះផ្ទាល់ ក្បត់នឹងអង្គការហើយក្រោយមក អង្គការលើដឹងរឿងចាប់គាត់យកទៅសម្លាប់ចោលតែម្តង ។

ខ្ញុំសោកស្តាយដែលខ្ញុំគ្មានឱកាសបានស្គាល់មុខពូនិងបងខ្ញុំជារៀងរហូត ពិសេសបញ្ញវន្តខ្មែរដែលមានគុណសម្បត្តិផ្តល់ឧត្តមប្រយោជន៍ជូនជាតិមាតុភូមិបានស្លាប់បាត់បង់អស់ជាច្រើននាក់ ។ ឆ្លងតាមព្រឹត្តិការណ៍ដែលខ្ញុំបានដឹងឮ ឃើញថាព្រឹត្តិ-ការណ៍ដែលបានកើតឡើងនៅក្នុងប្រទេសកម្ពុជាជាហូរហែមកនេះឃើញថាខ្មែរសម្លាប់គ្នាស្ទើរគ្រប់ជំនាន់ ។ ជាក់ស្តែងបងប្អូនខ្ញុំបានស្លាប់ជាបន្តបន្ទាប់គឺ ÷

- នៅក្នុងសម័យអាណានិគមបារាំង ខ្មែរឥស្សរៈបានសម្លាប់ជីតាខ្ញុំដោយចោទថាគិញរបស់បារាំង ។
- សម័យ លន់ នល់ បងប្អូនបានស្លាប់ដោយសារយន្តហោះទម្លាក់គ្រាប់បែក ។
- សម័យ ប៉ុល ពត បងប្អូនខ្ញុំត្រូវស្លាប់អស់ជាច្រើននាក់និងមកដល់សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា បងប្អូនខ្ញុំត្រូវស្លាប់ដោយធ្វើទាហាននិងឈ្លបនៅក៥ ។

ដូច្នេះ ក្នុងការស្លាប់ទាំងអស់នេះ ខ្ញុំសូមឲ្យអន្តរជាតិ ព្រមទាំងមេដឹកនាំខ្មែរទាំងអស់ ធ្វើយ៉ាងណាកុំឲ្យខ្មែរស្លាប់តទៅទៀតដើម្បីបញ្ចៀសប្រវត្តិសាស្ត្រចាស់ដែលកើតមានពីអតីតកាលនិងជួយរកយុត្តិធម៌ឲ្យអ្នករងគ្រោះដោយអំពើឧក្រិដ្ឋកម្មទាំងឡាយឲ្យបាន ហើយសាមគ្គីពួតដៃគ្នាកសាងប្រទេសជាតិឲ្យមានការអភិវឌ្ឍន៍ លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ។

នៅទីបញ្ចប់ ខ្ញុំសូមបួងសួងដល់លោកនាយក ព្រមទាំងសហការីនៃមជ្ឈមណ្ឌល ក៏ដូចជាប្រជាពលរដ្ឋខ្មែរទាំងអស់បានជួបប្រទះនូវពុទ្ធពរប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ បដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**គុង រ៉ា**

# ពាក្យស្លោកខ្មែរក្រហម

- **ស្លាប់ជាការធម្មតារបស់អ្នកតស៊ូ។**
- **ត្រូវមានស្មារតីរក្សាការសម្ងាត់ខ្ពស់។**

*(សៀវភៅកំណត់ហេតុលេខ១០៧/៧)*

# ដំណឹងសួររកឪពុក និងប្អូនស្រី

នាងខ្ញុំឈ្មោះ កាន់ បូរីនីន សព្វថ្ងៃរស់នៅសហរដ្ឋអាមេរិកជាមួយម្តាយឈ្មោះ ឈុន បូរីន និងបងប្អូនស្រី ៣នាក់ទៀតគឺ ៖

១) កាន់ បូរីយ៉ាន, ២) កាន់ ស្រីនួត, ៣) កាន់ ស្រីពៅ ។

សូមសួររកឪពុកឈ្មោះ កាន់ បូ និងប្អូនស្រីឈ្មោះ កាន់ បុប្ផាគន្ធា ហៅ ស្រីអូន ដែលទើប អាយុ៦-៧ឆ្នាំ បានបែកគ្នាតាំងពីឆ្នាំ១៩៧៩ នៅខេត្តបាត់ដំបង ។ ពីរខែមុនពេលវៀតណាមចូលទីក្រុងភ្នំពេញ អ្នកទាំងពីរត្រូវខ្មែរក្រហមជម្លៀសទៅភ្នំធិបដេ ខេត្តបាត់ដំបង ។ ក្រោយមកឮដំណឹងថា លោកឪពុកមានជំងឺបុសដូងបាត ដោយមានធ្លាក់ឈាមជាទម្ងន់មិនដឹងរស់ឬស្លាប់ ។ ចំណែកប្អូនស្រីដែលរស់នៅជាមួយឪពុកនោះមានការព្រួយបារម្ភជាខ្លាំង ហើយគិតតែអន្ទះយំ និងរត់រកឲ្យអ្នកជិតខាងជួយ ។

បើប្អូនស្រីឬបងប្អូនណាបានឮដំណឹងអំពីឈ្មោះទាំងពីរនេះ សូមជួយផ្តល់ដំណឹងឲ្យនាងខ្ញុំ សូមមេត្តាជួយផ្តល់ដំណឹងតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រអប់សំបុត្រលេខ ១១១០ ឬទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនប្រុសឈ្មោះ សេក ឌី



សេក ដល្លី

នាងខ្ញុំឈ្មោះ សេក ដល្លី ហៅ លី ស្រុកកំណើតនៅភូមិវាលល្វើត ឃុំកំពង់ចម្លង ស្រុកស្វាយជ្រុំ ខេត្តស្វាយរៀង សព្វថ្ងៃមករស់នៅភូមិគានូ ឃុំចំបក់ ។ ឪពុកឈ្មោះ សេក ទី (ស្លាប់) ម្តាយឈ្មោះ ចាន់ អែម (ស្លាប់) ។ នាងខ្ញុំមានបងប្អូនបង្កើតទាំងអស់៨នាក់ ប្រុស៤នាក់ ស្រី៤នាក់ ដូចមានរាយនាមខាងក្រោម ៖

១) សេក ដល្លី (ស្រី) ២) សេក ធី (ស្លាប់) ៣) សេក រី (ប្រុស) ៤) សេក វី (ប្រុសបាត់ខ្លួន) ៥) សេក អូន (ស្រី) ៦) សេក ពៅ (ស្រី) ៧) សេក នាង (ស្រី) និង ៨) សេក លាង (ប្រុស) ។ នាងខ្ញុំសូមប្រកាសសួររកប្អូនប្រុសទី៤ ។ ក្នុងឆ្នាំ១៩៧៧ ក្រុមគ្រួសារនាងខ្ញុំត្រូវបានជម្លៀសទៅខេត្តបាត់ដំបង ។ មកដល់ឆ្នាំ១៩៧៨ ប្អូនប្រុសបានបំបែកចេញពីគ្រួសារទៅនៅសហករណ៍ត្រពាំងក្រឡឹងខេត្តបាត់ដំបង ។

ប្រសិនបើប្អូននៅរស់ហើយឃើញសេចក្តីប្រកាសនេះសូមមករកបងតាមអាសយដ្ឋានខាងលើ ឬទំនាក់ទំនងមកមជ្ឈមណ្ឌលឯកសារកម្ពុជា អាសយដ្ឋានផ្ទះលេខ៦៦ ផ្លូវព្រះសីហនុ ភ្នំពេញ ទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ កុំខាន ។ សូមអរគុណ ។

# សេចក្តីប្រកាសរកប្អូនប្រុសឈ្មោះ ធុច សារឿន

ខ្ញុំបាទឈ្មោះ ធុច ថុន ជាបងប្រុស អាយុ៥៥ឆ្នាំ ស្រុកកំណើតនៅភូមិវាលតូច ឃុំអណ្តូងពោធិ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ សព្វថ្ងៃផ្លាស់មករស់នៅភូមិជីវិតភាព ។ ឪពុកឈ្មោះ ធុច ធឹម (ស្លាប់) និងម្តាយឈ្មោះ ធូ សួង ។ ខ្ញុំបាទមានបងប្អូនបីនាក់ឈ្មោះ ១) ធុច ម៉ាត់ (ប្រុស) ២) ធុច ខឿន (ស្រី) និងប្អូនប្រុសពៅឈ្មោះ ធុច សារឿន ហៅ សារ៉ែន ។ ខ្ញុំបាទសូមសួររកប្អូនប្រុសឈ្មោះ ធុច សារឿន ដែលបានចូលធ្វើយោធាចល័តតាំងពីឆ្នាំ១៩៧០ ។ នៅឆ្នាំ១៩៧២ សារឿន បានមកលេងផ្ទះម្តង ហើយក៏បាត់ដំណឹងនៅក្នុងឆ្នាំ១៩៧៣រហូតមក ។

ប្រសិនបើប្អូនឬញាតិមិត្តណាបានស្គាល់ដូចនៅក្នុងសេចក្តីប្រកាសនេះសូមទំនាក់ទំនងមកទូរស័ព្ទលេខ ០១២ ៧៨៨ ៥១២ សួររកឈ្មោះបង ឬក៏ទៅរកបងតាមអាសយដ្ឋានខាងលើ ឬតាមរយៈមជ្ឈមណ្ឌលឯកសារកម្ពុជាទូរស័ព្ទលេខ ០២៣ ២១១ ៨៧៥ ។ សូមអរគុណ ។

# ចូលរួមឃ្លាំមើលដំណើរការកាត់ទោស
# មេដឹកនាំខ្មែរក្រហម
## ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា


ជនរងគ្រោះក្រោមរបបកម្ពុជាប្រជាធិបតេយ្យមកធ្វើទស្សនកិច្ចនៅវាលពិឃាតបឹងជើងឯក


អគាររដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ


សាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ


ជនរងគ្រោះជួបសំណេះសំណាលជាមួយលោក រាជ សម្បត្តិ អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម


ជនរងគ្រោះក្នុងបន្ទប់សវនាការនៃអង្គជំនុំជម្រះវិសាមញ្ញ

- ការិយាល័យរដ្ឋបាលនៃអង្គជំនុំជម្រះវិសាមញ្ញ ចាប់ដំណើរការនៅថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៦។
- ដំណើរការទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជារៀបចំឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ជារៀងរាល់ថ្ងៃអង្គារ៍ក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ នៅក្នុងឆ្នាំ២០០៦។ មកទល់នឹងខែតុលានេះ មានប្រជាជន៥០០០នាក់រួចមកហើយដែលបានចូលរួម។
- អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាករកម្ពុជាមានទីតាំងនៅតាមផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ទំនាក់ទំនងជាមួយមន្ត្រីផ្នែកកិច្ចការសាធារណៈ ទូរស័ព្ទលេខ ០២៣ ២១៩ ៨១៤ ព័ត៌មានបន្ថែមសូមមើលគេហទំព័រ www.cambodia.gov.kh/krt ឬ www.eccc.gov.kh។
- មជ្ឈមណ្ឌលឯកសារកម្ពុជា ផ្ទះលេខ៦៦ វិថីព្រះសីហនុ (ខាងកើតវិមានឯករាជ្យ) ប្រអប់សំបុត្រ១១១០ ទំនាក់ទំនងជាមួយលោក វ៉ាន់ថាន់ ពៅដារ៉ា ទូរស័ព្ទលេខ ០១២ ៨៤៦ ៥២៦ ព័ត៌មានបន្ថែមសូមមើលគេហទំព័រ www.dccam.org។

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយរដ្ឋាភិបាល ដេនម៉ាក ន័រវ៉េ ស៊ុីតដេន និងសហរដ្ឋអាមេរិក
អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា ប្រកាសទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងព័ត៌មានលេខ ០២៩១ពម/៩៩ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

**មជ្ឈមណ្ឌលឯកសារកម្ពុជា : ការិយាល័យព័ត៌មានសាធារណៈ**
ផ្ទះលេខ ៦៦, មហាវិថីព្រះសីហនុ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥) ២៣ ២១១ ៨៧៥ ទូរសារ : (៨៥៥) ២៣ ២១០ ៣៥៨

DC-Cam/PIR : #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ Fax: (855) 23 210 358 ◆ dccam@online.com.kh ◆ www.dccam.org.
A magazine of the Documentation Center of Cambodia: Searching for the truth. ◆ Number 82, October 2006 ◆ Funded by Denmark, Norway, Sweden, and USA.
Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No.0291 P.M/99, 2 August 1999.